ISSN 1560 9812

# បញ្ហាប្រឈមចំពោះ ការចិញ្ចឹមជីវិតនៅជនបទ

## ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា

ឯកសារពិភាក្សាលេខ ២៥

ច័ន្ទ សុផល និង Sarthi Acharya

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឯកសារ
ពិភាក្សា
លេខ ២៥

# បញ្ហាប្រឈមចំពោះ
# ការចិញ្ចឹមជីវិតនៅជនបទ

## ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា

ឯកសារពិភាក្សាលេខ ២៥

ច័ន្ទ សុផល និង Sarthi Acharya

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ខែសីហា ឆ្នាំ២០០៣

© រក្សាសិទ្ធិឆ្នាំ២០០៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISSN 1560 9812

**បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទៈ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា**

**ឯកសារពិភាក្សាលេខ ២៥**

**ខែសីហា ឆ្នាំ២០០៣**

*ច័ន្ទ សុផល និង Sarthi Acharya*

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទៈ (៨៥៥-២៣) ៨៨១-៧០១/៨៨១-៩១៦/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារៈ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែលៈ cdri@camnet.com.kh website: http://www.cdri.org.kh

បកប្រែដោយៈ អែម សូវ៉ានី
កែសម្រួល និងរចនាដោយៈ យូ-សិទ្ធីរិទ្ធ អ៊ុំ-ចាន់ថា និងអេង-សាលត
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន ផ្ទះលេខ៧៤ ផ្លូវលេខ៩៩ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

# មាតិកា


សេចក្តីសង្ខេប ........ ១

សេចក្តីថ្លែងអំណរគុណ ........ ៧

**ជំពូកទី១. សេចក្តីផ្តើម** ........ ៩

១.១ ស្ថានភាពភូមិសាស្ត្រប្រទេសកម្ពុជា ........ ៩

១.២ បញ្ហាកើតមានចំពោះដីធ្លី ភាពក្រីក្រ និងសន្តិសុខស្បៀង ........ ១០

**ជំពូកទី២. ភូមិគំរូតាង** ........ ១៥

២.១ ការជ្រើសរើសភូមិគំរូតាង ........ ១៥

២.២ ទំហំគំរូតាង ........ ១៦

២.៣ ធនធានជាមូលដ្ឋាននៅក្នុងភូមិ ........ ១៧

២.៤ លក្ខណៈគ្រួសារ ........ ១៧

២.៥ សង្ខេប ........ ១៩

**ជំពូកទី៣. ដំណើរការទទួលបានដី និងភាពគ្មានដីធ្លី** ........ ២១

៣.១ ការទទួលបានដី ការលក់ដូរដី និងភាពគ្មានដីធ្លី ........ ២១

៣.២ ទំនាស់ដីធ្លី ........ ២៨

៣.៣ របាយការណ៍កាន់កាប់ដីកសិកម្ម ........ ២៩

៣.៤ ការជួលដីធ្លី ........ ៣១

៣.៥ ដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត ........ ៣២

៣.៦ ការកាន់កាប់ដី និងប្រាក់ចំណូល ........ ៣៣

៣.៧ សេចក្តីសង្ខេប ........ ៣៤

**ជំពូកទី៤. ចំណាយផលិតកម្មនិងផលិតភាពនៃការដាំដុះ** ........ ៣៧

៤.១ ទំហំកសិដ្ឋាន និងផលិតភាព ........ ៣៨

៤.២ ការប្រែប្រួលតាមតំបន់នៅក្នុងទិន្នផល និងលទ្ធភាពមានស្បៀង ........ ៤០

៤.៣ រចនាសម្ព័ន្ធចំណាយ ........ ៤១

៤.៤ ភាពមានចំណេញនៃដំណាំ ........ ៤៣

៤.៥ បន្ទរវាងផលិតភាព និងចំណូល ........ ៤៥

៤.៦ សេចក្តីសង្ខេប ........ ៤៧

**ជំពូកទី៥. ចំណូល និងតំរូវការឥណទាន**....................................................................................................៤៩
៥.១ គ្រួសារខ្ចីបុលគេ..............................................................................................................................................៥០
៥.២ ទំហំកំចី និងអត្រាការប្រាក់........................................................................................................................... ៥១
៥.៣ ចំណូល និងអត្រាការប្រាក់ ........................................................................................................................... ៥២
៥.៤ កំចី និងសមត្ថភាពសង ...............................................................................................................................៥៣
៥ សេចក្តីសង្ខេប......................................................................................................................................................៥៤
**ជំពូកទី៦. ចំរុះកម្មរបរចិញ្ចឹមជីវិតនៅជនបទ ធនធានទ្រព្យរួម និងចំណូលសរុប**...................................៥៥
៦.១ ចំណូលគ្រួសារតាមប្រភព..............................................................................................................................៥៥
៦.២ ការប្រែប្រួលប្រួលប្រភពចំណូលនៅក្នុងភូមិអង្កេតបី.................................................................................... ៥៧
៦.៣. ប្រភពចំណូល គិតតាមប្រភេទចំណូល............................................................................................................ ៦០
៦.៤ សារៈសំខាន់នៃធនធានទ្រព្យរួមចំពោះជីវភាពនៅជនបទ................................................................................... ៦១
៦.៥ និន្នាការនៃលទ្ធភាពមានធនធានទ្រព្យរួម .......................................................................................................៦៣
៦.៦ សេចក្តីសង្ខេប.................................................................................................................................................. ៦៦
**ជំពូកទី៧. ការបរិភោគ និងសន្តិសុខស្បៀង**...........................................................................................................៦៩
៧.១ ការបរិភោគអាហារសរុប................................................................................................................................... ៧០
៧.២ កន្ត្រកអាហារ ................................................................................................................................................... ៧៤
៧.៣ ការប្រើប្រាស់មិនមែនអាហារ.............................................................................................................................. ៧៥
៧.៤ ភាពយឺត Engel ..............................................................................................................................................៧៧
៧.៦ របាយប្រជាជនគិតតាមចំណាយប្រើប្រាស់ និងទំហំភាពក្រីក្រ.............................................................................. ៨០
៧.៧ សេចក្តីសង្ខេប.................................................................................................................................................. ៨៤
**ជំពូកទី៨. ទីផ្សារពលកម្ម** ...................................................................................................................................... ៨៥
៨.១ ការចូលរួមក្នុងកំលាំងពលកម្ម និងពលកម្មកុមារ.................................................................................................. ៨៥
៨.២ របរផ្តល់ដោយខ្លួនឯងក្នុងកសិកម្ម..................................................................................................................... ៨៦
៨.៣ ការងាររកប្រាក់កំរៃ ......................................................................................................................................... ៨៧
៨.៤ ចំណាកស្រុកលក់ពលកម្មទៅប្រទេសថៃ.............................................................................................................. ៨៨
៨.៥ សេចក្តីសង្ខេប....................................................................................................................................................៨៩
**ជំពូកទី៩. វិបត្តិ ដំណោះស្រាយ និងជំនួយពីក្រៅ**...................................................................................................... ៩១
៩.១ វត្តមានវិបត្តិ និង ការបាត់បង់ជាទឹកប្រាក់.......................................................................................................... ៩១
៩.២ ការឆ្លើយតបចំពោះវិបត្តិ.....................................................................................................................................៩៤
៩.៣ ជំនួយពីខាងក្រៅ សំរាប់សំរាលវិបត្តិ...................................................................................................................៩៥

៩.៤ សេចក្តីសង្ខេប ..... ៩៥

**ជំពូកទី១០. សេចក្តីសន្និដ្ឋាន** ..... ៩៧

១០.១ គំហើញទូទៅ ..... ៩៧

១០.២ ការស្វែងយល់ពីសេដ្ឋកិច្ចជនបទកម្ពុជា ..... ១០០

១០.៣ ជំរើសគោលនយោបាយ ..... ១០១

ឧបសម្ព័ន្ធទី១. ទិន្នន័យគំរូតាង ..... ១០៥

ឧបសម្ព័ន្ធទី២. ទិន្នន័យពីភាពគ្មានដីធ្លី និងការចាប់យកដី ..... ១១១

ឧបសម្ព័ន្ធទី៣. ទិន្នន័យចំណាយផលិតកម្ម និងផលិតភាពកសិដ្ឋាន ..... ១១៥

ឧបសម្ព័ន្ធទី៤. ទិន្នន័យតំរូវការឥណទាន និងបំណុល ..... ១២១

ឧបសម្ព័ន្ធទី៥. ទិន្នន័យចំណូលសរុប ធនធានរួម និងចំរុះកម្មរបរចិញ្ចឹមជីវិត ..... ១២៣

ឧបសម្ព័ន្ធទី៦. ទិន្នន័យសន្តិសុខស្បៀង និងការប្រើប្រាស់ ..... ១២៧

ឧបសម្ព័ន្ធទី៧. ទិន្នន័យកំលាំងពលកម្ម ..... ១២៩

ឧបសម្ព័ន្ធទី៨. ទិន្នន័យជំនួយពីខាងក្រៅ និងដំណោះស្រាយ ..... ១៣១

**បញ្ជីឯកសារពិភាក្សារបស់ វបសអ** ..... ១៣១

# បញ្ជីតារាង និងក្រាហ្វិក

## បញ្ជីតារាង


តារាង២.១ ពិពណ៌នាភូមិគំរូតាង.......... ១៦
តារាង២.២ ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន.......... ១៧
តារាង៣.១. ភាគរយរបាយដីកសិកម្ម ធៀបនឹងដីកសិកម្មសរុប..........២៣
តារាង៣.២ ការលក់ដីចាប់ពីឆ្នាំ១៩៨៩.......... ២៤
តារាង៣.៣ មូលហេតុចំបង១នៃការលក់ដី (គិតជាភាគរយនៃរបាយគ្រួសារដែលបានលក់ដី).......... ២៥
តារាង៣.៤ ភាពគ្មានដីធ្លី និងអថេរជាប់ទាក់ទង.......... ២៦
តារាង៣.៥ មូលហេតុចំពោះការបាត់បង់ដីកសិកម្ម (គិតជាភាគរយនៃរបាយគ្រួសារ) .......... ២៧
តារាង៣.៦ វិត្តមានទំនាស់ដីធ្លី និងប្រភេទដីមានទំនាស់..........២៩
តារាង៣.៧ ការកាន់កាប់ដីកសិកម្ម (គិតតាម % នៃការបែងចែកតាមគ្រួសារ) .......... ៣០
តារាង៣.៨ ការជួលដីធ្លី និងទំហំដីជួលមធ្យម (គិតតាមគ្រួសារ)..........៣២
តារាង៣.៩ ចំណូលគ្រួសារប្រចាំឆ្នាំ រួមទាំងផលិតកម្មកសិកម្ម (លានរៀល) .......... ៣៤
តារាង៤.១ ដំណាំស្រូវវស្សានៅឆ្នាំ២០០១ តាមទំហំដី (គ្រប់ភូមិ) .......... ៣៩
តារាង៤.២ ដំណាំស្រូវប្រាំង (មិនស្រោចស្រព) នៅឆ្នាំ២០០១ គិតតាមទំហំកសិដ្ឋាន (គ្រប់ភូមិ).......... ៣៩
តារាង៤.៣ក បន្ទុកចំណាយនៃផលិតកម្មស្រូវវស្សា ក្នុងឆ្នាំ២០០០-២០០១ (ហ.ត).......... ៤២
តារាង៤.៣ខ បន្ទុកចំណាយនៃផលិតកម្មស្រូវប្រាំង ក្នុងឆ្នាំ២០០១.......... ៤៣
តារាង៤.៤ ភាពមានចំណេញលើស្រូវវស្សា តាមទំហំដី (គ្រប់ភូមិ) ..........៤៤
តារាង៤.៥ ភាពមានចំណេញនៃផលិតកម្មស្រូវប្រាំង តាមទំហំដី (គ្រប់ភូមិ) ..........៤៥
តារាង៥.១ ភាគរយនៃគ្រួសារមានជំពាក់ឥណទានមិនទាន់សង..........៥០
តារាង៥.២ អត្រាការប្រាក់ និង ទឹកប្រាក់កំចីនៅរដូវប្រាំង និងវស្សា.......... ៥២
តារាង៥.៣ក កំចីគិតជាភាគរយនៃចំណូល (តាមចំណាត់ថ្នាក់ចំណូល) .......... ៥៣
តារាង៥.៣ខ កំចីគិតជាភាគរយនៃចំណូល (តាមភូមិ) .......... ៥៣
តារាង៦.១ ភាគរយនៃចំណូលពីធនធានរួម.......... ៦២
តារាង៦.២ លទ្ធភាពរកបានត្រីនិងធនធានផ្សេងទៀតពីស្រែ និងផ្ទៃទឹកនានា, ធៀបនឹងមួយឆ្នាំមុន.......... ៦៣
តារាង៦.៣ មូលហេតុចំបង១នៃការថយចុះត្រី និងជលផលចំបង១ផ្សេងទៀត..........៦៤
តារាង៦.៤ ការឆ្លើយតបនឹងនិន្នាការនៃលទ្ធភាពរកធានធានព្រៃឈើ និងធនធានជាប់ទាក់ទិននឹងព្រៃឈើ..........៦៤

តារាង៦.៥ ការឆ្លើយតបនិងមូលហេតុចំបង៧នៃការថយចុះធនធានព្រៃឈើ (ភាគរយរបាយគ្រួសារ) ........... ៦៥
តារាង៧.១ ការហូបស្បៀង និងចំណាយសរុប សំរាប់ឆ្នាំ២០០១ និង១៩៩៦-៩៧ (ក្នុងមនុស្សម្នាក់ក្នុង១ឆ្នាំ)... ៧១
តារាង៧.២ ការហូបអង្ករ និងហូបស្បៀងសរុប គិតក្នុងមនុស្សពេញវ័យម្នាក់ និងគិតតាមរដូវកាល.................. ៧២
តារាង៧.៣ ការបរិភោគអង្ករ/ម្នាក់/ថ្ងៃ: តួលេខកែតំរូវតាមឯកតាមនុស្សពេញវ័យ និងតួលេខគ្មានកែតំរូវ...... ៧៤
តារាង៧.៤ អាហារ និងការបរិភោគក្នុងមួយឯកតាមនុស្សពេញវ័យម្នាក់ ........................................... ៧៥
តារាង៧.៥ ចំណែកជាភាគរយនៃមុខចំណាយប្រើប្រាស់មិនមែនអាហារ នៅឆ្នាំ២០០១ និង ១៩៩៦-៩៧......... ៧៦
តារាង៧.៦ ភាពយឺត Engel សំរាប់អង្ករ អាហារមិនមែនអង្កររបស់មិនមែនអាហារ និងសុខភាព.................... ៧៨
តារាង៧.៧ បន្ទាត់ក្រីក្រ និងអត្រាអ្នករស់នៅក្រោមបន្ទាត់ក្រីក្រ (តាមភូមិ) ................................ ៧៩
តារាង៧.៨ ចំណាត់ថ្នាក់ចំណាយប្រើប្រាស់ (គិតជាភាគរយនៃរបាយប្រជាជន) ..................................... ៨២
តារាង៧.៩ ការវាស់វែងគំលាតភាពក្រីក្រ និងអាំងតង់ស៊ីតេភាពក្រីក្រ ឆ្នាំ២០០១ និង ១៩៩៦-៩៧................៨៣
តារាង៨.១ ប្រជាជនសកម្ម និងមិនសកម្មក្នុងសេដ្ឋកិច្ច តាមអាយុ និងភេទ.......................................... ៨៦
តារាង៨.២ ចំនួនម៉ោង និងខែ ធ្វើការងារកសិកម្មផ្ទាល់ខ្លួនក្នុងក្រុមអាយុ១៥-៥៤ឆ្នាំ........................................ ៨៦
តារាង៨.៣ ចំណូល/ប្រាក់កំរៃ បែងចែកតាមកំរិតអប់រំ ប្រភេទការងារ និងយ៉ែនឌ័រ (ពាន់រៀល/ថ្ងៃ) ............ ៨៨
តារាង៨.៤ ចំនួនជនចំណាកស្រុកទៅថៃ និងអត្រាប្រាក់កំរៃ.......................................................................៨៩
តារាង៩.១ វត្តមាន និងទំហំវិបត្តិនៅឆ្នាំ២០០០-០១................................................................................ ៩២
តារាង៩.២ វត្តមាន និងការខាតបង់ដោយវិបត្តិ នៅក្នុងមួយឆ្នាំ (បែងចែកតាមបញ្ចភាគចំណូល)................... ៩៣
តារាង៩.៣ ការដោះស្រាយចំពោះវិបត្តិ តាមបញ្ចភាគចំណូល (របាយតាមគ្រួសារ) .......................................៩៤
តារាង៩.៤ វត្តមាននៃជំនួយពីខាងក្រៅ......................................................................................................៩៥

## បញ្ជីក្រាហ្វិក

ក្រាហ្វិក៦.១ ចំណូលគ្រួសារតាមប្រភព (ពាន់រៀល/ឆ្នាំ)................................................................. ៥៦
ក្រាហ្វិក៦.២ក ការប្រែប្រួលចំណូលគ្រួសារគិតតាមប្រភពចំណូលនៅភូមិបាបោង (ពាន់រៀល/ឆ្នាំ)...................... ៥៨
ក្រាហ្វិក៦.២ខ ការប្រែប្រួលចំណូលគ្រួសារ គិតតាមប្រភពចំណូលនៅភូមិព្រែកក្មេង (ពាន់រៀល/ឆ្នាំ) ............ ៥៨
ក្រាហ្វិក៦.២គ ការប្រែប្រួលចំណូលគ្រួសារ គិតតាមប្រភពចំណូលនៅភូមិត្រពាំងប្រិយ (ពាន់រៀល/ឆ្នាំ) ........ ៥៨
ក្រាហ្វិក៦.៣ ប្រភពចំណូលគ្រួសារ តាមបញ្ចភាគនៃក្រុមចំណូល (ពាន់រៀល/ឆ្នាំ) ...................................... ៦០
ក្រាហ្វិក៧.១ក ការបរិភោគអង្ករគិតតាមទសភាគ និងតាមខែ (គ.ក/ថ្ងៃ/មនុស្សពេញវ័យ) ......................... ៧៣
ក្រាហ្វិក៧.១ខ ការបរិភោគអាហារសរុប គិតតាមទសភាគ និងតាមរដូវ (រៀល/ថ្ងៃ/មនុស្សពេញវ័យ)......... ៧៣
ក្រាហ្វិក៧.២ក ការប្រែប្រួលលើការប្រើប្រាស់មិនមែនអាហារគិតតាមភូមិ................................................៧៧
ក្រាហ្វិក៧.២ខ ការប្រែប្រួលលើការប្រើប្រាស់មិនមែនអាហារ ....................................................................៧៧
ក្រាហ្វិក៧.៣ ខ្សែកោង Lorenz នៃចំណាយប្រើប្រាស់សរុប និង ចំណាយអាហារ............................................ ៨១

# សេចក្តីសង្ខេប

ចាប់តាំងពីការកកើតកម្មវិធីស្រាវជ្រាវនៅវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) វបសអ បានប្រឹងប្រែងច្រើនណាស់ដើម្បីសិក្សាពីស្ថានភាព និងពីគោលនយោបាយស្តីពីការរកចិញ្ចឹមជីវិតនៅជនបទ បញ្ហាដីធ្លី ភាពក្រីក្រ និងប្រភពធនធានធម្មជាតិ ។ នៅឆ្នាំ២០០១ វបសអ បានចុះធ្វើអង្កេតលើ ៩ភូមិនៅកម្ពុជា ដើម្បីសិក្សាពីស្ថានភាពបច្ចុប្បន្ននៃជីវភាពជនបទ ។ ផ្អែកលើការសិក្សានេះវិទ្យាស្ថានបានបោះពុម្ពផ្សាយឯកសារពិភាក្សាពីរច្បាប់ គឺឯកសារពិភាក្សាលេខ២៤ និងឯកសារពិភាក្សាលេខ២៥ នេះ ។ ទោះជាបោះពុម្ពដាច់ចេញពីគ្នាក្តី ប៉ុន្តែឯកសារទាំងពីរមានពត៌មានបំពេញឱ្យគ្នាទៅវិញទៅមកនៅក្នុងបរិបទ និងលើកម្មវត្ថុតែមួយ ។ លើសពីនេះ ការស្រាវជ្រាវជារួមសំរាប់ឯកសារទាំងពីរនេះ គឺជាការពង្រីកនៃអង្កេតពីមុនរបស់ វបសអ នៅឆ្នាំ១៩៩៦-៩៧[១] ពីព្រោះមាន ៣ភូមិ ក្នុងចំនោមភូមិទាំង៩ ត្រូវបានសិក្សាកាលពីប្រាំឆ្នាំមុន ។

ឯកសារពិភាក្សាលេខ២៤ ដែលមានចំណងជើងថា *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* បកស្រាយពីដំណើរការសេដ្ឋកិច្ច-សង្គមកិច្ចក្នុង ៦ភូមិ ក្នុងចំណោមភូមិទាំង ៩ ដោយប្រើប្រាស់វិធីសាស្ត្របែបគុណភាព (Sedara, Chan, and Acharya 2002) ។ ឯកសារពិភាក្សាលេខ២៥ នេះ បំពេញបន្ថែមទៅលើការសិក្សាខាងដើម ដោយបកស្រាយពីលទ្ធផលអង្កេតជាមួយ ១.០០៥គ្រួសារនៅក្នុងខេត្តកណ្តាល កំពង់ស្ពឺ ព្រៃវែង កំពត កំពង់ធំ បាត់ដំបង និងក្រចេះ ។ ខេត្តទាំងនេះស្ថិតនៅក្នុងតំបន់ធាតុអាកាស-កសិកម្មខុសៗគ្នានៃប្រទេសកម្ពុជា គឺមានតំបន់ឆ្នេរ តំបន់ទន្លេសាប តំបន់ទំនាបទន្លេមេគង្គ និងតំបន់ខ្ពង់រាប ។ ដើម្បីក្តាប់ឱ្យបានពីលក្ខណៈរដូវកាលនៃប្រាក់ចំណូល និងការប្រើប្រាស់ស្បៀងអាហារ អង្កេតនេះបានធ្វើឡើងជាពីរដង គឺនៅរដូវវស្សាម្តង និងរដូវប្រាំងម្តង ។

កម្មវត្ថុសំខាន់នៃឯកសារពិភាក្សាលេខ២៥ នេះ គឺការវិភាគពីស្ថានភាពបច្ចុប្បន្ន ការវាស់វែងពីលក្ខណៈរដូវកាលនៃសន្តិសុខស្បៀង និងការប្រៀបធៀបពីស្ថានភាពសន្តិសុខស្បៀងនៅក្នុងតំបន់អេកូឡូស៊ីទាំងបួន ជាមួយនឹងអង្កេតធ្វើដោយ វបសអ នៅឆ្នាំ១៩៩៦-៩៧ ។ សំណួរសំខាន់ៗប្រើប្រាស់នៅក្នុងការស្រាវជ្រាវ និងគំហើញចំបងៗ មានសង្ខេបដូចខាងក្រោម:

១) តើចរិតនៃការបែងចែកការកាន់កាប់ដីនៅក្នុងតំបន់ផ្សេងៗមានលក្ខណៈយ៉ាងណា និងតើវិសមភាពនៃការបែងចែកដីធ្លី និងភាពគ្មានដីធ្លី[២] មានទំហំប៉ុនណា? តើមានហេតុផលអ្វីខ្លះដែលធ្វើឱ្យកសិករលក់ដី និងបាត់បង់ដី ហើយទីផ្សារដីធ្លីកើតឡើងដោយរបៀបណា?

២) តើមានចំណងទាក់ទងយ៉ាងដូចម្តេចខ្លះរវាងទំហំផ្ទៃដីដាំដុះ ផលិតភាព និងប្រាក់ចំណូលរកបានពីផ្ទៃដីដាំដុះដែលមានទំហំខុសគ្នា និងស្ថិតនៅតំបន់ផ្សេងគ្នា និងតើទំហំដីដាំដុះជះឥទ្ធិពលដល់សន្តិសុខស្បៀងយ៉ាងដូចម្តេច?

[១] ឯកសារពិភាក្សាលេខ ៦ ស្តីពីសន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរកាលអាស៊ី: បទពិសោធន៍កម្ពុជា (Murshid, 1998) ។

[២] ក្នុងអត្ថបទនេះ ពាក្យ *ភាពគ្មានដី* សំដៅដល់ *ភាពគ្មានដីធ្វើកសិកម្ម* នៅក្នុងតំបន់ជនបទ ។

៣) តើទីផ្សារឥណទានមានចរិតយ៉ាងដូចម្តេច? តើមានតំរូវការឥណទានញឹកញាប់ប៉ុណ្ណា តើក្រុមកសិករប្រភេទណាត្រូវការឥណទាន និងចំណាយការប្រាក់ប៉ុន្មាន? តើឥណទានស្ថាប័នមានប្រយោជន៍ដែរទេ មានប្រយោជន៍ប៉ុណ្ណា?

៤) តើតាមដំណើរការបែបណាដែលប្រជាជននៅជនបទទទួលបានស្បៀង និងផលិតផលផ្សេងទៀតពីដី ពីធនធានរួម នឹងពីប្រភពចំណូលក្រៅកសិកម្ម? តើផលប៉ះពាល់នៃការបង្កើនឯកជននីយកម្មនៃធនធានទ្រព្យរួមលើបរិមាណ និងគុណភាពនៃផលិតផលទទួលបានពីនេសាទ និងព្រៃឈើ?

៥) តើប្រជាជនត្រូវប្រឈមនឹងកង្វះស្បៀងរ៉ាំរ៉ៃដែរឬទេ? តើនៅជនបទភាពក្រីក្រមានវិសមភាព និងទំងន់ប៉ុណ្ណា?

៦) តើទីផ្សារពលកម្មមានចរិតយ៉ាងដូចម្តេច? តើប្រាក់ឈ្នួលបច្ចុប្បន្នមានកំរិតប៉ុណ្ណា? តើមានប្រជាជនប៉ុណ្ណាដែលទទួលបានការងារមានប្រាក់កំរៃនៅក្នុងស្រុក និងតាមរយៈការធ្វើចំណាកស្រុក?

៧) តើគ្រួសារប្រជាជនប្រភេទខុសៗគ្នាអនុវត្តយុទ្ធសាស្ត្រសំរបសំរួលអ្វីខ្លះដើម្បីទប់ទល់នឹងវិបត្តិ?

## ១. វិសមភាពដីធ្លី និងភាពគ្មានដីធ្លី

បន្ទាប់ពីការបែងចែកដីធ្លីនៅពាក់កណ្តាលទសវត្សរ៍១៩៨០ និងការបង្កើតកម្មសិទ្ធិដីធ្លីជាឯកជនក្នុងឆ្នាំ១៩៨៩ ឡើងវិញ ទីផ្សារដីធ្លីបានចាប់ផ្តើមមានចលនានៅក្នុងភូមិទាំង ៩ ដែលបានសិក្សា ។ នៅឆ្នាំ២០០១ មានតែ ៤៤% នៃអ្នកកាន់កាប់ដីធ្លីប៉ុណ្ណោះដែលបានរាយការណ៍ថា ដីធ្លីពួកគាត់កាន់កាប់សព្វថ្ងៃ គឺជាដីរដ្ឋប្រគល់ឱ្យ ។ ឯ ២៤% ទៀតបានរាយការណ៍ថា ជាដីបន្តមតិក ១៧% បានទិញដី និង ១៦% រាយការណ៍ថា ទទួលបានដីដោយការរានដីព្រៃ ។ នៅតាមភូមិដែលមានដីព្រៃអាចប្រើប្រាស់បាន (រួមទាំងព្រៃលិចទឹកផងដែរ) ការកាប់ព្រៃរានយកដីកំពុងបន្តទៅមុខ ។

កត្តាចំបងនៃកំណើនភាពគ្មានដីធ្លី (ប៉ុន្តែមិនមែនជាហេតុផលតែមួយនោះទេ) គឺកំណើនប្រជាជន ក្នុងនេះ ៣០% នៃគ្រួសារកសាងថ្មី មិនដែលមានដីតាំងពីដំបូង ។ ហេតុផលផ្សេងទៀត គឺការពុំមានលទ្ធភាពរក្សាទុកដីធ្លី ព្រោះខ្វះធនធានផ្សេងៗ និងការទាញយកចំណូលមិនបានគ្រប់គ្រាន់ពីដីធ្លី ។ ក្នុងករណីខ្លះដែលដីមានគុណភាពល្អ ឬមានទីតាំងជាយុទ្ធសាស្ត្រ គេឃើញមានការទិញដីសំរាប់លក់យកចំណេញ ។ ១២% នៃគ្រួសារក្នុងគំរូតាងបានរាយការណ៍ថា បានលក់ដីខ្លះ ឬលក់ដីអស់រលីងតាំងពីឆ្នាំ១៩៨៩ ។ មូលហេតុចំបងដែលពួកគេលក់ដី គឺមកពីពុំអាចរកចំណូលបានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់តំរូវការចំណាយក្នុងគ្រួសារ ហើយចំណាយដែលបន្ទាន់ជាងគេបំផុត គឺចំណាយពាក់ព័ន្ធនឹងជំងឺ ។ គ្រួសារខ្លះបានលក់ដី ពីព្រោះវារួមតូចពេកលែងមានផលចំណេញខាងសេដ្ឋកិច្ច បន្ទាប់ពីមានការពុះចែកដីជាច្រើនចំណែកមក ។ អ្នកគ្មានដីធ្វើកសិកម្ម គឺមាន ២០% ជាមធ្យមនៅក្នុងភូមិទាំង ៩ ហើយ ២៥% ទៀតជាអ្នកមានដីតិចជាង ០,៥ហិកតារ ។ ប្រការនេះបញ្ជាក់ថា អ្នកគ្មានដី និងអ្នកស្ទើរគ្មានធ្វើកសិកម្មសរុបមាន ៤៥% នៃគ្រួសារនៅជនបទ (ប៉ុន្តែអ្នកនៅជនបទទាំងអស់មិនមែនសុទ្ធតែជាកសិករទេ) ។ គេប៉ាន់ស្មានថា ភាពគ្មានដីកំពុងកើនឡើងក្នុងអត្រា ២% ក្នុងមួយឆ្នាំ ។

គ្រួសារអ្នកមានដីកាន់កាប់ គឺមានដីកសិកម្មជាមធ្យម ១,៥ហ.ត ។ ប៉ុន្តែទំហំដីជាមធ្យមនេះគ្មានន័យអ្វីច្រើនទេ ពីព្រោះការបែងចែកដីមានវិសមភាពខ្លាំងណាស់ ។ គ្រួសារប្រជាជន ២០% គ្មានដី, ២៥% មានដី ០,៥ហ.ត ឬតិចជាង ហើយ ១០% នៃគ្រួសារដែលមានដីច្រើនជាងគេបានកាន់កាប់ ៤០% នៃដីនៅក្នុងភូមិ ។

តើភាពគ្មានដីធ្លីវាចោទបញ្ហាឬទេ ចំពោះជីវភាពប្រជាជននៅជនបទកម្ពុជា? ចម្លើយគឺពិតជាចោទបញ្ហា ពីព្រោះនៅជនបទមានកំណើនតិចតួចពេកនូវការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម ។ គ្រួសារអ្នកគ្មានដី គឺមានទ្រព្យតិចតួច

និងមានចំណូលទាបជាងគ្រួសារអ្នកមានដីកាន់កាប់ ។ ចំណុចសំខាន់មួយទៀតដែលគួរកត់សំគាល់គឺ អ្នកស្ទើរគ្មានដី គ្រាន់តែមានជីវភាពធូរធារជាងអ្នកគ្មានដីតែបន្តិចបន្តួចប៉ុណ្ណោះ ហើយប្រការនេះក៏ជាការព្រួយបារម្ភមួយយ៉ាងធ្ងន់ធ្ងរដែរ ។

## ២. សេដ្ឋកិច្ចនៃការធ្វើកសិកម្ម

ជាទូទៅ (ប៉ុន្តែមិនយ៉ាងដូច្នេះរាល់លើកនោះទេ) ផ្ទៃដីដាំដុះកាន់តែតូច គឺមានផលិតភាពកាន់តែខ្ពស់ បើគិតពីអត្រាទិន្នផល ។ ប្រការនេះវាជាក់ស្តែងណាស់ចំពោះការធ្វើស្រែវស្សាដែលមានការប្រើប្រាស់ធាតុចូលតិចតួច ដោយសារស្រូវវស្សាពឹងផ្អែកសឹងតែសុទ្ធសាធទៅលើទឹកភ្លៀងរដូវវស្សា និងកំលាំងពលកម្មតែប៉ុណ្ណោះ ។ ចំពោះស្រូវរដូវប្រាំងត្រូវការធាតុចូលច្រើនជាង ទំនាក់ទំនងរវាងផ្ទៃដីតូច និងផលិតភាពខ្ពស់ពុំមានលក្ខណៈពិតជាក់ស្តែងទៀតទេ ។

នៅរដូវវស្សាផ្ទៃដីដាំដុះតូចបានផ្តល់ឱ្យកសិករនូវចំណូលច្រើន *បើគិតក្នុងដី ១ហ.ត* ប៉ុន្តែមិនផ្តល់ចំណូលច្រើនឱ្យ*គ្រួសារនីមួយៗ* នោះទេ ។ ចំពោះការធ្វើស្រែប្រាំង ផ្ទៃដីដាំដុះតូចមិនបានផ្តល់ចំណូលច្រើនទេ ទោះបី *គិតក្នុងដី ១ហ.ត* ឬ *គិតជាចំណូលដល់គ្រួសារនីមួយៗ* ក្តី ។ ដូច្នេះហើយ ផលិតភាពដី និងកំរិតចំណេញក្នុងដី ១ហ.ត វាដើរស្របគ្នា ប៉ុន្តែភាពយឺតនៃចំណូលគ្រួសារធៀបនឹងអត្រាទិន្នផលដី វាមានទំហំតូចជាង ១ ។ ក្នុងនេះការពុះចែកដី គឺជាមូលហេតុ ពីព្រោះដីគុណភាពល្អតែងត្រូវបានគេពុះចែកវាលឿនជាង ។

រចនាសម្ព័ន្ធនៃចំណាយទូទៅបានបង្ហាញថា ធាតុចូលប្រើក្នុងការដាំដុះមានកំរិតទាប ។ នៅលើផ្ទៃដីដែលកសិករប្រើជី និងធាតុចូលផ្សេងទៀត ពួកគេតែងបានទទួលទិន្នផលខ្ពស់ជាង ។ ប្រការនេះបង្ហាញពីសក្តានុពលសំរាប់ការពង្រីកផលិតកម្មតាមរយៈការបង្កើនធាតុចូល ។

## ៣. លទ្ធភាពប្រើប្រាស់ឥណទាន

ការខ្ចីប្រាក់គេ គឺជារឿងធម្មតាមួយនៅក្នុងជីវិតរបស់កសិករ[៣] គឺបានន័យថា ពួកគេខ្ចីប្រាក់ដើម្បីបំរើគោលដៅផលិតកម្មក៏ដូចជាសំរាប់ចំណាយប្រើប្រាស់ ដោយពុំមានធ្វើការបែងចែកវាឱ្យដាច់ពីគ្នាទេ ។ ដោយហេតុនេះហើយ កំចីភាគច្រើនបានពីប្រភពមិនមែនស្ថាប័ន ជាពិសេសអ្នករកស៊ីចងការប្រាក់ និងញាតិមិត្ត ។ ម្ចាស់បំណុលតែងគិតថា ហានិភ័យមានកំរិតខ្ពស់ ឯការផ្គត់ផ្គង់ឥណទានក៏មិនសូវសំបូរផង ដូច្នេះហើយការប្រាក់មានអត្រាខ្ពស់ ។

វាហាក់ដូចជាមានបន្សំបញ្រ្ចាស (inverse association) រវាងទំហំដីកាន់កាប់ដោយអ្នកខ្ចីប្រាក់ និងអត្រាការប្រាក់ដែលពួកគេបង់ ។ ប្រការនេះអាចជាបន្សំយ៉ាងខ្សោយមួយ ប៉ុន្តែវាបង្ហាញថា ការមានដីកាន់កាប់ទំហំធំ គឺជាការធានារ៉ាប់រងមួយទប់ទល់នឹងករណីមិនសងប្រាក់ ។ ប្រាក់ជំពាក់មិនទាន់សងគិតក្នុងមនុស្សម្នាក់មានសមាមាត្រខ្ពស់ជាង ក្នុងចំណោមអ្នកក្រ បើធៀបនឹងក្រុមអ្នកមិនមែនក្រ ប៉ុន្តែទឹកប្រាក់ខ្ចីដោយអ្នកក្រ វាមានចំនួនតិចជាងទឹកប្រាក់ខ្ចីដោយក្រុមអ្នកមិនមែនក្រខ្លាំងណាស់ ។ ជារួម ភាគច្រើននៃកសិករ និងអ្នកភូមិ មានជំពាក់បំណុលគេ ។

## ៤. ចំណូលគ្រួសារសរុប

ចំណូលគ្រួសារជាមធ្យមនៅក្នុងភូមិទាំងឡាយ មានកំរិតទាបជាងចំណូលមធ្យមគិតក្នុងកំរិតជាតិយ៉ាងច្រើន ។ ទោះបីនៅក្នុងភូមិដែលបានរីកចំរើនច្រើនហើយក្តី ក៏គ្រួសារមួយ រកចំណូលបានត្រឹមតែ ៩២៣ដុល្លារ/ឆ្នាំ ធៀបនឹងចំណូលមធ្យមកំរិតជាតិដល់ទៅ ១.៣០០ដុល្លារ ។ គ្រួសារនៅជនបទរកចំណូលពីប្រភពផ្សេងៗជាច្រើន ដោយឡែកចំណូលមធ្យមពីកសិកម្មមានទំហំមិនលើសពី ៣០% នៃចំណូលសរុបទេ ។

---

[៣] ក្នុងអត្ថបទនេះ ពាក្យ "កសិករ" ត្រូវបានប្រើប្រាស់ក្នុងន័យជាផ្លូវការរបស់វា ដើម្បីពិពណ៌នាប្រជាជនក្នុងប្រទេសក្រីក្រ ដែលធ្វើការងារកសិកម្មជាសំខាន់នៅលើដីមួយកន្លែង ដើម្បីចិញ្ចឹមជីវិត ។

គ្រួសារនៅជនបទពឹងផ្អែកយ៉ាងខ្លាំងលើការលក់ពលកម្មយកកំរៃ និងការប្រមូលផលពីធនធានទ្រព្យរួម (CPR)[៤] ដែលមានជាសំខាន់គឺ ត្រី និងព្រៃឈើ ។ បើធៀបនឹងកាលពី ៥ឆ្នាំមុន វិស័យកសិកម្មមានការរីកចំរើនគួរចាប់អារម្មណ៍ ដោយមានចំណែកកាន់តែធំឡើងនៅក្នុងចំណូលជាតិសរុប ។ ផ្ទុយទៅវិញ ចំណូលបានពីធនធានទ្រព្យរួមបានថយចុះ លើកលែងតែក្នុងភូមិនានាដែលបានទទួលផលពីការចិញ្ចឹមត្រី និងពីការលុបចោលឡូត៍នេសាទឯកជនមួយចំណែកប៉ុណ្ណោះ ។ បច្ចុប្បន្នអ្នកភូមិកាន់តែបង្កើនការចាប់យកពលកម្មមានប្រាក់កំរៃនៅតាមស្រុកភូមិរបស់ខ្លួន ឬធ្វើដំណើរចេញពីភូមិខ្លួន ដើម្បីរកការងារធ្វើ ។ គ្រួសារក្រីក្រដែលធ្លាប់មានប្រពៃណីពឹងផ្អែកលើធនធានទ្រព្យរួមសំរាប់ចិញ្ចឹមជីវិត ឥឡូវកំពុងទទួលរងគ្រោះដោយសារចំណូលពីការលក់ពលកម្មមានកំរិតទាប គឺតិចជាង ១ដុល្លារ/ថ្ងៃ ។

អ្នកភូមិឥឡូវធ្វើដំណើរកាន់តែឆ្ងាយទៅៗ ដើម្បីប្រមូលភោគផលពីព្រៃឈើ និងផ្ទៃទឹក ។ ពួកគេបានគូសបញ្ជាក់ថា ការធ្វើអាជីវកម្មហួសកំរិត និងការប្រើប្រាស់ឧបករណ៍ចាប់ត្រីខុសច្បាប់ (ដូចជាគ្រឿងផ្ទុះ និងគ្រឿងឆក់សំលាប់ត្រី) បានធ្វើឱ្យថយចុះផលប្រយោជន៍ដែលអាចទទួលបានពីធនធានទ្រព្យរួម ។

## ៥. ការបរិភោគ និងភាពក្រីក្រ

ចំណាយសរុបតាមគ្រួសារមានការប្រែប្រួលយ៉ាងច្រើនទៅតាមរដូវកាល និងតំបន់ ។ ចំណាយលើស្បៀងអាហារមានទំហំដល់ទៅ ៦៨% នៃចំណាយសរុប (វាប្រែប្រួលពី ៥៩-៧៨% តាមភូមិខុសៗគ្នា) ។ ភូមិសំបូរធូរធារមានចំណាយលើអាហារក្នុងសមាមាត្រទាបជាង ។ ការបរិភោគបាយមិនមានភាពយឺតទេ (inelastic) គឺបានន័យថា ប្រជាជនបរិភោគបាយក្នុងសមាមាត្រជាក់លាក់មួយ (មិនលើសមិនខ្វះ) ទោះបីគេស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ច-សង្គមកិច្ច ប្រភេទណាក៏ដោយ, ប៉ុន្តែតំរូវការគ្រឿងមិនមែនជាអាហារ មានភាពយឺតខ្ពស់ជាង (more elastic) ។ នៅពេលគិតរួមគ្នាជាក្រុម គ្រឿងមិនមែនអាហារមានភាពយឺតដូចគ្នានឹងអាហារផ្សេងៗក្រៅពីបាយដែរ ។ ចំពោះចំណាយព្យាបាលសុខភាព វាគ្មានភាពយឺតទេ គឺបានន័យថា ទាំងអ្នកក្រ និងអ្នកមិនក្រ ត្រូវតែចំណាយក្នុងទំហំណាមួយដោយខានមិនបានលើការព្យាបាលជំងឺ (ប្រហែល ៩-១០% នៃចំណាយសរុបក្នុងគ្រួសារ) ។

គិតជាសរុបក្នុងភូមិទាំង៩ គឺមានប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រប្រហែល ៣៨% ប៉ុន្តែ គេឃើញមានការខុសគ្នាច្រើនពីភូមិមួយទៅភូមិមួយ ។ ភូមិមិនសូវមានធនធានផលិតភាពទាបទេ និងប្រជាជនច្រើនរកចំណូលតាមការលក់កំលាំងពលកម្ម ប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រមានលើសពី ៦០% ។ ភូមិដែលសំបូរធនធាន មានផលិតភាពខ្ពស់ ហើយប្រជាជនច្រើនរកចំណូលពីធនធានរូបវ័ន្ត ប្រជាជនរស់នៅក្រោមបន្ទាត់ក្រីក្រមានតិចជាង ២៥% ។ របាយនៃភាពក្រីក្រមានលំនាំប្រហាក់ប្រហែលគ្នា ។ ប្រការនេះបញ្ជាក់ថា ចំណូលទទួលបានពីការលក់កំលាំងពលកម្ម វាទាបជាងចំណូលជាប្រពៃណីដែលរកបានតាមរយៈការប្រើប្រាស់ធនធានរូបវ័ន្តយ៉ាងច្រើន ។

គេអាចធ្វើការប្រៀបធៀបមួយទៅនឹងអង្កេតពីលើកមុនក្នុងឆ្នាំ១៩៩៦-៩៧ ដែល វបសអ បានធ្វើនៅក្នុង ៣ភូមិ ។ នៅក្នុងភូមិពីរដែលមានធនធានរូបវ័ន្តច្រើន ចំនួនអ្នករស់នៅក្រោមបន្ទាត់ក្រីក្របានថយចុះយ៉ាងច្រើន ។ ចំពោះភូមិទីបីដែលក្រខ្សត់ធនធាន និងមានអ្នកលក់កំលាំងពលកម្មយកប្រាក់កំរៃយ៉ាងច្រើន សមាមាត្រអ្នករស់នៅក្រោមបន្ទាត់ក្រីក្របានកើនឡើង ។

## ៦. វិបត្តិ និងភាពងាយរងគ្រោះ

ការប្រឈមមុខនឹងវិបត្តិ ទោះបីវាកើតពីធម្មជាតិ ឬអំពើរបស់មនុស្សក្តី បានក្លាយជាចំណែកមួយនៃជីវិតក្នុងភូមិភាគច្រើន ។ ក្រៅតែពីរឿងបញ្ហាសុខភាពដែលមានជាប្រចាំទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅឆ្នាំ២០០០ និង ២០០១ បានបង្កថែមមួយកំរិតទៀត

---

[៤] CPR សំដៅដល់ធនធានត្រី និងព្រៃឈើនៅក្នុងប្រទេសកម្ពុជា ។

នូវបញ្ហាហិរញ្ញវត្ថុចំពោះភូមិនានាស្ថិតនៅតាមតំបន់ទន្លេមេគង្គ និងទន្លេសាប ។ អ្នកមិនក្របានខាតបង់ប្រាក់ច្រើនជាងអ្នកក្រ ប៉ុន្តែអ្នកក្រខាតបង់ធ្ងន់ជាង បើគិតជាភាគរយនៃចំណូលរបស់ពួកគេ ។

ការទប់ទល់ជាមួយវិបត្តិខុសគ្នាយ៉ាងខ្លាំងពីភូមិមួយទៅភូមិមួយ និងពីគ្រួសារមួយទៅគ្រួសារមួយ ។ គ្រួសាររងគ្រោះភាគច្រើនបានទប់ទល់វិបត្តិដោយប្រើប្រាក់សន្សំ និង/ឬកាត់បន្ថយចំណាយប្រើប្រាស់ ។ ជំរើសមិនធម្មតាផ្សេងៗ រួមមានការខ្ចីបុលការលក់ដី និងការធ្វើចំណាកស្រុក ។ ម្យ៉ាងទៀត មានអង្គការក្រៅរដ្ឋាភិបាល (NGO) និងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗ បានផ្តល់ជំនួយសង្គ្រោះដល់គ្រួសារមួយចំនួនដែលរងគ្រោះដោយទឹកជំនន់ ។

នៅក្នុងបរិបទនៃសន្តិសុខស្បៀង គ្រួសារក្រីក្រងាយរងគ្រោះជាខ្លាំងដោយសារគ្រោះធម្មជាតិ និងបញ្ហាផ្ទាល់ខ្លួន ។ ដោយគ្មានប្រព័ន្ធសុវត្ថិភាពសង្គម គ្រួសារជាច្រើនបានធ្លាក់ខ្លួនដល់ថ្នាក់ត្រូវលះបង់មធ្យោបាយរកចិញ្ចឹមជីវិតដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះថែមទៀត ។

## ៧. បញ្ហាកំលាំងពលកម្ម

ពលកម្មកុមារ គឺជាកត្តាចំបងមួយ ។ កុមារជាច្រើនធ្វើការពេញម៉ោង ហើយកុមារជាច្រើនទៀតដែលកំពុងសិក្សា ក៏ចូលរួមធ្វើពលកម្មដែរ ។ ការដាំដុះរបស់គ្រួសារ*នីមួយៗ* មិនបានផ្តល់ការងារឱ្យពួកគេលើសពី ៥ខែទេជាមធ្យម ហើយបុរស និងស្ត្រីបានចំណាយពេលប្រហែលគ្នាក្នុងការដាំដុះ ។ ដូច្នេះមនុស្សជាច្រើននាក់ គេមានពេលទំនេរមួយរយៈ ពីព្រោះការងារក្នុងកសិដ្ឋានមិនបានស្រូបយកពេលរបស់គេអស់ទេ ។ ក្នុងប្រហែល ៧ខែ ពួកគេចំណាយពេលប្រមូលធនធានទ្រព្យរួម លក់ពលកម្ម (អាចមានទាំងការធ្វើចំណាកស្រុក) ឬប្រកបរបរលក់ដូរកំប៉ិកកំប៉ុក ។

ប្រាក់កំរៃរកបានដោយពលករបុរសជាមធ្យមមានកំរិត ១៥% ខ្ពស់ជាងប្រាក់កំរៃពលករស្ត្រី ប៉ុន្តែការងាររបស់បុរសអាចខុសគ្នាពីការងាររបស់ស្ត្រី) ។ ចំណូលប្រាក់កំរៃនៅតាមភូមិនានាភាគច្រើនបានប្រហែលពី ៣.០០០-៥.០០០៛/ថ្ងៃ ប៉ុន្តែប្រាក់កំរៃរកបានដោយពលករដែលទៅធ្វើការនៅប្រទេសថៃបានដល់ ៦.០០០-៧.០០០៛/ថ្ងៃ ។ នៅក្នុងក្រុមឧស្សាហកម្មជ្រើសរើសមួយចំនួន ពលករដែលមានកំរិតអប់រំដល់មធ្យមសិក្សាអាចរកចំណូលបាន ២០% ច្រើនជាងពលករដែលគ្រាន់តែមានការអប់រំជាមូលដ្ឋាន ហើយអ្នកមានការអប់រំជាមូលដ្ឋានអាចរកចំណូលបាន ១៨% ច្រើនជាងពលករដែលមិនចេះអក្សរ ។

នៅក្នុងបរិបទសន្តិសុខស្បៀងការងារមានប្រាក់កំរៃកាន់តែមានសារៈសំខាន់ ។ ស្ទើរតែគ្រប់ការងារដែលពលករខ្មែរធ្វើ គឺជាប្រភេទការងារគ្មានជំនាញ និងការងារធ្វើដោយដៃ ។ អត្រាប្រាក់កំរៃទទួលបានមានកំរិតទាបសឹងតែមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពផង ។ នេះហើយជាមូលហេតុដែលភាពក្រីក្រមិនបានថយចុះក្នុងកំរិតដែលអ្នកធ្វើផែនការគេចង់បាន ។

## ៨. ការស្វែងយល់ពីជីវភាពនៅតាមជនបទកម្ពុជា

គេដឹងជាទូទៅថា កសិកម្មកម្ពុជាមានកំណើតពីប្រព័ន្ធកសិកម្មយថាផល ដែលក្នុងនោះ ចំនួនប្រជាជនទាំងអស់ដែលពឹងផ្អែកលើដី និងធនធានធម្មជាតិផ្សេងទៀតតែងតែមានតិចនាក់ទេ[៥] ។ ដូច្នេះទោះជាផលិតភាពមានកំរិតទាបក្តី ប៉ុន្តែនៅតែមានស្បៀងគ្រប់គ្រាន់ដដែល ។ រហូតមកដល់ពាក់កណ្តាលសតវត្សរ៍ទី២០នេះហើយ ក៏ប្រជាជននៅមានតិចជាង ៤លាននាក់ (ធៀបទៅនឹង ១១លាននាក់នៅឆ្នាំ១៩៩៨) ។ ដោយសារកំណើនការធ្វើពាណិជ្ជកម្មនៃសេដ្ឋកិច្ចជនបទ និងការជួបទាក់ទងនឹងទីផ្សារធំៗនៅសតវត្សរ៍ទី២០ ប្រព័ន្ធកសិកម្មកាន់តែជួបការតឹងតែងច្រើនឡើង ។ កន្លងមកមានកិច្ចប្រឹងប្រែងមួយចំនួនដើម្បីផ្លាស់ប្តូររចនាសម្ព័ន្ធនៃការផ្គត់ផ្គង់ និងការរៀបចំផលិតកម្មនៅក្នុងសេដ្ឋកិច្ចជនបទ ហើយឥឡូវនេះមានការទាមទារកាន់តែច្រើនពីសំណាក់អ្នកនៅខាងក្រៅវិស័យកសិកម្មទៅលើធនធានព្រៃឈើ ត្រី ដីធ្លី និងទឹក ។ បញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារ

[៥] សូមអាន Boseup (1965) ស្តីពីចំណាត់ថ្នាក់ប្រព័ន្ធកសិកម្ម ។

ប្រជាជនកើនយ៉ាងលឿន ហើយតំរូវការធនធាននៅក្នុងសេដ្ឋកិច្ចជនបទ ក៏កើនយ៉ាងលឿនដែរ ។ ដោយតំរូវការកើនលើសការផ្គត់ផ្គង់កាន់តែខ្លាំង ដូច្នេះធនធានជាប្រពៃណី (ដូចជា ដីធ្លី ព្រៃឈើ និងត្រី) មានកាន់តែតិចទៅៗសំរាប់ប្រជាជនជនបទ ។

នៅក្នុងតំបន់ជាច្រើន កសិកម្មបានធ្វើទំនើបកម្ម ហើយពូជដំណាំផ្តល់ទិន្នផលខ្ពស់, ជី និងប្រព័ន្ធស្រោចស្រពកាន់តែមានការនិយមច្រើនឡើង ។ បដិវត្តន៍បៃតងនេះ (green revolution) ទទួលបានជោគជ័យជាពិសេសនៅក្នុងតំបន់ដែលដីមានជីជាតិ និងមានប្រភពទឹកស្រួលយកមកប្រើប្រាស់ ។ ក្នុងតំបន់ទាំងនេះ ចំណូលកសិករបានកើនឡើង ហើយកសិកម្មបានក្លាយជាប្រភពចិញ្ចឹមជីវិតដ៏ចំបង ។ ក្នុងតំបន់ខ្លះទៀត ធនធានដូចជា ត្រី នៅតែសំបូរ (លទ្ធភាពមានត្រីបានកើនឡើងដោយសារការចាប់ផ្តើមចិញ្ចឹមត្រី) ។ ដូច្នេះប្រាក់ចំណូលបានកើនឡើងនៅតាមតំបន់ដែលមានកំណើនធនធាន (ឬកំពុងអភិវឌ្ឍធនធាន) ហើយអ្នកដែលមានធនធាន គឺទទួលបានប្រយោជន៍ ។

នៅកន្លែងផ្សេងទៀតដែលមានធនធានរួមតូច ទំងន់នៃកំណើនតំរូវការកំពុងបង្កបញ្ហា ។ ពេលចំណូលពីធនធានទ្រព្យរួមថយចុះ ប្រជាជនកាន់តែច្រើនឡើងចាប់យកការងារមានប្រាក់កំរៃ ប៉ុន្តែផលទទួលបានពីការងារនេះ វាទាបជាងផលទទួលបានធនធានផលិតកម្មរូបវន្ត ។ ក្នុងការផ្លាស់ប្តូរមុខរបរដែលកើតមាននៅគ្រប់កន្លែង (ទោះមានឱនភាព ឬអតិរេកក្តី) ចំណូលរបស់អ្នកខ្លះបានធ្លាក់ចុះ ដោយសារប្រាក់កំរៃទាប និងមានការងារតិច ។ ដូច្នេះ អត្រាក្រីក្រសរុបមិនបានថយចុះក្នុងល្បឿនដែលស៊ីសង្វាក់គ្នាជាមួយអថេរម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀត ដូចជា កំណើន ផសស ជាដើម ។

កសិកម្មមិនបានរីកលូតលាស់លឿនគ្រប់គ្រាន់ទេ ហើយដីធ្លីនៅកម្ពុជាបច្ចុប្បន្ន ផ្តល់ទិន្នផលទាបជាងគេបង្អស់នៅអាស៊ីអគ្នេយ៍ ។ មូលហេតុសំខាន់ៗមានជាអាទិ៍ កង្វះឥណទាន ប្រព័ន្ធស្រោចស្រពមិនគ្រប់គ្រាន់ ទំនាក់ទំនងទីផ្សារមិនគ្រប់គ្រាន់ និងហេដ្ឋារចនាសម្ព័ន្ធមិនល្អ (ទាំងរូបវន្ត និងសង្គមកិច្ច) ។ លើសពីនេះ សកម្មភាពមិនមែនកសិកម្ម ក៏មិនសូវរីកចំរើនដោយសារមូលហេតុដូចគ្នា ។ សេដ្ឋកិច្ចជនបទដែលលូតលាស់យឺតៗបែបនេះ មិនអាចទប់ទល់បានល្អនូវកំណើនអ្នកចំណូលថ្មីទៅក្នុងកំលាំងពលកម្មក្នុងមួយឆ្នាំៗនោះទេ ហើយនេះជាហេតុផលមួយនៃកំណើនអសន្តិសុខស្បៀង ។

កំលាំងពលកម្មទទួលបានផលទាបដោយសារមូលហេតុបីយ៉ាង ។ ទី១ នៅជនបទក៏ដូចជាទីក្រុងដែរ វិស័យមិនមែនកសិកម្មមិនបានរីកលូតលាស់លឿនទេ ។ ទោះបីជានៅកន្លែងខ្លះដែលមានការរីកលូតលាស់ ដូចជា វិស័យកាត់ដេរ, សំណង់ និងទេសចរណ៍ ក៏ចំនួនការងារមិនបានកើនច្រើនគ្រប់គ្រាន់ទេ ។ ទី២ ចរិត និងសមាសភាពនៃកំណើនសេដ្ឋកិច្ច គឺមានទំនាក់ទំនងតិចតួចជាមួយជនបទ ។ ទី៣ នៅកម្ពុជា វិនិយោគលើធនធានមនុស្សមានកំរិតទាប ជាពិសេសនៅតំបន់ជនបទ ។

ដូចបានបញ្ជាក់ពីខាងដើមហើយ កសិករនៅតែរកចំណូលតាមប្រភពជាច្រើន ។ ដោយប្រភពចំណូលមួយចំនួនកំពុងថយចុះ (ឧ. ត្រី ព្រៃឈើ) ចំនូលអ្នកភូមិមួយចំនួនកំពុងធ្លាក់ចុះ ។ ម្យ៉ាងទៀត បើសិនមានការអនុញ្ញាតឱ្យប្រើប្រាស់ធនធានទ្រព្យរួមដ៏ពេញលេញ ធនធានទាំងនោះនឹងត្រូវហិនហោចយ៉ាងលឿននៅក្រោមឥទ្ធិពលប្រព័ន្ធសមាហរណកម្មទីផ្សារថ្មី ដូចដែលធ្លាប់ឃើញនៅទសវត្សរ៍១៩៩០ ។ គេមិនទាន់មានអ្វីច្បាស់លាស់ទេថា ការគ្រប់គ្រងធនធានតាមបែបសហគមន៍ ដែលលើកឡើងដោយរដ្ឋាភិបាល និងម្ចាស់ជំនួយ វានឹងអាចរកដំណោះស្រាយលើបញ្ហានេះបាន ។

តើស្ថានភាពសន្តិសុខស្បៀងជាទូទៅមានលក្ខណៈយ៉ាងដូចម្តេច? ពិតហើយ ផលិតកម្មស្បៀងបានកើនឡើងយឺតៗ ប៉ុន្តែយ៉ាងទៀងទាត់ ហើយវានឹងបន្តយ៉ាងដូច្នេះមួយរយៈពេលខ្លីទៅអនាគតទៀត ពីព្រោះមានកសិករកាន់តែយ៉ាងច្រើនអនុវត្តប្រើគ្រាប់ពូជ និងជីទំនើបៗ ព្រមទាំងម្ចាស់ការលើទឹកស្រោចស្រពទៀតផង ។ លើសពីនេះ គេបានពង្រីកចំនួនមុខដំណាំផងដែរ ។ ប៉ុន្តែជោគជ័យក្នុងវិស័យមួយមុខៗដូចខាងលើ អាចជួយកែលំអបានតែមួយកំរិតប៉ុណ្ណោះនូវសន្តិសុខស្បៀងរបស់កសិករ និងអ្នកភូមិដែលខ្វះខាតស្បៀង ។ ហើយការបែងចែកផលចំណេញ វាទាក់ទងមួយភាគធំទៅនឹងបែបបទ និងកំរិតនៃកំណើនប្រាក់ កំរៃ និងឱកាសមានការងារធ្វើ ទាំងក្នុងវិស័យកសិកម្ម ទាំងក្នុងវស័យសកម្មភាពផ្សេងៗទៀត ។

# សេចក្តីថ្លែងអំណរគុណ

នៅក្នុងដំណើរការនៃការសិក្សាក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ ក្រុមអ្នកនិពន្ធបានជំពាក់គុណបុគ្គល និងស្ថាប័នផ្សេងៗជាច្រើន ។ ការសិក្សានេះមិនអាចចប់បានឡើយ បើសិនគ្មានការគាំទ្រ និងសហប្រតិបត្តិការពីអ្នកទាំងអស់នោះទេ ។ ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់កសិករជាច្រើននាក់ ដែលបានស្ម័គ្រចិត្តចំណាយពេលវេលាដ៏មានតំលៃពីការរកចិញ្ចឹមជីវិតប្រចាំថ្ងៃ ដើម្បីផ្តល់ពត៌មានដែលយើងខ្ញុំត្រូវការ ។ យើងខ្ញុំបានទទួលពត៌មានយ៉ាងច្រើនពីកសិករ ប៉ុន្តែអ្វីដែលយើងបានផ្តល់ឱ្យពួកគេវិញមានតិចតួចណាស់ ។ យើងខ្ញុំសង្ឃឹមថាគុណបំណាច់នេះនឹងអាចសងវិញបានមួយចំណែកដោយផលប៉ះពាល់ពីគោលនយោបាយជាវិជ្ជមានណាមួយដែលផុសចេញពីការសិក្សានេះ ។ ដូចគ្នាដែរ យើងខ្ញុំសូមអរគុណចំពោះមន្ត្រីរាជការជាច្រើននាក់នៅថ្នាក់ស្រុក និងខេត្ត ដែលបានជួយសំរួលដល់ដំណើរការសិក្សា ។

អ្នកនិពន្ធសូមអរគុណផងដែរចំពោះអ្នកបញ្ចូលទិន្នន័យ និងប្រមូលទិន្នន័យ ដែលបានធ្វើការនៅក្នុងលក្ខខណ្ឌដ៏លំបាក ដើម្បីធានាឱ្យទិន្ន័យមានលក្ខណៈត្រឹមត្រូវល្អ ។ យើងខ្ញុំសូមអរគុណចំពោះលោក គឹម សេតារា, សូ សុវណ្ណារិទ្ធិ, លោកស្រី ជឹម ចរិយា និង ប៊ុន ដូរីណា ដែលបានជួយប្រមូលទិន្នន័យ ផ្ទៀងផ្ទាត់ កែសំរួល និងបញ្ចោក់ទិន្នន័យនៅក្នុងការសិក្សានេះ ។ យើងខ្ញុំសូមថ្លែងអំណគុណដល់ការជួយឧបត្ថម្ភថវិកាយ៉ាងទាន់ពេលវេលា ពីនាយកដ្ឋានសំរាប់ការអភិវឌ្ឍន៍អន្តរជាតិប្រទេសអង់គ្លេស (DFID-UK) ។

ឯកសារនេះទទួលការពិគ្រោះពិភាក្សាយោបល់ដ៏មានតំលៃពីសំណាក់ Dr Gus Edgren, Dr Daram Ghai, Dr Daniel Arghiros, Mr. Bruce McKenney, Ms Eva Mysliwiec and Mr. Andrew Young ។ យើងសូមអរគុណផងដែរចំពោះលោក គិម-យាត ដារ៉ារិទ្ធិ លោកស្រី ថោង បុប្ផារ៉ា និងកញ្ញា នូ កុលសូរិយា ដែលផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងការគ្រប់គ្រងដ៏ប្រសើរបំផុតជួយជំរុញឱ្យការចុះសិក្សាផ្ទាល់ដល់កន្លែងមានប្រសិទ្ធិភាពល្អ និងមានដំណើរការយ៉ាងរលូន ។

# ផែនទីទីតាំងភូមិទាំង ៩

ផែនទីៈ ភូមិខ្មែរ
មាត្រដ្ឋានៈ ១:៣.៥០០.០០០




© រក្សាសិទ្ធិឆ្នាំ២០០៣ វិទ្យាស្ថានបណ្តុះបណ្តាល
និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា១៩៩៨
ការតំណាងព្រំប្រទល់ គឺគ្រាន់តែបង្ហាញទីតាំងភូមិទេ
មិនមែនតំណាងឱ្យទូទាំងប្រទេសទេ ។

## ជំពូកទី ១

# សេចក្ដីផ្ដើម

### ១.១ ស្ថានភាពភូមិសាស្ត្រប្រទេសកម្ពុជា

យោងតាមជំរឿនឆ្នាំ១៩៩៨ ប្រជាជនកម្ពុជាប្រហែល ៨០% រស់នៅតំបន់ជនបទ ហើយប្រហែល ៨៥% ធ្វើកសិកម្ម និង របរផ្សេងទៀតដែលទាក់ទិននឹងកសិកម្ម ។ ប្រជាជនជនបទមានប្រហែល ៩.៦លាននាក់នៅឆ្នាំ១៩៩៨ ហើយអាចកើនឡើងដល់ ១០.៦លាននាក់នៅឆ្នាំ២០០២ បើគិតតាមអត្រាកំណើនប្រជាជន ២.៥%[៦] ។ ទោះបីមានប្រជាជនយ៉ាងច្រើនធ្វើកសិកម្ម និងរបរទាក់ទិននឹងកសិកម្មក្តី ក៏ប្រទេសកម្ពុជាមិនទាន់ក្រខ្សត់ដីនៅឡើយទេ ។ ផ្ទៃដីសរុបមាន ១៨.១លានហិកតារ ក្នុងនេះ ៣.៩លានហិកតារសំរាប់ដាំដំណាំ ដែលមាន ២.៣លានហិកតារសំរាប់ដំណាំស្រូវ និង ១.៦លានហិកតារសំរាប់ដំណាំចំការ ។ ផ្ទៃដី ១.៧លានហិកតារទៀត ជាផ្ទៃដីមិនប្រើប្រាស់ដែលស្ថិតនៅជាដីព្រៃ ដីលិចទឹក ឬក៏ជាភ្នំ (McKenney and Prom 2002; Chan, Tep and Acharya 2001) ។ ដូច្នេះ មានផ្ទៃដីប្រហែល ៥.៦លានហិកតារជាដីដាំដុះ ឬអាចដាំដុះបាន ។ គិតតាមតួលេខនេះ លទ្ធភាពមានដីសំរាប់មនុស្សម្នាក់ គឺមានច្រើន[៧] ។

ប្រទេសកម្ពុជាមានកំណើនចំណូលជាតិយ៉ាងខ្ពស់ ចាប់តាំងពីដើមទសវត្សរ៍១៩៩០ ។ ពីឆ្នាំ១៩៩២-១៩៩៦ ផសស មានកំណើនមធ្យមប្រចាំឆ្នាំប្រហែល ៦% ប៉ុន្តែបន្ទាប់ពីនោះមក វាថយកំណើនវិញ ។ កំណើនប្រចាំឆ្នាំមធ្យមពីឆ្នាំ១៩៩៧-២០០២ ស្ថិតក្នុងចន្លោះ ៤-៤.៥% ដោយមានការឡើងចុះម្តងៗ ។ ប៉ុន្តែកំណើននេះកើតមានភាគច្រើនក្នុងសកម្មភាពមួយចំនួនតូច ដូចជា វិស័យកាត់ដេរ និងទេសចរណ៍ ហើយប្រមូលផ្តុំតែក្នុងតំបន់ទីក្រុងសំខាន់ៗប៉ុណ្ណោះ ។ ឧទាហរណ៍ កំលាំងពលកម្មនៅក្នុងវិស័យកាត់ដេរមានមិនលើសពី ២០០.០០០នាក់ទេ ដែលត្រូវជាជាង ៣% បន្តិចនៃកំលាំងពលកម្មសរុប ។ អ្នកបំរើការងារសរុបក្នុងវិស័យផ្លូវការ (វិស័យដែលមានច្បាប់ស្តីពីប្រាក់ឈ្នួលដូចជាវិស័យកាត់ដេរ) មាន ៥% ឬ ២៨០.០០០នាក់ ។ អ្នកបំរើការក្នុងវិស័យនេះ ពុំមានច្រើនគ្រប់គ្រាន់ក្លាយជាចំណែកធំមួយនៃរចនាសម្ព័ន្ធកំលាំងពលកម្មឡើយ ។ ទន្ទឹមនេះដែរ ទោះជាក្នុងវិស័យទាំងនេះក្តី ក៏ប្រាក់កំរៃ (៤០-៦០ដុល្លារ/ខែ) មិនទាន់ខ្ពស់គ្រប់គ្រាន់អាចបង្កើតឥទ្ធិពលមេគុណ (multiplier effect) សំរាប់វិស័យផ្សេងទៀតបានទេ ។ ឥទ្ធិពលមេគុណក៏នៅមានកំរិត ដោយសារតំលៃបន្ថែមមានកំរិតទាប ក្នុងគ្រប់វិស័យ

---

[៦] ទិន្នន័យទាំងអស់ស្តីពីប្រជាជន ដកស្រង់ចេញពីរបាយការណ៍សេដ្ឋកិច្ចប្រចាំឆ្នាំរបស់ វបសអ ដែលប្រើទិន្នន័យបានពីការព្យាករណ៍ និងការប៉ាន់ស្មានដោយក្រសួងផែនការ ។

[៧] របាយការណ៍នេះគឺជាការសិក្សាប្រៀបធៀប ។ នៅប្រទេសអភិវឌ្ឍន៍ផ្សេងទៀត លទ្ធភាពមានដីរបស់មនុស្សម្នាក់ អាចតិចជាងខ្លាំងណាស់ ។ សូមអានឯកសាររបស់ធនាគារពិភពលោក (២០០១) ។

(រួមទាំងវិស័យទំនើបមានកំណើនល្អ) ហើយវាមានចំណងទាក់ទងតិចតួចជាមួយវិស័យផ្សេងទៀត ។ គេអាចនិយាយបានថា ផលប៉ះពាល់នៃឧស្សាហូបនីយកម្មនេះ ទៅលើតំបន់ជនបទនៅមានតិចតួចនៅឡើយ (Acharya 2002)[៨] ។

គ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដែលកម្ពុជាស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតនៅអាស៊ី ។ កសិកម្មកម្ពុជានៅតែជាកសិកម្មជីវព្រឹត្តិ ហើយផលិតភាពដំណាំមធ្យមក៏ស្ថិតនៅក្នុងកម្រិតផលិតភាពទាបៗបំផុតនៅអាស៊ីអគ្នេយ៍ដែរ ។ ដោយហេតុថា ប្រជាជនភាគច្រើនរស់នៅក្នុងតំបន់ជនបទ និងមានជីវភាពពឹងផ្អែកលើកសិកម្ម និងសកម្មភាពទាក់ទងនឹងកសិកម្មផ្សេងៗ ដូច្នេះកំណើនកសិកម្មមានសារៈសំខាន់ណាស់ ប៉ុន្តែកំណើននេះមានត្រឹមតែ ១%/ឆ្នាំប៉ុណ្ណោះ (Sok and Acharya 2002) ។ លើសពីនេះទៀត កំណើនប្រជាជនដ៏ខ្ពស់ដល់ ២,៥%/ឆ្នាំក្នុងទសវត្សរ៍១៩៨០ និង ១៩៩០ បណ្តាលឱ្យមានប្រជាជនកាន់តែច្រើនចូលទៅ ក្នុងទីផ្សារពលកម្ម ហើយកំណើននេះបានដាក់សំពាធទៅលើការងារ និងប្រាក់កំរៃដែលអាចរកបាន ។

ភាពក្រីក្រគិតតាមចំនួនកាឡូរីបរិភោគ (មនុស្សម្នាក់ត្រូវស្ថិតនៅក្រោមបន្ទាត់ក្រីក្រ បើសិនជាបរិភោគអាហារមានថាមពលតិចជាង ២.១០០កាឡូរី/ថ្ងៃ) បង្ហាញថា នៅឆ្នាំ១៩៩៣-៩៤ ភាពក្រីក្រមាន ៣៩% (RGC 1999) ។ សមាមាត្រនេះបានថយចុះអស់ ៣% មកត្រឹម ៣៦% នៅឆ្នាំ១៩៩៧ ។ គេគិតថា តាំងពីពេលនោះមកចំនួនភាគរយអ្នករស់នៅក្រោមបន្ទាត់ក្រីក្រស្ថិតនៅនឹងដដែល (RGC 1999, RGCC 2001) ។ ប្រជាជនក្រីក្រប្រហែល ៩០% រស់នៅតំបន់ជនបទ និងធ្វើកសិកម្មរួមផ្សំដោយការនេសាទ និងការប្រមែប្រមូលផលពីព្រៃឈើ ។ មធ្យោបាយចំបងសំរាប់ចិញ្ចឹមជីវិតនៅជនបទគឺ ដីកសិកម្ម និងការនេសាទ ។ ដូច្នេះ ដីមិនគ្រប់គ្រាន់ ដីគុណភាពមិនល្អភាគច្រើន (ឬដីមានការវិនិយោគតិចតួច) ផលិតភាពដីទាប ភាពគ្មានដី និងការថយចុះលទ្ធភាពប្រើប្រាស់តំបន់នេសាទ គឺជាមូលហេតុដោយឡែកៗពីគ្នា ឬរួមផ្សំគ្នាដែលធ្វើឱ្យកំរិតជីវភាពមានកំរិតទាប ។

បញ្ហាប្រឈមចំបងបំផុតចំពោះកម្ពុជាសព្វថ្ងៃគឺ ធ្វើយ៉ាងណាឱ្យការកាត់បន្ថយភាពក្រីក្រជនបទមានដំណើរលូតលាស់ទៅមុខលឿន ។ សេដ្ឋកិច្ចជនបទត្រូវស្ថិតនៅលើគន្លងមួយដែលមានចីរភាព និងល្បឿនលឿន និងដែលធានាឱ្យមានការបែងចែកសមភាពគ្នានូវផលចំណេញនៃការរីកលូតលាស់ទៅដល់គ្រប់ស្រទាប់ប្រជាជននៅក្នុងសង្គមជនបទ ។ ក្នុងកិច្ចប្រឹងប្រែងនេះ ធនធានចំបងៗ ដូចជា ដីធ្លី ព្រៃឈើ និងផ្ទៃទឹក ត្រូវតែមានការប្រើប្រាស់ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រឱ្យបានប្រសើរបំផុត ។

## ១.២ បញ្ហាកើតមានចំពោះដីធ្លី ភាពក្រីក្រ និងសន្តិសុខស្បៀង

ការសិក្សាជាច្រើនស្តីពីជីវភាពនៅជនបទកម្ពុជាបានពិនិត្យបញ្ហាខុសៗគ្នា ដូចជា ការបែងចែកដី ភាពគ្មានដីធ្លី កំណើនកសិកម្ម លទ្ធភាពប្រើប្រាស់ធនធានរួម និងការវាស់វែងភាពក្រីក្រ ។ ការសិក្សាទាំងនេះមានជាអាទិ៍ Murshid 1998; Williams 1999; Kato 1999; Biddulph 2000; Williams 2000; Sik 2000; So *et al* 2001; Chan, Tep and Acharya 2001; RGC 2001; Chan and Acharya 2002, Sok and Acharya 2002 and McKenney and Prom 2002 ។ គំហើញសំខាន់ៗដែលផុសចេញពីការសិក្សាទាំងនេះ មានដូចខាងក្រោម:

### *១.២.១ វិសមភាពដីធ្លី និងភាពគ្មានដី*

ផ្អែកតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ឆ្នាំ១៩៩៩ មេគុណ Gini[៩] នៃវិសមភាពក្នុងការកាន់កាប់ដីកសិកម្មគឺ 0,៥៧ ហើយចំនួនគ្រួសារដែលគ្មានដីកសិកម្មមានប្រហែល ១៦% ក្នុងតំបន់ជនបទ ។ វិសមភាពក្នុងការបែងចែកដីធ្លី និងភាពគ្មានដីធ្លី

---

[៨] ភាពយឺតនៃការកាត់បន្ថយភាពក្រីក្រ ធៀបនឹងកំណើន គឺមាន ១៤%នៅទសវត្សរ៍១៩៩០ (Acharya 2001) ។ រចនាសម្ព័ន្ធនៃផលិតកម្ម និងការបែងចែកដែលមិនផ្សារភ្ជាប់គ្នា បានធ្វើឱ្យប្រទេសកម្ពុជាខុសពីប្រទេសផ្សេងទៀតនៅក្នុងតំបន់ ជាពិសេស វៀតណាម និងថៃ ។

បានផុសឡើងជិតមួយទសវត្សរ៍ហើយៈ នៅឆ្នាំ១៩៨៩ នៅពេលដីធ្លីត្រូវបានធ្វើឯកជននីយកម្មជាផ្លូវការ គេទទួលស្គាល់ជាទូទៅថា ការបែងចែកដីធ្លីឡើងវិញនេះជាទូទៅគឺមានសមភាពល្អ[១០] ។ ការគណនាផ្សេងៗដោយផ្អែកលើការសិក្សាខាងលើបានបង្ហាញថា ភាពគ្មានដីកើនឡើងប្រហែល ២% ក្នុងមួយឆ្នាំៗ ។

ដីកសិកម្មផ្លាស់ប្តូរម្ចាស់យ៉ាងលឿនតាមរយៈការលក់ (ពិសេសដីដែលមានតំលៃទីផ្សារខ្ពស់) ជួនកាលតាមការទន្ទ្រានយកដី និងការគំរាមគំហែង ។ ករណីជំលោះដីធ្លីបានកើតមានឡើង ហើយសមត្ថភាពនៃរដ្ឋអំណាច ដើម្បីដោះស្រាយបញ្ហានេះនៅមានកំរិត ។ កំណត់ត្រាជាផ្លូវការលើទិញដូរដីបញ្ជាក់ឱ្យឃើញថា ទីផ្សារដីធ្លីមានសកម្មភាពខ្លាំង ជាពិសេសនៅតាមខេត្តដែលមានចរន្តទីផ្សារ ។ គេអាចសន្និដ្ឋានថា ការលក់ទិញដី និងការផ្ទេរកម្មសិទ្ធិដីនាំឱ្យមានវិសមភាពក្នុងការបែងចែកដីធ្លី ។

កំណើនប្រជាជនយ៉ាងលឿន កន្លងមកបានរួមចំណែកមួយភាគធ្វើឱ្យមានកំណើនការពុះចែកដីកាន់កាប់ដោយកសិករព្យាយាមផ្តល់ដីធ្លីខ្លះទៅឱ្យកូនៗ នៅពេលកូនៗ កសាងគ្រួសាររបស់គេ ។ ដោយគ្មានការធ្វើចំរុះកម្មមុខរបរឱ្យបានគ្រប់គ្រាន់ដូច្នេះសម្ពាធប្រជាសាស្ត្របានបណ្តាលឱ្យទំហំដីកាន់កាប់រួមតូច ព្រមទាំងបង្កើនចំនួនភាគរយនៃគ្រួសារដែលមានដីកាន់កាប់តូចៗ ឬគ្មានសោះ ។

### *១.២.២ ដី និងផលិតកម្ម*

នៅទសវត្សរ៍១៩៦០ កម្ពុជាមានដីស្រែយ៉ាងសំបូរ ។ ថ្វីបើអត្រាទិន្នផលមានតួលេខទាបនៅកំរិតម៉ាក្រូក្តី ប៉ុន្តែវាអាចធានារ៉ាប់រងតំរូវការក្នុងប្រទេស និងមានអតិរេកសំរាប់នាំចេញទៀតផង ពីព្រោះអត្រាប្រើប្រាស់ដីធៀបនឹងចំនួនប្រជាជនមានលក្ខណៈល្អប្រសើរ ។ បន្ទាប់មកសង្គ្រាម ៣ទសវត្សរ៍ បានធ្វើឱ្យប្រែប្រួលដល់រូបភាពកសិកម្ម ។ ផ្ទៃដីដាំស្រូវធ្លាក់ចុះពី ២,៥លានហិកតារនៅឆ្នាំ១៩៦៧ ដល់ ១,៩លានហិកតារនៅឆ្នាំ១៩៩៤ ។ រហូតដល់ដើមសហសវត្សរ៍ថ្មី ទើបផ្ទៃដីសាបព្រួសអាចកើនដល់ ២,៣លានហិកតារឡើងវិញ[១១] ។

ប៉ុន្តែ ស្ថានភាពទិន្នផលស្រូវ មិនទាន់មានលក្ខណៈគួរពេញចិត្តទេ ។ ទោះបីមានការកែលំអខ្លះៗក្តី កម្ពុជានៅអន់ថយខ្លាំងណាស់ធៀបនឹងប្រទេសជិតខាងនៅអាស៊ី បើគិតពីអត្រាទិន្នផល និងផលិតភាពដំណាំ ។ ពីឆ្នាំ១៩៨០-១៩៩៤ ទិន្នផលស្រូវមធ្យមគឺ ០,៩-១,៤តោន/ហ.ត ។ ចាប់តាំងពីឆ្នាំ១៩៩៥ មក ទិន្នផលស្រូវអាចរក្សាបានលើសពី ១,៦តោន/ហ.ត ហើយនៅឆ្នាំ១៩៩៩ ទិន្នផលឡើងដល់ ២តោន/ហ.ត ។ ប៉ុន្តែតួលេខនេះនៅតែទាបជាងទិន្នផលនៅវៀតណាម ឥណ្ឌូនេស៊ី និងហ្វីលីពីនដែលមានបានលើសពី ៣តោន/ហ.ត ។

ដោយសារកំណើនទាំងផ្ទៃដីដាំដុះ និងទិន្នផលស្រូវ ផលិតកម្មស្រូវសរុបកើនទ្វេនៅពាក់កណ្តាលទសវត្សរ៍១៩៨០ និងចុងទសវត្សរ៍១៩៩០ ។ ទិន្នផលស្រូវកើនដល់ ៤លានតោននៅជាលើកដំបូងនៅឆ្នាំ១៩៩៩ ដែលនាំឱ្យមានអតិរេកមួយចំនួននៅកំរិតជាតិ ។ ប៉ុន្តែអតិរេកនេះមិនបានធានាឱ្យប្រជាជនបានរួចផុតពីភាពអត់ឃ្លានទាំងអស់គ្នានោះទេ ។ ទី១ ផលិតកម្មស្រូវមានការឡើងចុះគួរកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារការមិនអាចទាយទុកជាមុនលើលក្ខខណ្ឌអាកាសធាតុ ជាពិសេស ទឹកជំនន់និងគ្រោះរាំងស្ងួត ដែលអាចនាំឱ្យមានអតិរេកស្រូវនៅឆ្នាំមួយ និងឱនភាពស្រូវនៅឆ្នាំបន្ទាប់ទៀត ។ ទី២ ផលិតកម្មស្រូវមានភាពខុសគ្នាច្រើនពីតំបន់មួយទៅតំបន់មួយ ។ ទី៣ លទ្ធភាពមានស្បៀងអាហារមានលក្ខណៈខុសគ្នាច្រើនណាស់ រវាងគ្រួសារ

---

[៩] មេគុណ Gini ជាតួលេខមួយ ស្មើនឹងតួលេខដែលបង្ហាញនៅក្នុងក្រាហ្វិក Lorenz Curve (សូមអានជំពូកទី៧) ។

[១០] គ្រួសារដែលត្រឡប់ពីជំរំតាមទល់ដែនវិញ គឺមកដល់ក្រោយពេលបែងចែក ។ ពួកគេមិនបានទទួលដីគ្រប់គ្នាទេ ។

[១១] តួលេខនេះ មិនគិតចូលនូវ ដីធ្វើចំការកសិកម្មទេ ។

មានដី និងគ្រួសារគ្មានដី ។ អសន្តិសុខស្បៀងកាន់តែធ្ងន់ធ្ងរឡើង ដោយសារប្រជាជននៅជនបទធ្វើសមាហរណកម្មមិនបានល្អទៅក្នុងទីផ្សារធំៗ ។

គេឯកភាពជាទូទៅថា ដើម្បីកាត់បន្ថយអសន្តិសុខស្បៀង ត្រូវផ្តល់អាទិភាពខ្ពស់ទៅលើការបង្កើនផលិតភាពនៅក្នុងប្រព័ន្ធផលិតកម្មជនបទ ជាពិសេសផ្នែកកសិកម្ម ។ ដូច្នេះហើយ បញ្ហាប្រឈមមួយក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទគឺការរកឱ្យឃើញពីឧបសគ្គចំពោះការបង្កើនផលិតភាពកសិកម្មនៅកំរិតកសិដ្ឋាន ។

## ១.២.៣ ការកើនឡើងសម្ពាធប្រជាសាស្ត្រលើដីធ្លី

ចាប់តាំងពីចុងឆ្នាំ១៩៧៩មក តុល្យភាពរវាងការផ្គត់ផ្គង់ និងតំរូវការដីធ្លីបានប្រែប្រួល ។ ទសវត្សរ៍១៩៨០ និង ១៩៩០ជារយៈពេលមានកំណើនប្រជាជនលឿនណាស់ (ក្នុងរង្វង់ ២,៥%/ឆ្នាំ) គឺលឿនជាងកំណើនផលិតកម្ម និងផលិតភាពកសិកម្មទៅទៀត ។ រឿងនេះបានបង្កើតតំរូវការស្បៀងអាហារយ៉ាងច្រើន ប៉ុន្តែវាមិនមែនសុទ្ធតែមកពីកង្វះសមត្ថភាពទិញនោះទេ ។ កំណើនប្រជាជនយ៉ាងគំហុកបានជះឥទ្ធិពលដល់រចនាសម្ព័ន្ធអាយុផងដែរ គឺមានមនុស្សច្រើនពេកក្នុងក្រុមអាយុក្មេងខ្ចី ធៀបនឹងប្រជាជនអ្នកធ្វើការ ហើយវាកាត់បន្ថយទំហំប្រាក់ចំណូលគិតក្នុងមនុស្សម្នាក់ ។ លើសពីនេះទៀត ចំនួនគ្រួសារថ្មីកំពុងស្វែងរកដីធ្លី ក៏កើនឡើងដែរ ដោយមានមនុស្សកាន់តែច្រើននាក់ឡើងបានពេញវ័យ ។ ការសិក្សារបស់អុកស្វាមអង់គ្លេស[១២] រកឃើញថាក្នុងចំណោមអ្នកគ្មានដីនៅឆ្នាំ២០០០ មាន ៥៦% មិនដែលមានដីទេ ក្នុងនេះ ៤២% ជាគ្រួសាររៀបការថ្មី និង ៥៣% ជាជនចំណាកស្រុក ។ ស្ថិតិទាំងនេះ គឺជាភស្តុតាងបង្ហាញថាកំលាំងប្រជាសាស្ត្រ គឺជាមូលហេតុចំបងដែលបណ្តាលឱ្យមនុស្សគ្មានដី ។

ឥទ្ធិពលកត្តាគ្រួសារកកើតថ្មី នៅក្នុងតំរូវការដីធ្លីថ្មី អាចវាយតំលៃបានដោយពិនិត្យការព្យាករណ៍ក្នុងជំរឿនប្រជាជនឆ្នាំ១៩៩៨ ចំពោះក្រុមអាយុដែលត្រូវរៀបការជាលើកដំបូង (២០-២៤ឆ្នាំ) ។ ចំនួនមនុស្សក្នុងក្រុមអាយុនេះរំពឹងថា នឹងកើនឡើង ៤០% ពីឆ្នាំ២០០១-២០០៦ ហើយកើន ១៣% ថែមទៀត ពីឆ្នាំ២០០៦-២០១១ ។ តួលេខនេះស្មើនឹងកំណើន ៥៨% នៃក្រុមអាយុនេះ បើធៀបនឹងទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០ ។

ការព្យាករណ៍លើក្រុមអាយុនេះ មានការពាក់ព័ន្ធយ៉ាងសំខាន់ចំពោះតំរូវការដីថ្មីក្នុងរយៈពេល ១០ឆ្នាំខាងមុខ ។ កំណើនដែលបានព្យាករណ៍លើក្រុមអាយុ២០-២៤ឆ្នាំ សំរាប់រហូតដល់ឆ្នាំ២០០៦ (ប្រហែល ៣៥០.០០០នាក់ថែមទៀត) អាចបង្កើតបាន ១៥០.០០០គ្រួសារថ្មីនៅជនបទដែលត្រូវការមានដីធ្លីដោយផ្ទាល់ ឬត្រូវរកការងារក្រៅកសិដ្ឋាន ។ តំរូវការដីដែលកើតពីក្រុមអាយុនេះ នឹងបូកបន្ថែមទៅលើតំរូវការដីរបស់ប្រជាជនអ្នកគ្មានដីក្នុងពេលបច្ចុប្បន្ន ។ម្យ៉ាងទៀត គឺមានតំរូវការយ៉ាងច្បាស់ដើម្បីបង្កើតការងារធ្វើឱ្យបានច្រើនសំដៅស្រូបយកប្រជាជននៅក្នុងក្រុមអាយុនេះ ជាពិសេសនៅតំបន់ជនបទ (Desbarats and Sik 2000) ។

## ១.២.៤ ទីផ្សារ និងទំហំដីតូច

កសិករដែលដាំដុះលើដីតូចៗ ពុំមានលទ្ធភាពប្រើធាតុចូលទំនើប ឬវិនិយោគលើដីរបស់ខ្លួនទេ ពីព្រោះគ្មានលទ្ធភាពទិញ និងគ្មានលក្ខណៈអំណោយផលខាងសេដ្ឋកិច្ចវិមាត្រដោយសារផ្ទៃដីតូចពេក។ ដូច្នេះហើយគេទទួលបានផលិតភាពទាបដែលមានផលប៉ះពាល់អវិជ្ជមានដល់ចំណូល ។ ម្យ៉ាងទៀត កសិដ្ឋានកាន់តែតូច គឺកាន់តែពិបាកធ្វើសមាហរណកម្មទៅក្នុងទីផ្សារនៅក្នុងលក្ខខណ្ឌធ្វើពាណិជ្ជកម្មបានស្មើភាពគ្នា ។

## ១.២.៥ ការរួមតូចនៃធនធានធម្មជាតិ

[១២] អុកស្វាមអង់គ្លេស បានស្រាវជ្រាវលើបញ្ហាផ្សេងៗនៃដីធ្លី នៅក្នុងគំរោងដីធ្លីនៅកម្ពុជា ។

យុទ្ធសាស្ត្ររកចិញ្ចឹមជីវិតឱ្យរស់រានតាមបែបប្រពៃណីប្រជាជនកម្ពុជា ស្ថិតនៅលើការធ្វើកសិកម្ម ដំណាំ ការនេសាទ និង ការប្រមូលផលព្រៃឈើ ។ គេប៉ាន់ស្មានថា ប្រហែល ៣/៤ នៃប្រូតេអ៊ីនបរិភោគដោយប្រជាជនកម្ពុជាទទួលបានពីត្រីទឹកសាប ។ បន្ថែមលើនេះ ព្រៃឈើផ្តល់អនុផលសំខាន់ៗច្រើនយ៉ាង ។ ដោយសារកំណើនភាពគ្មានដីធ្លី សព្វថ្ងៃអ្នកក្រីក្រកាន់តែពឹងផ្អែកលើធនធានទ្រព្យរួម ដូចជា ត្រី សត្វស្លាបទឹក ពស់ ចង្រិត និងបន្លែព្រៃ ។ ការពឹងផ្អែកនេះ បាននាំឱ្យមានការចាប់ត្រី និងការធ្វើអាជីវកម្មហួសហេតុ ជាពិសេសធនធានធម្មជាតិនៅតាមតំបន់ដែលពុំមានការហាមឃាត់ ។

ទន្ទឹមនេះ ឯកជននីយកម្មនៃធនធានទ្រព្យរួមតាំងពីដើមទសវត្សរ៍១៩៩០ តាមរយៈការផ្តល់សម្បទានព្រៃឈើ និងឡូត៍នេសាទដល់ក្រុមហ៊ុនឯកជន បានរួមចំណែកកាត់បន្ថយលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិរបស់អ្នកភូមិ ។ ទង្វើនេះបានកាត់បន្ថយចំណូលដែលប្រជាជនជនបទអាចទាញយកបានពីធនធានរួមថែមទៀត ។ ការបាត់បង់ធនធានត្រី និងព្រៃឈើ និងហាមឃាត់កាន់តែច្រើនលើលទ្ធភាពប្រើធនធានទាំងនេះបានធ្វើឱ្យភាពក្រីក្រ និងអសន្តិសុខស្បៀងនៅជនបទកាន់តែធ្ងន់ធ្ងរទៀត ។

ផលប៉ះពាលអាក្រក់នៃការថយចុះធនធានត្រី និងព្រៃឈើទៅលើសន្តិសុខស្បៀង និងការរកចិញ្ចឹមជីវិតនៃប្រជាជនមូលដ្ឋាន គឺធ្លាក់ធ្ងន់ធ្ងរទៅលើអ្នកក្រីក្រ និងងាយរងគ្រោះជាងគេ ដោយសារការពឹងផ្អែកលើធនធានទ្រព្យរួមមានកំរិតខ្ពស់ ។

និន្នាការស្របគ្នានៃភាពគ្មានដីធ្លី និងការថយចុះលទ្ធភាពប្រើប្រាស់ធនធានរួម បានគួបផ្សំគ្នាធ្វើឱ្យអសន្តិសុខស្បៀងកើនឡើង និងធ្វើឱ្យគ្រួសារនៅជនបទកាន់តែងាយរងគ្រោះចំពោះវិបត្តិផ្សេងៗ ។ និន្នាការនេះ ធ្វើឱ្យប្រជាជនវ័យក្មេងកាន់តែច្រើនឡើង គេគ្មានទ្រព្យផលិតកម្មអ្វីសោះ ក្រៅតែពីកំលាំងពលកម្មរបស់ខ្លួនផ្ទាល់ ។ ក្រៅពីការរួមចំណែកដោយផ្ទាល់បង្កើនភាពក្រីក្រនៅជនបទ និន្នាការនេះក៏ផលប៉ះពាល់ចំពោះស្ថិរភាពសង្គមដែរ ។ ផលវិបាកលេចធ្លោរជាងគេនៃអសន្តិសុខស្បៀងនៅជនបទ គឺកំណើនចំណាកស្រុកទាំងនៅក្នុងប្រទេស និងទៅក្រៅប្រទេស ។ កសិករកាន់តែច្រើនឡើងៗ (ជាពិសេស អ្នកមានដីធ្លីតិច មិនអាចទ្រទ្រង់តំរូវការក្នុងគ្រួសារបាន) បានចល័តខ្លួន ដើម្បីស្វែងរកដីមានជីជាតិ និងធំទូលាយជាងមុនហើយ ក្នុងដំណើរការនេះ ព្រៃឈើក៏ទទួលរងការគំរាមគំហែង ។ ម្យ៉ាងទៀត មានពលករចំណាកស្រុកពលកម្មកាន់តែច្រើន បានទៅស្វែងរកការងារមានប្រាក់កំរៃនៅក្នុងតំបន់ផ្សេងៗផងដែរ ទាំងនៅក្នុងប្រទេស និងទៅកាន់ប្រទេសថៃ ។

## ១.៣. ការសិក្សាពីការចិញ្ចឹមជីវិតនៅជនបទ និងដីធ្លី

បញ្ហាទាំងអស់ដូចលើកឡើងរួចមកហើយធ្វើឱ្យយើងយល់ច្បាស់លាស់ថា មានបញ្ហាចោទពិតមែនទាក់ទិននឹងការចិញ្ចឹមជីវិតនៅជនបទ និងដីធ្លី ។ វបសអ ជាអ្នកសង្កេតការណ៍យ៉ាងយកចិត្តទុកដាក់ពីស្ថានភាពជនបទ ដោយបានសិក្សាពីការចិញ្ចឹមជីវិតនៅជនបទអស់រយៈច្រើនឆ្នាំរហូតមកដល់ពេលនេះ ។ ការសិក្សានេះដែលបានរៀបចំឡើងនៅក្នុងឆ្នាំ២០០០ គឺជាការសិក្សាដ៏ល្អិតល្អន់មួយដែល វបសអ បានធ្វើលើដីធ្លី និងការប្រើប្រាស់ដីនៅកម្ពុជា ។

សព្វថ្ងៃនេះ ចំណេះដឹងពីបញ្ហាដីធ្លី និងការចិញ្ចឹមជីវិតនៅជនបទមានកង្វះខាតជាច្រើនខាងពតិមាន និងការយល់ដឹងលើទំហំ ហេតុផល និងដំណើរវិវត្តន៍នៃស្ថានភាព និងនិន្នាការបច្ចុប្បន្ន ។ ដូច្នេះការស្វែងយល់ពីស្ថានភាព និងនិន្នាការបច្ចុប្បន្ន គឺជាការចាំបាច់បំផុត ពីព្រោះវាអាចជួយផ្តល់អនុសាសន៍សំដៅសំរាលផលវិបាកនៃបញ្ហាបច្ចុប្បន្ន (ជាពិសេសបើបញ្ហាចេះតែបន្តកើនល្បឿន) និងជួយកំណត់ និងពង្រឹងនូវគោលនយោបាយដ៏សមស្របនានា ។ អន្តរាគមន៍បែបនេះមានសារៈសំខាន់បំផុត បើសិនកម្ពុជាចង់សំរេចឱ្យបាននូវកម្មវត្ថុអភិវឌ្ឍន៍របស់ខ្លួន ។

សំនួរស្រាវជ្រាវសំខាន់ៗដែលបានសិក្សាមានដូចតទៅ:

១) តើការបែងចែកការកាន់កាប់ដីនៅក្នុងតំបន់ផ្សេងៗមានចរិតយ៉ាងណា តើវិសមភាពក្នុងការបែងចែកដីធ្លី និងភាពគ្មានដីធ្លីមានទំហំប៉ុណ្ណា? តើមានហេតុផលអ្វីខ្លះដែលធ្វើឱ្យកសិករលក់ដី ឬបាត់បង់ដី? តើមានវិវាទ និងអសន្តិសុខក្នុងការកាន់កាប់ដីដែរឬទេ? ប្រសិនបើមាន តើមានវិបាកអ្វីខ្លះ?

២) តើលំនាំបច្ចុប្បន្ននៃប្រើប្រាស់ដីគិតតាមទំហំកសិដ្ឋាន និងទំហំដីកាន់កាប់មានលក្ខណៈយ៉ាងណា? តើមានទំនាក់ទំនងអ្វីរវាងទំហំកសិដ្ឋាន ផលិតភាព និងប្រាក់ចំណូលរកបានពីកសិដ្ឋានទំហំខុសៗគ្នាស្ថិតក្នុងតំបន់ខុសៗគ្នា និងមានរបបដាំដុះខុសៗគ្នា? តើកសិករដែលមានមធ្យោបាយខុសៗគ្នាអនុវត្តការដាំដុះដូចម្តេច (ឧ. តើកសិករភ្ជួរដីយ៉ាងដូចម្តេច និងប្រើធាតុចូលអ្វីខ្លះ)? តើកសិដ្ឋានទំហំខុសៗគ្នា នៅតាមតំបន់ខុសៗគ្នា ផ្តល់ចំណូលកំរិតណា?

៣) តើទីផ្សារឥណទានមានចរិតយ៉ាងដូចម្តេច? តើតំរូវការឥណទានមានញឹកញាប់ប៉ុណ្ណា តើកសិករប្រភេទណាត្រូវការឥណទាន និងត្រូវចំណាយសោហ៊ុយប៉ុន្មាន? តើមានគំលាតអ្វីទេនៅក្នុងលទ្ធភាពទទួលបានឥណទាន? តើឥណទានស្ថាប័នមានប្រយោជន៍ប៉ុណ្ណា?

៤) តើតាមដំណើរការបែបណាដែលប្រជាជននៅជនបទទាញយកស្បៀង និងផលិតផលផ្សេងទៀតពីធនធានរួមត្រី និងព្រៃឈើ) និងពីប្រភពចំណូលផ្សេងទៀត? ក្នុងពីរបីឆ្នាំចុងក្រោយនេះ តើមធ្យោបាយរកចិញ្ចឹមជីវិតមានការប្រែប្រួលអ្វីខ្លះ ជាពិសេសដោយលទ្ធភាពប្រើប្រាស់ធនធានទ្រព្យរួមបានប្រែប្រួលនោះ?

៥) តើកំណើនឯកជននីយកម្មលើធនធានទ្រព្យរួមមានផលប៉ះពាល់អ្វីខ្លះទៅលើបរិមាណ និងគុណភាពនៃផលិតផលទទួលបានពីនេសាទ និងព្រៃឈើ?

៦) តើមានកង្វះស្បៀងរ៉ាំរ៉ៃទេ ហើយកង្វះនេះមានលក្ខណៈរដូវកាលឬយ៉ាងណា? តើភាពក្រីក្រជនបទមានវិសមភាព និងមានកំរិតធ្ងន់ធ្ងរប៉ុណ្ណា? តើមានការផ្លាស់ប្តូរអ្វីខ្លះក្នុងជីវភាពប្រជាជនពីឆ្នាំ១៩៩៦-៩៧ ដល់ឆ្នាំ២០០១?

៧) តើទីផ្សារពលកម្មមានចរិតយ៉ាងដូចម្តេច? តើប្រាក់ឈ្នួលបច្ចុប្បន្នមានកំរិតប៉ុន្មាន តើមានប្រជាជនច្រើនប៉ុណ្ណាដែលទទួលបានការងារមានប្រាក់កំរៃ ទាំងនៅក្នុងស្រុក និងតាមរយៈចំណាកស្រុក?

៨) តើយុទ្ធសាស្ត្រសំរបសំរួលអ្វីខ្លះដែលគ្រួសារប្រភេទខុសៗគ្នាបានយកមកប្រើប្រាស់ ដើម្បីទប់ទល់នឹងវិបត្តិរួមទាំងការរកការងារធ្វើនៅក្រៅកសិដ្ឋាន និងការធ្វើចំណាកស្រុក?

កម្មវត្ថុចំបងនៃអង្កេតនេះ រួមមានការបូកសរុបពីស្ថានភាពបច្ចុប្បន្ន ការវាស់វែងលក្ខណៈរដូវកាលនៃសន្តិសុខស្បៀង ការប្រៀបធៀបស្ថានភាពសន្តិសុខស្បៀងនៅក្នុងតំបន់អេកូឡូស៊ីខុសៗគ្នា និងការវាយតំលៃការរួមចំណែក និងសារៈសំខាន់នៃធនធានរួមក្នុងការចិញ្ចឹមជីវិតនៅជនបទ ។ មានការពិនិត្យផងដែរពីទំនាក់ទំនងរវាងលទ្ធភាពប្រើប្រាស់ដី លទ្ធភាពប្រើប្រាស់ធនធានទ្រព្យរួម ឱកាសផ្សេងទៀតក្នុងការរកចំណូលនៅមូលដ្ឋាននិងសន្តិសុខស្បៀងនៅជនបទ ដោយពិនិត្យឡើងវិញលើ ៣ ភូមិដែល វបសអ បានធ្វើអង្កេតពីសន្តិសុខស្បៀងកាលពីឆ្នាំ១៩៩៦-៩៧ ។ មានបញ្ហាជាច្រើនត្រូវបានរាយការណ៍យ៉ាងលំអិតដោយប្រើវិធីសាស្ត្រគុណភាពនៅក្នុងការសិក្សាស្របគ្នាដែលបានបោះពុម្ពជាសៀវភៅ *ដីធ្លី ការចិញ្ចឹម ជីវិតតាមជនបទ និង សន្តិសុខស្បៀងនៅកម្ពុជា: គំហើញពីអង្កេតនៅមូលដ្ឋាន* (Sedara, Chan and Acharya, 2002) ។

ការសិក្សាបានធ្វើឡើងក្នុង ៩ភូមិ ដែលស្ថិតនៅតាមតំបន់មានអាកាសធាតុកសិកម្មខុសៗគ្នានៅកម្ពុជា ដូចជា តំបន់ឆ្នេរសមុទ្រ តំបន់ទន្លេសាប តំបន់វាលទំនាបទន្លេមេគង្គ និងតំបន់ខ្ពង់រាប ។ ទិន្នន័យបានប្រមូលដោយប្រើបញ្ជីសំនួរមានរចនាសម្ព័ន្ធជាក់លាក់ដោយបានសាកសួរតាមភូមិ និងតាមគ្រួសារ (មាន ១.០០៥គ្រួសារបានឆ្លើយសំភាសន៍) ។ ការប្រមូលទិន្នន័យធ្វើឡើងជាពីរដង ដើម្បីវាស់វែងការប្រែប្រួលសន្តិសុខស្បៀងតាមរដូវ ។

ជំពូកទី២ បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ និងឧទាហរណ៍លំអិតខ្លះៗ ។ ជំពូកទី៣ ពិនិត្យពីដំណើរការបែងចែកដីធ្លី និងភាពគ្មានដីធ្លី ។ ជំពូកទី៤ បង្ហាញលំអិតពីការប្រើប្រាស់ដីតាមរូបភាពផ្សេងគ្នា ។ ជំពូកទី៥ ពិនិត្យពីឥណទានស្ថាប័ន ។ ជំពូកទី៦ ពិនិត្យពីប្រភពចំណូលពីធនធានទ្រព្យរួម ដូចជាព្រៃឈើ និងការនេសាទ ជាបន្ថែមទៅលើរបរកសិកម្ម ។ ជំពូកទី៧ វាស់វែងពីកំរិតជីវភាព វិសមភាព និងបញ្ហាពាក់ព័ន្ធនឹងសន្តិសុខស្បៀង ។ ជំពូកទី៨ ពិនិត្យពីទីផ្សារពលកម្មនិងប្រាក់កំរៃ ។ ជំពូកទី៩ លើកពីវិបត្តិទាំងឡាយ និងសិក្សាពីយុទ្ធសាស្ត្រសំរាប់ទប់ទល់ផ្សេងៗដែលប្រជាជនជនបទប្រើប្រាស់រួមទាំងជំរើសក្នុងការរកការងារមានប្រាក់កំរៃ ។ ជំពូកទី១០ សន្និដ្ឋានដោយកត់សំគាល់ពីការប្តូររបបសេដ្ឋកិច្ចនៅជនបទកម្ពុជា នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។

# ជំពូកទី ២

# ភូមិគំរូតាង

## ២.១ ការជ្រើសរើសភូមិគំរូតាង

នៅឆ្នាំ១៩៩៦-៩៧ វិបសអ បានធ្វើអង្កេតគោល (benchmark survey) លើ ៣ភូមិ គឺភូមិព្រែកក្មេង ភូមិបាបោង និង ភូមិត្រពាំងប្រិយ ហើយលទ្ធផលអង្កេតនេះបានបោះពុម្ពជាឯកសារពិភាក្សា (Murshid: 1998) ។ ការសិក្សានេះ បានពិនិត្យឡើងវិញនូវភូមិទាំង៣នេះ និងមានថែមអង្កេតលើ ៦ភូមិផ្សេងទៀតនៅក្នុងគំរូតាង សរុបទាំងអស់មាន ៩ ភូមិ ។ មូលហេតុដែលភូមិទាំង ៩ បានជ្រើសរើសដើម្បីតំណាងឱ្យតំបន់អាកាសធាតុកសិកម្មទាំង៤ គឺជាប់ទាក់ទិននឹងទិដ្ឋភាពចំរុះច្រើនបែបនៃតំបន់នីមួយៗ ។ ជាដំបូងខេត្តត្រូវបានជ្រើសរើសដោយចៃដន្យ ។ នីតិវិធីជាក់លាក់សំរាប់ជ្រើសរើសភូមិទាំងនេះ គឺដំបូងពិគ្រោះជាមួយមន្ត្រីថ្នាក់ស្រុក និងខេត្ត និងសង្ខេបប្រាប់ពួកគេពីគំរូវការនៃគំរោង ។ បន្ទាប់មកមន្ត្រីទាំងនេះបានជួយកំណត់ឃុំ និងភូមិដែលអាចស៊ីគ្នាទៅនឹងលក្ខណៈវិនិច្ឆ័យជ្រើសរើសគំរូតាង (ពោលគឺលក្ខណៈអាកាសធាតុកសិកម្ម) ។ បន្ទាប់ពីជ្រើសរើសបាន ២-៣ភូមិ ដែលស្របតាមលក្ខណៈវិនិច្ឆ័យ ហើយក្រុមស្រាវជ្រាវបានចុះពិនិត្យផ្ទាល់តាមភូមិនីមួយៗ ។ ជាចុងក្រោយភូមិទាំង ៩ បានជ្រើសរើស ដោយផ្អែកលើការចុះវាយតំលៃដល់ទីកន្លែងផ្ទាល់ ។ មាន ៦ភូមិ ត្រូវបានធ្វើសង្កេតលំអិតតាមបែបគុណភាពនៅក្នុងអង្កេតស្របគ្នាជាមួយនឹងឯកសារដែលបានបោះផ្សាយជាឯកសារពិភាក្សាស្តីពី *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា: ទស្សនៈបានពីការអង្កេតតាមមូលដ្ឋាន* (Sedara, Chan and Acharya 2002) ។

ដោយហេតុថាគោលបំណងនៃការសិក្សានេះ គឺចង់បានពត៌មានក៏រិតភូមិ ដូច្នេះវិធីសាស្ត្រប្រើក្នុងគំរោងនេះ គឺធ្វើសំភាសន៍ឱ្យបានច្រើនគ្រួសារក្នុងភូមិនីមួយៗ ជាជាងពង្រាយគំរូតាងក្នុងភូមិច្រើន ។ លទ្ធភាពគ្របដណ្តប់មានក៏រិតទាបចំពោះភូមិធំៗ និងមានក៏រិតខ្ពស់ជាងចំពោះភូមិតូចៗ គឺវាមានសមាមាត្រពី ៣០-៩០% នៃគ្រួសារទាំងអស់នៅក្នុងភូមិ ។ ដូចបានបញ្ជាក់រួចហើយទិន្នន័យបានប្រមូលជាពីរលើកផ្សេងគ្នាគឺ លើកទី១ នៅខែមីនា/ឧសភា និងលើកទី២ ខែតុលា/វិច្ឆិកា ។ នៅលើកទី១ បានសួរអ្នកភូមិពីព្រឹត្តិការណ៍កើតមានចំពោះគាត់ ពីខែតុលាដល់មីនា (រដូវប្រាំងអាចខ្វះស្បៀង) ។ លើកទី២ សួរអ្នកភូមិពីព្រឹត្តិការណ៍ ពីខែមេសាដល់តុលា (រដូវវស្សាអាចមានអតិរេកស្បៀង) ។ ការពិពណ៌នាពីគំរូតាងមានចុះក្នុងតារាង២.១ ។

តំបន់វាលទំនាបទន្លេសាបជាដីមានជីជាតិល្អ ហើយប្រជាជនមានធ្វើស្រែច្រើនណាស់ ជាបន្ថែមទៅលើការនេសាទត្រីទឹកសាប ។ អ្នកភូមិតំបន់នេះជាច្រើន ក៏ធ្វើចំណាកស្រុកទៅប្រទេសថៃដើម្បីរកការងារមានប្រាក់កំរៃ ដើម្បីផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសារផងដែរ ។ ពួកគេត្រូវទាក់ទាញដោយប្រាក់កំរៃខ្ពស់ ហើយត្រូវរុញច្រានឱ្យចាកចេញភូមិដោយសារកំនើនប្រជាជនខ្ពស់ ។ ដូច្នេះ ភូមិក្រសាំងត្រូវបានជ្រើសរើសសំរាប់តំណាងភូមិនានាដែលមានពលករច្រើនធ្វើចំណាកស្រុកទៅថៃ ។ ក្នុងតំបន់នេះដែរ ភូមិអណ្តូងត្រាច ត្រូវបានជ្រើសរើសដើម្បីតំណាងភូមិនានា ដែលទទួលជនមាតុភូមិនិវត្តន៍មកពីជំរំតាមព្រំដែន បានបានន័យថាមានការតាំងទីលំនៅថ្មី និងការស្តារឡើងវិញយ៉ាងច្រើន ។ ភូមិខ្សាច់ជីរស់ តំណាងឱ្យភូមិដែលពឹងផ្អែកជាសំខាន់លើការនេសាទ និងដំណាំស្រូវឡើងទឹក និងជាភូមិដែលមានទិន្នផលស្រូវទាប ទោះបីលក្ខខណ្ឌអាកាសធាតុកសិកម្មអំណោយផលក្តី ។

វាលទំនាបទន្លេមេគង្គ គឺជាតំបន់តាំងលំនៅដ្ឋានរបស់ប្រជាជនកម្ពុជាជាងពាក់កណ្តាល ។ ក្នុងតំបន់នេះ មានការបង្កើត និងការប្រមូលផ្តុំភូមិករថ្មីយ៉ាងច្រើន (នគរូបនីយកម្ម) ថ្វីបើប្រជាជនប្រកបរបរនេសាទ និងកសិកម្មជាចំបងក៏ដោយ ។ ភូមិបាបោងនៅខេត្តព្រៃវែងត្រូវបានជ្រើសរើសសំរាប់តំណាងឱ្យភូមិផលិតស្រូវលើសតំរូវការ ។ ភូមិព្រែកក្មេងនៅខេត្តកណ្តាល ត្រូវបានជ្រើសរើសសំរាប់តំណាងឱ្យភូមិពឹងផ្អែកជាសំខាន់លើការនេសាទជាបន្ថែមលើការធ្វើកសិកម្មនៅរដូវប្រាំង ។ ភូមិទាំងពីរត្រូវបានអង្កេតនៅឆ្នាំ១៩៩៦-៩៧ ដូច្នេះមិនចាំបាច់ជ្រើសរើសទេ ។

ជាទូទៅ តំបន់ខ្ពង់រាបកំណត់ដោយផលិតភាពកសិកម្មទាប និងប្រជាជនតិច ប៉ុន្តែសំបូរដោយធនធានព្រៃឈើ ។ ដើម្បីស្វែងយល់ពីសន្តិសុខស្បៀងក្នុងតំបន់នេះ គេបានសិក្សាលំអិតលើ ៣ភូមិ ។ ភូមិដងក្តារនៅខេត្តកំពង់ធំ និងភូមិកញ្ជរនៅខេត្តក្រចេះ ត្រូវបានជ្រើសរើសមកតំណាងភូមិដែលពឹងផ្អែកជាចំបងលើធនធានព្រៃឈើ ។ ភូមិទី៣ គឺភូមិត្រពាំងប្រិយ នៅខេត្តកំពង់ស្ពឺ តំណាងឱ្យភូមិដែលពឹងផ្អែកលើការធ្វើចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះស្រាយជីវភាព ។

ភូមិកំពង់ត្នោតក្នុងខេត្តកំពត ត្រូវបានជ្រើសរើសសំរាប់តំណាងភូមិនៅតំបន់ឆ្នេរ ។ ការសិក្សានៅភូមិនេះ រំពឹងថានឹងបំផុសបញ្ហាទាក់ទិននឹងការនេសាទនៅតំបន់ឆ្នេរ និងសកម្មភាពផ្សេងៗដូចជាការធ្វើស្រែអំបិលជាដើម ។

**តារាង២.១ ពិពណ៌នាភូមិគំរូតាង**

| ភូមិ | ស្រុក | ខេត្ត | លក្ខណៈវិនិច្ឆ័យជ្រើសរើស |
|---|---|---|---|
| **ទំនាបទន្លេសាប** | | | |
| អណ្តូងត្រាច | សង្កែ | បាត់ដំបង | ធ្វើស្រូវវស្សាច្រើន នៅវាលលិចទឹកទន្លេសាប និងមានជនមាតុភូមិនិវត្តន៍តាំងទីលំនៅថ្មីច្រើន |
| ក្រសាំង | ថ្មគោល | បាត់ដំបង | ធ្វើស្រូវវស្សាច្រើន នៅវាលលិចទឹកទន្លេសាប និងមានចំណាកស្រុកខ្ពស់ |
| ខ្សាច់ជីរស់ | កំពង់ស្វាយ | កំពង់ធំ | ធ្វើស្រូវឡើងទឹក និងការនេសាទបន្ថែម នៅវាលលិចទឹកទន្លេសាប |
| **ទំនាបទន្លេមេគង្គ** | | | |
| ព្រែកក្មេង | ល្វាឯម | កណ្តាល | ធ្វើស្រូវប្រាំង និងធ្វើនេសាទច្រើនគួរកត់សំគាល់ |
| បាបោង | ពាមរក៏ | ព្រៃវែង | ធ្វើស្រូវប្រាំងច្រើនគួរកត់សំគាល់ |
| **តំបន់ខ្ពង់រាប** | | | |
| កញ្ជរ | ឆ្លូង | ក្រចេះ | ធ្វើស្រូវប្រាំង និងពឹងផ្អែកគួរកត់សំគាល់លើព្រៃឈើ |
| ដងក្តារ | សន្ទុក | កំពង់ធំ | ធ្វើស្រូវវស្សាទិន្នផលទាប និងពឹងផ្អែកគួរកត់សំគាល់លើព្រៃឈើ |
| ត្រពាំងប្រិយ | ឧត្តុង្គ | កំពង់ស្ពឺ | ស្រូវវស្សាទិន្នផលទាប និងពឹងផ្អែកលើការជួលពលកម្ម |
| **តំបន់ឆ្នេរ** | | | |
| កំពង់ត្នោត | កំពត | កំពត | ធ្វើស្រូវវស្សាទិន្នផលទាប និងនេសាទតាមឆ្នេរ និងធ្វើស្រែអំបិល |

## ២.២ ទំហំគំរូតាង

ជាមធ្យមប្រជាជនជិតដល់ ៣៥% ត្រូវបានអង្កេត (ឧបសម្ពន្ធ័១, តារាង១-៥: បង្ហាញលំអិតពីលក្ខណៈគំរូតាង) ។ ការជ្រើសរើសគ្រួសារតាមភូមិនានា បានធ្វើឡើងតាមរបៀបចៃដន្យ លើកលែងតែនៅភូមិត្រពាំងប្រិយដែលជាភូមិតូច និងដែលបានអង្កេតតាមបែបធ្វើជំរឿន ។ ទំហំគំរូតាងនៅភូមិនីមួយៗកំណត់ដោយវិធីយកគំរូតាងតាមកូតា ។

ក្នុងបរិបទកម្ពុជា ក្រៅពីភូមិត្រពាំងប្រិយមួយចេញ ភូមិឯទៀតជាភូមិធំដែលមានប្រជាជនជាមធ្យម (តាមជំរឿនឆ្នាំ១៩៩៨) ប្រហែល ៥៦០នាក់ (ឬ ១០០គ្រួសារ) ។ ជំរើសភូមិធំមានហេតុផលដូចតទៅ:

ក) ភូមិធំៗ មានទិដ្ឋភាពចំរុះច្រើន ដូច្នេះអាចបង្ហាញបានច្រើនពីលក្ខណៈផ្សេងៗនៃសង្គមក្នុងភូមិ ។

ខ) ភូមិធំៗហាក់ដូចជាកន្លែងស្រួលរស់នៅជាង ។ ភូមិបានរីកធំក្នុងកំរិតណាមួយដោយសារមានចំណាកស្រុកចូលច្រើន ។ ទន្ទឹមគ្នានេះដែរ ភូមិក៏អាចរក្សាបាននូវកំណើនធម្មជាតិនៃប្រជាជនក្នុងកំរិតខ្ពស់ ។

គ) ដូចបញ្ជាក់ហើយ មាន ៣ភូមិ (ក្នុងនេះ ២ភូមិជាភូមិធំ) បានធ្វើអង្កេតម្តងហើយកាលពីឆ្នាំ១៩៩៦-៩៧ ។

## ២.៣ ធនធានជាមូលដ្ឋាននៅក្នុងភូមិ

គេឃើញមានភាពខុសគ្នារវាងតំបន់នានា ទាំងខាងលក្ខណៈអំណោយផលពីធម្មជាតិ និងកំរិតជីវភាពរបស់ប្រជាជននៅតាមភូមិ ប៉ុន្តែភូមិទាំងអស់តែងខ្វះហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានមួយ ឬក៏ច្រើន ។ ឧទាហរណ៍ គ្មានភូមិណាមួយមានបណ្តាញសាធារណៈផ្គត់ផ្គង់អគ្គិសនីទេ ។ គ្រួសារធូរធារមួយចំនួនប្រើប្រាស់អាគុយ និងអ្នកឯទៀតប្រើប្រេងកាតសំរាប់ដុតបំភ្លឺ ។

**តារាង២.២ ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន**

| ភូមិ | ផ្លូវ | សាលារៀន | ការថែទាំសុខភាព |
|---|---|---|---|
| **ទំនាបទន្លេសាប** | | | |
| អណ្តូងត្រាច | ជាប់ផ្លូវជាតិលេខ៥ (ផ្លូវមិនល្អ) | បឋមសិក្សាក្នុងភូមិ, អត្រាចូលរៀន ៩៦% | គ្មានសេវាសាធារណៈ: មានពេទ្យឯកជនក្នុងភូមិ |
| ក្រសាំង | ជាប់ផ្លូវជាតិលេខ ៥ (ផ្លូវមិនល្អ) | បឋមសិក្សាចំងាយ ១គ.ម ពីភូមិ | មន្ទីរពេទ្យបង្អែកស្រុក ចំងាយ ៣គ.ម ពីភូមិ |
| ខ្សាច់ជីរស់ | គ្មានផ្លូវច្បាស់លាស់ (ទឹកលិច ៦ខែ ប្រើផ្លូវទឹកច្រើន) | បឋមសិក្សាមានពីរបន្ទប់ មានត្រឹមថ្នាក់ទី២ ចំងាយ៨គ.ម អត្រាចូលរៀន៥៤% | គ្មានសេវាសាធារណៈ: មានពេទ្យឯកជនក្នុងភូមិ |
| **ទំនាបទន្លេមេគង្គ** | | | |
| ព្រែកក្មេង | ផ្លូវដី (លិចទឹក៦ខែ) ចំនាយធ្វើដំណើរ ២ម៉ោងពីភ្នំពេញ | បឋមសិក្សា អត្រាចូលរៀន ៩០% | គ្មានសេវាសាធារណៈ: មានពេទ្យឯកជនក្នុងភូមិ |
| បាបោង | ជាប់ផ្លូវជាតិលេខ ៧ (ផ្លូវមិនល្អ) | សាលាបឋមសិក្សា ២ អត្រាចូលរៀន ៨០% | គ្មានសេវាសាធារណៈ: មានពេទ្យឯកជនក្នុងភូមិ |
| **តំបន់ខ្ពង់រាប** | | | |
| កញ្ជរ | តាមដងទន្លេមេគង្គ (ផ្លូវគោកពិបាក) | សាលារៀនជិតបំផុត ៣គ.ម អត្រាចូលរៀន ៨០% | គ្មានសេវាថែទាំសុខភាព |
| ដងក្តារ | ផ្លូវដីចំងាយ ៨០គ.ម ពីផ្លូវជាតិលេខ ៦ | បឋមសិក្សា ២បន្ទប់ ត្រឹមថ្នាក់ទី៣ (ភូមិវែង៨គ.ម) អត្រាចូលរៀន ៤៤% | គ្មានសេវាសាធារណៈ: មានពេទ្យឯកជនក្នុងភូមិ |
| ត្រពាំងប្រិយ | ផ្លូវដី ចំនាយធ្វើដំណើរ ២ម៉ោងពីភ្នំពេញ | គ្មានបឋម មានមតេយ្យ ១ សាលាជិតបំផុត ៤ គ.ម អត្រាចូលរៀនៈ មិនដឹង | គ្មានសេវាសាធារណៈ: មានពេទ្យឯកជនម្នាក់ក្នុងភូមិ |
| **តំបន់ឆ្នេរ** | | | |
| កំពង់ត្នោត | ជាប់ផ្លូវជាតិ ផ្លូវល្អ ចំនាយ ២០នាទីពីទីរួមខេត្តកំពត | មានបឋមសិក្សាក្នុងភូមិ អត្រាចូលរៀន ៧០% | គ្មានសេវាសាធារណៈ: មានពេទ្យឯកជន ២នាក់ក្នុងភូមិ |

## ២.៤ លក្ខណៈគ្រួសារ

### *២.៤.១ អាយុ ភេទ និងស្ថានភាពគ្រួសារ*

ជាងពាក់កណ្តាលនៃប្រជាជនក្នុងភូមិទាំង ៩ មានអាយុក្រោម ២០ឆ្នាំ ។ ក្រៅពីបាបោង ក្រុមកុមារដែលមានអាយុ ៩ឆ្នាំ ឬតិចជាងតំណាងឱ្យ ១/៤នៃប្រជាជន ឬច្រើនជាងនេះ ។ តាមការទស្សន៍ទាយប្រជាសាស្ត្រសំរាប់ជនម្នាក់ស្ថិតក្នុងក្រុមអាយុ

ធ្វើការងារ គឺមានមនុស្សលើសពីមួយនាក់ពឹងផ្អែកលើចំណូលរបស់ជននោះ ។ របាយអាយុដែលរីកធំខ្លាំងខាងក្រុមអាយុក្មេង (បានសង្កេតឃើញច្បាស់ក្នុងជំរឿនប្រជាជនដែរ) គឺជាមូលហេតុសំខាន់នាំឱ្យចំណូលក្នុងមនុស្សម្នាក់នៅតែទាប ។ ទន្ទឹមនេះ ក្រុមអាយុច្រើនៗ ដែលមានមនុស្សតិចនាក់ (ចាប់ពី ៤០ឆ្នាំឡើង និងជាពិសេសចាប់ពី ៥៥ឆ្នាំឡើង) បង្ហាញថា អាចមានក្មេងជាច្រើនដែលគ្មានឪពុកម្ដាយនៅរស់ ។ ទិន្នន័យនេះបង្ហាញដែរថា រយៈកាលបំពេញការងាររបស់មនុស្សពេញវ័យទាបជាងការរំពឹងទុកយ៉ាងច្រើន តាមធម្មតាចំនួន ៣៥-៤០ឆ្នាំ ដែលធ្វើឱ្យថយចុះចំណូលសរុបក្នុងមួយជីវិតនៃអ្នកធ្វើការ ។

ការវិភាគពីរបាយប្រជាជនតាមភេទ និងតាមភូមិ បង្ហាញថា ស្រីមានច្រើនជាងប្រុស ។ ភូមិខ្សាច់ជីរស់ខុសពីបទដ្ឋានធម្មតាបន្តិចដោយមានប្រុស ៥០,៨% និងស្រី ៤៩,២% ។ ដូច្នេះគំរូតាងឆ្លុះបញ្ចាំងពីរបាយភេទនៃទូទាំងប្រទេស បើពិនិត្យតាមជំរឿន និងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនានា ។

ទិន្នន័យប្រមូលបានក៏បង្ហាញផងដែរថា ប្រជាជនក្មេងៗរៀបការយឺតនៅគ្រប់ភូមិ ។ រឿងនេះហាក់ផ្ទុយគ្នានឹងប្រជាជនជនបទនៅក្នុងប្រទេសផ្សេងៗដែលមានការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចប្រហាក់ប្រហែលកម្ពុជា (យ៉ាងហោចណាស់ ក៏ក្នុង ៩ ភូមិនេះដែរ) ។ ទោះយ៉ាងនេះក្ដី អត្រាមានកូនសរុប គឺមានកំរិតខ្ពស់ ។ ម្យ៉ាងទៀត ស្រីមេម៉ាយ និងបុរសពោះម៉ាយមានចំនួនច្រើន គឺលើសពី ១/៤នៃប្រជាជនសរុប ។ ស្រីមេម៉ាយ និងបុរសពោះម៉ាយក្នុងក្រុមអាយុចាប់ពី ៤៦ឆ្នាំឡើងទៅ មានចំនួនភាគរយខ្ពស់ណាស់ ដែលច្បាស់ជាមតិកនៃសង្គ្រាមកន្លងមកហើយមើលទៅ ។

## ២.៤.២ រយៈពេលស្នាក់នៅ និងប្រភេទផ្ទះសំបែង

រយៈពេលស្នាក់នៅក្នុងភូមិរបស់អ្នកភូមិបច្ចុប្បន្នប្រែប្រួលខុសគ្នាយ៉ាងច្រើន ។ ឧទាហរណ៍ បើសិនជាយកឆ្នាំ១៩៨៩ ធ្វើជាខ្នាតវាស់ (១៩៨៩ ជាឆ្នាំដែលដីកសិកម្មត្រូវបានបែងចែកជាផ្លូវការ) គេឃើញថា គ្រួសារភាគច្រើនក្នុង ៨ភូមិ (គឺភូមិទាំង ៩ លើកលែងតែអណ្ដូងត្រាច) បានស្នាក់នៅក្នុងភូមិយូរជាងកាលពីឆ្នាំ១៩៨៩ ។ អណ្ដូងត្រាច ហាក់ដូចបានទទួលជនមាតុភូមិនិវត្តន៍ និងអ្នកតាំងលំនៅថ្មីច្រើន បន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩២ ។ ប៉ុន្តែ ទិន្នន័យនេះគួរប្រើប្រាស់ដោយប្រុងប្រយ័ត្ន ពីព្រោះការប្រៀបធៀបរយៈពេលស្នាក់នៅឆ្លងភូមិ អាចរងឥទ្ធិពលពីកត្តារបាយអាយុប្រជាជនក្នុងភូមិ ។

ទំហំរូបវ័ន្តនៃផ្ទះជាមធ្យមគឺ ១៦ម$^{២}$ នៅអណ្ដូងត្រាច និង ៤៨ម$^{២}$ នៅកញ្ជរ ប៉ុន្តែនិន្នាការកណ្ដាលគឺប្រហែល ៣០ម$^{២}$ ។ ហាក់ដូចគ្មានបន្សំអ្វីច្បាស់លាស់ទេ រវាងទំហំផ្ទះរូបវ័ន្ត និងអថេរផ្សេងៗទៀត ។ អ្វីដែលអាចសន្និដ្ឋាននៅពេលនេះ គឺអថេរជាច្រើនដូចជា លទ្ធភាពមានដីរយៈពេលដែលគ្រួសារមកតាំងលំនៅថ្មីលទ្ធភាពអាចទិញបាន... សុទ្ធតែមានតួនាទីសំខាន់ទាំងអស់ ។ ផ្ទះភាគច្រើនក្នុង ៩ភូមិ មានដំបូលប្រក់ស្បូវ បន្ទាប់មកគឺ ផ្ទះប្រក់ស័ង្កសី និងផ្ទះប្រក់ក្បឿង ។ មានតែភូមិក្រសាំងដែលមានផ្ទះថ្ម (ឥដ្ឋ និងស៊ីម៉ង់ត៍) ច្រើនគួរសម ។

## ២.៤.៣ ភាពចេះអក្សរ ការអប់រំ និង ការចូលរួមការងារ

ភាគរយនៃក្រុមអ្នកដែលមានអាយុចាប់ពី ៧ឆ្នាំឡើងទៅដែលមិនចេះអាន និងសរសេរមានចាប់ពី ២១% នៅភូមិកញ្ជរ ២៣% នៅបាបោង រហូតដល់ ៥២% នៅដងក្ដារ ។ នៅភូមិផ្សេងទៀត អ្នកមិនចេះអក្សរមានជាមធ្យម ៤០% ។ អ្នកចេះអក្សរភាគច្រើនគ្រាន់តែចេះអាន និងសរសេរប៉ុណ្ណោះ ដោយមានតិចនាក់ណាស់ដែលរៀនចប់បឋមសិក្សា និងមានរឹតតែតិចនាក់ទៀតដែលរៀនចប់ថ្នាក់ខ្ពស់ៗថែមទៀត ។

ក្នុងគំរូតាង ការចូលរួមក្នុងកំលាំងពលកម្មមានកំរិតខ្ពស់បើគិតជាតួលេខសុទ្ធ ទោះបីមានមនុស្សជាច្រើនស្ថិតក្រុមអាយុអាយុក្មេងៗក៏ដោយ ។ ការស្រាវជ្រាវបានបង្ហាញថា ជិតដល់ ៥០% នៃកុមារក្នុងអាយុ ១៣-១៧ឆ្នាំ បានចូលធ្វើការងារក្នុងរូបភាពណាមួយ ទោះបីពួកគេកំពុងសិក្សាក្ដី ។ ជំពូកទី៨ នឹងពិភាក្សាបញ្ហានេះយ៉ាងលំអិត ។

## ២.៥ សង្ខេប

ជំពូកនេះ ផ្តល់លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសគំរូតាងដែលត្រូវសិក្សាព្រមទាំងលក្ខណៈសំគាល់នៃគំរូតាង ។ ចំណុចផ្តោតនៃការស្រាវជ្រាវ គឺប្រមូលពតិមាននៅកំរិតភូមិ មិនមែនស្វែងរកលក្ខណៈតំណាងទូទាំងប្រទេសនោះទេ ។ ទោះយ៉ាងនេះក្តី គំរូតាងបង្ហាញលក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្រ ដូចធម្មតាដែលគេឃើញមានក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច និងជំរឿននានា ។ ដូច្នេះគ្រួសារទាំងនេះ គ្មានអ្វីពិសេសខុសពីជនបទកម្ពុជាធម្មតាៗទេ ។ ភាពស្រដៀងគ្នាច្រើនរវាងកំរងទិន្នន័យនេះ និងទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនានានៅចុងទសវត្សរ៍១៩៩០ ផ្តល់គំនិតថា លទ្ធផលមួយចំនួននៃអង្កេតនេះអាចមានតំលៃជាទូទៅសំរាប់ជនបទកម្ពុជាទាំងមូល ។

# ជំពូកទី ៣

# ដំណើរការទទួលបានដី និងភាពគ្មានដីធ្លី

បន្ទាប់ពីការធ្វើឯកជននីយកម្មដីធ្លី កសិករទទួលបានដីធ្លីតាមមធ្យោបាយច្រើនយ៉ាង ហើយភាគច្រើនអាចរកបានដីធ្លីមួយចំនួន ។ ប៉ុន្តែដោយដីធ្លីបានផ្លាស់ប្តូរម្ចាស់ច្រើនដង និងជារឿយៗ បានប្តូរម្ចាស់ច្រើនលើកក្នុងទសវត្សរ៍ចុងក្រោយ ដូច្នេះវាច្បាស់ជាមិនមែនទ្រព្យដែលមិនអាចផ្ទេរ និងលក់ដូរបានដូចដីធ្លីក្នុងសង្គមកសិកម្មខ្លះៗនោះទេ ។ ទីផ្សារដីធ្លីមានដំណើរការយ៉ាងសកម្ម ហើយទាំងកសិករ និងមិនមែនកសិករ បានចូលរួមក្នុងដំណើរការប្រមូលដីធ្លីយក និងលក់/ផ្ទេរចេញ ។ ជំពូកនេះនឹងពិនិត្យបញ្ហាដូចតទៅ:

១. តើកសិករទទួលបានដីកសិកម្មដោយរបៀបណា?

២. តើកសិករបាត់បង់ដីដោយរបៀបណា ហើយជាវិបាក តើភាពគ្មានដីធ្លីមានស្ថានភាពយ៉ាងណា?

៣. តើវិសមភាពនៃការបែងចែកដីធ្លីមានទំហំប៉ុណ្ណា?

៤. តើដីធ្លីមានសារៈសំខាន់ប៉ុណ្ណាក្នុងការកំណត់ក៏រិតជីវភាពប្រជាជន?

ជាដំបូង ជំពូកនេះនឹងបកស្រាយពីដំណើរដែលកសិករទទួលបានដីតាំងពីទសវត្សរ៍១៩៨០ ។ បន្ទាប់មកនឹងពិនិត្យពីបែបបទដែលកសិករមួយចំនួនបាត់បង់ដី និងការប្រមូលផ្តុំដីធ្លីដែលចាប់ផ្តើមចាក់ឫសក្នុងរបបទីផ្សារថ្មីនាទសវត្សរ៍១៩៩០ ។ ទំហំនៃភាពគ្មានដីធ្លីដែលជាលទ្ធផលនៃប្រតិបត្តិការទីផ្សារ ក៏ដូចជាសម្ពាធប្រជាសាស្ត្រ ត្រូវបានពិភាក្សាដោយពិនិត្យពីកត្តាតំរូវការ និងការផ្គត់ផ្គង់ ។ ជំពូកនេះពិនិត្យផងដែរពីទំហំនៃភាពគ្មានដីធ្លីនៅក្នុងបរិបទនៃការរកចំណូល និងក៏រិតជីវភាព ។

## ៣.១ ការទទួលបានដី ការលក់ដូរដី និងភាពគ្មានដីធ្លី

នៅទសវត្សរ៍១៩៨០ ដីធ្លីត្រូវបានបែងចែកឡើងវិញតាមបែបស្មើភាព ដល់គ្រួសារអ្នកជនបទ នៅតាមសហគមន៍នានាដែលកកើតរួចហើយ ។ ប៉ុន្តែ អ្នកដែលបន្តរស់នៅក្នុងជំរំតាមព្រំដែនរហូតដល់ឆ្នាំ/ដល់ក្រោយឆ្នាំ១៩៨៩ គឺមិនបានទទួលដីបែងចែកនេះគ្រប់គ្នាទេ ។ នៅដើមទសវត្សរ៍១៩៩០ បន្ទាប់ពីការលក់ដូរដីធ្លីត្រូវបានអនុញ្ញាត ភាពគ្មានដីកសិកម្មក្នុងជនបទកម្ពុជាមានប្រហែល ៥% (Williams 1999) ។ យោងតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (SES) ធ្វើនៅឆ្នាំ១៩៩៧ ភាពគ្មានដីធ្លីប្រហែល ១២% នៅឆ្នាំនោះ ។ យោងតាមអង្កេត (SES) ១៩៩៩ វាកើនដល់ ១៦% នៅឆ្នាំ១៩៩៩ គឺមានកំណើន ៤% ក្នុងរយៈពីរឆ្នាំ ។ បើសិនភាពគ្មានដីធ្លីកើន ២%/ឆ្នាំ (ដូចបានឃើញក្នុងសំណុំទិន្នន័យ SES ទាំងពីរ) ភាពគ្មានដីធ្លីនឹងកើនដល់ ២០% នៅឆ្នាំ២០០១ ។ ក្នុងភូមិគំរូតាងទាំង៩ ភាពគ្មានដីធ្លីមាន ២០% នៅឆ្នាំ២០០១ តែតួលេខនេះអាចជាការគាប់ជួនក៏ថាបាន ។

### *៣.១.១ ការទទួលបានដី*

មុនពេលពិនិត្យពីហេតុផលនៃភាពគ្មានដីធ្លី សំខាន់ត្រូវពិនិត្យមើលពីរបៀបដែលប្រជាជនចាប់យកដី បន្ទាប់ពីការបែងចែកដីឡើងវិញនៅទសវត្សរ៍១៩៨០ ។ ក្រាហ្វិក៣.១ បង្ហាញពីបន្សំមធ្យោបាយផ្សេងៗដែលគ្រួសារនៅជនបទប្រើប្រាស់ ដើម្បី

បានទទួលដីកសិកម្ម ។ ជាដំបូងគួរកត់សំគាល់ថា ទិន្នន័យក្នុងឯកសារនេះបង្ហាញនូវរបៀបដែលប្រជាជនទទួលបានដីដែលគេ *កំពុងកាន់កាប់* នៅពេលធ្វើអង្កេត ។ ពតិមានលំអិតស្តីពីដីដែលគេបានពុះចែក ឬលក់កាលពីមុន គឺមិនអាចដឹងទេ ។ ឧទាហរណ៍ នៅភូមិខ្លះមានប្រជាជនពីរ-បីគ្រួសារ ទទួលបានដីដោយការរានព្រៃលិចទឹក ។ បន្ទាប់មក ពួកគេលក់ដីទៅឱ្យអ្នកកាន់កាប់សព្វថ្ងៃដែលបានរាយការណ៍ថា ពួកគេទទួលបានដីដោយ *ការទិញ* ។ ដូច្នេះ ការរានព្រៃកាលពីមុនគ្មានរាយការណ៍ប្រាប់ទេ ។

ជាសរុបប្រហែល ៤៤% នៃដីដែលកាន់កាប់ដោយគ្រួសារក្នុងភូមិគំរូតាងបានទទួលដីពីការបែងចែកដីឡើងវិញនៅពាក់កណ្តាលទសវត្សរ៍១៩៨០ (ក្រាហ្វិក៣.១) ។ ដីប្រមាណ ១៦% ទៀតទទួលបានពីការរានព្រៃ ។ ជាមធ្យមគេឃើញថា ដីធ្លីប្រមាណ ៦០% ដែលកាន់កាប់ដោយគ្រួសារនៅឆ្នាំ២០០១ មិនទាន់បានផ្លាស់ប្តូរកម្មសិទ្ធិនៅឡើយ ឯចំពោះដីប្រមាណ ៤០% ដែលបានប្តូរម្ចាស់ថ្មី គឺមាន ២៤% តាមរយៈការផ្ទេរមតិក និង ១៦% តាមការទិញដូរ ។ ការផ្ទេរមតិកប្រហែលកើតចេញពីការពុះចែកដីតូចៗ ក្រោមសំពាធអត្រាកំណើនប្រជាជនខ្ពស់ក្នុង២ទសវត្សរ៍កន្លងទៅ ។ ការទិញដូរដីអាចមានន័យថា អ្នកលក់ដីអាចក្លាយជាអ្នកមានដីរួមតូច បន្ទាប់ពីគេបានលក់ដីខ្លះ ឬក៏ក្លាយជាអ្នកគ្មានដី បន្ទាប់ពីបានលក់ដីអស់[១៣] ។

**ក្រាហ្វិក៣.១ ប្រភេទនៃការទទួលបានដី (គិតតាមក៏រិតភាគរយនៃរបាយដីកសិកម្ម)**




នៅក្នុងភូមិដ៏ជាប់លាប់និងមានស្ថិរភាព ដូចជា ត្រពាំងប្រិយ និង កញ្ជរ ជាដើម អ្នកភូមិចាត់ទុកដីដែលខ្លួនកាន់កាប់សព្វថ្ងៃជាដីកេរ្តិ៍មតិក មិនមែនដីរដ្ឋចែកឱ្យទេ ។ រឿងនេះគឺដោយសារដីដែលពួកគេកាន់កាប់មុនឆ្នាំ១៩៧៥ ត្រូវបានបែងចែកឱ្យមកពួកគេវិញនៅទសវត្សរ៍១៩៨០ ។ ការទទួលបានដីតាមរយៈការទិញមានយ៉ាងច្រើននៅភូមិក្រសាំង និងព្រែកក្មេង ។ នៅភូមិទាំងនេះជាង ១/៣ នៃផ្ទៃដីកាន់កាប់នៅឆ្នាំ២០០១ គឺជាដីទិញពីគ្រួសារផ្សេង ហើយការផ្លាស់ប្តូរម្ចាស់យ៉ាងច្រើននេះ គឺជាមូលហេតុមួយនៃភាពគ្មានដីធ្លីនៅភូមិទាំងពីរ ។ នៅភូមិព្រែកក្មេង និងដងក្តារ ដីធ្លីជាង ១/៣ បានមកពីការរានដីសាធារណៈ ។ នៅដងក្តារគេកាប់រានព្រៃជុំវិញភូមិ ឯនៅព្រែកក្មេង គេកាប់រានព្រៃលិចទឹក ។

តារាង៣.១ បង្ហាញពីរបៀបទទួលបានដីតាមពេលវេលាខុសៗគ្នា ។ រដ្ឋបានបញ្ចប់ការបែងចែកដីនៅឆ្នាំ១៩៨៩ លើកលែងតែតំបន់ទន្លេសាបដែលដីធ្លី ១៥% ត្រូវបានរដ្ឋផ្តល់ឱ្យពីឆ្នាំ១៩៩០-២០០១ ។ តំបន់នេះបានទទួលជនភៀសខ្លួនយ៉ាងច្រើន

---

[១៣] គ្រួសារគ្មានដីសោះ គឺមានអ្នកដែលលក់ដីអស់ និងគ្រួសារថ្មីៗជាច្រើនដែលមិនបានទទួលដីមតិក និងដែលគ្មានមធ្យោបាយទិញដី ។

ហើយគ្រួសារខ្លះ រដ្ឋបានចែកដីឱ្យតាំងពីពេលត្រលប់មកដល់ភ្លាម ។ នៅតំបន់នានាដែលដីមានជីជាតិល្អដូចជា តំបន់ទន្លេសាប និងតំបន់វាលទំនាបមេគង្គជាដើម ការបន្តមតិក គឺជាវិធីឃើញមានច្រើនជាងគេក្នុងការទទួលបានដីរហូតមកទល់ពេលថ្មីៗនេះ ។ ផ្ទុយទៅវិញនៅតំបន់ខ្ពង់រាបដែលពុំសូវដីកសិកម្មមានគុណភាពខ្ពស់ទេនោះ គេឃើញមានតែ ១៤% នៃដីធ្លីសរុបប៉ុណ្ណោះដែលត្រូវបានផ្ទេរតាមរយៈការបន្តមតិកពីឆ្នាំ១៩៩៦-២០០១ ។

**តារាង៣.១. ភាគរយរបាយដីកសិកម្ម ធៀបនឹងដីកសិកម្មសរុប (គិតតាមឆ្នាំទទួលបានដី ដោយអ្នកកាន់កាប់ថ្មី)**

| តើដីទទួលបានរបៀបណា? | ពេលបានទទួលដី* | | | |
|---|---|---|---|---|
| | ត្រឹម ឬមុនឆ្នាំ១៩៨៩ | 1990 – 1995 | 1996 – 2001 | សរុប |
| **តំបន់ទន្លេសាប** | | | | |
| ផ្តល់ដោយរដ្ឋអំណាច | 84 | 8 | 7 | 100 |
| បន្តមតិក | 55 | 10 | 35 | 100 |
| ទិញ | 25 | 44 | 31 | 100 |
| ការរានដី | 64 | 19 | 17 | 100 |
| សរុប | 64 | 18 | 18 | 100 |
| **តំបន់ទន្លេមេគង្គ** | | | | |
| ផ្តល់ដោយរដ្ឋអំណាច | 99 | 1 | 1 | 100 |
| បន្តមតិក | 46 | 32 | 21 | 100 |
| ទិញ | 33 | 28 | 39 | 100 |
| កាប់រាន | 78 | 11 | 11 | 100 |
| សរុប | 75 | 12 | 13 | 100 |
| **តំបន់ខ្ពង់រាប** | | | | |
| ផ្តល់ដោយរដ្ឋអំណាច | 96 | 1 | 3 | 100 |
| បន្តមតិក | 72 | 14 | 14 | 100 |
| ទិញ | 44 | 15 | 42 | 100 |
| កាប់រាន | 30 | 10 | 59 | 100 |
| សរុប | 66 | 10 | 24 | 100 |
| **តំបន់ឆ្នេរ** | | | | |
| ផ្តល់ដោយរដ្ឋអំណាច | 99 | 0 | 1 | 100 |
| បន្តមតិក | 49 | 43 | 8 | 100 |
| ទិញ | 19 | 23 | 58 | 100 |
| កាប់រាន | 89 | 0 | 11 | 100 |
| សរុប | 82 | 9 | 9 | 100 |

** ភាគរយដីទទួលបានដោយម្ចាស់បច្ចុប្បន្ន ។*

នៅតំបន់ទន្លេសាប ដីធ្លីប្រហែល ១/៤ បានទិញនៅឆ្នាំ១៩៨៩ ឬមុននេះទៀត ។ នៅតំបន់ទន្លេមេគង្គ ដីប្រភេទនេះមាន ៣៣% នៅតំបន់ខ្ពង់រាបមាន ៤០% ឯនៅតំបន់មាត់ឆ្នេរមានតិចជាង គឺប្រហែល ១/៥ប៉ុណ្ណោះ ។ ការសិក្សាផ្សេងៗទៀត ក៏បានរាយការណ៍ជាទូទៅដែរពីការទិញលក់ដីយ៉ាងច្រើននៅក្នុងតំបន់ភាគច្រើនក្នុងប៉ុន្មានឆ្នាំកន្លងមក (Chan and Acharya 2002) ។ ដីភាគច្រើនបានមកពីការកាប់ឆ្ការព្រៃលិចទឹកគឺទទួលបាននៅមុនឆ្នាំ១៩៩០ នៅតំបន់ទន្លេសាបទន្លេមេគង្គ និងតំបន់ឆ្នេរ (ផ្ទុយគ្នាពីតំបន់ខ្ពង់រាប) ។ សម្ភាធកាប់រានព្រៃ (ព្រៃមិនលិចទឹក) មានកើតខ្ពស់នៅភូមិដងក្តារ និងកញ្ជរ ។

### *៣.១.២ ការលក់ដី*

តារាង៣.២ បង្ហាញពីទំហំនៃការលក់ដី ចាប់ពីឆ្នាំ១៩៨៩ នៅពេលមានកម្មសិទ្ធិឯកជនលើដីធ្លី និងការលក់ដី ត្រូវបានអនុញ្ញាតជាផ្លូវការ[១៤] ។ គិតជាសរុប ១២% នៃគ្រួសារទាំងអស់ដែលបានអង្កេត រាយការណ៍ថាបានលក់ដី ប៉ុន្តែពីតំបន់មួយទៅតំបន់មួយមានការខុសគ្នាគួរចាប់អារម្មណ៍ ។ សមាមាត្រខ្ពស់បំផុតនៃគ្រួសារបានលក់ដី ស្ថិតនៅតំបន់ទន្លេសាប (១៦%) នៅតំបន់ខ្ពង់រាបមាន ៨% និងនៅតំបន់ទន្លេមេគង្គ និងតំបន់ឆ្នេរមាន ១២-១៣% ។ ការលក់ដីកើតមានឡើងច្រើនបំផុតនៅភូមិក្រសាំងដែលមានគ្រួសារ ២៤% បានលក់ដី ។ នេះជាមូលហេតុមួយចំណែកដែលធ្វើឱ្យភូមិនេះមានភាពគ្មានដីកំរិតខ្ពស់ក្នុងលំដាប់ទី២ (បន្ទាប់ពីភូមិអណ្ដូងត្រាច) ។

**តារាង៣.២ ការលក់ដីចាប់ពីឆ្នាំ១៩៨៩**

| ភូមិ | ចំនួនភាគរយ គ្រួសារបានលក់ដី | ទំហំមធ្យមនៃដីលក់ (ហិកតារ) | គំលាតមធ្យម នៃទំហំដីលក់ |
|---|---|---|---|
| **វាលទំនាបទន្លេសាប** | | | |
| អណ្ដូងត្រាច | 12 | 1.17 | 0.53 |
| ក្រសាំង | 24 | 0.90 | 0.53 |
| ខ្សាច់ជីរស់ | 10 | 0.95 | 0.44 |
| **វាលទំនាបទន្លេមេគង្គ** | | | |
| ព្រែកក្មេង | 12 | 0.50 | 0.49 |
| បាបោង | 13 | 1.48 | 2.20 |
| **តំបន់ខ្ពង់រាប** | | | |
| កញ្ជរ | 6 | 0.10 | 0.06 |
| ដងក្ដារ | 9 | 0.24 | 0.14 |
| ត្រពាំងប្រិយ | 7 | 0.32 | 0.16 |
| **តំបន់ឆ្នេរ** | | | |
| កំពង់ត្នោត | 13 | 0.16 | 0.07 |
| **សរុប** | **12** | **0.66** | **0.82** |

*បញ្ជាក់: ដីលក់កត់ត្រាក្នុងតារាងនេះ មានទាំងដីលំនៅដ្ឋាន និងដីកសិកម្ម (តែភាគច្រើនជាដីកសិកម្ម) ។*

ដីធ្លីដែលបានលក់ ក៏មានទំហំខុសគ្នាពីតំបន់មួយទៅតំបន់មួយដែរ ។ នៅតំបន់ទន្លេសាប ទំហំដីមធ្យមដែលបានលក់ គឺប្រហែល ១ហិកតារ ធៀបនឹង ០,២ហិកតារនៅតំបន់ខ្ពង់រាប ។ ទំហំខុសគ្នានេះ ប្រហែលទាក់ទងនឹងផ្ទៃដីដាំដុះដែលមាននៅតាមតំបន់ទាំងនេះ ។ ទំហំមធ្យមធំបំផុតនៃដីលក់ ស្ថិតក្នុងភូមិបាបោងដែលសំបូរដីស្រែធំៗ ។ គេអាចនិយាយថា បាបោងមានលក្ខណៈដូច្នេះ ពីព្រោះភូមិនេះមានក្បាលដីធំជាងកន្លែងផ្សេងៗទៀត ។

ដោយហេតុថា ភាពគ្មានដីកសិកម្មកាន់តែចោទជាបញ្ហា មានការពិភាក្សាយ៉ាងទូលាយនៅកម្ពុជា ពីមូលហេតុដែលប្រជាកសិករលក់ដី ។ អុកស្វាមអង់គ្លេស បានធ្វើអង្កេតពីភាពគ្មានដីធីក្នុងជាង ១០០ភូមិ ហើយរកឃើញថា ប្រជាជន ៤៥% ដែលធ្លាប់មានដី ប៉ុន្តែក្រោយមកបានបាត់បង់ដី បានលក់ដីអស់ ដើម្បីដោះស្រាយចំណាយខ្ពស់ហួសហេតុលើការព្យាបាលជំងឺ ។ ថ្វីបើការសិក្សាបង្ហាញថា បញ្ហាសុខភាពមានចំណែកធំខ្លាំងណាស់នៅក្នុងភាពគ្មានដីធ្លីក៏ដោយ (Biddhulph 2000) ប៉ុន្តែគេក៏អាចឃើញដែរថា បញ្ហាសុខភាពមិនមែនជាមូលហេតុចំបងតែមួយនៃភាពគ្មានដីធ្លីទេ ។ ផ្ទុយទៅវិញគេរំកញ្ចែកថាគឺ *ភាពក្រីក្រ ឬកង្វះលទ្ធភាព* ក្នុងការបង់ថ្លៃចំណាយព្យាបាលជំងឺ ដែលបានបង្ខំអ្នកក្រឱ្យលក់ដីរបស់ខ្លួន (Chan, Tep and Acharya 2001) ។

[១៤] ដូចបានកត់សំគាល់ខាងលើ ដីមួយចំនួនបានទិញមុនឆ្នាំ១៩៨៩ ។ ប៉ុន្តែដោយសារអ្នកឆ្លើយសំភាសន៍ចងចាំមិនសូវច្បាស់ យើងបានយកឆ្នាំ ១៩៨៩ ធ្វើជាឆ្នាំគោល ។

ក្នុងអង្កេតនេះ អ្នកភូមិត្រូវបានសាកសួរពីមូលហេតុចំបងដែលគេលក់ដីខ្លះ ឬទាំងអស់ ។ ប្រហែល ៥០% នៃគ្រួសារដែលបានលក់ដីតាំងឆ្នាំ១៩៨៩ ឆ្លើយថា គេត្រូវការប្រាក់ដើម្បីព្យាបាលជំងឺក្នុងគ្រួសារ (តារាង៣.៣) ។ ក្នុងចំណោមគ្រួសារ (អ្នកលក់ដី) ៥០% ទៀត មាន ១២% បានលក់ដីដើម្បីសងបំណុលគេ ៩% លក់ដីដើម្បីធ្វើជំនួញ និង ៨% លក់ដីដើម្បីបំពេញតំរូវការចំណាយប្រើប្រាស់[១៥] ។

**តារាង៣.៣ មូលហេតុចំបងៗនៃការលក់ដី (គិតជាភាគរយនៃរបាយគ្រួសារដែលបានលក់ដី)**

| | ចំនួនគ្រួសារបានលក់ដី តាំងពីឆ្នាំ១៩៨៩ | ភាគរយគ្រួសារបានលក់ដី តាំងពីឆ្នាំ១៩៨៩ |
|---|---|---|
| បង់ថ្លៃព្យាបាលជំងឺ | 57 | 50 |
| សងបំណុល | 14 | 12 |
| ត្រូវការប្រាក់ធ្វើអាជីវកម្មផ្សេងទៀត | 10 | 9 |
| ត្រូវការប្រាក់ចំណាយប្រើប្រាស់ | 9 | 8 |
| សមាជិកគ្រួសារស្លាប់ | 7 | 6 |
| ធ្វើកសិកម្មមិនកើត ព្រោះដីតូចពេក | 4 | 3 |
| ធ្វើចំណាកស្រុកចេញពីភូមិ | 4 | 3 |
| ផ្លាស់ប្តូរមុខរបរ | 1 | 1 |
| ផ្សេងៗ | 9 | 8 |
| **សរុប** | **115** | **100** |

## *៣.១.៣ ភាពគ្មានដីធ្លី*

តារាង៣.៤ ផ្តល់ការប៉ាន់ស្មានលើភាពគ្មានដីធ្លី និងទំនាក់ទំនងរបស់វាជាមួយនឹងអថេរមួយចំនួន ។ តារាងនេះបង្ហាញថា គ្រួសារគ្មានដីលំនៅដ្ឋាន មានចំនួនច្រើននៅក្នុងភាគច្រើននៃភូមិទាំង ៩ ជាមធ្យមប្រហែល ១២% ។ ដូចមានបង្ហាញក្នុងអង្កេតនេះ គ្រួសារជាច្រើនជាពិសេសគ្រួសារកសាងថ្មីក្រោយឆ្នាំ១៩៨៩ គ្មានដីលំនៅដ្ឋានទេ ។ ហេតុផលលើកឡើងជារឿយៗពីរឿងគ្រួសារមួយចំនួនគ្មានដីសង់ផ្ទះ គឺពួកគេជាជនភៀសសឹក ឬជាគ្រួសារកកើតថ្មី ។ ការលក់ដីមិនមែនជាមូលហេតុចំបងទេ ។ ភាពគ្មានដីលំនៅដ្ឋាន គឺជាអាំងឌីកាទ័រដ៏សំខាន់មួយនៃភាពក្រីក្រ ។ អង្កេតនេះរកឃើញថា គ្រួសារទាំងឡាយដែលគ្មានដីលំនៅដ្ឋាន តែងក្រីក្រខ្លាំងជាងគ្រួសារអ្នកមានដីលំនៅដ្ឋាន ទាំងចំពោះទ្រព្យសកម្មផ្សេងទៀត និងប្រាក់ចំណូល ។

គិតជាសរុបលើភូមិទាំង៩ តារាងនេះបង្ហាញថា ២០% នៃគ្រួសារទាំងអស់គ្មានដីកសិកម្មទេ គឺមានតាំងពីអត្រាទាបត្រឹម ៧% នៅភូមិបាបោង និងដងក្តារ រហូតដល់ ៣៨-៣៩% នៅភូមិក្រសាំង និងអណ្តូងត្រាច ។ ភាពគ្មានដីកសិកម្មនៅភូមិព្រែកក្មេង (៣១%) និងកញ្ជរ (២៩%) គឺជាកំរិតខ្ពស់ខ្លាំងជាងមធ្យមភាគ ។

គេអាចលើកឡើងថា ទំហំនៃភាពគ្មានដីធ្លីផ្អែកលើថ្លៃដី ផលិតភាព និងលទ្ធភាពមានដី (កត្តាខាងតំរូវការ) ជាបន្ថែមទៅលើការលក់ដីដោះស្រាយចំណាយចាំបាច់បន្ទាន់ (កត្តាខាងការផ្គត់ផ្គង់) ។ ឧទាហរណ៍ កសិករអាចត្រូវទាក់ទាញដោយថ្លៃដីខ្ពស់ ដូច្នេះពួកគេលក់ដីដើម្បីដោះស្រាយតំរូវការប្រាក់ ។ ម្យ៉ាងទៀត បើសិនដីមានផលិតភាពល្អ គឺមានតំរូវការខ្ពស់ដែលធ្វើឱ្យវាឡើងថ្លៃ និងដែលក្លាយជាគ្រឿងជំរុញចិត្តឱ្យលក់ដី ។

[១៥] ឡូស៊ីកនៃការបាត់បង់ដីក្នុងមូលហេតុទីមួយៗដែលលើកឡើង អាចជាអសមត្ថភាពក្នុងការរក្សាទុកដី ដោយហេតុថាចំណូល (ពីដីធ្លី និងពីប្រភពផ្សេងទៀត) មានតិចតួចពេកសំរាប់សងថ្លៃថែទាំសុខភាព ឬសងបំណុល ឬដោះស្រាយតំរូវការប្រើប្រាស់ ។ ដូច្នេះ ការកើតមានចំណាយច្រើនពេកលើរឿងឈឺថ្កាត់ គឺជា*ដំណើរការ* ដ៏សំខាន់ ដែលតាមរយៈនេះ ដីធ្លីត្រូវបាត់បង់ ចំណូលរកមិនបានគ្រប់គ្រាន់អំពីដី និងប្រភពផ្សេងទៀត (ផ្ទុយពីចំណាយ) និងជាមូលហេតុយ៉ាងច្បាស់ ។ មតិអះអាងនេះនឹងមានបកស្រាយថែមនៅខាងក្រោយទៀត ។

តារាង៣.៤ បង្ហាញយ៉ាងច្បាស់ពីបន្សំជាវិជ្ជមានរវាងផលិតភាពដី និងថ្លៃដី ។ លើកលែងតែភូមិកំពង់ត្នោត (ដែលដីមានថ្លៃខ្ពស់ព្រោះនៅជិតឆ្នេរសមុទ្រ) ភូមិផ្សេងៗទៀតផ្តល់ភស្តុតាងថា ទិន្នផលស្រូវខ្ពស់តែងធ្វើឱ្យដីមានថ្លៃខ្ពស់ ។ ក្នុងភូមិនានានៅខេត្តបាត់ដំបង (អណ្តូងត្រាច និងក្រសាំង) ពូជស្រូវថ្លៃ និងពិសេសៗ គឺអាចដាំដុះបាន ដូច្នេះដីមានថ្លៃខ្ពស់ ។ ផ្ទុយទៅវិញដី ១ ហ.ត ដែលផ្តល់ទិន្នផល ១,៥តោនស្រូវធម្មតា អាចលក់បានថ្លៃ ៨០-២០០ដុល្លារ (ភូមិដងក្តារ ខ្សាច់ជីវស់ និងត្រពាំងប្រិយ) ។

**តារាង៣.៤ ភាពគ្មានដីធ្លី និងអថេរជាប់ទាក់ទង**

| ភូមិ | គ្មានដីលំនៅដ្ឋាន គិតជាភាគរយ | គ្មានដីកសិកម្ម គិតជាភាគរយ | ថ្លៃដីកសិកម្ម (ដុល្លារ/ហ.ត) | ទិន្នផលស្រូវ (តោន/ហ.ត) | លទ្ធភាពមានដីកសិកម្ម (ហ.ត/៥នាក់) |
|---|---|---|---|---|---|
| **វាលទំនាបទន្លេសាប** | | | | | |
| អណ្តូងត្រាច | 7 | 39 | 545 | 2.2 | 2.8 |
| ក្រសាំង | 18 | 38 | 619 | 2.0 | 0.9 |
| ខ្សាច់ជីវស់ | 17 | 9 | 89 | 1.5 | 1.9 |
| **វាលទំនាបទន្លេមេគង្គ** | | | | | |
| ព្រែកក្មេង | 17 | 31 | 292 | 3.5 | 0.8 |
| បាបោង | 6 | 7 | 480 | 3.3 | 1.4 |
| **តំបន់ខ្ពង់រាប** | | | | | |
| កញ្ជរ | 15 | 29 | 400 | 3.0 | 0.4 |
| ដងក្តារ | 5 | 7 | 128 | 1.6 | 0.5 |
| ត្រពាំងប្រិយ | 25 | 12 | 214 | 1.2 | 0.5 |
| **តំបន់ឆ្នេរ** | | | | | |
| កំពង់ត្នោត | 3 | 8 | 747 | 1.5 | 0.4 |
| សរុប | **12** | **20** | **390** | **2.2** | **1.2** |

តើដីមានផលិតភាពខ្ពស់មានន័យថាមានអតិរេកទីផ្សារ, មានកំរិតពាណិជ្ជកម្មខ្ពស់, និងដីមានថ្លៃខ្ពស់, ដែលជំរុញឱ្យគ្រួសារនានាលក់ដីឬយ៉ាងណា? មានបន្សំជាវិជ្ជមានរវាងអថេរទាំងបីគឺ ផលិតភាពដី ថ្លៃដី និងភាពគ្មានដីធ្លី នៅក្នុង ៧ភូមិ ក្នុងចំណោមភូមិទាំង ៩ ។ នៅភូមិអណ្តូងត្រាច ក្រសាំង ព្រែកក្មេង និងកញ្ជរ ដីមានថ្លៃខ្ពស់ ហើយមានភាពគ្មានដីធ្លី ក៏មានកំរិតខ្ពស់ (លើសពី ៣០%) ។ នៅភូមិខ្សាច់ជីវស់ និងត្រពាំងប្រិយ ទាំងថ្លៃដី និងផលិតភាពដី មានកំរិតទាប ហើយភាពគ្មានដីធ្លីក៏មានកំរិតទាប ។ ចំពោះភូមិគំរូតាងទាំង ៧ មេគុណសហសម្ព័ន្ធ (coefficient of correlation)[១៦] រវាងទំហំនៃភាពគ្មានដី និងផលិតភាពស្រូវគឺ ០,៦២ ឯមេគុណសហសម្ព័ន្ធរវាងទំហំនៃភាពគ្មានដី និងថ្លៃដី គឺស្មើនឹង ០,៩៣ ។

ទំនាក់ទំនងរវាងផលិតភាពដី ថ្លៃដី និងភាពគ្មានដីធ្លី មានភាពខុសគ្នានៅភូមិបាបោង និងកំពង់ត្នោត ។ នៅបាបោង ផលិតភាពស្រូវ និងថ្លៃដី គឺខ្ពស់ ចំណែកឯភាពគ្មានដីមានកំរិតទាបបំផុត (៧%) ។ អ្នកភូមិបាបោងពឹងផ្អែកស្ទើរតែទាំងស្រុងលើរបរធ្វើស្រែ ដូច្នេះដីគឺជាទ្រព្យដ៏ចាំបាច់ ហើយគ្រួសារភាគច្រើនព្យាយាមរក្សាវាទុក ។ កំពង់ត្នោត ជាភូមិតែមួយដែលអ្នកស្រុកសង់ផ្ទះនៅកណ្តាលដីកសិកម្មរបស់ខ្លួន ។ ដោយសារភាពគ្មានដីធ្លីធ្វើកសិកម្ម អាចធ្វើឱ្យគ្មានជំរកផងដែរ ដូច្នេះអ្នកស្រុកខិតខំរក្សាទុកដីមួយចំនួន ។

ទាក់ទិននឹងលទ្ធភាពមានដីកសិកម្មនៃគ្រួសារក្នុងភូមិនានា ទិន្នន័យបង្ហាញថា ទោះបីដីកសិកម្មត្រូវបានបែងចែកស្មើគ្នាក៏ដោយ ក៏គ្រួសារនីមួយៗអាចទទួលបានមិនលើសពី ២ហិកតារទេ ។ ដូច្នេះ ការផ្គត់ផ្គង់ដីក្នុងភូមិទាំងនេះមិនខ្ពស់ប៉ុន្មានទេ ។

[១៦] បើសិនមេគុណសហសម្ព័ន្ធ ស្មើនឹង ១ គឺបានន័យថា អថេរទាំងពីរដើរស្របគ្នាឥតខ្ចោះ (វិជ្ជមាន) ។

ទោះយ៉ាងនេះក្តី មានសញ្ញាមួយចំនួនបង្ហាញពីទំនាក់ទំនងរវាងលទ្ធភាពមានដី និងកំរិតនៃភាពគ្មានដី ។ លើកលែងតែនៅភូមិអណ្តូងត្រាចចេញ លទ្ធភាពមានដីតិចក្នុងមួយគ្រួសារ វាទាក់ទងនឹងភាពគ្មានដីធ្លីកំរិតខ្ពស់ (ភូមិក្រសាំង ព្រៃកក្អែង និងកញ្ជរ) ។ នៅភូមិខ្សាច់ជីរស់ និងបាបោង ដែលមានការផ្គត់ផ្គង់ដី/គ្រួសារកំរិតខ្ពស់ជាង ភាពគ្មានដីធ្លីក៏មានកំរិតទាបជាងដែរ ។ ចំពោះភូមិអណ្តូងត្រាចវិញ ការផ្គត់ផ្គង់ដីក្នុងភូមិមានកំរិតខ្ពស់ជាងគេ (២,៨ហ.ត/គ្រួសារ) ប៉ុន្តែភាពគ្មានដីក៏មានកំរិតខ្ពស់ជាងគេដែរ ។ ភូមិនេះត្រូវទទួលការតាំងទីលំនៅរបស់ ១០០គ្រួសារដែលវិលត្រឡប់ពីជំរំតាមព្រំប្រទល់ កាលពីដើមទសវត្សរ៍១៩៩០ គឺនៅពេលដែលដីធ្លីត្រូវបានបែងចែកចប់ហើយ ។ ជាវិបាក ការបែងចែកដីនៅភូមិនេះមានភាពមិនស្មើគ្នាខ្លាំង ។

ទំហំនៃភាពគ្មានដីធ្លីហាក់ដូចជាទាក់ទងនឹងជំរើសរបរចិញ្ចឹមជីវិតផ្សេងទៀត ។ នៅភូមិព្រៃកក្អែង អត្រាខ្ពស់នៃគ្រួសារគ្មានដី (៣១%) ហាក់ដូចមិនប៉ះពាល់ខ្លាំងដល់ការរកចិញ្ចឹមជីវិតទេ ពីព្រោះអ្នកភូមិពឹងផ្អែកជាសំខាន់លើការនេសាទ ។ ឧទាហរណ៍ប្រហែលគ្នាមួយទៀត គឺភូមិក្រសាំង (គ្រួសារគ្មានដី ៣៨%) ដែលចំណូលរកបានពីធនធានទ្រព្យរួម និងការធ្វើចំណាកស្រុកទៅថៃ តំណាងឱ្យមួយចំណែកយ៉ាងធំនៃចំណូលសរុប ។ ក្នុងភូមិទាំងពីរ ប្រជាជនអាចធ្វើការជ្រើសរើសថា តើគួររក្សាទុកដីឬទេ ជាពិសេសបើសិនដីតូចពេកមិនអាចចិញ្ចឹមខ្លួនបាន ។

តារាង៣.៥ បង្ហាញពីមូលហេតុដែលគ្រួសារនានាលើកឡើងថា បានធ្វើឱ្យពួកគេគ្មានដីធ្លី ។ ក្នុងចំណោមគ្រួសារគ្មានដីមាន ១៨% បានក្លាយជាអ្នកគ្មានដីដោយសារបានលក់ដីអស់ ៧% បានចែកដីឱ្យកូនចៅ ៣៨% មិនដែលមានដីសោះ (ភាគច្រើនគ្រួសារថ្មី) ៣៣% ជាជនមាតុភូមិនិវត្តន៍ ឬជនភៀសសឹក និង ៤% ដោយមូលហេតុផ្សេងទៀត ។

**តារាង៣.៥ មូលហេតុចំពោះការបាត់បង់ដីកសិកម្ម (គិតជាភាគរយនៃរបាយគ្រួសារ)**

| | លក់ដីអស់ | ចែកដីឱ្យកូន | មិនដែលមានដី | ជនមាតុភូមិនិវត្តន៍/ភៀសសឹក | មូលហេតុផ្សេងទៀត | សរុប |
|---|---|---|---|---|---|---|
| **វាលទំនាបទន្លេសាប** | | | | | | |
| អណ្តូងត្រាច | 6 | 0 | 0 | 94 | 0 | 100 |
| ក្រសាំង | 37 | 7 | 24 | 26 | 7 | 100 |
| ខ្សាច់ជីរស់ | 17 | 0 | 67 | 17 | 0 | 100 |
| **វាលទំនាបទន្លេមេគង្គ** | | | | | | |
| ព្រៃកក្អែង | 16 | 3 | 65 | 14 | 3 | 100 |
| បាបោង | 22 | 11 | 44 | 11 | 11 | 100 |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 3 | 9 | 65 | 18 | 6 | 100 |
| ដងក្តារ | 13 | 38 | 0 | 50 | 0 | 100 |
| ត្រពាំងប្រិយ | 38 | 13 | 13 | 25 | 13 | 100 |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 8 | 17 | 58 | 17 | 0 | 100 |
| **សរុប** | 18 | 7 | 38 | 33 | 4 | 100 |

ក្នុងចំណោមគ្រួសារគ្មានដី, មានសរុប ១៨% បានក្លាយជាអ្នកគ្មានដីដោយសារបានលក់ដីអស់ដែលស្មើនឹង ៤% នៃចំនួនគ្រួសារទាំងអស់ ។ តួលេខនេះមិនមែនមានន័យថា មានតែ ៤% នៃគ្រួសារទាំងអស់ប៉ុណ្ណោះដែលពាក់ព័ន្ធនឹងការលក់ដីនោះទេ ។ ជាក់ស្តែង ដូចមានបញ្ជាក់ក្នុងតារាង៣.២ ខាងលើ ប្រហែល ១២% នៃគ្រួសារក្នុងភូមិទាំង៩ បានលក់ដីចាប់តាំងពីឆ្នាំ១៩៨៩ ។ ពួកគេនៅតែជាអ្នកមានដី ពីព្រោះបានលក់ដីតែមួយចំណែក ឬបានទិញដីផ្សេងមកជំនួសដីលក់ ។

យ៉ាងហោចណាស់ ៧% នៃអ្នកគ្មានដីបានអស់ដីធ្លីដោយសារបានចែកដីទាំងអស់ឱ្យទៅសមាជិកគ្រួសារខ្លួន ។ គ្រួសារខ្លះបានចែកដីមួយចំណែកទៅឱ្យកូនខ្លួន (ពុះដីចែក) ។ ដូចបានជំរាបជូនខាងលើ ២៤% នៃអ្នកមានដីបានទទួលដីបច្ចុប្បន្នរបស់ខ្លួនតាមការបន្តមតិក ។ រីឯតួលេខ ៣៨% នៃអ្នកគ្មានដីដែលមិនធ្លាប់មានដីសោះ និងដែលភាគច្រើនជាគ្រួសារក្មេងៗ គឺបានបង្ហាញច្បាស់ពីសម្ពាធប្រជាសាស្ត្រយ៉ាងខ្ពស់លើដីធ្លី ។

នៅភូមិអណ្តូងត្រាច ស្ទើរគ្រប់គ្រួសារគ្មានដី គឺគ្មានដីដោយសារពួកគាត់ជាអ្នកតាំងលំនៅថ្មី ក្រោយត្រឡប់ពីជំរំតាមព្រំដែនមកវិញ ។ តាមពិត ពួកគាត់រាយការណ៍ថា បានទទួលដីពីរដ្ឋដែរ ប៉ុន្តែខ្លះមធ្យោបាយដាំដុះវា ។ គ្រួសារឯទៀតដែលមានមធ្យោបាយក៏បានទិញយកដីទាំងនេះពីជនមាតុភូមិនិវត្តន៍ ។

ស្ថានភាពប្រែប្រួលខុសគ្នាពីភូមិមួយទៅភូមិមួយ ទិន្នន័យបង្ហាញថា ៣៧% នៃគ្រួសារគ្មានដីនៅភូមិក្រសាំង និង ៣៨% នៅភូមិត្រពាំងប្រិយបានលក់ដីរបស់ខ្លួន ហើយក្លាយជាអ្នកគ្មានដី ។ នៅភូមិក្រសាំង ២៤% នៃគ្រួសារគ្មានដី គឺមិនធ្លាប់មានដីសោះ ហើយ ២៦% បានបាត់បង់ដីដោយការក្បៀសខ្លួន ។ នៅភូមិព្រែកក្មេង និងកញ្ជរដែលមានអត្រាគ្មានដីកើនខ្ពស់ ការ "មិនធ្លាប់មានដីសោះ" ជាមូលហេតុទូទៅជាងគេនៃគ្រួសារគ្មានដី ហើយឆ្លុះបញ្ចាំងពីភាពក្រខ្សត់ដីនៅភូមិទាំងនេះ ។ ក្នុងភូមិទាំង៩ មានតែ ៥គ្រួសារប៉ុណ្ណោះរាយការណ៍ថា បានបាត់បង់ដីដោយការរំលោភយកដីពីអ្នកផ្សេង (ឧបសម្ព័ន្ធ៣, តារាង១) ។ Chan និង Acharya (2002) រកឃើញថា គ្រួសារជាច្រើនបានពុះចែកដីរបស់ខ្លួន ហើយឥឡូវមានដីរួមតូច ។ ដោយប្រជាជនកើនក្នុងអត្រា ២,៥%/ឆ្នាំ ដូច្នេះការពុះចែកដី និងភាពគ្មានដី គឺមិនអាចជៀសរួចទេ បើសិនព្រំប្រទល់ដីវាមិនរីកធំ ។

ជាសន្និដ្ឋាន ប្រជាជនបាត់បង់ដី ឬក្លាយជាអ្នកគ្មានដីដោយមូលហេតុជាច្រើន ។ មូលហេតុទី១ គឺគ្រួសារជាច្រើនមិនអាចរក្សាទុកដីបាន ពីព្រោះមិនអាចរកចំណូលបានគ្រប់គ្រាន់ពីដីធ្លី ។ តំរូវការប្រាក់បន្ទាន់ ទាំងសំរាប់ចំណាយជាប្រចាំ និងចំណាយមិនបានដឹងមុន (ពិសេសជំងឺ) បានជំរុញឱ្យពួកគេលក់ដី ។ ទី២ ទំហំដីតូចដោយសារការពុះចែកបន្តបានកាត់បន្ថយផលប្រយោជន៍ដី ហើយជំរុញចិត្តប្រជាជនឱ្យលក់វាចេញ ។ ទី៣ ក្នុងករណីខ្លះម្ចាស់ដីត្រូវបានបញ្ចុះបញ្ចូលឱ្យលក់ដី ដោយអ្នកទិញហ៊ានឱ្យថ្លៃដីខ្ពស់ៗ ហើយពួកគេរំពៃរករបរចិញ្ចឹមជីវិតផ្សេងទៀត ។ ទី៤ អ្នកគ្មានដីខ្លះទៀត គឺមកពីពួកគេមិនធ្លាប់មានដីកាន់កាប់សោះ ។

## ៣.២ ទំនាស់ដីធ្លី

ក្នុងភូមិគំរូតាងទាំង៩ មានតែ ៦% នៃគ្រួសារប្រជាជនប៉ុណ្ណោះដែលធ្លាប់មានទំនាស់ដីម្តង ឬច្រើនដងចាប់តាំងពីឆ្នាំ ១៩៨៩ (តារាង៣.៦) ។ ក្នុងការសិក្សានេះ ទំនាស់ដីធ្លីហាក់ដូចពុំមានច្រើនណាស់ណាទេ ។ នៅភូមិក្រសាំង គ្មានវិវាទដីធ្លីទេ ។ នៅភូមិត្រពាំងប្រិយ មានតែមួយគ្រួសារគត់ដែលធ្លាប់មានទំនាស់ដីធ្លី ។ ភូមិបាបោងដែលជាភូមិធំជាងគេ ក៏មានគ្រួសារច្រើនជាងគេដែរ (១៣% ឬ ១៦គ្រួសារ) ដែលធ្លាប់មានទំនាស់ដីធ្លី ក្នុងនេះ ៧គ្រួសារមានទំនាស់ទាក់ទងនឹងដីកសិកម្ម ។ ជាទូទៅទំនាស់ភាគច្រើនកើតមានលើដីលំនៅដ្ឋាន លើកលែងតែនៅភូមិអណ្តូងត្រាច និងខ្សាច់ជីរស់ ។ នៅភូមិអណ្តូងត្រាច ៤% នៃគ្រួសារអ្នកភូមិមានទំនាស់ដីធ្លីទាក់ទងនឹងដីកសិកម្ម ឯនៅភូមិខ្សាច់ជីរស់មាន ៨ទំនាស់ ក្នុងនេះ ៦ទំនាស់ទាក់ទងនឹងដីកសិកម្ម ។

ចំពោះគំរូតាងទាំងមូល (សូមអានឧបសម្ព័ន្ធ២, តារាង១, ២, និង៣) ទំនាស់ច្រើនបំផុតទាក់ទងនឹងព្រំប្រទល់ដី (២៦គ្រួសារ) បន្ទាប់មក គឺទំនាស់ដីធ្លីជាមួយសាច់ញាតិ និងមិនមែនសាច់ញាតិ (១៥គ្រួសារ ក្នុងមួយប្រភេទៗ) ។ មានតែគ្រួសារមួយគត់ដែលមានទំនាស់ដោយការរំលោភយកដីពីសំណាក់ទាហាន ឬមន្ត្រីមានអំណាច ហើយមាន ៤គ្រួសារ បានរាយការណ៍ថា ត្រូវរដ្ឋអំណាចរំលោភយកដី[១៧] (មានមួយៗករណីនៅភូមិអណ្តូងត្រាច ខ្សាច់ជីរស់ ព្រែកក្មេង កញ្ជរ បាបោង ដែល

[១៧] រដ្ឋអំណាចត្រូវគេចាត់ទុកថា ក្រៅពីទាហាន និងអ្នកមានអំណាច តាមចំណាត់ថ្នាក់ពីមុនដែលជារដ្ឋអំណាចស៊ីវិល និងក្រោយមកជាចំណាត់ថ្នាក់យោធា ។

មានទំនាស់ច្រើនបំផុត ទំនាស់ភាគច្រើនពាក់ព័ន្ធនឹងព្រំដី ហើយគ្មានការរាយការណ៍ពីករណីទំនាស់ជាមួយអាជ្ញាធរ យោធា ឬ មន្ត្រីមានអំណាចទេ ។

ចំនួនទំនាស់ដីធ្លីដែលបានដោះស្រាយ និងដែលមិនបានដោះស្រាយក៏បានពិនិត្យសិក្សាដែរ ។ ក្នុងចំណោមគ្រួសារទាំងអស់ដែលមានទំនាស់ដីធ្លី, មាន ២០គ្រួសារ (៣១%) មិនទាន់ដោះស្រាយរួចទេ, ១៦គ្រួសារ (២៥%) បានដោះស្រាយទំនាស់តាមការសំរុះសំរួលគ្នា, ២១គ្រួសារទៀត (៣៣%) បានដោះស្រាយរួចនៅកំរិតឃុំ, និង ២គ្រួសារបានទទួលសេចក្តីសំរេចរបស់តុលាការខេត្តនៅលើទំនាស់របស់ខ្លួន (កំពង់ត្នោត) ។

**តារាង៣.៦ វត្តមានទំនាស់ដីធ្លី និងប្រភេទដីមានទំនាស់**

| | ភាគរយគ្រួសារ ធ្លាប់មានទំនាស់ដី | ប្រភេទដីមានទំនាស់ | | |
|---|---|---|---|---|
| | | លំនៅដ្ឋាន | កសិកម្ម | សរុប |
| **វាលទំនាបទន្លេសាប** | | | | |
| អណ្តូងត្រាច | 4 | - | 3 | 3 |
| ក្រសាំង | 0 | - | - | - |
| ខ្សាច់ជីរស់ | 8 | 3 | 6 | 9 |
| **វាលទំនាបទន្លេមេគង្គ** | | | | |
| ព្រៃកក្ដេង | 8 | 9 | 1 | 10 |
| បាបោង | 13 | 9 | 7 | 16 |
| **តំបន់ខ្ពង់រាប** | | | | |
| កញ្ជរ | 9 | 8 | 3 | 11 |
| ដងក្តារ | 8 | 7 | 3 | 10 |
| ត្រពាំងប្រិយ | 1 | - | 1 | 1 |
| **តំបន់ឆ្នេរ** | | | | |
| កំពង់ត្នោត | 3 | 3 | 1 | 4 |
| **សរុប** | 6 | 39 | 25 | 64 |

ក្នុងចំណោមគ្រួសារដែលបានដោះស្រាយទំនាស់រួច មាន ៣៩គ្រួសារ (៦០%) មិនបានបាត់បង់ដីអ្វីទេ, ២០គ្រួសារ (៣២%) បាត់បង់ដីខ្លះ និង ៥គ្រួសារ (៨%) បាត់បង់ដីទាំងអស់ ។

## ៣.៣ របាយការណ៍កាន់កាប់ដីកសិកម្ម

តារាង៣.៧ បង្ហាញពីរបាយគ្រួសារមានដីកសិកម្មគិតតាមទំហំដី (ឬគ្មានដី) និងវិសមភាពនៃការកាន់កាប់ដី ។ គិតសរុបទាំង ៩ភូមិ មាន ២០% ជាគ្រួសារគ្មានដី ២៥% មានដី ០,៥ហ.ត ឬតិចជាង ២០% មានដី ០,៥-១,០ហ.ត ២០% មានដី ១-២ហ.ត និង ១០% មានដីច្រើនជាង ៣ហ.ត ។ គ្រួសារមានដីកាន់កាប់ ០,៥ហ.ត ឬតិចជាង បានចាត់ជា "អ្នកជិតគ្មានដី" ។ ដូចមានពិភាក្សានៅខាងក្រោម ក្រុមនេះមានស្ថានភាពប្រាក់ចំណូលមិនបានល្អជាងអ្នកគ្មានដីទេ តាមពិតពួកគេរកចំណូលបានតិចជាងអ្នកគ្មានដីទៅទៀត ។ ដូច្នេះគឺមាន គ្រួសារ ៤៥% (ជិតពាក់កណ្តាល) ជាអ្នកគ្មានដី ឬជិតគ្មានដី ។ ចំនួនអ្នកគ្មានដី និងអ្នកជិតគ្មានដីនេះ វាជាមូលហេតុដែលមានគ្រួសារយ៉ាងច្រើនពឹងផ្អែកលើប្រភពចំណូលមិនមែនកសិកម្មនៅតំបន់ជនបទ គឺផ្ទុយពីទស្សនៈជាទូទៅដែលថា ប្រជាជននៅជនបទកម្ពុជាស្ទើរតែទាំងអស់ គឺជាកសិករ ។ ទស្សនៈនេះនឹងមានពិភាក្សាបន្ថែមនៅជំពូកទី៥ និង ៨ ។

**តារាង៣.៧ ការកាន់កាប់ដីកសិកម្ម (គិតតាម % នៃការបែងចែកតាមគ្រួសារ)**

| | គ្មានដី | >0-0.5ha | >0.5–1ha | >1–3ha | >3 ha | សរុប | មធ្យម/គ្រួសារ (ហ.ត)[១] | មេគុណGini នៃកម្មសិទ្ធិ |
|---|---|---|---|---|---|---|---|---|
| | គិតជាភាគរយ | | | | | | | |
| **វាលទំនាបទន្លេសាប** | | | | | | | | |
| អណ្តូងត្រាច | 39 | 7 | 13 | 31 | 11 | 100 | 2.3 | 0.63 |
| ក្រសាំង | 38 | 12 | 13 | 23 | 14 | 100 | 2.3 | 0.65 |
| ខ្សាច់ជីរស់ | 9 | 12 | 14 | 36 | 29 | 100 | 2.8 | 0.51 |
| **វាលទំនាបទន្លេមេគង្គ** | | | | | | | | |
| ព្រែកក្មេង | 31 | 19 | 22 | 20 | 8 | 100 | 1.4 | 0.65 |
| បាបោង | 7 | 12 | 17 | 54 | 9 | 100 | 1.8 | 0.41 |
| **តំបន់ខ្ពង់រាប** | | | | | | | | |
| កញ្ជរ | 29 | 32 | 20 | 15 | 4 | 100 | 1.1 | 0.69 |
| ដងក្តារ | 7 | 46 | 27 | 19 | 0 | 100 | 0.8 | 0.49 |
| ត្រពាំងប្រិយ | 12 | 38 | 28 | 21 | 1 | 100 | 0.9 | 0.45 |
| **តំបន់ឆ្នេរ** | | | | | | | | |
| កំពង់ត្នោត | 8 | 51 | 31 | 8 | 2 | 100 | 0.7 | 0.47 |
| **សរុប** | 20 | 25 | 20 | 25 | 10 | 100 | 1.5 | 0.57 |

[១] *ទំហំដីមធ្យមក្នុងមួយគ្រួសារ គិតក្នុងចំណោមអ្នកមានដី ។*

ក្នុងចំណោមតំបន់អាកាសធាតុកសិកម្មទាំងបួន តំបន់ទន្លេសាប មានវិសមភាពដីធ្លីកាន់កាប់ខ្ពស់ជាងគេ ។ ភូមិអណ្តូងត្រាច និងក្រសាំង មានចំនួនភាគរយខ្ពស់បំផុតនៃគ្រួសារគ្មានដី ហើយមានសមាមាត្រខ្ពស់ច្រើននៃគ្រួសារកាន់កាប់ដីច្រើនជាង ៣ហ.ត ។ មេគុណ Gini នៃវិសមភាពបែងចែកដីនៅភូមិទាំងពីរគឺ ០,៦៣ និង ០,៦៥ រៀង១គ្នា គឺខ្ពស់ជាងមធ្យមភាគក្នុងគំរូតាង ។ ទំហំដីជាមធ្យមនៅភូមិទាំងពីរគឺ ២,៣ហ.ត ដែលធំជាងទំហំដីជាមធ្យមគិតលើភូមិទាំងអស់ ។ ខ្សាច់ជីរស់ ដែលជាភូមិមួយទៀតក្នុងតំបន់ទន្លេសាបដែរ មានប្រជាជន ២៩% ជាគ្រួសារមានដីកសិកម្មច្រើនជាង ៣ហ.ត ជាសមាមាត្រខ្ពស់ជាងគេខ្លាំងណាស់នៅក្នុងគំរូតាង ។ ចំណែកទំហំដីកាន់កាប់ជាមធ្យមក្នុងមួយគ្រួសារគឺ ២,៨ហ.ត ដែលជាតួលេខខ្ពស់បំផុតក្នុងចំណោមភូមិទាំង៩ ។ ប៉ុន្តែមេគុណ Gini នៃការបែងចែកដីនៅភូមិនេះ គឺ ០,៥១ ដែលទាបជាងមេគុណមធ្យមក្នុងគំរូតាង ។ ទិន្នន័យនេះឆ្លុះបញ្ចាំងពីភាពសំបូរដីនៅភូមិដាច់ស្រយាលនេះ ។

នៅតំបន់វាលទំនាបទន្លេមេគង្គ ភូមិទាំងពីរបង្ហាញពីលំនាំផ្ទុយគ្នានៃកម្មសិទ្ធិដីធ្លី ។ នៅភូមិនេសាទព្រែកក្មេងភាគច្រើននៃគ្រួសារម្ចាស់ដី មានដីមិនលើសពី ១ហ.តទេ ។ ដោយអ្នកគ្មានដីធ្លីមានច្រើនគួរកត់សំគាល់ មេគុណ Gini ឡើងខ្ពស់ដល់ ០,៦៥ សំរាប់ភូមិនេះ ។ អ្នកមានដីច្រើនជាង ៣ហ.ត មានតិចគ្រួសារទេ ហើយទំហំដីកាន់កាប់ជាមធ្យមក្នុងមួយគ្រួសារគឺ ១,៤ហ.ត ។ ផ្ទុយទៅវិញ ភូមិបាបោងមានសមភាពខ្ពស់ក្នុងការបែងចែកដីធ្លី ដោយមានមេគុណ Gini ទាបបំផុត (០,៤១) ក្នុងគំរូតាង[១៨] ។ តំបន់ខ្ពង់រាប និងតំបន់មាត់ឆ្នេរ បើប្រៀបធៀបជាមួយតំបន់ផ្សេងទៀតឃើញថា ដីកសិកម្មមិនសូវមានច្រើនទេ ប៉ុន្តែការបែងចែកដីកាន់កាប់មានសមភាពល្អជាង លើកលែងតែនៅភូមិកញ្ជរ ដែលមានមេគុណ Gini ស្មើនឹង ០,៦៩ ។

[១៨] មេគុណ Gini អាចមានតំលៃតូចជាងនេះ បើសិនអ្នកគ្មានដីមានចំនួនតិច ទោះបីវិសមភាពដីធ្លីមានកំរិតខ្ពស់ក៏ដោយ ។ ដូច្នេះមិនគួរពឹងផ្អែកតែលើតំលៃមេគុណ Gini មួយមុខគត់នោះទេ ។

ក្នុង ២ភូមិ (ដងក្តារ និងកំពង់ត្នោត) ទោះបីភាពគ្មានដីធ្លីមិនខ្ពស់ខ្លាំងក្តី ប៉ុន្តែគ្រួសារម្ចាស់ដីមានដីកាន់កាប់ជាមធ្យម តិចជាង ១ហ.ត/គ្រួសារ ក្នុងនេះប្រហែលពាក់កណ្តាលមានដីត្រឹមតែ 0,៥ហ.ត ឬតិចជាង ។ វត្តមានអ្នកជិតគ្មានដីមានកំរិតខ្ពស់ក្នុងភូមិទាំងនេះ ។ មេគុណវិសមភាពនៅក្នុងភូមិនីមួយៗគឺ តិចជាង 0,៥ ដែលទាបច្រើនជាងកំរិតមធ្យម ។

ក្រាហ្វិក៣.២ គឺ Lorenz Curve នៃវិសមភាពដែលបង្ហាញថាតើការបែងចែកដីមិនស្មើគ្នាយ៉ាងណានៅក្នុងភូមិទាំង៩ ។ នៅចុងម្ខាងគឺ គ្រួសារ ២0% គ្មានដីសោះ ប៉ុន្តែ គ្រួសារ ២0% នៅលើគេ មានដីដល់ទៅ ៦0% ។ គិតឱ្យលំអិតជាងនេះទៀតគឺ គ្រួសារ ១0% ខាងលើ គេមានដីដល់ទៅ ៤0% ចំណែកឯគ្រួសារ ៥0% ខាងក្រោម មានដីត្រឹមតែ ១0% ប៉ុណ្ណោះ ។ ដូច្នេះ វិសមភាពដីធ្លីមានកំរិតខ្ពស់ ។ ថ្វីបើនៅកម្ពុជាគ្មានអ្នកមានទ្រព្យសម្បត្តិបែបសក្តិភូមិដូចនៅតំបន់ផ្សេងទៀតនៃពិភពលោកក្តី ក៏ប្រព័ន្ធកសិកម្មកម្ពុជាច្បាស់ជាធ្លាក់យ៉ាប់យ៉ឺនមិនខាន បើសិនវិសមភាពកម្មសិទ្ធិដីធ្លីកើនឡើង ។

**ក្រាហ្វិក៣.២ Lorenz Curve នៃការកាន់កាប់ដីកសិកម្ម**




## ៣.៤ ការជួលដីធ្លី

មានកត្តាជាច្រើនដែលបង្កឡើងនូវការជួលដីធ្លី ។ ការជួលដីធ្លីអាចជាជំរើសមួយប្រើដោយអ្នកគ្មានដី ឬអ្នកមានដីមិនគ្រប់គ្រាន់ដើម្បីកែលំអយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ខ្លួន ។ ទន្ទឹមគ្នានេះ អ្នកមានដីច្រើនលើសកំលាំងផលិតកម្មរបស់ខ្លួនបានផលចំណេញដោយជួលដីលើសទៅឱ្យអ្នកផ្សេង ។ កត្តាផ្សេងៗទៀត ដូចជា ផលិតភាព និងភាពមានចំណេញនៃការដាំដុះដីជួលប្រៀបធៀបនឹងចំណូលពីរបរផ្សេងទៀត ក៏អាចជះឥទ្ធិពលដល់ការជួលដីធ្លីដែរ[១៩] ។

អង្កេតនេះមិនបានបង្ហាញថា ការជួលដីមានច្រើនទេ ។ ហេតុផលមួយចំពោះរឿងនេះ គឺដោយខ្វះសន្តិសុខលើកម្មសិទ្ធិដីធ្លី ពីព្រោះដោយសារប្លង់ដីភាគច្រើនមិនទាន់ចុះបញ្ជី ។ គិតក្នុង ៩ភូមិ មានគ្រួសារ ៧,៤% បានជួលដី ។ ទំហំជាមធ្យមនៃដីជួលគឺប្រហែល ១ហ.ត ។ តារាង៣.៨ បង្ហាញថា គ្រួសារជាង ១0% (ច្រើនជាងមធ្យម) នៅភូមិអណ្តូងត្រាច ព្រៃកក្មេង បាបោង និងកញ្ជរ បានជួលដី ។ នៅបាបោងមានការជួលដីខ្ពស់បំផុត (១៥%) ។ ការជួលដីនៅពេលវាកើតមានឡើងតែងមានចំណងទាក់ទងវិជ្ជមានជាមួយផលិតភាពដី និងភាពគ្មានដី ។ ក្នុង ៤ភូមិខាងលើទិន្នផលស្រូវមានកំរិតខ្ពស់, ឯភាពគ្មានដីធ្លីក៏មាន

---

[១៩] ទោះជាមានការអះអាងយ៉ាងនេះក្តី ក៏ការប្រើប្រាស់ដីក្រោមរូបភាពជួល មិនសូវបានផលល្អទេក្នុងប្រទេសភាគច្រើន ដោយអ្នកប្រើដីពុំមានទឹកចិត្តធ្វើវិនិយោគលើដីដែលមិនមែនជាកម្មសិទ្ធិខ្លួន ។ តែគេមិនច្បាស់ថាតើការអះអាងនេះត្រឹមត្រូវសំរាប់កម្ពុជាដែរឬយ៉ាងណា ។

ក៏រិតខ្ពស់ក្រៅពីនៅបាបោងមួយចេញ ។ ផ្ទុយទៅវិញ ការជួលដីមានកំរិតទាបនៅខ្សាច់ជីរស់ ដងក្ដារ ត្រពាំងប្រិយ និងកំពង់ត្នោត ដែលទាំងផលិតភាពដី និងភាពគ្មានដីធ្លីមានកំរិតទាប[២០] ។ ស្ថិតិនេះបង្ហាញថា អ្នកគ្មានដី គឺជួលដីធ្លី ហើយវិធីជួលដី គឺជាកត្តាបែងចែកដីឱ្យបានស្មើល្អនៅកម្ពុជា ។

**តារាង៣.៨ ការជួលដីធ្លី និងទំហំដីជួលមធ្យម (គិតតាមគ្រួសារ)**

| | ជួលដីពីគេ | | ជួលដីឱ្យគេ | | ភាពគ្មានដីធ្លី | ទិន្នផលស្រូវ |
|---|---|---|---|---|---|---|
| | %គ្រួសារសរុប | ទំហំមធ្យម (ha) | %គ្រួសារ សរុប | ទំហំមធ្យម (ha) | | (តោន/ហ.ត) |
| **វាលទំនាបទន្លេសាប** | | | | | | |
| អណ្ដូងត្រាច | 10.6 | 1.89 | 1.2 | 0.50 | 39 | 2.2 |
| ក្រសាំង | 5.8 | 1.95 | 3.3 | 2.25 | 38 | 2.0 |
| ខ្សាច់ជីរស់ | 3.3 | 0.48 | 0.0 | - | 9 | 1.5 |
| **វាលទំនាបទន្លេមេគង្គ** | | | | | | |
| ព្រែកក្មេង | 13.3 | 0.44 | 3.3 | 1.83 | 31 | 3.5 |
| បាបោង | 15.0 | 1.18 | 7.1 | 0.81 | 7 | 3.3 |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 11.7 | 0.53 | 9.2 | 0.31 | 29 | 3.0 |
| ដងក្ដារ | 3.2 | 0.34 | 3.2 | 0.28 | 7 | 1.6 |
| ត្រពាំងប្រិយ | 1.5 | 1.50 | 0.0 | - | 12 | 1.2 |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 0.0 | - | 0.8 | 2.00 | 8 | 1.5 |
| **សរុប** | 7.4 | 0.98 | 3.4 | 0.90 | 20 | 2.2 |

ចំនួនគ្រួសារជួលដីពីគេ និងគ្រួសារជួលដីឱ្យគេ មិនស្មើគ្នាទេ ។ ទី១ គ្រួសារមួយអាចមានដីស្រែច្រើន ហើយជួលវាឱ្យទៅច្រើនគ្រួសារ ។ ករណីនេះមាននៅព្រែកក្មេង ។ ទី២ គ្រួសារខ្លះអាចជួលដីពី (ឬជួលដីឱ្យ) គ្រួសារដែលមិនរស់នៅក្នុងភូមិ ។ ម្យ៉ាងទៀត គ្រួសារដែលជួលដីស្រែឱ្យគេប្រហែលព្យាយាមលាក់បាំងរឿងនេះ ពីព្រោះគ្រួសារកសិករភាគច្រើនមិនចង់ឱ្យគេដឹងថាខ្លួនមិនអាចភ្ជួររាស់ដី ឬមានដីលើសទេ ដោយខ្លាចក្រែងអជ្ញាធរឬអ្នកផ្សេងនៅក្នុងសហគមន៍បង្កការគំរាមគំហែងដល់ដីខ្លួន ។ បាតុភាពនេះក៏បានកត់សំគាល់ឃើញនៅក្នុងប្រទេសផ្សេងដែរ (Singh 1988) ។

## ៣.៥ ដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត

ការប្រៀបធៀបទ្រព្យរបស់គ្រួសារគ្មានដី និងគ្រួសារមានដីទំហំខុសៗគ្នា អាចផ្ដល់ចម្លើយខ្លះលើសំនួរថាតើភាពគ្មានដីធ្លីមានចំណែកប៉ុណ្ណាក្នុងការកំណត់កំរិតជីវភាព ពីព្រោះទ្រព្យសម្បត្តិផ្សេងទៀតក៏អាចផ្ដល់ចំណូល និងរបរចិញ្ចឹមជីវិតបានដែរ ។ ក្រៅពីដី ទ្រព្យសម្បត្តិ ជាអាទិ៍ លំនៅដ្ឋាន គ្រឿងម៉ាស៊ីន មធ្យោបាយដឹកជញ្ជូន ឧបករណ៍កសិកម្ម និងវត្ថុជាប់លាប់ផ្សេងៗ[២១] ។ ក្រាហ្វិក៣.៣ ផ្ដល់ពតិមានខ្លះៗពីទ្រព្យសម្បត្តិទាំងនេះ ។ ទិន្នន័យនេះអាចផ្ដល់ការសន្និដ្ឋានថា បើគ្រួសារមួយមានដីកាន់តែធំ គ្រួសារនោះមានទ្រព្យសរុប និងទ្រព្យមិនមែនដីកសិកម្មកាន់តែច្រើនដែរ[២២] ។ នៅគ្រប់ភូមិគ្រួសារដែលមានដីច្រើនជាង ១ហ.ត គឺមានទ្រព្យច្រើនជាងគ្រួសារមានដីតិចជាង ១ហ.ត ។ គេឃើញមានភាពខុសគ្នាយ៉ាងច្បាស់រវាងគ្រួសារមានដីច្រើនជាង ៣ហ.ត

---

[២០] សន្តិសុខកម្មសិទ្ធិដីទាប និងទីផ្សារដីសកម្មគ្មានអ្វីប្រឆាំងគ្នាទេ ។ ម្ចាស់ដីអាចស្ទាក់ស្ទើរមិនចង់ជួលដី តែការលក់ផ្ដាច់ជារឿងមួយផ្សេង ។

[២១] ប៉ុន្តែគួរបញ្ជាក់ថា ទ្រព្យទាំងអស់មិនមែនសុទ្ធតែអាចផ្ដល់ចំណូលនោះទេ ។

[២២] ទ្រព្យក្រៅពីដីរួមមាន ផ្ទះ សត្វ មធ្យោបាយដឹកជញ្ជូន និងរបស់ជាប់លាប់ផ្សេងទៀត ។ ទ្រព្យជាហិរញ្ញវត្ថុមិនបានបូកបញ្ចូលនៅក្នុងការគណនានេះទេ ពីព្រោះគ្រួសារទាំងនោះអាចមិនព្រមប្រាប់ការពិតពីទ្រព្យហិរញ្ញវត្ថុដែលខ្លួនមាន ។

និងគ្រួសារផ្សេងទៀត ។ ករណីលើកលែង គឺនៅភូមិព្រៃកក្អែង បាបោង និងកញ្ជរដែលគ្រួសារគ្មានដីគេ មានទ្រព្យមិនមែនដីកសិកម្មធំជាងគ្រួសារមានដីតិច ។ រឿងនេះ គឺដោយសារតែគ្រួសារធូរធារមួយចំនួននៅភូមិព្រៃកក្អែង និងកញ្ជរ គេរកចិញ្ចឹមជីវិតដោយការនេសាទ និងមួយចំនួនតូចនៅបាបោង ពឹងផ្អែកលើពាណិជ្ជកម្ម ។ ពួកគេមិនមែនជាកសិករទេ ។ តួលេខបញ្ជាក់ទៀតថា ជាទូទៅដី និងទ្រព្យផ្សេងទៀត បំពេញឱ្យគ្នាទៅវិញទៅមកមិនមែនជំនួសគ្នាបាននោះទេ ។ បើគ្រួសារមានទ្រព្យប្រភេទណាមួយច្រើនហើយ គ្រួសារនោះក៏មានទ្រព្យប្រភេទផ្សេងទៀតច្រើនដែរ ។

**ក្រាហ្វិក៣.៣ ទ្រព្យសម្បត្តិគ្រួសារគិតតាមទំហំដីកាន់កាប់ (លានរៀល)**




## ៣.៦ ការកាន់កាប់ដី និងប្រាក់ចំណូល

គ្រួសារគ្មានដីមិនមែនសុទ្ធតែរកចំណូលបានទាបបំផុតនោះទេ ។ លើកលែងតែនៅភូមិបាបោងចេញគ្រួសារគ្មានដីរកចំណូលបានស្មើនឹងគ្រួសារមានដីតូចជាង ឬស្មើនឹង ០,៥ហ.ត (តារាង៣.៩ និងក្រាហ្វិក៣.៤) ។ នៅភូមិអណ្តូងត្រាច និងក្រសាំងគ្រួសារគ្មានដីរកចំណូលបានច្រើនជាងគ្រួសារមានដីតូច ។ ក្នុងករណីខ្លះ គ្រួសារមានដី ០,៥-១ហ.ត ក៏មិនអាចរកចំណូលបានច្រើនគួរកត់សំគាល់ជាងគ្រួសារគ្មានដីនោះដែរ ។ ដូចបានបញ្ជាក់រួចហើយ រឿងនេះអាចពន្យល់បានមួយចំណែកថា គ្រួសារគ្មានដីជាច្រើនមិនមែនជាកសិករទេ ។ ពួកគេរកចំណូលតាមរយៈការនេសាទ ឬជំនួញ[២៣] ។ បើសិនជាភាពគ្មានដីធ្លីជាចំណុចគួរបារម្ភ ភាពជិតគ្មានដី (មានដី ០,៥ហ.ត ឬតិចជាង) ដែលទាក់ទិននឹងប្រហែល ២៥% នៃគ្រួសារក្នុងគំរូតាងក៏គួរឱ្យបារម្ភដែរ ។

គ្រួសារគ្មានដីទទួលចំណូលបានតិចបំផុតពីរបរកសិកម្ម ប៉ុន្តែទទួលចំណូលបានច្រើនជាងក្រុមផ្សេងទៀត ពីការបង្កើតរបររកស៊ីខ្លួនឯង, ការលក់កំលាំងពលកម្ម និងការប្រមូលធនធានទ្រព្យរួមដែលមានជាសំខាន់គឺការនេសាទ និងការបេះបន្លែផ្លែឈើព្រៃ (តួលេខសព្វគ្រប់អំពីចំនូលគ្រួសារមានចុះក្នុងឧបសម្ពន្ធ័២, តារាង៥) ។ របរចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកជាសារវ័ន្តលើការងារមានប្រាក់កំរៃ និងធនធានទ្រព្យរួម ។ ដូច្នេះបើសិនការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្មអាចពង្រីកបន្ថែម ហើយធនធានទ្រព្យរួមត្រូវបានគ្រប់គ្រងដោយមានចីរភាពថែមទៀត ភាពគ្មានដីធ្លីនឹងលែងចោទបញ្ហាអ្វីជាសំខាន់ដល់ការចិញ្ចឹមជីវិតរបស់ប្រជាជនទៀតហើយ ។ សេចក្តីអះអាងនេះ នឹងលើកមកពិភាក្សាលំអិតក្នុងជំពូកទី៦ ។

[២៣] វាហាក់ដូចជាប្រទាំងប្រទើសគ្នាបន្តិច រវាងលក្ខណៈបំពេញឱ្យគ្នាទៅវិញទៅមកនៃទ្រព្យសម្បត្តិ (បានបកស្រាយរួចហើយ) និងការពន្យល់ថ្មីនេះ ។ តាមពិត គ្រួសារមានដី សុទ្ធតែមានទ្រព្យផ្សេងៗទៀត, ប៉ុន្តែគ្រួសារអ្នកមានទ្រព្យ មិនមែនសុទ្ធតែជាគ្រួសារអ្នកមានដីនោះទេ ។

ក្រាហ្វិក៣.៤ ចំណូលគ្រួសារប្រចាំឆ្នាំ រួមទាំងផលិតកម្មកសិកម្ម (លានរៀល)




តារាង៣.៩ ចំណូលគ្រួសារប្រចាំឆ្នាំ រួមទាំងផលិតកម្មកសិកម្ម (លានរៀល)

| | ទំហំដីកាន់កាប់ដោយគ្រួសារនីមួយៗ តាមក្រុម | | | | |
|---|---|---|---|---|---|
| | អ្នកគ្មានដី | >0–0.5ha | >0.5–1ha | >1–3ha | >3 ha |
| **វាលទំនាបទន្លេសាប** | | | | | |
| អណ្តូងត្រាច | 2.05 | 1.51 | 1.88 | 2.82 | 2.91 |
| ក្រសាំង | 2.64 | 2.00 | 3.36 | 3.28 | 3.37 |
| ខ្សាច់ជីរស់ | 1.13 | 1.19 | 1.15 | 1.76 | 2.69 |
| **វាលទំនាបទន្លេមេគង្គ** | | | | | |
| ព្រៃកក្មេង | 2.55 | 2.53 | 3.48 | 5.47 | 5.26 |
| បាបោង | 2.46 | 3.27 | 2.99 | 3.69 | 7.34 |
| **តំបន់ខ្ពង់រាប** | | | | | |
| កញ្ជរ | 1.31 | 1.40 | 1.40 | 3.00 | 3.24 |
| ដងក្តារ | 0.86 | 1.02 | 1.18 | 1.78 | |
| ត្រពាំងប្រិយ | 0.99 | 1.02 | 1.59 | 2.53 | 3.15 |
| **តំបន់ឆ្នេរ** | | | | | |
| កំពង់ត្នោត | 2.39 | 2.07 | 3.50 | 3.96 | 2.85 |
| សរុប | **2.04** | **1.67** | **2.34** | **3.12** | **3.77** |

## ៣.៧ សេចក្តីសង្ខេប

បន្ទាប់ពីការបែងចែកដីឡើងវិញនៅពាក់កណ្តាលទសវត្សរ៍១៩៨០ និងការអនុញ្ញាតឡើងវិញនូវកម្មសិទ្ធិដីធ្លីឯកជននៅឆ្នាំ១៩៨៩ ទីផ្សារដីធ្លីក៏ចាប់ផ្តើមមានសកម្មភាពនៅគ្រប់ភូមិសិក្សាទាំង ៩ ។ រហូតដល់ឆ្នាំ២០០១ មាន ៤៤% នៃគ្រួសារម្ចាស់ដីបានរាយការណ៍ថា ដីរបស់ខ្លួនទទួលបានពីរដ្ឋ, ២៤% ទៀតប្រាប់ថាបានដីពីការបន្តមត៌ក, ១៦% ថាបានទិញដី, និង ១៦% ថាបានដីពីការរានដីព្រៃ ។ នៅតាមភូមិដែលមានលទ្ធភាពប្រើប្រាស់ព្រៃ (រួមទាំងព្រៃលិចទឹក) ការរានព្រៃយកដីនៅតែកើតមាននៅឡើយ ។

១២% នៃគ្រួសារនៅក្នុងគំរូតាងរាយការណ៍ថា បានលក់ដីខ្លះ ឬលក់ទាំងអស់តាំងពីឆ្នាំ១៩៨៩មក ក្នុងនេះ មានពាក់កណ្តាលរាយការណ៍ថា បានលក់ដីដើម្បីដោះស្រាយចំណាយព្យាបាលសុខភាព ។ គ្រួសារ ១៨% ទៀតដែលបានក្លាយជាអ្នកគ្មាន

ដីបានប្រាប់ថា បានលក់ដីទាំងអស់របស់ខ្លួន, ចំណែកឯ ៣៨% ទៀតជាគ្រួសារមិនធ្លាប់មានដីសោះ ។ គេបានរកឃើញដែរថា ដីមានផលិតភាពខ្ពស់ បានផ្លាស់ប្តូរម្ចាស់យ៉ាងលឿន ។

ក្នុងចំណោមគ្រួសារមានដី ទំហំដីកសិកម្មកាន់កាប់ជាមធ្យម គឺ ១,៥ហ.ត ។ ប៉ុន្តែទំហំមធ្យមនេះមិនអាចផ្តល់ពត៌មានអ្វីច្រើនទេ ពីព្រោះរបាយនៃការកាន់កាប់ដីធ្លី មានវិសមភាពខ្ពស់ណាស់ ។ គ្រួសារ ២០% គ្មានដីកាន់កាប់ទេ, ២៥% មានដី ០,៥ហ.ត ឬតិចជាង, ចំណែកឯ ១០% ទៀតមានដីដល់ទៅ ៤០% ។

តើភាពគ្មានដីធ្លីមានចោទបញ្ហាដែរឬទេ? ពិតហើយ វាមានចោទបញ្ហាខ្លះដែរ ។ ទិន្នន័យអង្កេតបង្ហាញថា ភាគច្រើននៃគ្រួសារគ្មានដី គេមានទ្រព្យផ្សេងទៀតតិចតួច និងរកចំណូលបានតិចជាងគ្រួសារមានដីកាន់កាប់ ។ លើសពីនេះ ភាពជិតគ្មានដី គឺជាបញ្ហាធ្ងន់ធ្ងរមួយ ។ ប៉ុន្តែ វាជាការពិតខ្លះដែរដែលថា គ្រួសារខ្លះមិនមែនស្ថិតនៅក្នុងសហគមន៍ដាំដុះទេ ហើយពួកគេរកចិញ្ចឹមជីវិតដោយជំនួញនេសាទ ឬរបរផ្សេងទៀត ។ គ្រួសារទាំងនេះ រកចំណូលបានយ៉ាងសមរម្យដែរ ។ ដីមានសារៈសំខាន់ចំពោះគ្រួសារមានមុខរបរចំបងធ្វើការងារដាំដុះ គឺបើគ្មានដីដាំដុះទេ ការចិញ្ចឹមជីវិតរបស់ពួកគេជួបគ្រោះថ្នាក់ ។ ដូច្នេះ វាជាប្រការមួយគួរព្រួយបារម្ភ បើសិនកសិករដោយការបង្ខំចិត្ត ឬដោយគ្មានជំរើសអ្វីផ្សេងត្រូវបាត់បង់ដី ហើយក្លាយជាជនទុគិត ។

# ជំពូកទី ៤

# ចំណាយផលិតកម្មនិងផលិតភាពនៃការដាំដុះ

ផលិតភាពដំណាំនៅកម្ពុជា ស្ថិតក្នុងចំណោមផលិតភាពទាបៗបំផុតនៅតំបន់អាស៊ីអគ្នេយ៍ ។ ទិន្នផលដំណាំតែងតែទាប ដូច្នេះតាំងពីដើមមក - ឧទាហរណ៍ នៅទសវត្សរ៍១៩៦០ និង ១៩៧០ តៃវ៉ាន់ កូរ៉េ ហ្វីលីពីន ឬឥណ្ឌូនេស៊ី មានទិន្នផលស្រូវលើសពី ៣-៣,៥ត/ហ.ត រីឯកម្ពុជាមិនដែលបានលើសពី ២ត/ហ.តទេ ។ មូលហេតុដែលកម្ពុជាអាចនាំចេញស្បៀងនៅទសវត្សរ៍ ១៩៥០ និង ១៩៦០ គឺដោយមានកត្តាគួបផ្សំជាច្រើនដូចជា ដង់ស៊ីតេប្រជាជនទាប និងការយកពន្ធលើសលប់នៅផលកសិកម្ម ។

ពីទសវត្សរ៍១៩៦០ ដល់ ១៩៩០ ប្រជាជនបានកើន ២-៣ដង ។ ដោយមានចំរុះកម្មមុខរបរតិចតួចប្រជាជនភាគច្រើនត្រូវបានស្រូបយកដោយវិស័យកសិកម្ម ទោះបីផ្ទៃដីដាំដុះនៅចុងទសវត្សរ៍១៩៩០ មានទំហំប៉ុនគ្នានឹងទសវត្សរ៍១៩៦០ក៏ដោយ ។ បច្ចុប្បន្នប្រជាជនជាង ៨លាននាក់ (១,៨លានគ្រួសារ) រស់នៅដោយរបរកសិកម្ម ក្នុងនេះគឺមានការធ្វើស្រែជីវព្រឹត្តិជាសំខាន់ ។ កសិករដាំដំណាំផ្សេងៗនៅរដូវវស្សា និងរដូវប្រាំង បើសិនជីត្រូវលិចទឹកនៅរដូវវស្សា ។ ពហុរដូវដាំដំណាំមិនទាន់បានអនុវត្តនៅឡើយទេ ព្រោះប្រព័ន្ធស្រោចស្រពមានក៏រិតតិចជាង ១០% នៃផ្ទៃដីដាំដំណាំ[២៤] ។ ដូច្នេះគេអាចនិយាយបានថា កសិកម្មកម្ពុជានៅតែជាកសិកម្មប្រើធាតុចូលក៏រិតទាប ហើយពឹងផ្អែកយ៉ាងធ្ងន់ធ្ងរលើលក្ខណៈអំណោយផលពីធម្មជាតិ ។

ផលិតភាពទាប កំណើនប្រជាជន ការពុះចែកដីតូចទៅៗ និងការឡើងចុះតាមរដូវនូវផលិតកម្មកសិកម្ម បានជះឥទ្ធិពលដល់សន្តិសុខស្បៀងនៅកម្ពុជា (Murdhid 1998) ។ ដូច្នេះ ទំនើបកម្មកសិកម្ម និងកំណែទំរង់ដីធ្លី គឺមានសារៈសំខាន់ខ្លាំងណាស់ ។ ជំហានដំបូងក្នុងទិសដៅនេះ គឺការស្វែងយល់ពីធម្មជាតិ ផលិតភាព ចំណូល និងចំណាយក្នុងប្រតិបត្តិការកសិកម្ម ។

ជំពូកនេះ មានគោលដៅពិនិត្យលើសំនួរជាច្រើនៈ

១) តើទំនាក់ទំនងរវាងផ្ទៃដីដាំដុះ និងផលិតភាពមានចរិតយ៉ាងណា?

២) តើទំនាក់ទំនងរវាងចំណាយផលិតកម្ម ផលិតភាព និងប្រាក់ចំណេញមានលក្ខណៈយ៉ាងណា?

៣) តើភាពមានចំណេញនៃការងារកសិដ្ឋាន វាផ្សារភ្ជាប់នឹងផលិតភាពក្នុងក៏រិតណា?

៤) តើអថេរទាំងនេះមានភាពខុសគ្នាយ៉ាងណារវាងតំបន់ផ្សេងៗ?

លំនាំនៃបន្ទុកចំណាយ ផលិតភាពនិងភាពមានចំណេញ និងបន្សំរវាងកត្តាទាំងនេះ គឺជាទំនាក់ទំនងបច្ចេកទេសដែលអាចពិនិត្យបានច្បាស់ល្អតាមរយៈទិន្នន័យប្រមូលបានពីកសិដ្ឋាន ជាជាងទិន្នន័យប្រមូលបានពីគ្រួសារ ។ ប៉ុន្តែដោយសារបញ្ហានីមួយៗទាក់ទងយ៉ាងជិតស្និទ្ធនឹងជីវភាពជនបទ ដូច្នេះក៏មានការធ្វើវិភាគពីដំបូងៗខ្លះដែរ ទោះបីទិន្នន័យមួយចំនួនប្រមូលបាននៅ ក៏រិតគ្រួសារក្តី ។

[២៤] តួលេខប្រព័ន្ធស្រោចស្រពទទួលបានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ៤.១ ទំហំកសិដ្ឋាន និងផលិតភាព

ការពិភាក្សាពីទំហំកសិដ្ឋាន និងផលិតភាព ឃើញមានកត់ត្រាច្រើនណាស់នៅក្នុងឯកសារផ្សេងៗស្តីពីកំណែទំរង់ដី និងការប្រើប្រាស់ដីធ្លីនៅអាស៊ីក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០នេះ ។ មតិជាទូទៅ គឺថាកសិដ្ឋានតូចៗនៅក្នុងស្ថានភាពមធ្យោបាយ និងលទ្ធភាពបច្ចុប្បន្នរបស់កសិករ គឺមានប្រសិទ្ធិភាពខ្ពស់ជាងកសិដ្ឋានធំៗ ។ បើសិនដីត្រូវបានបែងចែកស្មើភាពជាងនេះ និងក្នុងទំហំមិនធំពេក ផលិតកម្មនឹងកើនឡើង ហើយការងារ និងសន្តិសុខស្បៀងក៏កើនឡើងដែរ ។ បន្ទាប់ពីមានការធ្វើវិភាគលើសំណុំទិន្នន័យជាច្រើនស្តីពីសេដ្ឋកិច្ចកសិកម្មមានចំណូលទាបនានាក្នុងឯកសារផ្សេងៗ មានការលើកឡើងនូវសេចក្តីអះអាងដូចតទៅសំរាប់ប្រទេសអាស៊ី[២៥]

១) ដីតូចៗជាទូទៅគឺបានពីការពុះចែកដីមានជីជាតិល្អ ដូច្នេះហើយវាមានផលិតភាពខ្ពស់ ។ ជាលក្ខណៈសេដ្ឋកិច្ចគេអាចពុះចែកដីទាំងនេះបានក្នុងការផ្ទេរដីពីជំនាន់មួយទៅជំនាន់មួយ ។ ដូច្នេះហើយ វាក៏មានទំហំតូច ។

២) ក្នុងលទ្ធភាពជំរើសបច្ចុប្បន្ន (សព្វថ្ងៃមានវិធីសាស្ត្រទំនើបតិចតួចណាស់ដែលគេបានដាក់អនុវត្ត ដើម្បីទាញយកចំណេញតាមសេដ្ឋកិច្ចវិមាត្រ) កសិករធុនតូចប្រើបច្ចេកទេសល្អៗជាង និងធ្វើការគ្រប់គ្រងបានល្អជាង ។

៣) គេសង្កេតឃើញជារឿយៗថា ដីធ្លីនៅក្រោមកិច្ចសន្យាជួលមានការប្រើប្រាស់មិនល្អទេ ។ ប៉ុន្តែមិនសូវមានការលើកទឹកចិត្តឱ្យជួលដីតូចៗទេ ។ ដោយកសិករដាំដុះដីនោះដោយខ្លួនឯង ពួកគេបានទទួលផលិតភាពខ្ពស់ ។

៤) ធាតុចូលជាកំលាំងគ្រួសារ និងទ្រព្យ (គ្មានគិតថ្លៃ) ផ្សេងទៀត ត្រូវបានប្រើប្រាស់យ៉ាងសកម្មជាងលើទំហំដីតូចដោយមិនគិតពីផលិតភាពតាមឯកតាឡើយ ។ ដូច្នេះហើយអត្រាទិន្នផលក្នុងកសិដ្ឋានតូចៗ មានកំរិតខ្ពស់ ។

៥) ប្រពលភាព និងមុខដំណាំជ្រើសរើសដោយកសិករធុនតូច មានតំលៃខ្ពស់ជាង ហើយជាទូទៅអាចដាំបានច្រើនដងក្នុងមួយឆ្នាំៗជាងកសិករធុនធំ ។

តើសេចក្តីអះអាងទាំងនេះមានប៉ុន្មានដែលពិតសំរាប់កម្ពុជា? គេគ្មានពតិមានអ្វីច្រើនទេ ក្រៅពីដឹងថា វាមិនអាចប្រើបានទាំងអស់នៅគ្រប់កន្លែង និងគ្រប់ពេលនោះទេ ។ ការស្រាវជ្រាវដោយគីម សេតារា, ច័ន្ទ សុផល និង Sarthi Acharya (២០០២) រកឃើញថា ដីតូចៗជារឿយៗត្រូវបានជួលឱ្យគេ ។ ការជួលនេះ គឺដោយសារ ឬមួយវាមិនផ្តល់ចំណូលគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពគ្រួសារម្ចាស់ដី ឬមួយកសិករធុនតូច ពុំមានមធ្យោបាយគ្រប់គ្រាន់ដើម្បីទាញយកផលពីដីនោះ ។ ដំណើរការជួលដីបានងាយស្រួល ដោយសារលំនាំដាំដុះនៅកម្ពុជាមិនប្រែប្រួលច្រើនៈ គេដាំស្រូវស្ទើរគ្រប់រដូវ ។ ប៉ុន្តែអង្កេតមួយទៀតលើ ៣ភូមិក្នុងចំណោម៩ភូមិ រកឃើញថា កសិករក្រក្រោមលក្ខខណ្ឌដាំដុះដោយទឹកភ្លៀង រកចំណូលសុទ្ធបានច្រើនជាងចំណូលសុទ្ធកំរិតមធ្យម ប៉ុន្តែក្នុងលក្ខខណ្ឌប្រព័ន្ធស្រោចស្រពមានប្រើធាតុចូលទំនើប កសិករក្ររកចំណូលបានតិចជាងកំរិតមធ្យម (Murshid 1998)[២៦] ។

នៅកម្ពុជាគេដាំដុះពីររដូវគឺ រដូវវស្សា និងរដូវប្រាំង ។ កសិករភាគច្រើនណាស់ធ្វើស្រែនៅរដូវវស្សា ធ្វើនេសាទ និងប្រមូលអនុផលព្រៃនៅរដូវប្រាំង ។ ដូចបានបញ្ជាក់ពីខាងដើម កសិករមានដីនៅតំបន់ទំនាបធ្វើស្រែនៅរដូវប្រាំង ពីព្រោះដីស្រែរបស់គេត្រូវលិចទឹកនៅរដូវវស្សា[២៧] ។ ដំណាំរដូវវស្សាពឹងលើទឹកភ្លៀងជាចំបង ចំណែកដំណាំរដូវប្រាំងទទួលការស្រោចស្រពខ្លះៗ ។ សេដ្ឋកិច្ចនៃដំណាំទាំងពីររដូវខុសគ្នាយ៉ាងខ្លាំង ដូច្នេះជំពូកនេះ នឹងពិនិត្យពីដំណាំរដូវប្រាំង និងដំណាំរដូវវស្សាដាច់ពីគ្នា ។

---

[២៥] ការពិភាក្សាដោយឡែកពីគ្នាលើទំហំកសិកដ្ឋាន និងផលិតភាពមានក្នុងឯកសារ Bhardwaj (1976) និង Acharya (1995) ។

[២៦] Murshid មិនបានធ្វើវិភាគតាមទំហំកសិដ្ឋានទេ ។ គាត់កសាងសន្ទស្សន៍គួបផ្សំមួយ ដើម្បីកំណត់ពីសុខុមាលភាព ហើយកម្មសិទ្ធិដីធ្លី គឺជាធាតុផ្សំមួយ ។ ក្នុងចំណាត់ថ្នាក់ពី ១-៦ ពីរថ្នាក់ខាងក្រោមគឺជា "អ្នកក្រ" ។

[២៧] ផ្ទៃដីដាំដំណាំរដូវប្រាំងតូចជាងផ្ទៃដីដាំដំណាំរដូវវស្សាច្រើនណាស់ ។

តារាង៤.១ ទិន្នន័យផ្អែកលើទំហំកសិដ្ឋាន និងផលិតភាពសំរាប់រដូវវស្សានៅក្នុងតំណាក់កាលដែលការប្រើប្រាស់ធាតុចូលទំនើបនៅក្នុងកសិកម្មមានកំរិតទាប ។ ចំពោះគំរូតាងទាំងមូលផលិតភាពក្នុងរដូវវស្សា (វាស់វែងជាទិន្នផលស្រូវជាតោន/ហិកតារ) មានកំរិតខ្ពស់បំផុតសំរាប់កសិដ្ឋានតូចៗ (១,៨២ត./ហ.ត) ។ ទិន្នផលនេះធ្លាក់ចុះជាបណ្តើរៗនៅពេលទំហំកសិដ្ឋានកើនឡើង ហើយលំនាំនេះបានពិនិត្យឃើញក្នុង ៧ភូមិ ក្នុងចំណោម៨ភូមិ (ទិន្នន័យសំរាប់ភូមិនីមួយៗចុះក្នុងតារាង៤.១ និង ៤.២ នៃឧបសម្ព័ន្ធ៣) ។ ទិន្នន័យទាំងនេះស្របតាមការពន្យល់បែបក្លាសិុកសំរាប់តំបន់អាស៊ីដែលថា កសិដ្ឋានតូចៗមានផលិតភាពខ្ពស់ជាង ។ គេរំពឹងថានឹងរកឃើញលទ្ធផលបែបនេះ ពីព្រោះកសិកម្មកម្ពុជាភាគច្រើននៅតែប្រើវិធីដាំដុះបែបជីវព្រឹត្តិ និងបុរាណ ។ ហេតុផលផ្សេងទៀតគឺថា ដីល្អៗត្រូវបានពុះចែកជាឡូត៍តូចៗ ដូចមានបង្ហាញក្នុងទិន្នន័យអំពីថ្លៃដីគឺ ដីតូចថ្លៃខ្ពស់ជាងដីធំៗ ។ ទំនាក់ទំនងរវាងផលិតភាព-ទំហំដី នៅបាបោង គឺខុសគ្នាខ្លះ ប្រហែលដោយសារនៅបាបោងមានប្រើគ្រឿងយន្តច្រើន និងមានកំរិតទំនើបកម្មកសិកម្មខ្ពស់ជាង ទោះបីចំពោះដំណាំរដូវវស្សាក្តី ។ លំនាំនៅភូមិអណ្តូងត្រាច គ្មានអ្វីគួរកត់សំគាល់ទេ ពីព្រោះកសិកម្មនៅទីនោះមិនទាន់បានធ្វើទំនើបកម្មនៅឡើយ ។

**តារាង៤.១ ដំណាំស្រូវវស្សានៅឆ្នាំ២០០១ តាមទំហំដី (គ្រប់ភូមិ)**

| ទំហំកសិដ្ឋាន | កសិដ្ឋានគំរូតាង | ផ្ទៃដីប្រមូលផល (ha) | ផលិតកម្ម (tonnes) | ទិន្នផល (tonnes/ha) |
|---|---|---|---|---|
| >0 - 0/5ហ.ត | 225 | 0/34 | 0/56 | 1/82 |
| >0/5 - 1 ហ.ត | 133 | 0/84 | 1/10 | 1/29 |
| >1 - 2 ហ.ត | 225 | 1/69 | 1/84 | 1/08 |
| ធំជាង 2 ហ.ត | 64 | 3/99 | 2/71 | 0/75 |
| សរុប | **495** | **1/15** | **1/17** | **1/43** |

តារាង៤.២ ផ្តល់ទិន្នន័យប្រហែលគ្នានឹងតារាង៤.១ដែរ តែសំរាប់ដំណាំរដូវប្រាំង ហើយវាបង្ហាញលទ្ធផលខុសប្លែកពីតារាង៤.១ ។ គិតជាសរុប កសិដ្ឋានធំៗជាងគេ ផ្តល់ទិន្នផលខ្ពស់ជាងគេ ប៉ុន្តែគំលាតរវាងកសិដ្ឋានធំ និងកសិដ្ឋានតូចក៏មិនច្រើនណាស់ដែរ ។ នៅភូមិខ្សាច់ជីរស់ ទំនាក់ទំនងច្រាសរវាងទំហំកសិដ្ឋាននឹងផលិតភាពឃើញមានជាក់ស្តែង គឺកសិដ្ឋានតូចទទួលទិន្នផល ១,៧៣ត/ហ.ត ឯកសិដ្ឋានធំបានតែ 0,៨៦ត./ហ.ត (ឧបសម្ព័ន្ធ៣ តារាង២) ។ លទ្ធផលនេះ ប្រហែលមកពីភូមិខ្សាច់ជីរស់ នៅឆ្ងាយដាច់ស្រយាលមិនទាន់មានប្រើវិធីដាំដុះទំនើបទេទោះនៅរដូវណាក៏ដោយ ។ នៅភូមិផ្សេងៗទៀត ផលិតភាពខ្ពស់ៗបំផុត ពុំមែនមាននៅកសិដ្ឋានធំៗ ឬតូចៗនោះទេ គឺវាកើតមាននៅរាយប៉ាយពាសពេញគំរូតាង ។ ដូច្នេះ ប្រហែលជាទំនាក់ទំនងរវាងទំហំកសិដ្ឋាន និងផលិតភាពត្រូវបានរាំងស្ទះហើយ ពីព្រោះដំណាំរដូវប្រាំងបានដាំដោយមានការស្រោចស្រពគ្រប់គ្រាន់ ហើយកសិករមានប្រើច្រើននូវវិធីទំនើបនៃការដាំដុះ និងការថែទាំដំណាំ ។ សេចក្តីអះអាងនេះ ត្រូវបានគាំទ្រដោយការពិតជាក់ស្តែងដែលអត្រាទិន្នផលនៅរដូវប្រាំង ជាទូទៅតែងបានខ្ពស់ជាង បើធៀបនឹងរដូវវស្សា ។

**តារាង៤.២ ដំណាំស្រូវប្រាំង (មិនស្រោចស្រព) នៅឆ្នាំ២០០១ គិតតាមទំហំកសិដ្ឋាន (គ្រប់ភូមិ)**

| ទំហំកសិដ្ឋាន | គំរូតាង | ផ្ទៃដីប្រមូលផល/គ្រួសារ (ha) | ផលិតកម្ម/គ្រួសារ (tonnes) | ទិន្នផល (tonnes/ha) |
|---|---|---|---|---|
| >0 - 0/5ហ.ត | 95 | 0/33 | 0/81 | 2/62 |
| >0/5 - 1 ហ.ត | 70 | 0/83 | 2/16 | 2/65 |
| >1 - 2 ហ.ត | 68 | 1/61 | 4/30 | 2/65 |
| ធំជាង 2 ហ.ត | 44 | 3/40 | 9/17 | 2/69 |
| សរុប | **277** | **1/26** | **3/33** | **2/65** |

ដូច្នេះសរុបមក គឺហាក់ដូចជា ទំនាក់ទំនងផលិតភាព-ទំហំកសិដ្ឋាន កើតមានពិតមែន បើសិនវាស្ថិតនៅក្រោមលក្ខខណ្ឌដាំដុះតាមវិធីបុរាណ (ក្នុងករណីនេះគឺដំណាំរដូវវស្សា) ហើយវាហាក់ដូចជាមានកំរិតខ្សោយ ឬមិនពិតជាក់ស្តែង នៅពេលវិធីសាស្ត្រដាំដុះទំនើបត្រូវបានប្រើប្រាស់ដូចសំរាប់ដំណាំរដូវប្រាំង ។ ដូច្នេះលទ្ធផលទាំងនេះ ប្រហាក់ប្រហែលគ្នានឹងលទ្ធផលបង្ហាញដោយ Murshid (1998) ហើយវាបញ្ជាក់ថា មានការប្រែប្រួលតិចតួចនៅក្នុងទំនាក់ទំនងបច្ចេកទេសកសិកម្មក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ។

## ៤.២ ការប្រែប្រួលតាមតំបន់នៅក្នុងទិន្នផល និង លទ្ធភាពមានស្បៀង

ទិន្នន័យក្នុងតារាង១ នៃឧបសម្ព័ន្ធ៣ បង្ហាញពីការប្រែប្រួលនៅក្នុងអត្រាទិន្នផល (តោន/ហ.ត) ។ ចំពោះស្រូវវស្សា អត្រាទិន្នផលសរុបមានកំរិតខ្ពស់បំផុតនៅបាបោង (២,៩៦តោន/ហ.ត) បន្ទាប់មកគឺ កញ្ជរ (២,៨៧តោន/ហ.ត) ហើយទិន្នផលសរុបទាបបំផុតគឺនៅខ្សាច់ជីរស់ (០,៩០តោន/ហ.ត) ។ កសិកម្មនៅបាបោង មានកំរិតទំនើបកម្មខ្ពស់ជាងគេ ចំណែកឯខ្សាច់ជីរស់ ស្ថិតនៅតំបន់ដាច់ស្រយាល ។ ភូមិក្រសាំងបង្ហាញទិន្នផលទាប ទោះបីមានទំនើបកម្មកសិកម្មក្តី ពីព្រោះនៅឆ្នាំធ្វើអង្កេតនេះ មានទឹកជំនន់ធ្ងន់ធ្ងរធ្វើឱ្យអាក់ខានដល់ការដាំដុះដំណាំរដូវវស្សា ។

តារាង៤.១ បញ្ជាក់ដែរថា ផលិតកម្មស្រូវសរុប (ពោលគឺលទ្ធភាពមានស្បៀង) របស់អ្នកកាន់កាប់ដីតូចៗ មានបរិមាណយ៉ាងទាប ទោះបីផលិតភាពមានកំរិតខ្ពស់ក្តី បើធៀបនឹងអ្នកមានដីធំៗ ។ រឿងនេះបញ្ជាក់ថា ផលិតភាពល្អ មិនមែនសុទ្ធតែអាចបានរួចផុតពីភាពអត់ឃ្លាននោះទេ ។ នៅក្នុងបរិបទសន្តិសុខស្បៀងកំរិតគ្រួសារ កសិដ្ឋានតូចៗមិនមែនសុទ្ធតែករណីល្អគួរចង់បាននោះទេ ។ ផ្ទុយទៅវិញ ជាការសំខាន់ដែលត្រូវរកឱ្យឃើញថា តើកសិដ្ឋានតូចគួរតូចប៉ុណ្ណាដើម្បីធានាសន្តិសុខស្បៀង ។ ចម្លើយចំពោះសំណួរនេះ អាចជាមេរៀនដ៏សំខាន់សំរាប់កំណែទំរង់ និងការបែងចែកដីធ្លី ។

ចំពោះស្រូវប្រាំង តួលេខទិន្នផលស្រូវសរុបមានកំរិតខ្ពស់បំផុតនៅភូមិបាបោង (៣,១៦តោន/ហ.ត) បន្ទាប់មក គឺភូមិព្រៃកក្អេង (២,៦៩តោន/ហ.ត) ឯទិន្នផលទាបបំផុតគឺនៅភូមិខ្សាច់ជីរស់ (១,៣៩តោន/ហ.ត) ដូចមានចុះក្នុងឧបសម្ព័ន្ធ៣, តារាង១. ផលិតកម្មក្នុងមួយគ្រួសារ ។ កសិកម្មនៅភូមិបាបោងមានកំរិតទំនើបកម្មខ្ពស់ជាងគេ ចំណែកឯភូមិខ្សាច់ជីរស់ ស្ថិតក្នុងតំបន់ដាច់ស្រយាល ។ ភូមិព្រៃកក្អេងមានផលិតភាពខ្ពស់ ពីព្រោះស្រូវប្រាំងបានដាំដុះតាមលក្ខណៈវិទ្យាសាស្ត្រច្រើនជាងគេ បើធៀបនឹងភូមិផ្សេងៗទៀត (Kim, Chan, and Acharya 2002) ។ ចំពោះមតិអះអាងថា កសិករតូចៗតែងមានស្រូវតិច (ដូចបានស្រាវជ្រាវឃើញចំពោះស្រូវវស្សា) ក៏មានលក្ខណៈពិតជាក់ស្តែងសំរាប់ស្រូវប្រាំងដែរ ។

ក្នុងបរិបទតំបន់ផលិតកម្មក្នុងមួយគ្រួសារ (លទ្ធភាពមានស្បៀង) មិនផ្សារភ្ជាប់នឹងអត្រាទិន្នផលកំរិតភូមិសរុបទេ ។ លទ្ធភាពមានស្រូវច្រើនបំផុត គឺមាននៅភូមិអណ្តូងត្រាច (រដូវវស្សា) និងបាបោង (រដូវប្រាំង) ថ្វីបើអត្រាទិន្នផលនៅអណ្តូងត្រាច មានកំរិតទាបជាងអត្រាទិន្នផលមធ្យមទាំង៩ភូមិក្តី ។ ទិន្នន័យទាំងនេះបញ្ជាក់ថា អត្រាទិន្នផលមិនអាចធានាឱ្យកសិករមានស្បៀងគ្រាន់ទេ ។ ផ្ទុយទៅវិញ បើកសិករមានដីធំ ស្បៀងនឹងមានច្រើនក្នុងគ្រួសារគាត់ដូចពិនិត្យឃើញនៅអណ្តូងត្រាច ។

ដើម្បីប្រៀបធៀបតាមឆ្នាំ ទិន្នន័យនៃអង្កេតធ្វើដោយ វបសអ នៅឆ្នាំ១៩៩៧ បង្ហាញថា ផលិតភាពមធ្យមនៅភូមិព្រៃកក្អេង គឺ ៣,៣៣តោន/ហ.ត (៣,៤៣តោន/ហ.តនៅឆ្នាំ២០០១), នៅបាបោងគឺ ៣,៥៦តោន/ហ.ត (៣,១៦តោន/ហ.ត នៅឆ្នាំ២០០១) និងនៅត្រពាំងប្រិយគឺ ១,៨៦តោន/ហ.ត (១,១៩តោន/ហ.តនៅឆ្នាំ២០០១) ។ ក្នុង ៣ភូមិនេះមាន ២ភូមិ ដែលផលិតភាពដីបានធ្លាក់ចុះ ប៉ុន្តែនៅភូមិទី៣ វាបានកើនឡើង ។ គេមិនច្បាស់ទេថាតើនៅតំណាក់កាលនេះតួលេខសរុបខាង លើអាចបកស្រាយយ៉ាងណាបាន

ពីព្រោះអត្រាទិន្នផលប្រែប្រួលពីមួយរដូវទៅមួយរដូវ ប៉ុន្តែគេអាចបញ្ជាក់បានថា ពុំមានការ ប្រែប្រួលអ្វីខ្លាំងទេ ចំពោះកសិកម្មនៅក្នុងភូមិទាំងនេះ ។

## ៤.៣ រចនាសម្ព័ន្ធចំណាយ

ចំណាយដែលបានគណនានៅក្នុងរបាយការណ៍នេះ គឺជាចំណាយបានបង់ជាប្រាក់មិនមែនចំណាយជាកំលាំងផ្ទាល់ខ្លួននោះទេ ។ គ្រួសារនីមួយៗអាចជួលកំលាំងពលកម្ម ដោយផ្អែកលើទំហំកំលាំងពលកម្មដែលមាននៅក្នុងគ្រួសារ ។ កំរិតដែលកសិដ្ឋានត្រូវជួលកំលាំងពលកម្ម មានផលប៉ះពាល់លើបរិមាណដែលត្រូវទូទាត់ជាសាច់ប្រាក់ ឬត្រូវធ្វើការសងវិញ ។ ដូច្នេះពុំមានការកំណត់និយមន័យស្តង់ដារច្បាស់ទេ អំពីចំណាយក្រៅពីចំណាយសំភារៈ ពីព្រោះមានពតិមានតិចពេកដែលប្រមូលបានលើចំណាយផ្សេងទៀត ។ ទោះជាយ៉ាងនេះក្តី មានធ្វើការប្រៀបធៀបមួយចំនួនពីភូមិមួយទៅភូមិមួយ ដោយគេជឿថានៅកំរិតភូមិជាសរុប មានការកំណត់ច្បាស់លាស់ខ្លះហើយរវាងកំលាំងពលកម្មផ្ទាល់ខ្លួន/គ្រួសារ ទល់នឹងពលកម្មជួល ។ ប៉ុន្តែគេត្រូវតែប្រយ័ត្នប្រយែង ខ្លះដែរនៅពេលបកស្រាយផ្សេងៗ ។ រចនាសម្ពន្ធ័ចំណាយលើការធ្វើស្រែនៅកម្ពុជា (បន្ទុកចំណាយ/ហ.ត) សំរាប់ភូមិទាំង៩ និងសំរាប់គ្រប់ទំហំកសិដ្ឋានមានកត់ត្រានៅក្នុងតារាង៤.៣ក និង ៤.៣ខ ដែលបានបង្ហាញដាច់ពីគ្នានូវស្រូវប្រាំង និងស្រូវវស្សា ។

តារាង៤.៣ក និង ៤.៣ខ បង្ហាញពីតំលៃសុទ្ធនៃចំណាយ និងចំនែកនៃធាតុចូលនីមួយៗក្នុងចំណាយសរុប ។ តារាង ៤.៣ក ដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធចំណាយសំរាប់ស្រូវវស្សាបានបង្ហាញថា បន្ទុកចំណាយក្នុងមួយហិចតារ មានកំរិតខ្ពស់គឺ ២៥០.០០០រៀលនៅភូមិក្រសាំង (មានកសិកម្មទំនើបគួរសម) និងភូមិកញ្ជរ បន្ទាប់មកគឺភូមិកំពង់ត្នោត មានបន្ទុកចំណាយ ១៥០.០០០រៀល និង ៤ភូមិផ្សេងទៀត ដែលមានចំណាយសរុបតិចជាង ១០០.០០០រៀល/ហ.ត ។ មានហេតុផលសមស្រប មួយដែលភូមិនេសាទដាច់ស្រយាលដូចជាភូមិកញ្ជរនេះ មានចំណាយផលិតកម្មស្រូវវស្សាខ្ពស់ គឺដោយសារតែចំណាយដកស្ទូង និងច្រូតកាត់ខ្ពស់ (ត្រូវជួលកំលាំងពលកម្ម) ។ នៅភូមិដែលមានចំនាយសរុបទាប ការដោះដូរកំលាំងពលកម្មផ្ទាល់ខ្លួន/គ្រួសារ ប្រហែលមានអនុវត្តយ៉ាងច្រើន ហើយវិធីនេះពុំមានការបង់ប្រាក់អ្វីជាក់ស្តែងទេ (Sedara, Sophal និង Acharya 2002) ។

តាមពិត មួយចំណែកធំនៃបន្ទុកចំណាយ គឺទាក់ទងនឹងកំលាំងពលកម្ម (ក្រៅពីជីគីមីថ្នាំសំលាប់សត្វចង្រៃ និងថ្លៃជួលដីខ្ទង់ចំនាយឯទៀតទាំងអស់ទាក់ទងនឹងកំលាំងពលកម្ម) ។ ក្នុងភូមិ ឬគ្រួសារនានាដែលគ្មានកំលាំងពលកម្មក្នុងគ្រួសារគ្រប់គ្រាន់ដោយសារចំណាកស្រុក ឬកង្វះកំលាំងមនុស្សប្រុសធ្វើការគេត្រូវការជួលកំលាំងពលកម្មដែលធ្វើឱ្យកើនបន្ទុកចំណាយ ។ ដូច្នេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដែលគ្រួសារស្ត្រីដឹកនាំ (ខ្វះកំលាំងពលកម្មបុរស) មិនអាចប្រើប្រាស់ដីមានប្រសិទ្ធិភាពល្អហើយក៏ត្រូវបាត់បង់ដីទៅ (Sedara, Sophal nig Acharya 2002) ។

កសិករនៅភូមិក្រសាំង និងកំពង់ត្នោត ប្រើប្រាស់ជីគីមីយ៉ាងច្រើន ពីព្រោះភូមិទាំងពីរអំណោយផលខាងកសិកម្ម និងប្រើ ប្រាស់បច្ចេកទេសកសិកម្មទំនើប ។ នៅភូមិផ្សេងទៀតទាំងអស់មានប្រើធាតុចូលជាសំភារៈយ៉ាងតិចតួច (បើសិនមានប្រើ) ។ ភស្តុតាងនេះបញ្ជាក់ថា ស្រូវរដូវវស្សាពឹងផ្អែកជាសំខាន់តែលើកំលាំងពលកម្មមួយមុខគត់ ។

ចំណាយលើការដាំដុះនៅរដូវប្រាំង មានកំរិតខ្ពស់ជាងចំណាយលើការដាំដុះនៅរដូវវស្សាដូចមានចុះក្នុងតារាង៤.៣ខ ។ ទិន្នន័យសរុបញ្ជាក់ថា ចំណាយមធ្យមក្នុងមួយហិចតារក្នុងការដាំដុះនៅរដូវប្រាំងខ្ពស់ជាងការដាំដុះនៅរដូវវស្សា ៨០%, ពីព្រោះមិនមែនត្រឹមតែត្រូវប្រើធាតុចូលជាសំភារៈ (ជីគីមី ថ្នាំសំលាប់សត្វចង្រៃ និងទឹក) ច្រើនជាងប៉ុណ្ណោះទេ ប៉ុន្តែចំណាយលើកំលាំងពលកម្មក៏ច្រើនដែរ ជាពិសេសការរៀបចំដី ។ ការប្រើប្រាស់ធាតុចូលសរុបមានកំរិតខ្ពស់ជាង ចំពោះភូមិដែលមានទំនើបកម្ម

កសិកម្មខ្ពស់ ។ ដោយឡែក ដំណាំរដូវប្រាំង គឺស្ថិតក្នុងក្របខ័ណ្ឌកសិកម្មធ្វើទំនើបកម្ម ពីព្រោះលុះត្រាតែកសិករមានមធ្យោបាយគ្រប់គ្រាន់ទើបអាចធ្វើដំណាំរដូវប្រាំងបាន ។

ជាសេចក្តីសន្និដ្ឋាន ស្រូវវស្សាអាចចាត់ជាដំណាំជីវព្រឹត្ត តែងពឹងផ្អែកជាសំខាន់លើកំលាំងពលកម្ម និងទទួលបានទិន្នផលទទួលក៏រិតទាប ។ ផ្ទុយទៅវិញ ស្រូវប្រាំងប្រើធាតុចូលច្រើនដែលធ្វើឱ្យចំណាយកើនឡើង ប៉ុន្តែ ទិន្នផលក៏បានច្រើនដែរ ។

**តារាង៤.៣ក បន្ទុកចំណាយនៃផលិតកម្មស្រូវវស្សា ក្នុងឆ្នាំ២០០០-២០០១ (ហ.ត)**

| | អណ្ដូងត្រាច | ក្រសាំង | ខ្សាច់ជីរស់ | កញ្ជរ | ដងក្ដារ | ត្រពាំងប្រិយ | កំពង់ត្នោត |
|---|---|---|---|---|---|---|---|
| | ពាន់រៀលក្នុងមួយ ហ.ត | | | | | | |
| ជីគីមី | 9/0 | 65/4 | 0/3 | 0/0 | 20/2 | 26/1 | 65/2 |
| ថ្នាំសំលាប់សត្វចង្រៃ | 2/4 | 5/9 | 3/3 | 10/2 | 1/1 | 0/0 | 0/0 |
| ទឹក | 3/8 | 2/8 | 1/3 | 7/8 | 0/0 | 8/3 | 0/0 |
| ការរៀបចំដី | 20/7 | 68/8 | 11/6 | 3/7 | 6/8 | 10/4 | 33/2 |
| ដកស្ទូង | 5/5 | 29/9 | 1/3 | 107/8 | 25/4 | 13/2 | 18/2 |
| ច្រូតកាត់ | 13/9 | 24/4 | 13/2 | 70/2 | 13/5 | 4/3 | 13/4 |
| បោកបែន | 4/6 | 20/3 | 0/6 | 3/0 | 8/8 | 0/0 | 4/0 |
| ជួសជុលឧបករណ៍កសិកម្ម | ½ | 0/0 | 0/5 | 3/8 | 4/7 | 0/1 | 0/1 |
| ដឹកជញ្ជូន | 3/9 | 16/3 | 1/5 | 0/8 | 1/7 | 0/5 | 1/5 |
| ជួលដី | 7/4 | 0/0 | 0/0 | 56/3 | 2/6 | 2/2 | 0/0 |
| ជួលឧបករណ៍ និងសត្វអូសទាញ | 0/0 | 1/0 | 0/0 | 0/0 | 0/0 | 3/1 | 0/0 |
| ផ្សេងៗ | 0/3 | 5/0 | 0/1 | 0/0 | 0/0 | 0/2 | 13/7 |
| **សរុប** | **72/8** | **239/7** | **33/7** | **263/7** | **84/6** | **68/4** | **149/4** |
| | គិតជាភាគរយ | | | | | | |
| ជីគីមី | 12 | 27 | 1 | 0 | 24 | 38 | 44 |
| ថ្នាំសំលាប់សត្វចង្រៃ | 3 | 2 | 10 | 4 | 1 | 0 | 0 |
| ទឹក | 5 | 1 | 4 | 3 | 0 | 12 | 0 |
| ការរៀបចំដី | 29 | 29 | 34 | 1 | 8 | 15 | 22 |
| ដកស្ទូង | 8 | 12 | 4 | 41 | 30 | 19 | 12 |
| ច្រូតកាត់ | 19 | 10 | 39 | 27 | 16 | 6 | 9 |
| បោកបែន | 6 | 8 | 2 | 1 | 10 | 0 | 3 |
| ជួសជុលឧបករណ៍កសិកម្ម | 2 | 0 | 2 | 1 | 6 | 0 | 0 |
| ដឹកជញ្ជូន | 5 | 7 | 4 | 0 | 2 | 1 | 1 |
| ជួលដី | 10 | 0 | 0 | 21 | 3 | 3 | 0 |
| ជួលឧបករណ៍ និងសត្វអូសទាញ | 0 | 0 | 0 | 0 | 0 | 5 | 0 |
| ផ្សេងៗ | 0 | 2 | 0 | 0 | 0 | 0 | 9 |
| **សរុប** | **100** | **100** | **100** | **100** | **100** | **100** | **100** |

**តារាង៤.៣ខ បន្ទុកចំណាយនៃផលិតកម្មស្រូវប្រាំង ក្នុងឆ្នាំ២០០១**

| | ក្រសាំង | ខ្សាច់ជីរស់ | ព្រែកក្មេង | បាបោង | កញ្ជរ |
|---|---|---|---|---|---|
| | | | (ពាន់រៀល/ហ.ត) | | |
| ជីគីមី | 1 | 15 | 12 | 82 | 57 |
| ថ្នាំសំលាប់សត្វចង្រៃ | 20 | 8 | 5 | 19 | 4 |
| ទឹក | 26 | 93 | 70 | 55 | 97 |
| ការរៀបចំដី | 194 | 3 | 42 | 30 | 11 |
| ដកស្ទូង | 44 | 10 | 66 | 47 | 31 |
| ច្រូតកាត់ | 11 | 5 | 32 | 72 | 26 |
| បោកបែន | 25 | 0 | 24 | 26 | 5 |
| ជួសជុលឧបករណ៍កសិកម្ម | 0 | 4 | 3 | 3 | 6 |
| ដឹកជញ្ជូន | 11 | 0 | 22 | 17 | 0 |
| ជួលដី | 24 | 0 | 1 | 13 | 4 |
| ជួលឧបករណ៍ និងសត្វអូសទាញ | 9 | 1 | 0 | 0 | 0 |
| ផ្សេងៗ | 29 | 0 | 16 | 2 | 4 |
| **សរុប** | **580** | **139** | **291** | **367** | **243** |
| | | | (គិតជាភាគរយ) | | |
| ជីគីមី | 32 | 11 | 4 | 22 | 24 |
| ថ្នាំសំលាប់សត្វចង្រៃ | 3 | 5 | 2 | 5 | 2 |
| ទឹក | 5 | 67 | 24 | 15 | 40 |
| ការរៀបចំដី | 33 | 2 | 14 | 8 | 4 |
| ដកស្ទូង | 8 | 7 | 23 | 13 | 13 |
| ច្រូតកាត់ | 2 | 4 | 11 | 20 | 11 |
| បោកបែន | 4 | 0 | 8 | 7 | 2 |
| ជួសជុលឧបករណ៍កសិកម្ម | 0 | 3 | 1 | 1 | 2 |
| ដឹកជញ្ជូន | 2 | 0 | 8 | 5 | 0 |
| ជួលដី | 4 | 0 | 0 | 3 | 1 |
| ជួលឧបករណ៍ និងសត្វអូសទាញ | 2 | 1 | 0 | 0 | 0 |
| ផ្សេងៗ | 5 | 0 | 5 | 1 | 2 |
| **សរុប** | **100** | **100** | **100** | **100** | **100** |

## ៤.៤ ភាពមានចំណេញនៃដំណាំ

ចំពោះសេដ្ឋកិច្ចកសិកម្មមួយដែលកំពុងធ្វើសមាហរណកម្មជាបណ្តើរៗទៅក្នុងប្រព័ន្ធទីផ្សារ ដូចជា ប្រទេសកម្ពុជា ចំណេញ និងភាពមានចំណេញ គឺជាកត្តាមានន័យធំធេងចំពោះសេដ្ឋកិច្ចរបស់កសិករ ។ ក្នុងករណីនេះ ចំណេញ គឺជាបរិមាណនៅ

សល់ក្រោយពីកាត់កងចំណាយហើយ គឺមានចំណាយសំភារៈ និងចំណាយជួលពលកម្មទាំងអស់ ។ ថ្វីបើចំណាយដើមទុន ឬចំណាយដីធ្លី ពិបាកនឹងវាយតំលៃតាមរយៈវិធីធ្វើអង្កេតក្តី ក៏ប្រាក់ចំណេញអាចបកស្រាយបានថា ជាបន្សំនៃផលទទួលបានពីដីធ្លី ដើមទុន និងកំលាំងពលកម្មផ្ទាល់ខ្លួន/គ្រួសារ (អាចមានលំអៀងខ្លះ ដោយសារការប្រើប្រាស់មិនស្មើគ្នានូវពលកម្មជួល) ។

តារាង៤.៤ ផ្តល់ទិន្នន័យលើភាពមានចំណេញនៃស្រូវវស្សា ដែលគិតជាប្រាក់ចំណេញក្នុងមួយគ្រួសារប្រាក់ចំណេញក្នុងមួយហិកតារ ប្រាក់ចំណេញក្នុងមួយតោនស្រូវ និងប្រាក់ចំណេញក្នុងមួយរៀលនៃផលិតកម្ម ។ តួលេខពាន់រៀល/តោន និងភាគរយនៃផលិតកម្មសរុបនៅក្នុងតារាង៤.៤ គឺជារូបភាពដ៏ច្បាស់មួយនៃភាពមានចំណេញ ពោលគឺចំណូលគិតជាសមាមាត្រនៃផលិតកម្ម[២៨] ។ តារាងបង្ហាញថា គិតលើភូមិទាំងអស់ចំណូល (ភាគរយនៃផលិតកម្មសរុប) មានទំហំធំគួរសមចំពោះគ្រប់ទំហំដីទាំងអស់ ។ វាមានកំរិតខ្ពស់បំផុតចំពោះក្រុមដីមានទំហំ ០,៥-១ហ.ត បន្ទាប់មក គឺក្រុមដីទំហំតូចបំផុត ។ មានតែក្រុមដីទំហំធំបំផុតទេ ដែលភាពមានចំណេញបានត្រឹមតែពាក់កណ្តាលនៃភាពមានចំណេញជាមធ្យម ។ ស្ថានភាពតាមភូមិជាក់លាក់នីមួយៗមានលក្ខណៈចំរុះ (តារាង៣ ឧបសម្ព័ន្ធ៣) ដូចជានៅភូមិអណ្តូងត្រាច និងខ្សាច់ជីរស់ គឺមានទំនាក់ទំនងបញ្រ្ចាសយ៉ាងច្បាស់ (inverse relationship) រវាងទំហំដី និងភាពមានចំណេញ ។ ចំណែកឯនៅភូមិផ្សេងៗទៀត លំដាប់នៃទំនាក់ទំនងមិនសូវច្បាស់ល្អទេ ។ ទោះយ៉ាងនេះក្តី ទិន្នន័យសរុបបង្ហាញពីនិន្នាការនៃដីទំហំតូចៗដែលច្រើនផ្តល់ភាពមានចំណេញកំរិតខ្ពស់ ។ ហើយការពិនិត្យតួលេខគិតជាពាន់រៀល/តោនក្នុងតារាង៤.៤ ក៏ផ្តល់ការសន្និដ្ឋានប្រហែលគ្នានេះដែរ ។

**តារាង៤.៤ ភាពមានចំណេញលើស្រូវវស្សា តាមទំហំដី (គ្រប់ភូមិ)**

| ទំហំដី | ទំហំគំរូតាង | ពាន់រៀល/គ្រួសារ | ពាន់រៀល/ហ.ត | ពាន់រៀល/ត | %ផលិតកម្មសរុប |
|---|---|---|---|---|---|
| 0-0,៥ហ.ត | 225 | 129 | 395 | 214 | 68 |
| 0,៥ - ១ហ.ត | 133 | 264 | 322 | 231 | 71 |
| ១-២ហ.ត | 73 | 341 | 209 | 177 | 58 |
| ធំជាង ២ហ.ត | 64 | 371 | 101 | 95 | 31 |
| សរុប | **495** | **227** | **309** | **197** | **63** |

ទោះបីគ្មានការតវ៉ាចំពោះការសន្និដ្ឋានទូទៅដែលថា ដីតូចផ្តល់ទិន្នផល និងភាពមានចំណេញច្រើនជាងក្តី ប៉ុន្តែត្រូវប្រយ័ត្នចំពោះរឿងមួយ ។ ម្ចាស់ដីតូចៗ មិនសុទ្ធតែត្រូវចំណាយទិញធាតុចូលទាំងអស់នោះទេៈ ពួកគេរកធាតុចូលបានយ៉ាងច្រើនពីប្រភពផ្ទាល់ខ្លួន (ជាពិសេសកំលាំងពលកម្ម) ហើយធាតុចូលទាំងនេះមិនបានគិតចូលជាចំណាយបានបង់ទេ ហើយនេះជាមូលហេតុមួយដែលធ្វើឱ្យដីតូចៗហាក់ដូចមានចំណេញខ្ពស់ជាង ។

ភាពមានចំណេញ គឺជាចំណូលសុទ្ធក្នុងមួយហិកតារ ។ បើសិនគ្មានឥទ្ធិពលសេដ្ឋកិច្ចវិមាត្រទេ ភាពមានចំណេញក្នុងមួយហិកតារ និងភាពមានចំណេញក្នុងមួយឯកតាផលិតកម្មត្រូវស៊ីគ្នាទាំងស្រុង ។ ប៉ុន្តែដោយលក្ខខណ្ឌនេះមិនអាចក្តាប់បាន ដូច្នេះទិន្នន័យភាពមានចំណេញក្នុងមួយហិកតារ ត្រូវបានបង្ហាញដាច់ដោយឡែក (ពាន់រៀល /ហ.ត) ។ បើគិតសរុបលើ ៩ភូមិ គឺមានលំដាប់ផ្ទុយគ្នាយ៉ាងខ្លាំង ។ ប៉ុន្តែតួលេខពាន់រៀល/គ្រួសារបង្ហាញថា ចំណូលទទួលបានពីការដាំដុះរបស់គ្រួសារមានដីតូចមានកំរិតទាបជាខ្លាំងជាងចំណូលទទួលបានពីការដាំដុះដីធំៗ ។ ទំនាក់ទំនងនេះបានពិនិត្យឃើញពិតនៅកំរិតគ្រប់ភូមិ ។ ដូច្នេះសេចក្តីសន្និដ្ឋានពីខាងដើមដែលថាជាលក្ខណៈបច្ចេកទេសដីតូចៗ នៅក្រោមលក្ខខណ្ឌពឹងផ្អែកទឹកភ្លៀង គឺមានប្រសិទ្ធិភាពខ្ពស់ជាង ត្រូវបានបញ្ជាក់ម្តងទៀត ពីព្រោះវាផ្តល់ចំណូលក្នុងមួយហិកតារខ្ពស់ជាង ។ ប៉ុន្តែដូចបានបញ្ជាក់ក្នុងជំពូកទី៣ គ្រួសារមានដីតូចៗតែងមានស្បៀងតិចជាង និងរកបានតិចជាងនូវ *ចំណូលដែលអាចប្រើប្រាស់បាន* ។

---

[២៨] គេប្រើរង្វាស់នេះ ពីព្រោះវាឆ្លុះបញ្ចាំងពីសមត្ថភាពបច្ចេកទេសរបស់សហគ្រាស ឬកសិដ្ឋាន ដើម្បីផ្តល់ចំណូលអំពីផលិតកម្ម ។

អនុបាទនៃភាពមានចំណូលទាំង៤ សំរាប់ស្រូវប្រាំងគិតតាមក្រុមទំហំដី មានបង្ហាញនៅក្នុងតារាង៤.៥ ។ ទិន្នន័យក្នុងតារាងនេះបង្ហាញពីការឃ្លាតឆ្ងាយយ៉ាងច្រើនចេញពីទំនាក់ទំនងបែបក្លាសិកនៃ "ទំហំដី-ផលិតភាព" និង "ទំហំដី-ភាពមានចំណេញ" ដូចបានបញ្ជាក់ខាងលើ ។ គិតសរុបលើភូមិទាំងអស់ ភាគរយនៃភាពមានចំណេញ (ភាគរយនៃផលិតកម្មសរុប) មានកំរិតខ្ពស់បំផុតចំពោះដីធំៗជាងគេ បន្ទាប់មកគឺក្រុមដីទំហំ ០,៥-១ហ.ត រួចហើយក្រុមដី ១-២ហ.ត ។ ទោះជាអនុបាទភាពមានចំណេញមិនខុសគ្នាខ្លាំងទេពីក្រុមមួយទៅក្រុមមួយ ប៉ុន្តែភាពមានចំណេញនៃក្រុមដីទំហំតូចបំផុត (តូចជាង០,ហ.ត) មានកំរិតទាបខ្លាំងណាស់ប្រហែលតែពាក់កណ្តាលនៃតួលេខសំរាប់ក្រុមផ្សេងៗទៀតប៉ុណ្ណោះ ។ ឯភាពមានចំណេញក្នុងមួយតោនស្រូវ (ពាន់រៀល/តោន) ក៏មានលំនាំប្រហែលគ្នាដែរ ប៉ុន្តែមានខុសគ្នាបន្តិចដែរនៅក្នុងលំដាប់ ពីព្រោះថ្លៃធាតុចេញមិនដូចគ្នាគ្រប់កសិដ្ឋាន/ភូមិទេ[២៩] ។

បើគិតសរុបលើភូមិទាំងអស់ ភាពមានចំណេញក្នុងមួយហិកតារ (ចំណូល/ហ.ត) នៃដីធំៗវាខ្ពស់ជាងអត្រាសំរាប់ដីតូចៗ ។ លំដាប់នៃបន្ទុំជាវិជ្ជមានរវាងភាពមានចំណេញ និងទំហំកសិដ្ឋាន មិនដូចគ្នាគ្រប់កន្លែងទេ ប៉ុន្តែ *លំនាំជាទូទៅ* ឃើញមាននៅក្នុង ៣ភូមិក្នុងចំណោម ៥ភូមិដែលកសិករធ្វើស្រូវប្រាំង (តារាង២ ឧបសម្ព័ន្ធ៣) ។

ដូច្នេះ ការវិភាគនៅក្នុងផ្នែកនេះ បដិសេធនូវឧត្តមភាពនៃដីតូចៗនៅពេលធ្វើស្រូវប្រាំង ។ ទិន្នន័យជាពាន់រៀល/គ្រួសារនៅក្នុងតារាង៤.៥ បញ្ជាក់គាំទ្រថែមដល់គំហើញពីខាងដើមដែលថា គ្រួសារមានដីធំរកចំណូលបានច្រើន គិតជាតំលៃដាច់ខាតទាំងនៅរដូវប្រាំងផងដែរ ។

ចំពោះលក្ខខណ្ឌធ្វើស្រែដាក់ធាតុចូលតិច ទិន្នន័យទាំងនេះគាំទ្រទស្សនៈដែលថា ដីតូចអាចមានផលិតភាពច្រើនជាង និងផ្តល់ចំណូលក្នុងមួយហិចតារច្រើនជាង ប៉ុន្តែវាផ្តល់ចំណូលតិចជាងដល់កសិករ ។ នេះគឺដោយសារផលចំណេញបានពីកត្តាដីមានទិន្នផលខ្ពស់មិនអាចទូទាត់ការបាត់បង់ក្នុងចំណូលសរុបដោយសារទំហំដីតូចនោះបានទេ ។ ម្យ៉ាងទៀត ដីតូចផ្តល់លទ្ធភាពតូចចំពោះការប្រើប្រាស់វិធីសាស្ត្រដាំដុះទំនើប ។ ដោយសាររបបធ្វើស្រែប្រើធាតុចូលតិចកំពុងប្រែប្រួលទៅប្រើច្រើនជាងមុននូវដី ប្រព័ន្ធស្រោចស្រព និងពូជទំនើប ដូច្នេះឧត្តមភាពនៃដីតូចក៏ត្រូវបាត់បង់ទៅដែរ[៣០] ។ ដោយហេតុនេះ ការបែងចែកដី គឺជាប្រការគ្រោះថ្នាក់ដល់សន្តិសុខស្បៀង និងចំណូលរបស់កសិករ ។ តាមការពិនិត្យទិន្នន័យទាំងនេះ នៅក្នុងបរិបទនៃការវិភាគក្នុងជំពូកមុនៗ គេទទួលបានការបញ្ជាក់បន្ថែមថា ទំហំដីកាន់កាប់ពិតជាមានសារៈសំខាន់មែន ។

**តារាង៤.៥ ភាពមានចំណេញនៃផលិតកម្មស្រូវប្រាំង តាមទំហំដី (គ្រប់ភូមិ)**

| ទំហំដី | ទំហំគំរូតាង | ពាន់រៀល/គ្រួសារ | ពាន់រៀល/ហ.ត | ពាន់រៀល/តោន | %នៃផលិតកម្មសរុប |
|---|---|---|---|---|---|
| >0 – 0.5ha | 95 | 107 | 179 | 93 | 29 |
| >0.5 – 1ha | 70 | 325 | 393 | 147 | 51 |
| >1 – 2ha | 68 | 589 | 362 | 134 | 49 |
| >2ha | 44 | 1,355 | 393 | 141 | 52 |
| សរុប | **277** | **469** | **305** | **122** | **43** |

## ៤.៥ បន្សុំរវាងផលិតភាព និងចំណូល

[២៩] មានហេតុផលពីរបញ្ជាក់ថា ហេតុអ្វីបានជាថ្លៃវាខុសគ្នា គឺទី១ កសិករផ្សេងគ្នាលក់ស្រូវនៅពេលខុសគ្នា និងទី២ មានការប្រែប្រួលថ្លៃពីតំបន់មួយទៅតំបន់មួយ ។

[៣០] ទិន្នន័យចំណាយ ក៏បានប្រមូលក្នុងអង្កេតឆ្នាំ១៩៩៧ ដែរ ។ ប៉ុន្តែការរៀបចំតារាងបង្ហាញ មានលក្ខណៈខុសគ្នាខ្លាំងណាស់ពីអ្វីដែលគណនានៅពេលនេះ ។ ដូច្នេះ ពុំមានធ្វើការប្រៀបធៀបអ្វីមួយទេ ។

តើអត្រាទិន្នផលខ្ពស់ដែលផ្តល់ចំណេញខ្ពស់ដែរ នឹងផ្តល់ចំណូលច្រើនដល់កសិករពិតមែនទេ? នៅក្នុងកាលៈទេសៈធម្មតា ទំនាក់ទំនងនេះមានលក្ខណៈខ្លាំង និងវិជ្ជមាន លើកលែងតែថ្លៃទីផ្សារប្រែប្រួលខ្លាំងពេកចំពោះផលិតផលកសិកម្ម ឬក៏កសិដ្ឋានធ្វើប្រតិបត្តិការនៅក្នុងតំបន់ដែលមានសេដ្ឋកិច្ចអន់ថយខ្លាំង ។ ក្នុងនេះ regression equations ត្រូវបានធ្វើឡើងដើម្បីពិនិត្យមើលនូវសេចក្តីអះអាងនេះ ។

ក្នុងសមីការទី១ អថេរឯករាជ្យគឺ ចំណូល/គ្រួសារ (រៀល) និងអថេរមិនឯករាជ្យគឺ ទិន្នផល/ហ.ត (គិតជាតោន) ។ សមីការប៉ាន់ប្រមាណប្រភេទនេះ (ដោយអថេរត្រូវបានប្តូរទៅជាទំរង់ឡូការីត) នឹងផ្តល់នូវភាពយឺតនៃចំណូលរបស់កសិករគិតតាមមួយឯកតាកំណើនក្នុងអត្រាទិន្នផលដី ។ The ordinary least squares regression equations, estimated separately for wet and dry seasons, using pooled data from all villages ។

*រដូវវស្សា*

(1) Ln (Profit/household) = 5.058 + 0.440 Ln (yield/hectare); $R^2$ = 0.110; n=456
(7.010)

*រដូវប្រាំង*

(2) Ln (Profit/household) = 5.576 + 0.883 Ln (yield/hectare); $R^2$ = 0.264; n=276
(9.941)

(Brackets show t values and Ln to natural logarithm; the coefficients are significant at 99 percent confidence)[៣១]

សមីការនេះបង្ហាញថា កំណើន ១០% ក្នុងទិន្នផលដី (ចំណេញ/គ្រួសារ) អាចបង្កើនការដាំដុះស្រូវវស្សាបានត្រឹមតែ ៤,៤% និង ៨,៨% សំរាប់ការដាំដុះស្រូវប្រាំង ។ កំណើនក្នុងផលិតភាព ជាពិសេសចំពោះស្រូវវស្សាអាចបង្កើនចំណូលគ្រួសារកសិករបានតិចជាងសមាមាត្រអត្រាទិន្នផល ។ ជាទូទៅ ទិន្នផល/ហ.ត តែងតែមានកំរិតខ្ពស់ជាងលើដីតូចៗ ពិសេសចំពោះស្រូវវស្សា ប៉ុន្តែចំណូលគ្រួសារកើនឡើងក្នុងសមាមាត្រតូចជាង ។

សមីការ regression equation ដែលអាចពន្យល់ទំនាក់ទំនងរវាងចំណូលក្នុងមួយហិកតារ និងអត្រាទិន្នផល សំរាប់ស្រូវប្រាំង និងស្រូវវស្សា គិតសំរាប់គំរូតាង (pooled sample) មានដូចខាងក្រោមៈ

*ស្រូវវស្សា*

(3) Ln (Profit/hectare) = 5.372 + 1.024 Ln (yield/hectare); $R^2$ = 0.561; n=456
(24.114)

*ស្រូវប្រាំង*

(4) Ln (Profit/hectare) = 5.034 + 0.990 Ln (yield/hectare); $R^2$ = 0.392; n=246
(12.561)

(Brackets show t values and Ln to natural logarithm; the coefficients are significant at 99 percent confidence)

សមីការនេះបង្ហាញថា ភាពយឺតនៃចំណូលសុទ្ធក្នុងមួយហិកតារនៅក្នុងរដូវទាំងពីរ មានទំហំជិតស្មើឯកតា ។ ប៉ុន្តែ ចំនូលក្នុងមួយហិកតារកើនឡើងក្នុងសមាមាត្រស្មើគ្នានឹងអត្រាទិន្នផលក្នុងរដូវទាំងពីរ ។ រឿងនេះបង្ហាញថា ផលិតកម្ម និងបរិមាណចំណូលប្រែប្រួលសឹងតែស៊ីសង្វាក់គ្នាទាំងស្រុង ។ ឯរឿងពិតដែលចំណូល/ហ.ត និងចំណូល/គ្រួសារ ប្រែប្រួលមិនស៊ីសង្វាក់គ្នាគឺ

[៣១] t values are statistics that determine the extent of significance of a coefficient and $R^2$ depicts the overall explanation in an equation. n = the number of observations ។

មកពីការប្រែប្រួលនៅក្នុងអត្រាទិន្នផល ត្រូវបានគួបផ្សំជាមួយនឹងរៀបចំឡើងវិញនូវនៃកម្មសិទ្ធិដីធ្លី ពិសេសការពុះចែកដី[៣២] ។ ទិន្នន័យនេះ គាំទ្រលើគំហើញដំបូងដែលថា ដីតូចមានផលិតភាពខ្ពស់ជាង ប៉ុន្តែមិនផ្តល់ចំនួលច្រើនដល់គ្រួសារទេ ។

សមីការដើម្បីប៉ាន់ប្រមាណពីទំនាក់ទំនងរវាងចំណេញក្នុងមួយតោនផលិតកម្ម ហើយនិងផលិតភាពដីរំពឹងថានឹងអាចបង្ហាញបានថា តើចំនាយឯកតាវាថយចុះឬទេនៅពេលអត្រាទិន្នផលកើនឡើង ។ សមីការប៉ាន់ប្រមាណនេះមានដូច ខាងក្រោមៈ

*ស្រូវវស្សា*

(5) Ln (Profit/tonne) = 5.367 + 0.056 Ln (yield/ha); $R^2$ = 0.004; n=456
(1.419)

*ស្រូវប្រាំង*

(6) Ln (Profit/tonne) = 4.886 + 1.104 Ln (yield/ha); $R^2$ =0.234; n=246
(8.654)

(Brackets show t values and Ln to natural logarithm; the coefficient in equation (5) is statistically not significant)

សមីការដំបូងមិនសូវស៊ីគ្នាល្អជាលក្ខណៈស្ថិតិវាបង្ហាញថា គ្មានការថយចុះក្នុងចំណាយឯកតាទេ (ច្រាសទៅនឹងចំណូល) នៅពេលមានកំណើនអត្រាទិន្នផល ។ សមីការទីពីរដែលស៊ីគ្នាល្អបានបង្ហាញពីវត្តមានទំនាក់ទំនងបែបនេះសំរាប់ស្រូវប្រាំង គឺបានន័យថា បើសិនទិន្នផលស្រូវប្រាំង កើនឡើងចំណាយឯកតាវាធ្លាក់ចុះហើយលក្ខណៈប្រកួតប្រជែងនៃដំណាំនេះក៏កើនឡើង ។

## ៤.៦ សេចក្តីសង្ខេប

ជំពូកនេះពិនិត្យពី ទំនាក់ទំនងរវាងទំហំដី ផលិតភាពភាពមានចំណេញ និងចំណាយផលិតកម្មក្នុងកសិកម្ម ។ ដីតូចជាទូទៅ ប៉ុន្តែមិនទាំងអស់ទេ តែងមានផលិតភាពខ្ពស់បើគិតតាមអត្រាទិន្នផល ។ ទំនាក់ទំនងច្រាសរវាងផលិតភាពទំហំដីឃើញមានពិតមែនក្នុងការដាំដុះស្រូវវស្សា ។ តែចំពោះស្រូវប្រាំងទំនាក់ទំនងនេះមិនសូវឃើញច្បាស់ទេ ។ ដោយហេតុថា ការដាំដុះស្រូវវស្សា មិនត្រូវការអ្វីទៀតច្រើនទេក្រៅពីកំលាំងពលកម្ម ហើយក្នុងភូមិជាច្រើនក៏សំបូរកំលាំងពលកម្មផង ដូច្នេះមានការប្រើធនធានមនុស្សច្រើនដោយទទួលបានទិន្នផលខ្ពស់ ។ ផ្ទុយទៅវិញ កសិកម្មរដូវប្រាំងត្រូវការការយកចិត្តទុកដាក់ច្រើនព្រមទាំងត្រូវប្រើធាតុចូលច្រើន ហើយម្ចាស់ដីតូចៗ មិនសុទ្ធតែមានលទ្ធភាព ឬសមត្ថភាពក្នុងការប្រើប្រាស់ធាតុចូលទាំងនេះទេ ។ ដូច្នេះក្រោយបានគិតចូលនូវកត្តាទាំងនេះ ទំនាក់ទំនងរវាងផលិតភាពខ្ពស់ និងទំហំដីតូច បានចុះខ្សោយវិញ ។

ដីតូចផ្តល់ចំណូល/ហ.តខ្ពស់ជាង ជាពិសេសស្រូវវស្សា ប៉ុន្តែមិនផ្តល់ចំណូលខ្ពស់ដល់គ្រួសារទេ ។ ចំពោះរដូវប្រាំងទំនាក់ទំនងនេះចុះខ្សោយ ។ ដូច្នេះនៅពេលផលិតភាព និងចំណូលក្នុងមួយហិកតារស៊ីសង្វាក់គ្នាខ្លាំងភាពយឺតនៃចំណូលគ្រួសារជាមួយនឹងអត្រាទិន្នផលដីមានកំរិតតូចជាងឯកតា ។ ការពុះចែកដីតូចៗ គឺជាហេតុផលមួយដែលនាំឱ្យមានចំណូលទាប ហើយដីល្អតែងត្រូវបានពុះចែកក្នុងល្បឿនលឿនជាង ។

រចនាសម្ព័ន្ធចំណាយទូទៅបង្ហាញថា មានការប្រើប្រាស់សំភារៈតិចតួចក្នុងការដាំដុះ ។ នៅទីណាដែលកសិករមានប្រើជីនិងធាតុចូលផ្សេងទៀត ពួកគេទទួលបានទិន្នផលខ្ពស់ ។

ទាក់ទិននឹងចរិតនៃការបែងចែកដី និងផលិតភាពកសិកម្មកម្ពុជាទិន្នន័យបង្ហាញថា ដីតូចៗក្នុងពេលសព្វថ្ងៃ (មតិកពីអតីតកាលនៅពេលដែលកសិកម្មជារបរជីវព្រិត្តហើយកសិករមានមធ្យោបាយតិចធ្វើបានតែដីតូចៗ) ឥឡូវបានក្លាយជារឿង

[៣២] អង្កេតបានបញ្ជាក់ថា ដីល្អត្រូវបានពុះចែកលឿនជាងដូចបានបញ្ជាក់ពីខាងដើម ។ ការពុះចែកនេះវារារាំងនូវការចែកចាយផលចំណេញទទួលបានពីផលិតភាពឱ្យបានទៅដល់កសិករ ។

ចាំបាច់ដោយសារកំណើនសម្ពាធប្រជាជន ។ ការពុះបំបែកដីជាតូចៗដែលទីបំផុតនឹងនាំទៅដល់ភាពគ្មានដីធ្លីវាធ្វើឱ្យកសិករមានអសន្តិសុខស្បៀង និងបង្ខំកសិករឱ្យរកជំរើសផ្សេងទៀតក្រៅពីកសិកម្មដើម្បីចិញ្ចឹមជីវិត ។

## ជំពូកទី ៥

# បំណុល និងតំរូវការឥណទាន

គ្រួសារនៅជនបទកម្ពុជា ក៏ដូចនៅប្រទេសកសិកម្មដទៃទៀតដែរ តែងត្រូវការឥណទានតាមរដូវកាល ឬពេញមួយឆ្នាំតែម្តង ។ កសិករធ្វើការខ្ចីបុលគេ ហើយតាមធម្មតាតែងសងគេវិញខ្លះៗ ឬសងទាំងអស់នៅរដូវច្រូតកាត់ ។ កសិករខ្ចីគេម្តងទៀតនៅពេលត្រូវការ ហើយវដ្តកំចីនេះចេះតែបន្ត ។ ប្រាក់កំចីមិនមែនចាំបាច់សំរាប់ធ្វើកសិកម្ម ពាណិជ្ជកម្ម ឬគោលដៅប្រហែលគ្នានេះទេ គឺអាចសំរាប់ការប្រើប្រាស់ធម្មតាបុណ្យទាន ឬពិធីផ្សេងៗ ។ កសិករមិនអាចបែងចែកដាច់រវាងកំចីសំរាប់គោលដៅណាមួយអំពីគោលដៅណាមួយផ្សេងនោះទេ ។ គេខ្ចីបុលប្រើកំចីតាមតំរូវការ និងសងវាវិញនៅពេលមានអតិរេក[៣៣] ។

ទន្ទឹមគ្នានេះ គេរកឃើញថា ឥណទានមានតំលៃខ្ពស់ ។ អត្រាការប្រាក់ខ្ពស់ ពីព្រោះហានិភ័យនៃការមិនសងប្រាក់ក៏ខ្ពស់ដែរ ។ ការដាំដុះអាចបរាជ័យ ហើយតាំងពីដើមរៀងមក គ្មានប្រព័ន្ធច្បាប់សំរាប់ដោះស្រាយទេ[៣៤] ។ ម្យ៉ាងទៀតដោយប្រភពឥណទានស្ថាប័នមានតិច ឬគ្មានសោះ ហើយទីផ្សារឥណទានបាក់បែកជាចំណែកៗ ដូច្នេះ ជាក់ស្តែងគឺមានការរកស៊ីផ្តាច់មុខនៅតាមមូលដ្ឋាន (អ្នករកស៊ីចងការប្រាក់ ២ ឬ ៣នាក់) ដែលធ្វើឱ្យការផ្គត់ផ្គង់ឥណទានមានតិច និងមានការប្រាក់ខ្ពស់ ។

លើសពីនេះ ប្រភពស្ថាប័នមិនទទួលស្គាល់វដ្តនៃតំរូវការឥណទានរបស់កសិករទេ ។ ពួកគេផ្តល់កំចីសំរាប់ដោះស្រាយគោលដៅដ៏ជាក់លាក់ (សំរាប់តែផលិតកម្ម) ដោយមានការដាក់វត្ថុធានាផង ហើយកំចីត្រូវសងវិញតាមពេលកំណត់ជាមុន ។ លក្ខខណ្ឌនីមួយៗ សុទ្ធតែផ្ទុយពីតំរូវការរបស់កសិករនៅក្នុងបរិស្ថាននៃការធ្វើកសិកម្ម ។ នេះជាមូលហេតុមួយទៀតដែលអ្នករកស៊ីចងការប្រាក់ឯកជនមានតួនាទីស្នូលបែបនេះ ។

ដូចបានបញ្ជាក់ពីខាងលើ ឥណទានគឺជាសមាសធាតុដ៏សំខាន់មួយនៅក្នុងវដ្តនៃនៃការរកចិញ្ចឹមជីវិតរបស់កសិករ ។ ប៉ុន្តែវាបានធ្វើឱ្យគាំងដំណើរចំពោះកសិករជាច្រើននាក់ ដោយហេតុថា មិនមែនកសិករគ្រប់គ្នាទាំងអស់ទេដែលមានសមត្ថភាពសងបំណុលទៅតាមអត្រាការប្រាក់ដែលគេទាមទារយកនោះ ។ ដូច្នេះគ្មានអ្វីគួរភ្ញាក់ផ្អើលទេដែលការជំពាក់បំណុលគេ គឺជាផ្នែកមួយនៃវដ្តជីវិតរបស់កសិករ ។ កសិករកម្ពុជា តាមធម្មតាគឺមានជំពាក់បំណុលគេជាប់រហូត ។ ក្នុងជំពូកនេះមានការប្រឹងប្រែងឆ្លើយសំណួរដូចខាងក្រោមដោយប្រើទិន្នន័យបានពីអង្កេត ។

១) តើអ្នកភូមិជំពាក់បំណុលគេកំរិតណា?

២) តើប្រភពឥណទានមានអ្វីខ្លះ?

៣) តើឥណទានមានតំលៃប៉ុណ្ណា?

៤) ក្នុងចំណោមអ្នកភូមិ តើអ្នកណាខ្លះទទួលរងជាអតិបរមានូវទំងន់នៃបំណុល?

---

[៣៣] នេះជាសេដ្ឋកិច្ចមួយដែល Chayanov បានចងក្រងជាគំរូតាំងពីមួយសតវត្សរ៍មុនសំរាប់ប្រទេសរុស្ស៊ី ។ សូមអាន Chayanov (1986) ។

[៣៤] កំណត់ហេតុប្រវត្តិសាស្ត្រភាគច្រើនរកឃើញថា អត្រាការប្រាក់ តែងតែមានខ្ពស់នៅកម្ពុជា ។ សូមអាន Tarling (1999)

## ៥.១ គ្រួសារខ្ចីបុលគេ

តារាង៥.១ ផ្តល់ទិន្នន័យលើសមាមាត្រនៃគ្រួសារដែលមានជំពាក់ឥណទានមិនទាន់សងក្នុងពេលធ្វើអង្កេត គឺគិតតាមវគ្គប្រមូលទិន្នន័យទាំងពីរលើក (ទឹកប្រាក់ជាក់លាក់មានចុះក្នុងតារាង១ ឧបសម្ព័ន្ធ៤) ។ តារាង៥.១ បញ្ជាក់ថា ៥៣% នៃគ្រួសារក្នុងអង្កេតរដូវប្រាំង និង ៦២% នៃគ្រួសារក្នុងអង្កេតរដូវវស្សាមានជំពាក់កំចីក្នុងរូបភាពណាមួយ ។ ក្នុង ៥៣% នៃគ្រួសារក្នុងអង្កេតរដូវប្រាំង, មានគ្រួសារ ៥០% ជំពាក់កំចីជាសាច់ប្រាក់ និង ១៣% មានកំចីជាវត្ថុ ។ តួលេខនេះបានន័យថា គ្រួសារ ១០% មានកំចីចំរុះ (ជាសាច់ប្រាក់ និងវត្ថុ) ។ ដូចគ្នាដែរ ក្នុងចំណោម ៦២% នៃគ្រួសារក្នុងអង្កេតរដូវវស្សា, គ្រួសារ ៥២% មានជំពាក់បំណុលជាសាច់ប្រាក់ និង ២៨% មានបំណុលជាវត្ថុ គឺបានានន័យថា ១៨% ជំពាក់បំណុលចំរុះ ជាសាច់ប្រាក់ និងជាវត្ថុ ។

**តារាង៥.១ ភាគរយនៃគ្រួសារមានជំពាក់ឥណទានមិនទាន់សង**

| | រដូវប្រាំង | | | រដូវវស្សា | | |
|---|---|---|---|---|---|---|
| | ប្រាក់/វត្ថុ | ប្រាក់ | វត្ថុ | ប្រាក់/វត្ថុ | ប្រាក់ | វត្ថុ |
| **ទំនាបទន្លេសាប** | | | | | | |
| អណ្តូងត្រាច | 39 | 35 | 13 | 41 | 33 | 18 |
| ក្រសាំង | 40 | 35 | 9 | 53 | 53 | 10 |
| ខ្សាច់ជីរស់ | 67 | 67 | 28 | 75 | 61 | 43 |
| **វាលទំនាបទន្លេមេគង្គ** | | | | | | |
| ព្រៃកក្អែង | 66 | 66 | 8 | 70 | 66 | 16 |
| បាបោង | 61 | 50 | 31 | 45 | 39 | 11 |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 56 | 55 | 10 | 58 | 42 | 28 |
| ដងក្តារ | 51 | 47 | 15 | 58 | 47 | 25 |
| ត្រពាំងប្រិយ | 49 | 46 | 4 | 82 | 65 | 56 |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 48 | 48 | 2 | 79 | 61 | 48 |
| **សរុប** | 53 | 50 | 13 | 62 | 52 | 28 |

ពិនិត្យតាមភូមិនៅរដូវប្រាំង ភូមិទាំងឡាយណាដែលមានទំនាក់ទំនងទីផ្សារ និងទំនើបកម្មកសិកម្មច្រើនភូមិទាំងនោះក៏មានកសិករច្រើនដែលមានកំចីមិនទាន់សង (ទំនាក់ទំនងត្រឡប់វិញក៏ពិតដែរ និងផ្ទុយមកវិញ) ។ ឧទាហរណ៍ មាន ៦០% នៃគ្រួសារនៅភូមិបាបោង និងព្រៃកក្អែង មានកំចីមិនទាន់សង និង ៥១% នៅដងក្តារ និង ៥៦% នៅកញ្ជរ (ទិន្នន័យអង្កេតរដូវប្រាំង) ។ មានករណីលើកលែងផងដែរ ឧទាហរណ៍នៅកញ្ជរមានការលំបាកនឹងពន្យល់ថា ហេតុអ្វីបានជាអ្នកភូមិយ៉ាងច្រើនមានជំពាក់បំណុល ។ នៅភូមិក្រសាំងប្រហែលជាមានគ្រួសារតិចជាងដែលជំពាក់បំណុលគេ ពីព្រោះនៅទីនោះមានអ្នកគ្មានដីច្រើននាក់ ។ អ្នកភូមិធ្វើចំណាកស្រុកទៅរកការងារធ្វើ ដូច្នេះពួកគេមិនចាំបាច់ខ្ចីប្រាក់មកធ្វើការដាំដុះ ឬដោះស្រាយចំណាយផ្សេងៗនៅមូលដ្ឋានទេ[៣៥] ។ អង្កេតទាំងពីរលើកមានភាពខុសគ្នាខ្លះ ។ មានកំចីច្រើនជាងនៅរដូវវស្សា (ពីមេសាដល់កញ្ញា) ដែលជាដំណាក់កាលមានការខ្វះខាត និងតំរូវការចំណាយលើធាតុចូលធ្វើស្រែវស្សា ។ ប៉ុន្តែអង្កេតរដូវវស្សាបង្ហាញថាភូមិនីមួយៗ មានលំនាំខុសពីគ្នា: នៅបាបោង អ្នកខ្ចីប្រាក់មានតិចនាក់ទេ ឯនៅកំពង់ត្នោតគឺមានច្រើននាក់ ។ រយៈពេលមធ្យមនៃការខ្ចីប្រាក់មិនវែងណាស់ណាទេ គឺតិចជាង ៦ខែ ។ រឿងនេះបញ្ជាក់ពង្រឹងដល់មតិដែលបានលើកឡើងថា វដ្តនៃការសងបំណុលវិញគឺ "ពីពេលប្រមូលផលទៅទល់នឹងពេលប្រមូលផលវិញ" ។

[៣៥] ប៉ុន្តែមានអ្នកខ្លះខ្ចី ដើម្បីធ្វើសោហ៊ុយទៅរកការងារក្រៅភូមិផងដែរ ។

ធៀបនឹងអង្កេតពីមុនក្នុងឆ្នាំ១៩៩៦-៩៧ ទំហំនៃការចូលរួមក្នុងទីផ្សាតរឥណទានបានថយចុះប្រហែល ១០-២០% ។ អង្កេតឆ្នាំ១៩៩៦-៩៧ បង្ហាញថា នៅព្រៃកក្អេង គ្រួសារ ៧៦% មានជំពាក់បំណុលមិនទាន់សង នៅបាបោងមាន ៦៣% និង ត្រពាំងប្រិយមាន ៩២% ។

## ៥.២ ទំហំកំចី និងអត្រាការប្រាក់

ចំនួនជាមធ្យមគឺ ១.៣៨៥កំចី សំរាប់ ១.០០៥គ្រួសារបានធ្វើអង្កេត គឺបានន័យថា ជាមធ្យមគ្រួសារនីមួយៗមានកំចីលើសពីមួយ[៣៦] ។ គិតជាសរុប ប្រភពឥណទានធំបំផុត គឺសាច់ញាតិ និងមិត្តភ័ក្តិ (៤៤,៥%) ហើយគំហើញនេះក៏ស្របគ្នានឹងទិន្នន័យក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៧ និង ឆ្នាំ១៩៩៩ ដែរ (តួលេខជាក់លាក់ពីប្រភពកំចី ចំនួនកំចី ទំហំកំចីមធ្យម និងអត្រាការប្រាក់ មានចុះក្នុងឧបសម្ព័ន្ធ៤ តារាង១) ។ អ្នកផ្គត់ផ្គង់ធំបន្ទាប់ គឺអ្នករកស៊ីចងការប្រាក់ (៣៣,១%) ប្រភពស្ថាប័ន (១៥,៧%) និងប្រភពផ្សេងៗទៀត ។ លំនាំមិនខុសគ្នាគួរកត់សំគាល់ទេពីភូមិមួយទៅភូមិមួយ ។ ប៉ុន្តែគេបានឃើញថា ក្នុងភូមិដែលមានសកម្មភាពតាមបែបបទពាណិជ្ជកម្មច្រើនក៏មានការខ្ចីបុលច្រើនដែរ ។ គេរំពឹងបែបនេះ ដោយសារមានសមាហរណកម្មចូលក្នុងទីផ្សារក៏រិតខ្ពស់និងធំទូលាយជាង[៣៧] ។ អង្កេតឆ្នាំ១៩៩៦-៩៧ របស់ វិបសអ រកឃើញថា នៅភូមិព្រៃកក្អេង ៤០% នៃគ្រួសារទទួលឥណទានពីសាច់ញាតិ, នៅបាបោងគឺ ៦៦%, និងនៅត្រពាំងប្រិយ ២៦% ។ ធៀបនឹងដំណាក់កាលនោះ អត្រាប្រភពកំចីជាសាច់ញាតិ បានធ្លាក់ចុះ ។ ឯតួនាទីរបស់អ្នករកស៊ីចងការប្រាក់ក្នុង ៣ភូមិធ្វើអង្កេតឡើងវិញ ក៏បានប្រែប្រួលដែរ ។ នៅភូមិព្រៃកក្អេង បានកើនឡើងពី ៤៣% ដល់ ៧៥%, ចំណែកនៅបាបោង បានធ្លាក់ចុះពី ៣៤% ដល់ ២៣% និងនៅត្រពាំងប្រិយវាបានថយចុះពី ២៥% ដល់ ៩% ។ ផ្អែកលើទិន្នន័យនេះ គេពិបាកធ្វើការវិនិច្ឆ័យឱ្យបានច្បាស់លាស់ គឺគ្រាន់តែអាចកត់សំគាល់ថា មានការប្រែប្រួល និងមានឥណទានប្រភពស្ថាប័នឥណទានខ្លះៗ ។

ទំហំមធ្យមនៃកំចីគឺ ៣១៥.០០០រៀល (២៧៧.០០០រៀល ក្នុងអង្កេតរដូវប្រាំង និង ៣៥៤.០០០រៀល ក្នុងអង្កេតរដូវវស្សា) ។ ទំហំមធ្យមនៃកំចីនៅរដូវវស្សា រំពឹងថាធំ ពីព្រោះវាជារដូវខ្វះខាត ហើយកសិករត្រូវខ្ចីបុលដើម្បីធ្វើកសិកម្ម ។ម្យ៉ាងទៀត ទោះបីប្រភពស្ថាប័នឥណទានមិនទាន់រីកធំនៅឡើយ ប៉ុន្តែទំហំមធ្យមនៃកំចីដែលធំបំផុត គឺបានពីអេស៊ីលីដា (៦៨៥.០០០រៀល) ។ បន្ទាប់មកអ្នករកស៊ីចងការប្រាក់ ឯទំហំកំចីពីសាច់ញាតិ ស្ថិតក្នុងចំណាត់ថ្នាក់ទី៣ ។ ទំហំកំចីពីសាច់ញាតិគឺប្រហែល ១/៣ នៃទំហំកំចីពីអាស៊ីលីដា ។ ប៉ុន្តែសាច់ញាតិនិងមិត្តភក្តិផ្តល់កំចីច្រើនដង គ្រាន់តែកំចីនីមួយៗ ទំហំតូចៗតែប៉ុណ្ណោះ គឺប្រហែលសំរាប់ដោះស្រាយពេលខ្វះស្បៀងតាមរដូវ ឬតំរូវការអត់បានព្រៀងទុកប៉ុណ្ណោះ ។ ផ្ទុយទៅវិញ កំចីពីស្ថាប័នច្រើនធំៗជាង ពីព្រោះភាគច្រើនសំរាប់បំរើគោលដៅផលិតកម្ម ។ ដោយសារតំរូវការកំចីមួយភាគធំសំរាប់ដោះស្រាយកង្វះខាតតាមរដូវកាល ដូច្នេះការផ្គត់ផ្គង់ និងតំរូវការឥណទានពីស្ថាប័នមានទំហំតូចទេ[៣៨] ។

ការប្រៀបធៀបតាមភូមិបង្ហាញថា ភូមិព្រៃកក្អេង និងបាបោង មានកំចីទំហំធំជាងភូមិឯទៀតៗ ។ នៅព្រៃកក្អេងប្រជាជនខ្ចីប្រាក់យ៉ាងច្រើនដើម្បីចិញ្ចឹមត្រី ចំណែកនៅបាបោងប្រជាជនខ្ចីប្រាក់ដើម្បីទិញពូជទំនើប ជី និងធាតុចូលផ្សេងទៀតសំរាប់ធ្វើស្រែ ។ អណ្តូងត្រាចជាភូមិប្លែកពីគេ ព្រោះមានទំហំកំចីមធ្យមខ្ពស់បំផុត ទោះបីភូមិនេះមិនសូវជាប់ពាក់ព័ន្ធនឹងទីផ្សារទំនើបក្តី ។ រឿងនេះអាចបណ្តាលពីអ្នកតាំងលំនៅថ្មីត្រូវខ្ចីប្រាក់ច្រើនដើម្បីតាំងលំនៅ ។ ចំពោះភូមិឯទៀតៗ ដោយសារកសិកម្មមិនទាន់ធ្វើទំនើបកម្ម និងការងារក្រៅពីកសិកម្មមិនសូវសំបូរ កំចីដែលត្រូវការនិងរកបានមានទំហំតូចៗ ។

---

[៣៦] ស្ថិតិនេះមិនត្រូវប្រៀបធៀបនឹងតារាង៥.១ ដែលឆ្លើយសំនួរថាតើគ្រួសារមានជំពាក់បំណុលគេឬទេ នៅពេលធ្វើសំភាសន៍។

[៣៧] គេពិបាកគិតថា ហេតុអ្វីបានជាក្នុងអង្កេតរដូវប្រាំង ចំនួនកំចី/គ្រួសារ មានច្រើនជាងក្នុងអង្កេតរដូវវស្សា ។ តារាង៥.១ បង្ហាញថា ចំនួនកំចីមិនទាន់សងមានច្រើននៅក្នុងអង្កេតវគ្គ២ (រដូវវស្សា) ។

[៣៨] Kim, Chan and Acharya (2002) ។

មានការខុសគ្នាយ៉ាងច្រើនរវាងអត្រាការប្រាក់យកដោយប្រភពហិរញ្ញវត្ថុខុសៗគ្នា ។ ជាមធ្យមអ្នករកស៊ីចងការប្រាក់យកការប្រាក់ខ្ពស់ជាងគេពី ៦-៩%/ខែ (ឬ ៧០-១០០%/ឆ្នាំ ហើយរយៈពេលឱ្យខ្ចីក៏ខ្លីជាងគេច្រើន) ចំណែកឯកំចីពីសាច់ញាតិមិនថ្លៃទេ ។ ប្រភពហិរញ្ញវត្ថុស្ថាប័ន ដូចជា អាស៊ីលីដា យក ៣-៥%/ខែ ឬ ៣៦-៦០%/ឆ្នាំ ។ តួលេខនេះទាប បើធៀបនឹងអ្នករកស៊ីចងការប្រាក់ ប៉ុន្តែនៅតែខ្ពស់នៅឡើយ បើធៀបនឹងអត្រាចំណូលលើដើមទុន (Kang 2002) ។ ថ្វីបើអ្នករកស៊ីចងការប្រាក់ យកការប្រាក់ខ្ពស់ក្តី ប៉ុន្តែប្រជាជនតែងតែទៅខ្ចីពីប្រភពនេះ ពីព្រោះឥណទានប្រភពស្ថាប័ននៅមានតិចតួច ។ម្យ៉ាងទៀត ដូចមានបញ្ជាក់ក្នុងសេចក្តីផ្តើមនៃជំពូកនេះ តំរូវការឥណទានគឺជាចំណែកមួយនៃជីវិតកសិកម្មនៅជនបទ ប៉ុន្តែប្រភពស្ថាប័នឱ្យខ្ចីតែសំរាប់គោលដៅជាក់លាក់ និងក្នុងចំនួនបានកំណត់ទុកមុន ។ ភាពមិនស៊ីគ្នានេះ គឺជាមូលហេតុសំខាន់ដែលអ្នកភូមិទៅរកខ្ចីពីអ្នករកស៊ីចងការប្រាក់ ។

## ៥.៣ ចំណូល និងអត្រាការប្រាក់

តើម្ចាស់បំណុលមានកំណើនហានិភ័យឬទេពេលឱ្យប្រាក់ខ្ចីដល់អ្នកក្រជាជាងឱ្យអ្នកមិនក្រ? ម្យ៉ាងទៀត តើអ្នកក្រត្រូវបង់ការប្រាក់ច្រើនជាងឬទេធៀបនឹងអ្នកមិនក្រ ដើម្បីប៉ះប៉ូវចំពោះហានិភ័យនេះ? តារាង៥.២ បង្ហាញទិន្នន័យពីអត្រាការប្រាក់គិតតាមទសភាគនៃកំរិតចំណូល ។

**តារាង៥.២ អត្រាការប្រាក់ និងទឹកប្រាក់កំចីនៅរដូវប្រាំង និងវស្សា**

| ទសភាគគិតតាមចំណូលមួយឯកតាមនុស្សពេញវ័យ | រដូវប្រាំង | | | | រដូវវស្សា | | | |
|---|---|---|---|---|---|---|---|---|
| | ការប្រាក់ប្រចាំខែ (%) | កំចីជាសាច់ប្រាក់ | កំចីជាវត្ថុ | សរុប | ការប្រាក់ប្រចាំខែ (%) | កំចីជាសាច់ប្រាក់ | កំចីជាវត្ថុ | សរុប |
| | | ពាន់រៀល/គ្រួសារ | | | | ពាន់រៀល/គ្រួសារ | | |
| 1 (10% ក្របំផុត) | 2.1 | 141 | 16 | 157 | 2.6 | 87 | 16 | 123 |
| 2 | 2.5 | 129 | 11 | 141 | 2.6 | 109 | 15 | 124 |
| 3 | 2.8 | 168 | 14 | 182 | 3.7 | 111 | 30 | 141 |
| 4 | 3.3 | 131 | 11 | 142 | 2.8 | 119 | 20 | 138 |
| 5 | 3.5 | 169 | 14 | 183 | 2.9 | 226 | 19 | 245 |
| 6 | 4.4 | 142 | 21 | 163 | 4.6 | 131 | 26 | 158 |
| 7 | 4.2 | 157 | 13 | 170 | 4.3 | 169 | 10 | 178 |
| 8 | 4.8 | 191 | 6 | 196 | 4.3 | 409 | 18 | 427 |
| 9 | 5.1 | 304 | 10 | 314 | 3.5 | 216 | 8 | 224 |
| 10 (10% មានបំផុត) | 3.6 | 284 | 28 | 312 | 3.2 | 599 | 10 | 609 |

តារាង៥.២ គ្មានផ្តល់ភស្តុតាងថា អ្នកក្របង់ការប្រាក់ខ្ពស់ជាងនោះទេ ។ ផ្ទុយទៅវិញ អ្នកមិនក្របង់ការប្រាក់ច្រើនជាង ថ្វីបើក្រុមទសភាគចំណូល និងកំរិតការប្រាក់ពុំមានលំដាប់ស្របគ្នាក្តី ។ តើហេតុអ្វីបានជាបែបនេះ? អ្នកមិនក្រខ្ចីប្រាក់ច្រើនមែន ប៉ុន្តែមិនមែនជាហេតុផលត្រូវបង់ការប្រាក់ច្រើននោះទេ ។ ហេតុផលមួយអាចជាប្រភពកំចី គឺអ្នកក្រខ្ចីពីញាតិ/មិត្តដែលយកការប្រាក់ទាប ប៉ុន្តែអ្នកមិនក្រ ខ្ចីពីអ្នកដទៃដោយបង់ការប្រាក់ខ្ពស់ ។ ហេតុផលមួយទៀតអាចជាបញ្ហាទាក់ទិននឹងការវាយតំលៃកំរិតចំណូលក្នុងមជ្ឈដ្ឋានធ្វើកសិកម្ម ។

ក្នុងរឿងនេះដែរ អត្រាការប្រាក់បង់ដោយអ្នកខ្ចី បានគណនាតាមទំហំដីរបស់អ្នកខ្ចី ។ ទិន្នន័យបង្ហាញថា មានទំនាក់ទំនងបញ្ច្រាសជាក់លាក់តែខ្សោយរវាងទំហំដីរបស់គ្រួសារមួយ និងការប្រាក់ដែលគ្រួសារនេះត្រូវបង់ ។ នៅតំបន់វាលទំនាបទន្លេមេគង្គ អត្រាការប្រាក់ចំពោះអ្នកគ្មានដីគឺ ៥,៥%/ខែ ប៉ុន្តែចំពោះអ្នកមានដីធំជាង ៣ហ.ត អត្រាការប្រាក់ត្រឹមតែ ៣,៨%/ខែប៉ុណ្ណោះ (ឧបសម្ព័ន្ធ៤, តារាង២) ។ ដូច្នេះគ្រួសារមានដីច្រើន (មានករណីជាក់ស្តែងមួយចំនួន) គេបង់អត្រាការប្រាក់ទាប ។

រឿងនេះហាក់ដូចជា ដីកាន់កាប់តាមមគ្រួសារ គឺជាគ្រឿងការពារ (ឬរបស់ធានា) ទប់ទល់នឹងការមិនសងបំណុល ។ សង្ខេបមក កំចីគ្មានគ្រឿងការពារ មានតំលៃខ្ពស់ជាង ។

## ៥.៤ កំចី និងសមត្ថភាពសង

ប្រជាជនខ្ចីប្រាក់តាមតំរូវការរបស់ខ្លួន ប៉ុន្តែសមត្ថភាពសងពឹងផ្អែកលើចំណូល ។ ដូច្នេះ បរិមាណកំចីធៀបនឹងចំណូល មានសារៈសំខាន់ណាស់ ។ អត្រាកំចីធៀបនឹងចំណូល មានគណនាក្នុងតារាង៥.៣ក និង ៥.៣ខ ។ តារាង៥.៣ក ផ្តល់ទិន្នន័យកំចីក្នុងមនុស្សពេញវ័យម្នាក់[៣៩] គិតតាមទសភាគចំណូល និងតារាង៥.៣ខ ធ្វើចំណាត់ថ្នាក់ទិន្នន័យតាមភូមិគំរូតាង ។

**តារាង៥.៣ក កំចីគិតជាភាគរយនៃចំណូល (តាមចំណាត់ថ្នាក់ចំណូល)**

| ទសភាគគិតតាមចំណូលមួយឯកតាមនុស្សពេញវ័យ | បរិមាណកំចីជាភាគរយនៃចំណូលសរុប | កំចីក្នុងមួយឯកតាមនុស្សពេញវ័យ (ពាន់រៀល/ម្នាក់) |
|---|---|---|
| 1 (10% ក្របំផុត) | 40 | 54 |
| 2 | 27 | 57 |
| 3 | 29 | 79 |
| 4 | 19 | 65 |
| 5 | 23 | 93 |
| 6 | 14 | 68 |
| 7 | 13 | 74 |
| 8 | 19 | 133 |
| 9 | 14 | 128 |
| 10 (10% មានបំផុត) | 13 | 227 |

**តារាង៥.៣ខ កំចីគិតជាភាគរយនៃចំណូល (តាមភូមិ)**

| | បរិមាណកំចី ជាភាគរយនៃចំណូលសរុប | កំចីក្នុងមួយឯកតាមនុស្សពេញវ័យ (ពាន់រៀល/ម្នាក់) |
|---|---|---|
| **វាលទំនាបទន្លេសាប** | | |
| អណ្តូងត្រាច | 13 | 57 |
| ក្រសាំង | 13 | 64 |
| ខ្សាច់ជីរស់ | 31 | 91 |
| **វាលទំនាបទន្លេមេគង្គ** | | |
| ព្រៃកក្អែង | 30 | 243 |
| បាបោង | 24 | 148 |
| **តំបន់ខ្ពង់រាប** | | |
| កញ្ជរ | 21 | 77 |
| ដងក្តារ | 22 | 48 |
| ត្រពាំងប្រិយ | 21 | 51 |
| **តំបន់ឆ្នេរ** | | |
| កំពង់ត្នោត | 13 | 69 |

[៣៩] កុមារពីរនាក់ ស្មើនឹងមនុស្សពេញវ័យមួយឯកតា ពីព្រោះកុមារក៏អាចជាប្រភពចំណូលដ៏សំខាន់ដែរ ។

តារាង៥.៣ក បង្ហាញថា ទោះបីទំហំកំចីរីកធំក្តី ប៉ុន្តែបរិមាណបំណុលថយចុះនៅពេលចំណូលកើនឡើង ។ សមាមាត្រកំចីធៀបនឹងចំណូល គឺប្រហែល ៤០% ក្នុងទសភាគចំណូលទាបបំផុត និងតែ ១៣% ប៉ុណ្ណោះក្នុងទសភាគខ្ពស់បំផុត ។ ក្នុងរយៈពេលដូចគ្នានេះដែរ ទំហំមធ្យមនៃបំណុលក្នុងមនុស្សម្នាក់ គឺ ៥៤.០០០រៀលក្នុងគ្រួសារនៃទសភាគទាបបំផុត និង ២២៧.០០០ រៀលក្នុងគ្រួសារនៃទសភាគខ្ពស់បំផុត ។ គេមិនអាចផ្តល់គំនិតពីទំហំសមរម្យនៃកំចីក្នុងមនុស្សម្នាក់នោះទេ ប៉ុន្តែទិន្នន័យបញ្ជាក់ថា អ្នកក្រជំពាក់បំណុលច្រើនជាងអ្នកមិនក្រ ។ ប៉ុន្តែជារួម អ្នកទាំងនេះជំពាក់បំណុលគេដូចគ្នា ។

តារាង៥.៣ខ បង្ហាញថា មានអត្រាកំចីធៀបនឹងចំណូល(ប្រចាំឆ្នាំ) កំរិតខ្ពស់នៅភូមិខ្សាច់ជីវស់ និងព្រៃកក្អេង (ប្រហែល ៣០%) បន្ទាប់មក គឺភូមិបាបោង ត្រពាំងប្រិយ ដងក្តារ និងកញ្ជរ (២១-២៤%) និងភូមិផ្សេងទៀត ១៣% ។ ព្រៃកក្អេង និងបាបោង ដែលជាភូមិទំនើបជាងគេ មានបំណុលមិនទាន់សងច្រើនជាងគេដែរ ។ ឯលំនាំផ្សេងទៀតមិនអាចសំគាល់ឃើញទេ គឺប្រហែលមានកត្តាមួយចំនួន ដូចជា ប្រជាសាស្ត្រ របាយទ្រព្យសម្បត្តិ និងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិមកចូលរួមផងដែរ ។ មូលហេតុដែលមិនអាចឱ្យយោបល់លើចំនុចនេះបាន គឺដោយសារមានពត៌មានតិចតួចពេកពីការប្រើប្រាស់ឥណទាន ។

## ៥. សេចក្តីសន្និដ្ឋាន

ការខ្ចីប្រាក់ គឺជាចំណែកមួយនៃជីវិតនៅជនបទ ។ ប្រជាជនខ្ចីប្រាក់សំរាប់ផលិតកម្ម និងការប្រើប្រាស់ប្រចាំថ្ងៃ ដោយមិនអាចញែកចេញពីគ្នាបាន ។ ដោយមូលហេតុនេះ កំចីភាគច្រើនទទួលបានពីប្រភពមិនមែនស្ថាប័នសំខាន់គឺអ្នករកស៊ីចងការប្រាក់ និងសាច់ញាតិ ។ អ្នកឱ្យខ្ចី ពិនិត្យមើលឃើញហានិភ័យខ្ពស់នៃការមិនសងបំណុល ហើយក្នុងពេលជាមួយគ្នានេះការផ្គត់ផ្គង់ ក៏មានកំរិត ។ ជាវិបាកអត្រាការប្រាក់មានកំរិតខ្ពស់ ។ វាហាក់ដូចមានជាបន្ទរបញ្ច្រាសគ្នារវាងទំហំដីរបស់អ្នកខ្ចី និងអត្រាការ ប្រាក់ដែលអ្នកខ្ចីត្រូវបង់ ។ បន្ទរនេះខ្សោយទេ តែវាបញ្ជាក់ថា ការមានដីច្រើនគឺជាគ្រឿងការពារមួយទប់ទល់នឹងការមិនសង បំណុល ។ អត្រាបំណុលមិនទាន់សងក្នុងមនុស្សម្នាក់មានកំរិតខ្ពស់ក្នុងចំណោមអ្នកក្រ បើធៀបនឹងអ្នកមិនក្រ ប៉ុន្តែជាតួលេខ ជាក់ស្តែងទឹកប្រាក់ខ្ចី ដោយអ្នកក្រមានតិចជាងអ្នកមិនក្រ ។ ទោះជាយ៉ាងនេះក្តី កសិករ និងអ្នកភូមិភាគច្រើនជំពាក់បំណុល គេដូចគ្នា ។

## ជំពូកទី ៦

# ចំរុះកម្មរបរចិញ្ចឹមជីវិតនៅជនបទ ធនធានទ្រព្យរួម និងចំណូលសរុប

ចំរុះកម្មរបរចិញ្ចឹមជីវិត មានសារៈសំខាន់បំផុត និងជាចំណែកមួយនៃជីវិតនៅតាមជនបទក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ។ វាមិនគ្រាន់តែផ្ដល់ចំណូលបន្ថែមទៅនឹងប្រភពចំណូលចំបងដែលតាមធម្មតាច្រើនតែមិនគ្រប់គ្រាន់នោះទេ ប៉ុន្តែវាជួយកាត់បន្ថយហានិភ័យនៃការពឹងផ្អែកលើការងារតែមួយមុខផង (Ellis 2000) ។ ជាប្រពៃណី ប្រជាជននៅជនបទកម្ពុជា រកចិញ្ចឹមជីវិតអំពីប្រភពជាច្រើនដែលសំខាន់ៗមានដូចជា កសិកម្ម នេសាទ ផលិផលព្រៃឈើ ។ ដោយមានការធ្វើទំនើបកម្មជាច្រើនទសវត្សរ៍ចុងក្រោយនេះ ស្ថាប័នជាច្រើន (រួមទាំងមកពីក្រៅប្រព័ន្ធកសិកម្មផងដែរ) បានចាប់ផ្ដើមដាក់ការទាមទារលើធនធានធម្មជាតិ ។ ទង្វើនេះបានរំខានដល់ភាពស៊ីសង្វាក់គ្នាល្អ ពីមុនរវាងលំហូរចំណូលពីប្រភពផ្សេងៗទៅដល់កសិករ ។ ដោយហេតុថាទំហំកសិដ្ឋាន វាតូចតាំងពីដើមមក ដូច្នេះការថយចំណូលពីប្រភពក្រៅពីកសិដ្ឋានបានន័យថា ចំណូលពីកសិដ្ឋានតែមួយមុខ មិនអាចបំពេញតំរូវការសន្តិសុខស្បៀងបាន ហើយចំណូលពីប្រភពច្រើន គឺជាការចាំបាច់ដើម្បីធានាការចិញ្ចឹមជីវិត ។ ប្រជាជនបានចាប់ផ្ដើមធ្វើចំរុះកម្មការរកចំណូល ដោយបង្វែទិសចេញពីប្រភពកសិកម្មធម្មតា ទៅធ្វើការ ដូចជា លក់ពលកម្ម និងជំនួញ ។ ជំពូកនេះ ព្យាយាមពិនិត្យមើលពីប្រភពចំណូលផ្សេងៗ និងបរិមាណចំណូលតាមប្រភពនីមួយៗ ។

ជំពូកនេះដោះស្រាយសំណួរជាក់លាក់មួយចំនួនដូចខាងក្រោមៈ

១) តើប្រភពផ្សេងៗគ្នាផ្ដល់ចំណូលជាតួលេខសុទ្ធប៉ុណ្ណា?

២) តើគ្រួសារជនបទពឹងផ្អែកប៉ុណ្ណាលើធនធានទ្រព្យរួម?

៣) តើការពឹងផ្អែកលើធនធានទ្រព្យរួមមានកំរិតខុសគ្នាប៉ុណ្ណា រវាងអ្នកមាន និងអ្នកក្រ?

៤) ក្នុងពេលថ្មីៗនេះ តើចំណូលពីធនធានទ្រព្យរួមមានប្រែប្រួលឬទេ?

## ៦.១ ចំណូលគ្រួសារតាមប្រភព

ក្រៅពីការដាំដំណាំ និងចិញ្ចឹមសត្វ អ្នកភូមិពឹងលើការ ១) ប្រកបរបរកំប៉ិកកំប៉ុក និងកែច្នៃស្បៀងអាហារ, ២) ជួលកំលាំងពលកម្មនៅក្នុង និងក្រៅភូមិ ៣) នេសាទ និងបេះប្រមូលអនុផលព្រៃឈើ និង ៤) រកចំណូលពីមធ្យោបាយផ្សេងទៀត ដូចជា ជួលទ្រព្យសម្បត្តិផ្សេងៗ ។

ចំណូល គឺជាអថេរពិបាកគណនាចេញពីអង្កេតគ្រួសារ ដូច្នេះអ្នកស្រាវជ្រាវភាគច្រើន យកចំណាយរបស់គេ ដើម្បីប៉ាន់ស្មានជំនួស ។ ប៉ុន្តែទិន្នន័យចំណាយមិនអាចប្រើសំរាប់វិភាគ និងប្រៀបធៀបចំណូលពីប្រភពខុសៗគ្នាទេ ។ ដូច្នេះ ក្នុងអង្កេតនេះ មានការប្រឹងប្រែងស្វែងរកទិន្នន័យចំណូល ។ ក្នុងអង្កេតមួយវគ្គៗ បានសាកសួរឱ្យអ្នកឆ្លើយសំភាសន៍ដោយប្រើការចងចាំ ដើម្បី

វាយការណ៍ពីចំណាយតាមប្រភពផ្សេងៗក្នុង ៦ខែ ក្រោយកាលបរិច្ឆេទគោលមួយដែលងាយសំគាល់បានច្បាស់ ។ ភ្ជុំបិណ្ឌឆ្នាំ២០០០ ត្រូវបានប្រើសំរាប់អង្កេតវគ្គ១ និងចូលឆ្នាំថ្មី ២០០១ សំរាប់អង្កេតវគ្គ២ ។ ដូច្នេះចំណូលសរុបសំរាប់មួយឆ្នាំពេញ (តុលា ២០០០ ដល់កញ្ញា ២០០១) ត្រូវបានគណនាក្នុងរយៈពេល ៦ខែ ។ ចំណូលពីប្រភពនីមួយៗមានការកំណត់និយមន័យដូចខាងក្រោម:

១) ចំណូលពី "ការដាំដុះតាមគ្រួសារ" ជាតំលៃដុលនៃផលិតកម្មស្រូវ និងដំណាំផ្សេងទៀត ។ ចំណូលពីកសិកម្ម មានរួមទាំងចំណូលដុលពីការចិញ្ចឹមសត្វតាមគ្រួសារ ផងដែរ ។

២) ចំណូលពី "របរផ្តល់ដោយខ្លួនឯងក្នុងសកម្មភាពមិនមែនកសិកម្ម" គឺជាចំណូលសុទ្ធពីជំនួញ ឬពាណិជ្ជកម្មដំណើរការដោយគ្រួសារ ។

៣) ចំណូលពីការលក់កំលាំងពលកម្ម សំដៅដល់ប្រាក់កំរៃសមាជិកគ្រួសារដែលទៅធ្វើការនៅក្នុង ឬក្រៅភូមិ ឱ្យអ្នកផ្សេង ។ ចំណូលពីការងារចំណាកស្រុក ក៏នៅក្នុងខ្ទង់នេះដែរ ។

៤) ចំណូលពីធនធានទ្រព្យរួមសំដៅដល់ចំណូលជា "សាច់ប្រាក់" ដែលគ្រួសារទទួលបានពីការលក់ផលិតផលប្រមូលបានពីក្នុងវាលស្រែ ផ្ទៃទឹកផ្សេងទៀត ព្រៃ ។ល។ ខ្ទង់ចំនូលនេះ មិនរាប់បញ្ចូលរបស់រកបានសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនទេ ។ ដូច្នេះខ្ទង់ចំណូលនេះ ប៉ាន់ស្មានទាបមួយក៏រិតនូវអត្ថប្រយោជន៍សរុបបានពីធនធានទ្រព្យរួម [40] ។

៥) ចំណូលពីប្រភពផ្សេងទៀត រួមមានការប្រាក់បានពីការឱ្យខ្ចី ប្រាក់ផ្ញើរ និងចំណូលពីការជួលទ្រព្យ ដូចជា ដី គោក្របី ឧបករណ៍ធ្វើស្រែ និងដឹកជញ្ជូន ជាដើម ។

**ក្រាហ្វិក៦.១ ចំណូលគ្រួសារតាមប្រភព (ពាន់រៀល/ឆ្នាំ)**




តារាង៦.១ បង្ហាញពីទិន្នន័យពីចំណូលសរុប និងចំណូលពីប្រភពនីមួយៗ (តួលេខពេញលេញគិតជារៀល និងភាគរយមាននៅក្នុងឧបសម្ព័ន្ធ៥ តារាង១) ។ ចំណូលមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារគិតលើ ៩ភូមិ គឺមានប្រហែល ២,៧៥លានរៀល (ប្រហែល ៧០០ដុល្លារ) សំរាប់ឆ្នាំ២០០០-០១ ដែលផ្តល់តួលេខចំណូលក្នុងមនុស្សម្នាក់ ប្រហែល ១៤០ដុល្លារ/ឆ្នាំ ។ ចំណូល

[40] របស់រកបានសំរាប់ហូបប្រចាំថ្ងៃមិនគិតបញ្ចូល ព្រោះអ្នកភូមិមិនអាចចាំបានតាំងពីរយៈពេល៦ ខែមុនទេ ។

នេះទាបជាងចំណូលមធ្យមថ្នាក់ជាតិ (២៦០ដុល្លារ) ។ ព្រែកក្មេង គឺជាភូមិធូរធារជាងគេ (ចំណូលៈ ៣,៦៣លានរៀល ត្រូវជា ៩៣០ដុល្លារ/គ្រួសារ ឬ ១៨០ដុល្លារក្នុងមួយនាក់ក្នុងមួយឆ្នាំ) បន្ទាប់មកគឺ ភូមិក្រសាំង កំពង់ត្នោត និងបាបោង ។ ភូមិក្រីក្រជាងគេ គឺភូមិនៅតំបន់ខ្ពង់រាប ដែលមានចំណូលសរុបក្នុងមួយគ្រួសារទាបជាង ៥០០ដុល្លារ (ឬ ១០០ដុល្លារ/ម្នាក់) ។

ជាមធ្យម កសិកម្មផ្តល់ចំណូលតែ ២៩% នៃចំណូលសរុប គឺស្មើនឹងចំណូលពីពាណិជ្ជកម្ម និងអាជីវកម្មតូចតាចរកដោយខ្លួនឯង ។ សារៈសំខាន់នៃកសិកម្មប្រែប្រួលទៅតាមតំបន់ធាតុអាកាសកសិកម្ម ។ បាបោងជាភូមិអំណោយផលខាងកសិកម្ម និងមានចំណូលពីកសិកម្មប្លែកខុសគេ ។ នៅឆ្នាំ២០០០-០១ គ្រួសារក្នុងភូមិនេះ រកបានចំណូលមធ្យមលើសពី ២លានរៀល/ឆ្នាំពីរបរកសិកម្ម គឺលើសភូមិផ្សេងៗទៀតពីរដង ។ ចំណូលពីកសិកម្មសំខាន់ស្រូវ តំណាងឱ្យ ២/៣ នៃចំណូលសរុបក្នុងឆ្នាំនោះ ។ នៅ ៣ភូមិតំបន់ខ្ពង់រាប ដែលមានដីកសិកម្មតិច ចំណូលពីកសិកម្មបានមិនដល់ ១/៣ នៃចំណូលក្នុងគ្រួសារទេ ។ ទិន្នន័យនេះបង្ហាញជាសំខាន់ថា កសិកម្មមិនមែនជាប្រភពចំបងសំរាប់ចិញ្ចឹមជីវិតទេ ។ ថ្វីបើគេអាចនិយាយថា ចំណូលពីការលក់ដូរ និងពីការងារស៊ី ប្រាក់កំរៃមានចំណងទាក់ទងផ្ទាល់ជាមួយកសិកម្មក្តី ក៏គេនៅតែត្រូវទទួលស្គាល់ដដែលថា កសិកម្មជាប្រភពចំណូល *មួយ* មិនមែនជាប្រភព *តែមួយ* នោះទេ ។

គ្រួសារនៅភូមិកំពង់ត្នោត ក្រសាំង និងព្រែកក្មេង មានចំណូលច្រើនពីការលក់ដូរ និងអាជីវកម្មតូចតាចរបស់គេ ។ ភូមិក្រៗមានចំណូលតិចក្នុងប្រភេទនេះ ឧទាហរណ៍ ភូមិដងក្តារដែលមានចំណូលសរុប ៣៥៤ដុល្លារ/គ្រួសារ/ឆ្នាំ ក៏មានចំណូលតិចក្នុងប្រភេទខាងលើនេះដែរ ។

ការជួលពលកម្ម រួមទាំងការធ្វើចំណាកស្រុកទៅក្រៅភូមិតំណាងឱ្យ ១៧% នៃចំណូលគ្រួសារសរុប ។ ភូមិក្រសាំងមានចំណូលច្រើនបំផុតពីការងារចំណាកស្រុក គឺមានពលករយ៉ាងច្រើន (ពីសមាជិកគ្រួសារម្នាក់ រហូតដល់ពាក់កណ្តាលគ្រួសារ) ធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ។ នៅឆ្នាំ២០០០-០១ សមាជិកគ្រួសារម្នាក់នៅក្រសាំងរកចំណូលបានជាមធ្យម ១លានរៀលពីការជួលពលកម្ម (២៨%) គឺស្មើនឹង ២ដងនៃចំណូលកសិកម្ម ។ បន្ទាប់មក គឺភូមិត្រពាំងប្រិយ ដែលមានចំណូលពីការលក់ពលកម្ម ៦៣០.០០០រៀល/ឆ្នាំ ។ ប្រភពនេះតំណាងឱ្យ ៣៧% នៃចំណូលសរុបនៅឆ្នាំ២០០០-០១ ។ គេអាចលើកឡើងបានថា ហេតុផលមួយដែលភូមិដងក្តារក្រ គឺមកពីមានឱកាសតិចតួច ដើម្បីលក់កំលាំងពលកម្ម ។

ជាមធ្យមគ្រួសារនីមួយៗរកបាន ២២% នៃចំណូលសរុប ពីធនធានទ្រព្យរួម (ឧបសម្ព័ន្ធ៥ តារាង១) ។ ភូមិធូរធាររកចំណូលពីធនធានទ្រព្យរួមបានច្រើនជាងភូមិក្រីក្រ (លើកលែងតែភូមិបាបោង) ។ ក្នុងភូមិទាំងអស់នៅតំបន់ទន្លេសាប ចំណូលពីធនធានទ្រព្យរួ មមានចំនួនស្មើ ឬលើសចំណូលពីកសិកម្ម ។ សេចក្តីអះអាងនេះ ពិតណាស់សំរាប់ភូមិព្រែកក្មេងដែលចំណូលពីការនេសាទ គឺជាខ្ទង់ចំណូលសំខាន់ ។ ប្រជាជននៅភូមិកញ្ជរ និងដងក្តារ ពឹងផ្អែកជាប្រពៃណីលើធនធានព្រៃឈើ ។ ប៉ុន្តែថ្មីៗនេះលទ្ធភាពប្រើប្រាស់ធនធានព្រៃឈើបានធ្លាក់ចុះ ហើយអ្នកភូមិកំពុងជួបការលំបាក ។ ជាសរុប ទំហំនៃការពឹងផ្អែកលើធនធានព្រៃឈើ ហាក់ដូចជាទាបជាងការនេសាទ រួមទាំងការនេសាទនៅតំបន់ឆ្នេរ សមុទ្រផងដែរ ។

## ៦.២ ការប្រែប្រួលប្រួលប្រភពចំណូលនៅក្នុងអង្កេត ៣ភូមិ

ទិន្នន័យលើ ៣ភូមិ បាបោង ព្រែកក្មេង និងត្រពាំងប្រិយ ដែលបានធ្វើអង្កេតនៅឆ្នាំ១៩៩៦-៩៧ និងនៅឆ្នាំ២០០១ មានបង្ហាញនៅក្នុងក្រាហ្វិក៦.២ក-គ ។ ចំណូលនៅឆ្នាំ២០០១ ត្រូវបានធ្វើការកែតំរូវតាមការិតថ្លៃឆ្នាំ១៩៩៦-៩៧ ដើម្បីអាចប្រៀបធៀបគ្នាបាន ។

ក្រាហ្វិក៦.២ក ការប្រែប្រួលចំណូលគ្រួសារ គិតតាមប្រភពចំណូលនៅភូមិបាបោង ខេត្តព្រៃវែង (ពាន់រៀល/ឆ្នាំ)




ក្រាហ្វិក៦.២ខ ការប្រែប្រួលចំណូលគ្រួសារ គិតតាមប្រភពចំណូលនៅភូមិព្រែកក្មេង ខេត្តកណ្តាល (ពាន់រៀល/ឆ្នាំ)




ក្រាហ្វិក៦.២គ ការប្រែប្រួលចំណូលគ្រួសារ គិតតាមប្រភពចំណូលនៅភូមិត្រពាំងប្រិយ ខេត្តកំពង់ស្ពឺ (ពាន់រៀល/ឆ្នាំ)




គិតតាមចំណូលសរុប ភូមិបាបោង និងព្រែកក្មេង មានកំណើនគួរកត់សំគាល់ពីឆ្នាំ១៩៩៦ ដល់ ២០០១ ចំណែកភូមិត្រពាំងប្រិយមានការធ្លាក់ចុះបន្តិច ។ ជាមធ្យមគ្រួសារនៅបាបោងមានកំណើន ៤៣% ក្នុងចំណូលសរុបក្នុងរយៈ ៥ឆ្នាំ (ឬ ៨%/ឆ្នាំ) ។ ព្រែកក្មេងមានកំណើនខ្ពស់ដល់ ៨២% ដោយសារកំណើនចំណូលនេសាទជាសំខាន់ ។ ផ្ទុយទៅវិញ ភូមិត្រពាំងប្រិយគ្មានកើនចំណូលសោះក្នុងរយៈ ៥ឆ្នាំនេះ ។ តើនិន្នាការនេះអាចពន្យល់បានយ៉ាងណា? ហេតុផលមួយគឺ រាល់សេដ្ឋកិច្ចពឹងផ្អែកលើ

ធនធាន (មិនពឹងលើជំនាញ) ធនធានរូបវ័ន្តបង្កើតចំណូលចំបង ។ នៅភូមិណាដែលមូលដ្ឋានធនធាននេះ បានពង្រីង (កសិកម្ម នៅបាបោង និងនេសាទនៅព្រៃកក្ងង) ចំណូលនៅភូមិនោះក៏កើនឡើង ។ នៅត្រពាំងប្រិយ ដែលមូលដ្ឋានធនធានធ្លាក់ចុះ ហើយការពឹងផ្អែកលើការលក់កំលាំងពលកម្មបានកើនឡើង ដែលធ្វើឱ្យចំណូលធ្លាក់ចុះ ។

ចំណូលពីកសិកម្មក្នុងភូមិទាំង៣ កើនយ៉ាងខ្លាំងពីឆ្នាំ១៩៩៦-២០០១ ។ ភូមិបាបោង មានកំណើនកសិកម្មទ្វេ ពី ៩០១.០០០រៀល/គ្រួសារ ទៅ ១,៧១លានរៀល/គ្រួសារ ។ ការធ្វើប្រពលវប្បកម្មដំណាំស្រូវលើដីល្បាប់ ដោយប្រើប្រាស់ពូជទំនើបៗច្រើន ព្រមទាំងជីគីមី និងប្រព័ន្ធស្រោចស្រព គឺជាហេតុផលចំបងនៃកំណើនចំណូលដ៏ខ្ពស់ ។ ចំណូលពីប្រភពផ្សេងទៀតទាំងអស់បានធ្លាក់ចុះ ។ ចំណែកនៃចំណូលពីកសិកម្មនៅភូមិនេះកើនពី ៥២% នៅឆ្នាំ១៩៩៦-៩៧ ដល់ ៦៩% នៅឆ្នាំ២០០១ (គិតជាតួលេខពិត) រីឯចំណូលពីការងារផ្តល់ដោយខ្លួនឯងក្រៅកសិកម្ម ការងារមានប្រាក់កំរៃ និងធនធានទ្រព្យរួម បានធ្លាក់ចុះយ៉ាងខ្លាំង ។

នៅព្រៃកក្ងង អ្នកភូមិទទួលចំណូលច្រើនពីកសិកម្ម និងធនធានទ្រព្យរួមនៅឆ្នាំ២០០១ បើធៀបនឹងឆ្នាំ១៩៩៦-៩៧ ។ នៅភូមិនេះ កសិកម្មមានរួមទាំង ការដាំកក់ដែលមានតំរូវការខ្ពស់នៅឆ្នាំ២០០១ ។ ប្រភពចំណូលធំបំផុតគឺ ការនេសាទ ។ ចំណូលនេសាទមានកំណើនខ្លាំង គឺអាចបណ្តាលមកពីការលុបចោលជាង ៥០% នៃឡូត៍នេសាទនៅជុំវិញភូមិ ។ គួរកត់សំគាល់ថារដ្ឋាភិបាលបានលុបចោលជាង ៥៦% នៃឡូត៍នេសាទនៅក្រោមរបបសម្បទាននេសាទនៅឆ្នាំ២០០០-០១ ។ លើសពីនេះ ការនេសាទមានសន្ទុះ ដោយសារភូមិនៅជិតទីផ្សារ គឺចំងាយតែ ២៥គ.ម ពីភ្នំពេញ ។

ភូមិត្រពាំងប្រិយដែលអន់ថយ ក៏មានការប្រែប្រួលចំណូលក្នុងរយៈ ៥ឆ្នាំនេះដែរ ។ ចំណូលពីកសិកម្មកើនឡើងពី ២០៥.០០០រៀល/គ្រួសារ ដល់ ៤០៨.០០០រៀល/គ្រួសារ (កំណើន ២០០.០០០រៀល) ឬកើនពី ១៦% ដល់ ៣២% ក្នុងចំណូលសរុបពីឆ្នាំ១៩៩៦ ដល់ ២០០១ ។ តើហេតុអ្វីមានកំណើនបែបនេះ? មូលហេតុចំបងគឺ កសិករចាប់ផ្តើមដាំដំណាំមិនមែនស្រូវច្រើនឡើង ។ ដំណាំទាំងនេះត្រូវការទឹកតិចជាង (ភូមិខ្សត់ទឹក) និងមានទីផ្សារនៅជិត ។ ផ្ទុយទៅវិញ ចំណូលបានពីការងារផ្តល់ដោយខ្លួនឯងក្រៅពីកសិកម្មធ្លាក់ចុះអស់ ២៥៤.០០០រៀល ដែលបានកាត់បន្ថយចំណែករបស់វាពី ៤៥% មកត្រឹម ២៦% ក្នុងរយៈ ៥ឆ្នាំ ។ ការធ្លាក់ចុះនៃចំណូលក្រៅពីកសិកម្ម បណ្តាលមកពីការធ្លាក់ចុះផលិតកម្មស្ករត្នោត ។ គ្រួសារជាច្រើនបោះបង់ចោលរបរជាប្រពៃណីរបស់ខ្លួន ដោយសារអុសដុតរកមិនបាន ឬឡើងថ្លៃពេក ។ ការធ្លាក់ចុះខ្លាំងមួយគឺ ចំណូលពីធនធានទ្រព្យរួម ។ ធនធានផ្សេងៗក្នុងភូមិ ដូចជា កង្កែប ក្តាម និងត្រី ដែលសំបូរគួរសមនៅឆ្នាំ១៩៩៦-៩៧ ឥឡូវបានថយចុះជាខ្លាំង ។ ដោយកំណើនក្នុងចំណូលពីកសិកម្មមិនគ្រប់គ្រាន់សំរាប់ចិញ្ចឹមទាំងអស់គ្នា អ្នកភូមិត្រពាំងប្រិយបានពឹងផ្អែកកាន់តែច្រើនលើចំណាកស្រុកទៅរកការងារធ្វើ ។ ប្រភពនេះបានផ្តល់ចំណូលធំជាងគេ (៤០%) ក្នុងឆ្នាំ២០០១ ។ សឹងតែគ្រប់គ្រួសារមានសមាជិកធ្វើចំណាកស្រុកទៅធ្វើការងារកសិកម្មតាមរដូវកាល (សំខាន់គឺដកស្ទូងស្រូវ) និងការងារគ្មានជំនាញឱ្យអ្នកភូមិផ្សេងទៀត ។ ដោយសារចំណូលពីការងារគ្មានជំនាញមានកំរិតទាប (តិចជាង ៣.៥០០រៀល/ថ្ងៃ) ការពឹងពាក់លើការលក់ពលកម្ម បានចំណូលតិច ទោះបីត្រូវប្រឹងប្រែងច្រើនក៏ដោយ ។

សង្ខេបមក អង្កេតនេះរកឃើញថា ភូមិដែលសំបូរធនធានមានជីវភាពកើនឡើង ឯភូមិអន់ថយ គឺកាន់តែអន់ថយ ។ ឯមូលហេតុគឺ ចំពោះភូមិដែលមានចំណូលចំបងពីប្រភពរូបវ័ន្ត (បាបោង ព្រៃកក្ងង) ធនធានមួយ ឬច្រើន បានរីកលូតលាស់តាមរយៈកំណែលំអការគ្រប់គ្រង ។ ហើយមូលហេតុចំបងមួយដែលធ្វើឱ្យធនធានរីកលូតលាស់ គឺដោយកសិករមានឱកាសល្អ បានពាក់ព័ន្ធនឹងទីផ្សារធំៗ ។ នៅវាលទំនាបទន្លេមេគង្គ ចំណាកស្រុកចេញ និងសកម្មភាពរបស់រដ្ឋាភិបាល និង NGOs បានរួមចំណែកធ្វើឱ្យមានទំនើបកម្ម និងកំណើនធនធាន ។ នៅក្នុងភូមិមានកង្វះខាតធនធាន អ្នកភូមិកាន់តែច្រើន ចាប់យកការងារគ្មានជំនាញ ប៉ុន្តែដោយសារចំណូលពីការងារនេះ បានតិចជាងចំណូលពីប្រភពធនធានរូបវ័ន្ត ចំណូលសរុបនៅត្រពាំងប្រិយ ក៏បានធ្លាក់ចុះ ។

## ៦.៣. ប្រភពចំណូល គិតតាមប្រភេទចំណូល

ដូចបានលើករួចហើយ អ្នកក្រ និងអ្នកធូរធារ ជាទូទៅរកចំណូលពីប្រភពផ្សេងគ្នា ។ ជារឿយៗ អ្នកក្រគ្មានដីទេ ហើយពឹងលើការលក់ពលកម្ម ចំណែកឯអ្នកធូរធារមានទ្រព្យច្រើន រួមទាំងដី ហើយគេរកចំណូលបានពីដីធ្លីច្រើនជាង និង/ឬអាជីវកម្មរបស់គេ ។ ប៉ុន្តែតើចំណូលពីធនធានទ្រព្យរួមមានលំនាំយ៉ាងដូចម្តេច? អង្កេតនេះរកឃើញថា អ្នកក្រពឹងផ្អែកលើធនធានទ្រព្យរួម មានចំនួនច្រើនជាង អ្នកធូរធារ ប៉ុន្តែអ្នកធូរធារ មានមធ្យោបាយច្រើនជាង ដើម្បីធ្វើអាជីវកម្មលើធនធានទ្រព្យរួម ។

ក្រាហ្វិក៦.៣ បង្ហាញពីសារៈសំខាន់នៃចំណូលនីមួយៗ តាមទសភាគចំណូល សំរាប់គំរូតាងសរុបទាំង ៩ភូមិ ។ ជាទូទៅគ្រួសារកាន់តែក្រ អាចរកចំណូលបានកាន់តែតិច ទោះជាពីប្រភពណាក្តី ។ ចំណូលមធ្យម/គ្រួសាររបស់អ្នកធូរធារបំផុត ២០% គឺ ៤,៨៩លានរៀល (១.២៥៥ដុល្លារ)/ឆ្នាំ ចំណែកឯអ្នកក្របំផុត ២០% បានតែ ១,១៤លានរៀល (ឬ ២៩៣ដុល្លារ) ក្នុងឆ្នាំ ២០០០-០១ ។ ប្រភពចំណូលពីកសិកម្មតំណាងឱ្យ ២០% នៃចំណូលសរុបសំរាប់ក្រុមអ្នកក្របំផុត និង ៣៥% សំរាប់ក្រុមអ្នកមានបំផុត ។ ចំពោះអ្នកក្រ ៦០% នៃប្រជាជនសរុបធនធានទ្រព្យរួម (៣០%) ផ្តល់ចំណូលច្រើនជាងកសិកម្ម (២០%) ។ គិតជាតួលេខដាច់ខាត អ្នកធូរធារ រកចំណូលបានច្រើនជាងអ្នកក្រ ពីគ្រប់ប្រភពទាំងអស់ រួមទាំងពីធនធានទ្រព្យរួមផង ។

**ក្រាហ្វិក៦.៣ ប្រភពចំណូលគ្រួសារ តាមបញ្ចភាគនៃក្រុមចំណូល (ពាន់រៀល/ឆ្នាំ)**




សារៈសំខាន់នៃប្រភពចំណូលនីមួយៗ ប្រែប្រួលទៅតាមលក្ខខណ្ឌធាតុអាកាសកសិកម្ម ហើយក៏បានពិនិត្យផងដែរពីសារៈសំខាន់នៃប្រភពចំណូលតាមបញ្ចភាគក្នុងភូមិនីមួយៗនៃប្រព័ន្ធអេកូឡូស៊ីទាំងបួន (ការប្រៀបធៀបភូមិ គិតជាភាគរយ មានចុះក្នុងតារាង៣ ឧបសម្ព័ន្ធ៥) ។

នៅភូមិអណ្តូងត្រាច អ្នកក្របំផុត ២០% ពឹងលើធនធានទ្រព្យរួម និងជួលពលកម្ម ។ ចំណូលពីកសិកម្មមាន ៧% នៃចំណូលសរុបដោយសារអ្នកក្រភាគច្រើនជាអ្នកគ្មានដី ។ អ្នកមានបំផុត ២០% រកចំណូលបាន ៣៦% ពីកសិកម្ម ២៤% ពីធនធានទ្រព្យរួម និង ១៨% ពីការលក់ពលកម្ម ។ នៅក្រសាំងដែលជាភូមិមួយទៀតនៅតំបន់ទន្លេសាប ប្រភពចំណូលមានលំនាំខុសគេច្រើន ។ អ្នកក្រភាគច្រើនជាអ្នកគ្មានដី ដូច្នេះ ចំណូលពីកសិកម្មរកបានតិចតួច ហើយចំណូលប្រហែលពាក់កណ្តាលរកបានពីការលក់ពលកម្ម (ភាគច្រើននៅថៃ) ។ អ្នកធូរធាររកចំណូលបានពីប្រភពចំរុះ ក្នុងនេះចំណូលពីធនធានទ្រព្យរួមមិនលើសពី ១៦% ទេនៅឆ្នាំ២០០១ ។ ភូមិខ្សាច់ជីរស់ ក៏នៅតំបន់ទន្លេសាបដែរ និងមានដីច្រើនជាងភូមិឯទៀត ។ អ្នកក្រីក្របំផុត

អាចរកចំណូលពីដីបានច្រើនជាង (២២%) បើធៀបនឹងភូមិពីរទៀតនៅតំបន់នោះ ។ ប៉ុន្តែទោះជានៅភូមិនេះក្តី ក៏ធនធានទ្រព្យរួមផ្តល់ចំណូលពីរដងច្រើនជាងកសិកម្ម ។

ភូមិពីរនៅតំបន់វាលទំនាបទន្លេមេគង្គ បង្ហាញនូវលំនាំចំណូលផ្ទុយពីភូមិខាងលើ ដោយវាឆ្លុះបញ្ចាំងពីប្រភពចំណូលខុសគ្នា ។ នៅភូមិព្រែកក្មេង អ្នកក្រពឹងផ្អែកខ្លាំងលើធនធានទ្រព្យរួម (៤៥% នៃចំណូលសរុប) ឯចំណូលពីកសិកម្មមានតែ ១៥%នៃចំណូលសរុបប៉ុណ្ណោះ ។ ទោះក្នុងក្រុមអ្នករកចំណូលខ្ពស់បំផុត ២០% ក្តី ក៏ចំណូលពីកសិកម្មមានតែ ១/៣ នៃចំណូលសរុបប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ចំណូលពីកសិកម្មនៅភូមិបាបោង តំណាងឱ្យប្រហែល ៥០% នៃចំណូលសរុបសំរាប់អ្នកក្របំផុត២០% និង ៧០% សំរាប់អ្នកមានបំផុត២០% ។ ធនធានទ្រព្យរួមមានសមាមាត្រ យ៉ាងតូចនៅក្នុងចំណូលសរុប ។

ក្នុង ៣ភូមិនៅតំបន់ខ្ពង់រាប លំនាំនៃប្រភពចំណូលមិនខុសគ្នាច្រើនទេ រវាងក្រុមចំណូលនានា ។ នៅភូមិកញ្ជរ និងត្រពាំងប្រិយ អ្នកក្រក៏ដូចជាអ្នកធូរធារ ទទួលបានចំណូលប្រហែលគ្នាពីកសិកម្ម របរតូចតាច ការលក់ពលកម្ម និងធនធានរួម ។ នៅភូមិត្រពាំងប្រិយ ដែលគ្រួសារភាគច្រើន គឺក្រដូចគ្នា ចំណូលពីធនធានទ្រព្យរួម ជាចំណែកដ៏តូចមួយក្នុងចំណូលសរុបនៃក្រុមចំណូលបញ្ចភាគនានា ។ ការលក់ពលកម្មទៅក្រៅភូមិ គឺជាប្រភពចំណូលធំជាងគេ ។ អ្នកក្រ ២០% នៅភូមិនេះរកបាន ៤៨% នៃចំណូលសរុបដោយការលក់ពលកម្ម ហើយនេះជាអត្រាខ្ពស់បំផុតធៀបនឹងគ្រប់ភូមិ លើកលែងតែភូមិក្រសាំងមួយចេញ ។ ចំណូលពីកសិកម្ម បានទាបបំផុតនៅភូមិតំបន់ឆ្នេរសមុទ្រ ។ មានការពឹងផ្អែកខ្លាំងលើការនេសាទសមុទ្រ និងការស៊ីឈ្នួលធ្វើស្រែអំបិល ។ នៅភូមិកំពង់ត្នោត អ្នកធូរធាររកចំណូលបានពីការផលិតអំបិល (របរផ្តល់ដោយខ្លួនឯងក្រៅពីកសិកម្ម) ។ ផ្ទុយទៅវិញ អ្នកក្រីក្ររកចំណូលពីធនធានទ្រព្យរួម ដែលជាការនេសាទនៅសមុទ្រ ។

## ៦.៤ សារៈសំខាន់នៃធនធានទ្រព្យរួមចំពោះជីវភាពនៅជនបទ

អ្នកក្រីក្រ និងអ្នកគ្មានដីពឹងលើធនធានទ្រព្យរួមដើម្បីរស់ និង/ឬរកចំណូលបន្ថែម ។ ត្រី និងធនធានព្រៃឈើ ជាធនធានទ្រព្យរួមសំខាន់ពីរប្រភេទនៅកម្ពុជា ។ កម្ពុជាមានធនធានត្រីទឹកសាបសំបូរជាងគេនៅអាស៊ីអគ្នេយ៍ ។ កម្ពុជា ក៏មានព្រៃឈើច្រើន ដែលសំបូរទៅដោយជីវៈចំរុះសំរាប់ជួយទ្រទ្រង់ជីវភាពនៅជនបទ ។ ព្រៃឈើគ្របដណ្តប់ប្រហែល ៦០% នៃផ្ទៃដីសរុប នៅឆ្នាំ១៩៩៧ (Chan, Tep and Acharya 2001) ។ ក្រៅពីឈើកាប់ ព្រៃផ្តល់អនុផលជាច្រើន ដូចជា ផ្តៅ ជ័រទឹក ស្លឹក និងផ្លែឈើ ដែលសុទ្ធតែផ្តល់ប្រយោជន៍ដល់ការចិញ្ចឹមជីវិត ។ ក្នុងអង្កេតនេះ ធនធានទ្រព្យរួម មានរាប់បញ្ចូលទាំង សត្វល្អិតអាចហូបបាន បន្លែ និងផលផលអាចហូបបាននានា ដែលប្រមូលបានពីដីគោកធម្មតា និងផ្ទៃទឹកផ្សេងៗ ។

តារាង៦.១ បង្ហាញពីភាគរយនៃគ្រួសារនៅក្នុងភូមិនីមួយៗ ដែលរកកំរៃបានពីប្រភេទផ្សេងៗនៃធនធានទ្រព្យរួម ។ គ្រួសារជាច្រើនដែលប្រើធនធានទ្រព្យរួមសំរាប់ការបរិភោគ ឬការប្រើប្រាស់ផ្ទាល់ខ្លួន និងមិនមែនសំរាប់រកប្រាក់ចំណូល គឺមិនបានគិតបញ្ចូលក្នុងតួលេខនេះទេ ។ ដូច្នេះគួរចងចាំថា អត្ថប្រយោជន៍សរុបបានពីធនធានទ្រព្យរួម មានច្រើនជាងតួលេខចុះក្នុងរបាយការណ៍នេះ ។

ការនេសាទ ជាប្រភពចំណូលមានជាទូទៅ និងសំខាន់ជាងគេ ។ គ្រួសារច្រើនណាស់រកចំណូលជាប្រាក់បានពីការនេសាទក្នុងនេះមានទាំង ២ភូមិក្នុងចំនោម ៣ភូមិនៅតំបន់ខ្ពង់រាបផង ។ ត្រពាំងប្រិយជាភូមិតែមួយដែលមានប្រជាជនតិចតួច អាចរកប្រាក់បានពីការនេសាទ ព្រោះភូមិនេះគ្មានផ្ទៃទឹក ។ កំពង់ត្នោតមានគ្រួសារ ៦៥% រកចំណូលបានពីការនេសាទតាមឆ្នេរសមុទ្រ ។

ការបរបាញ់មានតែចំពោះភូមិដែលមានលទ្ធភាពប្រើប្រាស់ព្រៃ ។ នៅដងក្តារជាភូមិដែលនៅក្នុងព្រៃ អ្នកភូមិរកចំណូលបាន ២២% ពីការបរបាញ់ ។ ក្រៅពីនេះ មានតែភូមិក្រសាំងមួយទេ ដែលនៅជាប់ព្រៃលិចទឹកជុំវិញបឹងទន្លេសាប ដែលមានប្រជាជនច្រើនគួរសម (៨%) រកចំណូលបានពីការបរបាញ់ ។

បន្លែ ផ្លែឈើ និងមើមឈើ រកបានពីព្រៃ ក៏ផ្តល់ចំណូលសន្ធឹកណាស់ដែរ ដល់គ្រួសារជាច្រើនក្នុងភូមិមួយចំនួន ។ នៅក្រសាំង ប្រជាជនជិតពាក់កណ្តាលរកប្រាក់បានពីប្រភពនេះ ពីព្រោះសំបូរត្រកួននៅក្នុងស្រែ ។ ភូមិអណ្តូងត្រាចដែលស្ថិតនៅ តំបន់ជាមួយគ្នានៃវាលទំនាបទន្លេសាប មានស្ថានភាពប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែធនធាននេះមិនសូវសំបូរទេនៅភូមិត្រពាំង ប្រិយ បាបោង កញ្ជរ និងកំពង់ត្នោត ។

**តារាង៦.១ ភាគរយនៃចំណូលពីធនធានរួម**

| | **នេសាទ** | **ប្រមាញ់** | **ប្រមូលបន្លែម** | **ផ្សេងៗ** |
|---|---|---|---|---|
| **វាលទំនាបទន្លេសាប** | | | | |
| អណ្តូងត្រាច | 85 | 2 | 34 | 12 |
| ក្រសាំង | 65 | 8 | 48 | 17 |
| ខ្សាច់ជីរស់ | 93 | 0 | 6 | 3 |
| **វាលទំនាបទន្លេមេគង្គ** | | | | |
| ព្រែកក្មេង | 90 | 0 | 12 | 44 |
| បាបោង | 37 | 0 | 1 | 5 |
| **តំបន់ខ្ពង់រាប** | | | | |
| កញ្ជរ | 30 | 1 | 4 | 54 |
| ដងក្តារ | 70 | 22 | 22 | 81 |
| ត្រពាំងប្រិយ | 3 | 0 | 0 | 18 |
| **តំបន់ឆ្នេរ** | | | | |
| កំពង់ត្នោត | 69 | 0 | 0 | 3 |

*ក្រុម "ផ្សេងៗ" នៅក្នុងតារាង៦.១ មានរួមទាំងចំណូលពីដើមឈើ និងអនុផលព្រៃឈើ សត្វតូចតាច ល្មៀស និងរបស់របរផ្សេងៗពីក្នុងទឹកដែលអាចហូបបាន ។ នៅដងក្តារ ៨១% នៃគ្រួសារនៅតាមភូមិ រកចំណូលពីប្រភពទាំងនេះ ។ នៅកញ្ជរ ដែលជាភូមិមួយនៅជិតព្រៃ ៥៤% នៃគ្រួសាររកចំណូលពីក្នុងប្រភពទាំងនេះ ជាពិសេសប្រមូលស្លឹកទ្រាំង ។ នៅភូមិព្រែកក្មេង ៤៤% នៃគ្រួសាររកចំណូលពីការរបស់របរដែលអាចហូបកើតនៅតាមទឹកបឹងបួរ ។*

នៅភូមិត្រពាំងប្រិយ គ្មានគ្រួសារណារកចំណូលពីការប្រមាញ់ ឬបេះផ្លែឈើនិងបន្លែទេ និងមានគ្រួសារតែ ៣% ទេដែលរកចំណូលពីការនេសាទ ។ គ្រួសារនៅត្រពាំងប្រិយរកចំណូលពីធនធានទ្រព្យរួម ដោយចាប់កង្កែបក្នុងស្រែ ជីកដំឡូងនៅព្រៃជិតៗ និងកាប់កូនឈើនៅព្រៃឆ្ងាយៗ ។ សរុបមក មានគ្រួសារតែ ២១% ប៉ុណ្ណោះដែលរកចំណូលបានពីធនធានទ្រព្យរួម ។

ចំណូលសរុបពីធនធានទ្រព្យរួមគិតតាមភូមិនីមួយៗ បានគណនាចេញពីទិន្នន័យចំណូលតាមប្រភពធនធានរួមខុសៗគ្នា ។ ការគណនានេះសំដៅធ្វើការប្រៀបធៀបសារៈសំខាន់តាមប្រភេទខុសៗគ្នានៃធនធានទ្រព្យរួម នៅ*កំរិតភូមិ* រវាងតំបន់នានា ។ នៅព្រែកក្មេង ចំណូលសរុបពីធនធានទ្រព្យរួមទទួលបានច្រើនបំផុតទាំងនៅកំរិតភូមិ និងគ្រួសារ ។ អ្នកភូមិរកបានប្រហែល ៣៣១លានរៀល/ឆ្នាំ ពីការលក់ត្រីចាប់បាន ។ តួលេខនេះមិនបានគិតចូលត្រីតូចៗចាប់សំរាប់ហូប និងធ្វើចំណីឱ្យត្រីចិញ្ចឹមធំៗស៊ីទេ ។ ក្នុងចំណូលប្រាក់សរុបបានពីធនធានទ្រព្យរួម មាន ៩៥% បានពីការនេសាទ (ឧបសម្ព័ន្ធ៥ តារាង៤ និង ៥) ។ បន្ទាប់ពីព្រែកក្មេង គឺភូមិកំពង់ត្នោតដែលគ្រួសារ ៦៩% រកចំណូលបាន ២៥៣លានរៀល/ឆ្នាំ ពីការនេសាទនៅសមុទ្រ ដែលតំណាងឱ្យ ៩៩% នៃចំណូលសរុបបានពីធនធានទ្រព្យរួម ។

ភូមិទាំងបីនៅតំបន់ទន្លេសាប ក៏រកចំណូលបានពីការនេសាទយ៉ាងច្រើនដែរ ។ ខ្សាច់ជីរស់ ដែលជាភូមិនេសាទរកចំណូលប្រាក់បាន ២២២លានរៀល ត្រូវជា ៩៨% នៃចំណូលសរុបបានពីធនធានទ្រព្យរួម ។ តួលេខនេះផ្តល់ជាចំណូល ៧៤០.០០០រៀល/គ្រួសារ គឺដូចគ្នានឹងភូមិកំពង់ត្នោត ។ ភូមិអណ្តូងត្រាច និងក្រសាំង រកចំណូលពីការនេសាទបានច្រើនដែរ គឺ ៨៣% និង ៦៥% នៃចំនូលសរុបពីធនធានទ្រព្យរួម ។ ភូមិទាំងពីរនេះ មានចំនូលតាមគ្រួសារបានពីធនធានទ្រព្យរួមក៏រិតខ្ពស់ជាងគេក្នុងគំរូតាង ។

ភូមិនានានៅតំបន់ខ្ពង់រាបមិនសូវមានផ្ទៃទឹកច្រើនទេ ដែលជាការចាញ់ប្រៀបមួយសំរាប់ពួកអ្នកភូមិ ។ ការប្រមាញ់មិនមែនជាប្រភពចំណូលធំគួរកត់សំគាល់ទេ ទោះបីភូមិស្ថិតនៅជាប់ព្រៃក្តី ។ នៅភូមិដងក្តារ ថ្វីបើមានអ្នកភូមិជាច្រើនធ្វើប្រមាញ់ក្តី ក៏របរនេះផ្តល់ចំណូលប្រាក់បានតែ ៧% នៃចំណូលសរុបបានពីធនធានទ្រព្យរួមប៉ុណ្ណោះ ។ ក្រសាំងជាភូមិនាំមុខគេក្នុងការបេះប្រមូលបន្លែ ផ្លែឈើ និងដំឡូង ។ ប្រហែល ៥០% នៃគ្រួសាររកចំណូលបាន ៥០០.០០០រៀល/ឆ្នាំ ពីការបេះបន្លែក្នុងស្រែលិចទឹក ។ ប្រភពនេះតំណាងឱ្យ ២៧% នៃចំណូលប្រាក់សរុបបានពីធនធានទ្រព្យរួម ។ ក្រៅពីភូមិក្រសាំង និងអណ្តូងត្រាច ប្រភពចំណូលប្រាក់នេះ មានតិចតួច ឬគ្មានសោះ ។

សរុបមក ផ្នែកនេះបង្ហាញថា ធនធានទ្រព្យរួមមានសារៈសំខាន់ស្ទួលសំរាប់រកចំណូលរបស់ប្រជាជន ហើយធនធានទ្រព្យរួមមានច្រើនមុខណាស់ មិនមែនមានតែការនេសាទ និងកាប់ឈើនោះទេ ។

## ៦.៥ និន្នាការនៃលទ្ធភាពមានធនធានទ្រព្យរួម

ដើម្បីពិនិត្យពីនិន្នាការរកបានធនធានទ្រព្យរួមអ្នកឆ្លើយសំភាសន៍ ត្រូវបានសាកសួរពីការរកបានធនធានរួមក្នុងឆ្នាំនេះធៀបនឹងកាលពី ១ឆ្នាំមុន និង ៥ឆ្នាំមុន ។ តារាង៦.២ និង ៦.៤ លើកឡើងពីចម្លើយសំរាប់កាលពីមួយឆ្នាំមុន ។ គ្រួសារភាគច្រើនរាយការណ៍ថា នៅឆ្នាំ២០០១ ត្រីមានតិចជាងឆ្នាំ២០០០ ។ ក្នុងទាំង ៩ភូមិ, គ្រួសារ ៦៦% រាយការណ៍ថា ធនធានត្រីធ្លាក់ចុះ, ១៨% ថាគ្មានការប្រែប្រួល និង ១៦% ថា ត្រីបានកើនឡើង ។ ទោះបីរបាយការណ៍ទាំងនេះមិនមែនជាការវាយតំលៃតាមបែបវិទ្យាសាស្ត្រក្តី ប៉ុន្តែហាក់ដូចជាច្បាស់លាស់គួរសមដែរដែលថា ធនធានត្រីក្នុង ៩ភូមិ បានធ្លាក់ចុះ ពីព្រោះមានអ្នកឆ្លើយសំភាសន៍ច្រើនលើសលុបបានបញ្ជាក់ដូច្នេះ ។ នៅភូមិព្រែកក្មេង និងខ្សាច់ជីរស់ (ភូមិនេសាទត្រីទឹកសាប) ការចាប់ត្រីនៅឆ្នាំ២០០១ បានតិចជាងឆ្នាំ២០០០ ។ ភូមិនេសាទតំបន់ឆ្នេរ (កំពង់ត្នោត) ក៏ហាក់ដូចមានការថយចុះធនធានត្រីដែរ ។ ប្រជាជនកម្ពុជាបរិភោគខ្យង ក្តាម ល្មៀស ចង្រិត កង្កែប និងបន្លែព្រៃ ជាចំណែកមួយនៃអាហារប្រចាំថ្ងៃរបស់ខ្លួន ។ អ្នកភូមិដែលរាយការណ៍ពីការធ្លាក់ចុះរបស់ហូបបានទាំងនេះ មានច្រើនជាងអ្នកដែលរាយការណ៍ថា គ្មានការប្រែប្រួល ។

**តារាង៦.២ លទ្ធភាពរកបានត្រីនិងធនធានផ្សេងទៀតពីស្រែ និងផ្ទៃទឹកនានា, ធៀបនឹងមួយឆ្នាំមុន (%គ្រួសារឆ្លើយសំភាសន៍)**

| | ត្រី | | ក្តាម ខ្យង | | ចង្រិត | | កង្កែប | | បន្លែ | |
|---|---|---|---|---|---|---|---|---|---|---|
| | ដដែល | តិចជាង | ដដែល | តិចជាង | ដដែល | តិចជាង | ដដែល | តិចជាង | ដដែល | តិចជាង |
| **វាលទំនាបទន្លេសាប** | | | | | | | | | | |
| អណ្តូងត្រាច | 15 | 43 | 43 | 43 | 50 | 50 | 13 | 63 | 35 | 55 |
| ក្រសាំង | 29 | 40 | - | - | 33 | 67 | 80 | 20 | 42 | 8 |
| ខ្សាច់ជីរស់ | 1 | 91 | 45 | 41 | 44 | 41 | 20 | 68 | 6 | 78 |
| **វាលទំនាបទន្លេមេគង្គ** | | | | | | | | | | |
| ព្រែកក្មេង | 11 | 65 | 58 | 4 | - | 100 | - | - | 40 | 60 |
| បាបោង | 21 | 64 | 22 | 78 | - | 100 | - | 100 | - | 11 |
| **តំបន់ខ្ពង់រាប** | | | | | | | | | | |
| កញ្ជរ | 53 | 38 | 43 | 43 | 33 | 60 | 31 | 54 | - | 100 |
| ដងក្តារ | 8 | 86 | 28 | 64 | 13 | 85 | 21 | 72 | 18 | 82 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ត្រពាំងប្រិយ | 24 | 67 | 23 | 34 | 21 | 61 | 2 | 82 | 33 | 38 |
| តំបន់ឆ្នេរ | | | | | | | | | | |
| កំពង់ត្នោត | 25 | 74 | 47 | 29 | 83 | 17 | 46 | 22 | 100 | 0 |
| សរុប | **18** | **66** | **41** | **37** | **32** | **59** | **22** | **63** | **34** | **54** |

អ្នកដែលរាយការណ៍ពីការធ្លាក់ចុះលទ្ធភាពរកធនធាន ក៏បានលើកពីហេតុផលនៃការធ្លាក់ចុះនេះដែរ ។ ហេតុផលទាំងនេះមានចុះក្នុងតារាង៦.៣ ។ ជាសរុប ៣៤% យល់ថាការធ្វើអាជីវកម្មហួសហេតុបានបង្កការធ្លាក់ចុះ ៤២% យល់ថា មកពីការប្រើគ្រឿងឆក់ និងគ្រឿងផ្ទុះ ១៣% ថាមកពីកំណើនប្រជាជនខ្ពស់ និង ១០% ថាមកពីការដាក់កំរិតលើលទ្ធភាពប្រើប្រាស់ធនធានដោយចំហ ។ ចម្លើយថាមានការប្រែប្រួលដោយសារទំងន់នៃហេតុផល នីមួយៗមានកំរិតខុសគ្នាពីភូមិមួយទៅភូមិមួយទៅតាមលក្ខខណ្ឌ និងឧបសគ្គជាក់ស្តែងក្នុងភូមិរបស់ពួកគេ ។

**តារាង៦.៣ មូលហេតុចំបងៗនៃការថយចុះ ត្រី និងជលផលចំបងៗផ្សេងទៀត (%របាយអ្នកឆ្លើយសំភាសន៍)**

| | អាជីវកម្មហួសហេតុ | កំណើនប្រជាជនខ្ពស់ | ការរាំងមិនឱ្យប្រើប្រាស់ក្រៅច្បាប់ | ការប្រើប្រាស់គ្រឿងឆក់ និងគ្រឿងផ្ទុះ | ការរាំងមិនឱ្យប្រើប្រាស់តាមច្បាប់ | សរុប |
|---|---|---|---|---|---|---|
| **វាលទំនាបទន្លេសាប** | | | | | | |
| អណ្តូងត្រាច | 42 | 15 | 3 | 27 | 12 | 100 |
| ក្រសាំង | 7 | 22 | 0 | 70 | 0 | 100 |
| ខ្សាច់ជីរស់ | 26 | 13 | 3 | 54 | 4 | 100 |
| **វាលទំនាបទន្លេមេគង្គ** | | | | | | |
| ព្រែកក្មេង | 28 | 7 | 0 | 6 | 59 | 100 |
| បាបោង | 9 | 34 | 0 | 55 | 2 | 100 |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 63 | 32 | 0 | 5 | 0 | 100 |
| ដងក្តារ | 22 | 5 | 0 | 73 | 0 | 100 |
| ត្រពាំងប្រិយ | 0 | 15 | 0 | 85 | 0 | 100 |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 100 | 0 | 0 | 0 | 0 | 100 |
| **សរុប** | **34** | **13** | **1** | **42** | **10** | **100** |

**តារាង៦.៤ និន្នាការនៃលទ្ធភាពរកធានធានព្រៃឈើ និងធនធានទាក់ទិននឹងព្រៃឈើធៀបនឹង១ឆ្នាំមុន (%នៃរបាយគ្រួសារ)**

| | រកឧស | | ឈើ | | ឫស្សី | | សត្វព្រៃ | | ជ័រ | | ឧបករណ៍ធ្វើកន្ទេល | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដដែល | តិចជាង | ដដែល | តិចជាង | ដដែល | តិចជាង | ដដែល | តិចជាង | ដដែល | តិចជាង | ដដែល | តិចជាង |
| **វាលទំនាបទន្លេសាប** | | | | | | | | | | | | |
| អណ្តូងត្រាច | 14 | 54 | 6 | 91 | 9 | 77 | .. | 100 | .. | .. | .. | .. |
| ក្រសាំង | 85 | 11 | 100 | .. | .. | .. | 33 | 67 | .. | 100 | 100 | .. |
| ខ្សាច់ជីរស់ | 16 | 78 | .. | 100 | 50 | 50 | .. | 100 | .. | 50 | 30 | 61 |
| **វាលទំនាបទន្លេមេគង្គ** | | | | | | | | | | | | |
| ព្រែកក្មេង | 19 | 79 | 100 | .. | .. | 100 | .. | .. | .. | .. | 25 | 75 |
| បាបោង | 2 | 98 | .. | .. | 33 | 33 | .. | .. | .. | .. | 100 | .. |
| **តំបន់ខ្ពង់រាប** | | | | | | | | | | | | |
| កញ្ជរ | 46 | 53 | 2 | 98 | .. | 100 | .. | 50 | .. | .. | .. | 100 |
| ដងក្តារ | 57 | 43 | 5 | 95 | 25 | 75 | .. | 100 | 3 | 97 | 29 | 57 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ត្រពាំងប្រិយ | 20 | 76 | .. | 100 | .. | .. | .. | .. | .. | 50 | .. | .. |
| **តំបន់ឆ្នេរ** | | | | | | | | | | | | |
| កំពង់ត្នោត | 37 | 54 | 40 | 60 | .. | .. | .. | .. | .. | .. | .. | .. |
| សរុប | **31** | **64** | **16** | **83** | **13** | **72** | **3** | **92** | **2** | **89** | **23** | **69** |

តារាង៦.៤ បង្ហាញពីនិន្នាការនៃលទ្ធភាពរកអុស ឈើ ទំពាំង សត្វព្រៃ ជ័រ និងគ្រឿងធ្វើកន្ទេល ។ និន្នាការសំរាប់ភូមិទាំងអស់ក្នុងតារាងនេះ ប្រហាក់ប្រហែលគ្នានឹងក្នុងតារាង៦.២ ។ ភាគច្រើននៃគ្រួសារដែលធ្លាប់រកបាន ឥឡូវរាយការណ៍ថា ធនធានក្នុងឆ្នាំ២០០១ បានថយចុះជាងឆ្នាំមុន ។

ដូចបានបញ្ជាក់ក្នុងជំពូកទី២ ស្ទើរគ្រប់គ្រួសារក្នុងគ្រប់ភូមិ ប្រើអុសដុតចំអិនអាហារ ។ នៅភូមិ ខ្សាច់ជីរស់ ព្រៃកក្មេង បាបោង និងត្រពាំងប្រិយ គ្រួសារជាង ៧៥%រាយការណ៍ថា លទ្ធភាពរកអុសឥឧសដុតបានថយចុះ ។ នេះជាការបារម្ភចំបងមួយ ដោយហេតុថា ឋាមពលផ្សេងទៀតសំរាប់ចំអិន មិនអាចរកបាន ឬ ថ្លៃហួសលទ្ធភាពទិញប្រើប្រាស់ ។

**តារាង៦.៥ ការឆ្លើយតបនឹងមូលហេតុចំបង១នៃការថយវចុះធនធានព្រៃឈើ (%របាយគ្រួសារ)**

| | អាជីវកម្ម ហួសហេតុ | កំណើន ប្រជាជនខ្ពស់ | អ្នកផ្សេងកាន់កាប់ ព្រៃឈើផ្តាច់មុខ | ការរារាំងមិនឱ្យប្រើ ប្រាស់តាមច្បាប់ | សរុប |
|---|---|---|---|---|---|
| **ទំនាបទន្លេសាប** | | | | | |
| អណ្តូងត្រាច | 17 | 64 | 4 | 14 | 100 |
| ក្រសាំង | 0 | 100 | 0 | 0 | 0 |
| ខ្សាច់ជីរស់ | 20 | 52 | 0 | 28 | 100 |
| **ទំនាបទន្លេមេគង្គ** | | | | | |
| ព្រៃកក្មេង | 43 | 49 | 8 | 0 | 100 |
| បាបោង | 33 | 67 | 0 | 0 | 100 |
| **តំបន់ខ្ពង់រាប** | | | | | |
| កញ្ជរ | 69 | 22 | 0 | 9 | 100 |
| ដងក្តារ | 67 | 5 | 26 | 2 | 100 |
| ត្រពាំងប្រិយ | 78 | 17 | 0 | 6 | 100 |
| **តំបន់ឆ្នេរ** | | | | | |
| កំពង់ត្នោត | 16 | 2 | 0 | 82 | 100 |
| សរុប | **39** | **40** | **5** | **15** | **100** |

អ្នកភូមិគ្រប់គ្នានៅខ្សាច់ជីរស់ និងត្រពាំងប្រិយ និងស្ទើរគ្រប់គ្នា នៅភូមិកញ្ជរ ដងក្តារ និងអណ្តូងត្រាច រាយការណ៍ថា ឈើបានថយចុះ ។ និន្នាការនេះប្រហែលគ្នានឹងនិន្នាការនៃប្រភពធនធានផ្សេងទៀតដែរ ។ ដោយសារមានការហាមឃាត់មិនឱ្យចូលព្រៃ អ្នកភូមិកញ្ជរ ដើម្បីដោះស្រាយអុសដុត បានពឹងផ្អែកលើការប្រមូលស្លឹកទ្រាំង ។ ប៉ុន្តែ អ្នកឆ្លើយសំភាសន៍ទាំងអស់បានរាយការណ៍ដែរថា ស្លឹកទ្រាំងនេះក៏ថយចុះដែរ ។

តាមអ្នកឆ្លើយសំភាសន៍ ការធ្វើអាជីវកម្មហួសហេតុ និងកំណើនប្រជាជនច្រើន បានធ្វើឱ្យធ្លាក់ចុះលទ្ធភាពរកបានអុស និងធនធានព្រៃឈើផ្សេងទៀត (តារាង៦.៥) ។ នៅ "កំរិតគ្រប់ភូមិ" ៣៩% នៃគ្រួសារមានលទ្ធភាពរកធនធានព្រៃឈើយល់ថាមកពីការធ្វើអាជីវកម្មហួសហេតុ និង ៤០% ទៀតគិតថាមកពីកំណើនប្រជាជនច្រើន ។ ចំពោះភូមិមានលទ្ធភាពប្រើប្រាស់ព្រៃច្រើន (តំបន់ខ្ពង់រាប) ភាគច្រើនគិតថាមកពីការធ្វើអាជីវកម្មហួសហេតុ ។ តើអ្វីដែលបង្កឱ្យមានការធ្វើអាជីវកម្មហួសហេតុ? ការសិក្សារបស់យើងមិនផ្តល់ចម្លើយពីរឿងនេះទេ ប៉ុន្តែមានការសិក្សាផ្សេងទៀតបានលើកថា ការដាក់បញ្ចូលសេដ្ឋកិច្ច

ទីផ្សារដោយពុំមានច្បាប់គ្រប់គ្រងមានអ្នកពាក់ព័ន្ធជាច្រើននៅក្នុងគ្រប់វិស័យសំខាន់ៗនៃធនធានធម្មជាតិ បានលេចមុខទាមទារដីធ្លី ទឹក ព្រៃឈើ និងត្រី (So, et al. 2001) ។ ដោយសារកង្វះប្រព័ន្ធច្បាប់ដ៏សក្តិសិទ្ធិសំរាប់ទីផ្សារ ការធ្វើអាជីវកម្មគ្មានលក្ខណៈវិទ្យាសាស្ត្រនូវធនធានធម្មជាតិក៏កើតមានឡើងយ៉ាងច្រើន ។ កំណើនសម្ពាធប្រជាជន បានធ្វើឱ្យបញ្ហាកាន់តែស្មុគស្មាញថែម ។

ការប្រែប្រួលក្នុងចំងាយផ្លូវធ្វើដំនើរទៅប្រមូលធនធានទ្រព្យរួម ក៏ជាសញ្ញាសំខាន់បង្ហាញពីការធ្លាក់ចុះធនធានធម្មជាតិដែរ ។ អ្នកភូមិត្រូវបានសាកសួរពីចំងាយផ្លូវទៅដល់ផ្ទៃទឹក និងព្រៃដើម្បីប្រមូលធនធានធម្មជាតិនៅឆ្នាំ២០០១ ធៀបនឹងឆ្នាំ១៩៩៨ (ឧបសម្ព័ន្ធ៥ តារាង៦)[៤១] ។ ៧០% នៃគ្រួសារឆ្លើយសំភាសន៍រាយការណ៍ថា គ្មានប្រែប្រួល, ឯ ៣០%ទៀតរាយការណ៍ថា ត្រូវធ្វើដំណើរឆ្ងាយជាងមុន ដើម្បីចាប់ត្រី ឬប្រមូលធនធានជលផលផ្សេងទៀត ។ ឯចំងាយផ្លូវទៅប្រមូលធនធានព្រៃឈើបានកើនជាងមុនសំបើមណាស់ ។ នៅភូមិកញ្ជរ និងដងក្ពារ ដែលពឹងជាសំខាន់លើព្រៃឈើ មានគ្រួសារ ៩១% និង ៧៦% រៀងៗគ្នា រាយការណ៍ថា ត្រូវធ្វើដំណើរឆ្ងាយជាងមុនដើម្បីទៅប្រមូលធនធានព្រៃឈើ ។ គិតជាសរុប ៥២% នៃគ្រួសារទាំងអស់រាយការណ៍ថា ត្រូវធ្វើដំណើរឆ្ងាយជាងមុនដើម្បីទៅប្រមូលធនធានព្រៃឈើ ។

## ៦.៦ សេចក្តីសន្ទេប

លទ្ធផលសំខាន់ៗបានពីការវិភាគទិន្នន័យនៅក្នុងជំពូកនេះគឺ :

ក) របរដាំដុះ ជាប្រភពចំណូលមួយនៅជនបទកម្ពុជា ហើយមិនមែនជាប្រភព*តែមួយ* ដូចប្រជាជនតែងគិតនោះទេ ។ ក្នុងករណីជាច្រើន វាមិនមែនជាប្រភពសំខាន់បំផុតនោះទេ ពិសេសសំរាប់អ្នកក្រ ។ ការងារមានប្រាក់កំរៃកំពុងក្លាយជារបរដ៏សំខាន់មួយ ។

ខ) ដោយលទ្ធភាពរកធនធានទ្រព្យរួមកាន់តែលំបាក អ្នកភូមិកាន់តែពឹងខ្លាំងលើចំណូលផ្អែកលើពលកម្ម ។ ប៉ុន្តែដោយសារកំរិតដ៏ទាបនៃប្រាក់ចំណូលលើពលកម្មគ្មានជំនាញ ដូច្នេះចំណូលក៏បានថយចុះ ។

គ) ធនធានទ្រព្យរួមផ្តល់ផលិតផលច្រើនមុខដែលជាស្បៀងអាហារដ៏សំខាន់ ប៉ុន្តែជារឿយៗ គេមិនបានយកមកគិតចូលទៅក្នុងអង្កេតជាច្រើន ។

ចំណូលគ្រួសារមធ្យមក្នុងភូមិនានាស្ថិតនៅទាបជាងចំណូលមធ្យមជាតិ ។ ទោះក្នុងភូមិមានការអភិវឌ្ឍន៍ខ្លាំងក្តី ក៏គ្រួសារមួយអាចរកចំណូលបានតែ ៩៣០ដុល្លារ/ឆ្នាំ ធៀបនឹងមធ្យមចំណូលជាតិ ១.៣០០ដុល្លារ ។ នៅតាមភូមិដែលបានធ្វើអង្កេតឡើងវិញ កសិកម្មបានរីកចំរើនគួរឱ្យកត់សំគាល់ក្នុងរយៈ ៥ឆ្នាំ និងបានកើនចំណែកនៅក្នុងចំណូលសរុប ។ ប៉ុន្តែ (យ៉ាងហោចណាស់ក៏មានមួយភូមិដែរ) ចំណូលពីធនធានទ្រព្យរួម និងរបរក្រៅកសិកម្មផ្តល់ដោយខ្លួនឯង បានធ្លាក់ចុះយ៉ាងខ្លាំង និងត្រូវជំនួសដោយចំណូលពីការលក់ពលកម្ម ។ ដូចបានបញ្ជាក់ពីខាងដើមរួចហើយ ចំណូលពីការលក់ពលកម្មទាបជាងចំណូលពីប្រភពផ្សេង ។ ជាវិបាកចំណូលសរុបនៅភូមិនេះបានធ្លាក់ចុះ ។

គ្រួសារក្រីក្រ ពឹងលើធនធានទ្រព្យរួមខ្លាំងជាងគ្រួសារមិនក្រ ប៉ុន្តែគ្រួសារមិនក្រ រកចំណូលពីធនធានទ្រព្យរួមបានច្រើនជាងគ្រួសារក្រីក្រ ។ ពីមួយឆ្នាំទៅមួយឆ្នាំហាក់ដូចមានការធ្លាក់ចុះលទ្ធភាពរកធនធានរួម ។ ក្រៅពីភូមិដែលទទួលផលពីការលុបឡូត៍នេសាទចេញខ្លះ ចំណូលពីធនធានទ្រព្យរួមបានថយចុះខ្លាំងណាស់ ។ អ្នកភូមិតឡូវត្រូវធ្វើដំណើរកាន់តែឆ្ងាយដើម្បីប្រមូលធនធនពីព្រៃឈើ និងផ្ទៃទឹក ។ ពួកគេបន្ទោសលើការធ្វើអាជីវកម្មហួសហេតុ និងការប្រើប្រាស់ឧបករណ៍ខុសច្បាប់ ចំពោះ

[៤១] បានជ្រើសយកឆ្នាំ១៩៩៨ សំរាប់ធ្វើការប្រៀបធៀប ដោយសារប្រជាជននៅចាំបានច្បាស់ ពីព្រោះជាឆ្នាំបោះឆ្នោត ។

ការថយចុះធនធានទ្រព្យរួម (ជាពិសេសផលនេសាទ) ។ ផលប៉ះពាល់នៃការថយចុះចំណូលពីធនធានទ្រព្យរួម វាធ្លាក់ធ្ងន់ទៅលើអ្នកក្រជាងអ្នកមិនក្រ ។

# ជំពូកទី ៧

# ការបរិភោគ និងសន្តិសុខស្បៀង

ការពិភាក្សាយ៉ាងសកម្មពីសន្តិសុខស្បៀងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានចំណូលទាបបានផ្តួចផ្តើមធ្វើឡើងនៅ ៥០ឆ្នាំចុងក្រោយនៃសតវត្សរ៍ទី២០ (Sen 1980; Dreze and Sen 1991) ។ ការពិភាក្សានេះបន្តមានតំលៃរហូតមកដល់សព្វថ្ងៃ ចំពោះប្រទេសដែលផលិតស្បៀងបានគ្រប់គ្រាន់ ក៏ដូចជាប្រទេសដែលផលិតស្បៀងមិនគ្រប់គ្រាន់ ។ រហូតមកទល់ពីរបីឆ្នាំមុននេះ កម្ពុជាស្ថិតក្នុងក្រុមប្រទេសផលិតស្បៀងមិនគ្រប់គ្រាន់ ។ ប៉ុន្តែក្រោយឆ្នាំ១៩៩៩ ផលិតកម្មស្បៀងសរុបរបស់កម្ពុជាកើនលើសការប្រើប្រាស់សរុប ហើយជាលទ្ធផលកម្ពុជាត្រូវបានចាត់ចូលក្នុងចំណោមប្រទេសផលិតស្បៀងគ្រប់គ្រាន់វិញ ។

នៅកម្ពុជាក៏ដូចជាប្រទេសផ្សេងទៀតដែរ ផលិតកម្មស្បៀងសរុបបានកើនឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗ ពីព្រោះតំបន់មួយចំនួន និង/ឬកសិករមួយចំនួននៅតាមខេត្តខ្លះៗ បានចាប់ផ្តើមផលិតស្បៀងមានអតិរេកច្រើនៗ ។ ក្នុងកំឡុងពេលនេះដែរ ក៏មានកសិករ និងពលករមិនមែនកសិករដែលមានធនធានតិច ដែលរស់នៅក្នុងតំបន់មានឱនភាពស្រូវក៏ដូចជាតំបន់មានអតិរេកស្រូវ និងដែលមិនអាចរកចំណូលបានគ្រប់គ្រាន់ដើម្បីមានស្បៀងហូបឆ្អែតពេញមួយឆ្នាំនោះដែរ ។ ពួកគេជួបបញ្ហាខ្វះស្បៀងតាមរដូវ ឬខ្វះពេញមួយឆ្នាំតែម្តង ។ គ្មានយន្តការស្វ័យប្រវត្តិអ្វីសំរាប់នាំស្បៀងអតិរេក (របស់កសិករខ្លះៗ) ឱ្យទៅដល់អ្នកជួបឱនភាពស្បៀងនោះទេ ។ "វិធីសាស្រ្តមានសិទ្ធិ (entitlement approach)" ដ៏ល្បីទាក់ទិននិងភាពក្រីក្របានបង្ហាញថា យ៉ាងដូចម្តេច និងតាមយន្តការអ្វីខ្លះ ដែលអ្នកខ្លះមានសិទ្ធិទទួលបានស្បៀង ឯអ្នកខ្លះទៀតគ្មានសិទ្ធិទេ (Sen 1980) ។

ការពិភាក្សាពីភាពក្រីក្រ បានលើកបញ្ហាស្បៀងមកពិនិត្យជាដំបូង: តើប្រជាជនគ្រប់គ្នាមានលទ្ធភាពរកបានស្បៀងដែរឬទេ ។ បន្ទាប់មកគេពិនិត្យពីលទ្ធភាពមានអ្វីប្រើប្រាស់ក្រៅពីស្បៀង (ទំនិញ និងសេវាជាសំខាន់) ។ ទិដ្ឋភាពទាំងនេះ វាទាក់ទិននឹងប្រជាជនរស់នៅតាមភូមិក្នុងប្រទេសកម្ពុជា ។

ជំពូកនេះមានគោលបំណងដៅ:

១) វាយតំលៃទំហំនៃការប្រើប្រាស់ស្បៀង និងរបស់ផ្សេងទៀតគិតជាសរុប និងគិតតាមក្រុមសេដ្ឋកិច្ច

២) វាស់វែងពីទំហំ និងជំរៅនៃភាពក្រីក្រ

៣) កំណត់ពីលក្ខណៈរដូវកាលនៃលទ្ធភាពមានស្បៀង

៤) ប្រៀបធៀបលទ្ធផលនៃអង្កេតនេះ ទៅនឹងលទ្ធផលអង្កេតឆ្នាំ១៩៩៦-៩៧ ។

ដោយសារអង្កេតនេះបានធ្វើជាពីរវគ្គ គេអាចវាយតំលៃទាំងពីរស្ថានភាពមានស្បៀងច្រើន (រដូវប្រាំង) និងស្ថានភាពមានស្បៀងតិច (រដូវវស្សា) ។ ទិន្នន័យបានប្រមូលលើការបរិភោគតាមមុខស្បៀងសំខាន់ៗ ។ លើសពីនេះ បានប្រមូលពត៌មានលើទ្រព្យមិនមែនស្បៀង ទាំងទ្រព្យជាប់លាប់ និងមិនជាប់លាប់ ។ រយៈពេលរំលឹកការចងចាំលើការបរិភោគស្បៀងគឺ ១ សប្តាហ៍មុន និងលើការប្រើប្រាស់ទ្រព្យមិនមែនស្បៀងគឺ ពី ១សប្តាហ៍ ទៅ ៦ខែតាមប្រភេទទ្រព្យ ។ ទ្រព្យមួយចំនួនដែលបាន

ផលិត ឬប្រមូលសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន គឺបានគិតតម្លៃទៅតាមថ្លៃទីផ្សារ ។ ការងារនេះផ្អែកទាំងស្រុងលើការវាយតំលៃស្បៀង និងទ្រព្យមិនមែនស្បៀងជាទឹកប្រាក់ ។ រឿងនេះអាចមានលំអៀងខ្លះ ដោយហេតុថាកំរិតថ្លៃនានាអាចមិនស៊ីគ្នាល្អជាមួយស្បៀង ឬតំលៃប្រើប្រាស់ទ្រព្យនៅក្នុងបរិបទនេះទេ ។ ប៉ុន្តែគ្មានមធ្យោបាយអ្វីដើម្បីចៀសវាងរឿងនេះទេ ពីព្រោះគេមិនអាចធ្វើការវាយតំលៃពីការប្រើប្រាស់សរុប ឬក៏ប្រៀបធៀបការប្រើប្រាស់តាមគ្រួសារដោយគិតគូរតែតាមចំនួនឯកតារូបវន្តនោះបានទេ[៤២] ។

ភាពក្រីក្រក្នុងប្រទេសមានចំណូលទាបត្រូវបានវាស់វែងតាមបទដ្ឋានអាហារូបត្ថម្ភ ។ បទដ្ឋានអាហារូបត្ថម្ភ ២១០០ កាឡូរី/មនុស្សពេញវ័យ/ថ្ងៃ គឺជាកំរិតអប្បបរិមា បើតិចជាងនេះទៀត គេចាត់ថាមនុស្សនោះស្ថិតក្រោមបន្ទាត់ក្រីក្រ ។ ប៉ុន្តែដោយសារមនុស្សម្នាក់ៗ មានជំរើសអាហារ និងចំណូលចិត្តផ្សេងគ្នា ដូច្នេះគេតែងទទួលស្គាល់ថា បើសិនមនុស្សម្នាក់មានលទ្ធភាពទិញ/រកបានអាហារមានតំលៃស្មើនឹង ២១០០កាឡូរីស្បៀងមនុស្សនោះមិនស្ថិតនៅក្រោមបន្ទាត់ក្រីក្រទេ ។

## ៧.១ ការបរិភោគអាហារសរុប

### *៧.១.១ ការបរិភោគអង្ករ និងស្បៀងសរុប*

តារាង៧.១ ផ្តល់ទិន្នន័យពីការប្រើប្រាស់ប្រចាំខែក្នុងមនុស្សម្នាក់ចំពោះអាហារ និងអីវ៉ាន់មិនមែនអាហារគិតជាមធ្យមក្នុងភូមិ និងគិតជារៀល ។ ការប្រៀបធៀបទី១ គឺលក្ខណៈខុសគ្នាតាមភូមិក្នុងលំនាំនៃការប្រើប្រាស់ ។ ចំណាយសរុបជាមធ្យមគិតលើ ៩ភូមិគឺ ៣៧.៩២១រៀល/ម្នាក់/ខែ ដែលមានតាំងពីកំរិតខ្ពស់ ៥១.៦៥៥រៀលនៅភូមិកំពង់ត្នោតនៅតំបន់ឆ្នេរ, និង ២២.៣៩៣រៀលនៅត្រពាំងប្រិយក្នុងតំបន់ខ្ពង់រាប មានឱនភាពស្រូវ ។ ភូមិព្រៃកក្ដេង និងក្រសាំង មានចំណាយមធ្យមខ្ពស់ក្នុងមនុស្សម្នាក់ (ខ្ពស់ជាងកំរិតមធ្យម) រីឯភូមិអណ្តូងត្រាច ដងក្តារ និងខ្សាច់ជីរស់ មានចំណាយសរុបទាបក្នុងមនុស្សម្នាក់ ។ កំពង់ត្នោតមានតួលេខចំណាយប្រើប្រាស់សរុបខ្ពស់ណាស់ ។ មូលហេតុគឺ ប្រជាជននៅភូមិនេះ បរិភោគរបស់សមុទ្រច្រើន ដែលជាអាហារមានតំលៃខ្ពស់ ។ ប៉ុន្តែ មិនមែនគ្រប់ៗគ្នាសុទ្ធតែទិញរបស់សមុទ្រហូបនោះទេ ប៉ុន្តែ ភាគច្រើនណាស់រកបានរបស់សមុទ្រមកបំរើការហូបចុកផ្ទាល់ខ្លួន (Kim, Chan and Acharya 2002) ។

ចំណែកសរុបនៃអាហារក្នុងចំណាយប្រើប្រាស់សរុប (គ្រប់ភូមិ) គឺ ៦៨% ដែលកៀកគ្នានឹងតួលេខក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៧ និង ១៩៩៩ និងក្នុងអង្កេត វបសអ ពីមុន[៤៣] ។ ភូមិក្រសាំង និងបាបោងប្លែកពីគេ ដោយការបរិភោគអាហារមានចំនែកតូច ។ ចំនែកស្បៀងនៅក្នុងចំណាយគ្រួសារសរុបក្នុងភូមិទាំងពីរ គឺតិចជាង ៦០%, រីឯក្នុងភូមិផ្សេងៗទៀតគឺ ៧០% ឬច្រើនជាង ។ ចំនែកតូចនៃស្បៀងនៅក្នុងចំនាយគ្រួសារតាមធម្មតាបញ្ជាក់ថា គ្រួសារមានស្ថានភាពធូរធារ ពីព្រោះអ្នកក្រមិនអាចចំនាយច្រើនលើអីវ៉ាន់មិនមែនអាហារទេ ។ ភូមិទាំងពីរនេះមានអតិរេកស្រូវ ហើយក៏អាចជាភូមិធូរធារដែរ ។ ភូមិមានឱនភាពស្រូវទាំងពីរ ត្រពាំងប្រិយ និងអណ្តូងត្រាច ស្ថិតនៅក្រោមគេ ចំណែកឯភូមិខ្សាច់ជីរស់ និងដងក្តារ (គ្មានអតិរេកស្រូវទេ) ក៏ស្ថិតនៅក្រោមមធ្យមដែរ ។ ភូមិទាំងអស់នេះបង្ហាញ ចំណែកខ្ពស់នៃស្បៀងនៅក្នុងចំណាយប្រើប្រាស់សរុប ។ តើ

[៤២] ក្នុងការសិក្សាជាច្រើន អ្នកសិក្សាបានគណនាចំនួនកាល់ឡូរីនៃអាហារមួយមុខៗ ។ វិធីនេះមានភាពល្អិតល្អន់ ប៉ុន្តែមិនអាចគណនាចំនួនកាល់ឡូរីសំរាប់គ្រប់មុខម្ហូបអាហារបានទេ ពីព្រោះមានច្រើនមុខពេក តាំងពីត្រី សាច់ បន្លែ ផ្លែឈើ និងអង្ករ ។

[៤៣] អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ បង្ហាញតួលេខ ៦៥% សំរាប់ជនបទកម្ពុជា ។ តួលេខអង្កេតឆ្នាំ១៩៩៦-៩៧ ដាក់ក្នុងវង់ក្រចកក្នុងតារាង៧.១ ។ តួលេខជាច់ខាតនីមួយៗហាក់ដូចជាខ្ពស់ ដែលជារឿងធម្មតាសំរាប់ប្រទេសមានចំណូលទាប ។

គេអាចសន្និដ្ឋាន "មានអតិរេកស្រូវ គឺបានន័យថាមានកំរិតជីវភាពខ្ពស់នៅកំរិតភូមិ" ដូច្នេះបានឬទេ? ដើម្បីឆ្លើយតបនឹងសំណួរនេះ ជំពូកទី៧ នឹងមានផ្ដល់នូវការវិភាគច្រើនទៀតនៅខាងក្រោយ[៤៤] ។

**តារាង៧. ១ ការហូបស្បៀង និងចំណាយសរុប សំរាប់ឆ្នាំ២០០១ និង ១៩៩៦-៩៧ (ក្នុងមនុស្សម្នាក់ក្នុង១ឆ្នាំ)**

| | ចំណាយលើស្បៀង | | សរុបចំណាយលើស្បៀង |
|---|---|---|---|
| | រៀល/ខែ | ភាគរយនៃចំណាយសរុប | រៀល/ខែ |
| **ទំនាបទន្លេសាប** | | | |
| អណ្ដូងត្រាច | 20,910 | 72 | 28,866 |
| ក្រសាំង | 23,143 | 57 | 40,422 |
| ខ្សាច់ជីរស់ | 24,098 | 72 | 33,694 |
| **ទំនាបទន្លេមេគង្គ** | | | |
| ព្រែកក្មេង | 33,925 | 70 (78) | 48,786 |
| បាបោង | 22,719 | 59 (69) | 38,554 |
| **តំបន់ខ្ពង់រាប** | | | |
| កញ្ជរ | 25,588 | 70 | 36,396 |
| ដងក្ដារ | 21,936 | 70 | 31,387 |
| ត្រពាំងប្រិយ | 17,563 | 78 (66) | 22,393 |
| **តំបន់ឆ្នេរ** | | | |
| កំពង់ត្នោត | 37,933 | 73 | 51,655 |
| **សរុប** | 25,832 | 68 | 37,921 |

*សំគាល់: តួលេខនៅក្នុងរង្វង់ក្រចក សំដៅទៅលើទិន្នន័យឆ្នាំ១៩៩៦-៩៧ ។*

តារាង៧.២ បង្ហាញពីទិន្នន័យលើការបរិភោគអង្ករគិតជាទំងន់ក្នុងមនុស្សពេញវ័យម្នាក់[៤៥] ។ តារាងនេះបង្ហាញទិន្នន័យលើវគ្គទាំងពីរនៃអង្កេតឆ្នាំ២០០១ ។

ការបរិភោគអង្ករជាមធ្យមមានកំរិតប្រហែលគ្នាតាមភូមិនានា គឺកំរិតទាបបំផុត ០,៤៧គ.ក/ថ្ងៃ នៅភូមិព្រែកក្មេង (មធ្យមភាគលើពីរវគ្គ) និងខ្ពស់បំផុត ០,៥៥គ.ក/ថ្ងៃនៅខ្សាច់ជីរស់ ។ ការប្រែប្រួលខុសគ្នាតិចតួចក្នុងការហូបអង្ករនេះ វាផ្ទុយគ្នានឹងការប្រែប្រួលខុសគ្នាយ៉ាងច្រើននៅក្នុងការបរិភោគស្បៀងសរុប គឺបើគិតជាទឹកប្រាក់វាអាចខុសគ្នាដល់ ១០០% (១.៩៩៥ រៀលក្នុងមនុស្សពេញវ័យម្នាក់នៅកំពង់ត្នោត ធៀបនឹង ៧៦៩រៀលនៅត្រពាំងប្រិយ) ។ ទិន្នន័យនេះបង្ហាញថា អ្នកភូមិធ្វើយ៉ាងណាធានាឱ្យមានអង្ករហូបនៅកំរិតអប្បបរមាណាមួយ ពោលគឺសន្តិសុខស្បៀង ត្រូវបានធានាដោយការហូបអង្ករជាសំខាន់ ហើយដើម្បីសំរបតាមថវិកាដែលខ្លួនមាន អ្នកភូមិកែតំរូវទៅលើការបរិភោគស្បៀងអាហារផ្សេងៗទៀត ។

ការបរិភោគអង្ករហាក់នៅថេរនៅក្នុងអង្កេតទាំងពីរវគ្គ គឺភូមិភាគច្រើនមានការហូបអង្ករប្រែប្រួលតិចជាង ៥% រវាងអង្កេតទាំងពីរវគ្គ ។ ប៉ុន្តែគេអាចមើលឃើញថា ប្រជាជនកាត់បន្ថយការហូបអាហារសរុបនៅខែខ្វះស្បៀងដល់ទៅជាង ១៥% (តារាង៧.២) នៅក្នុង ៨ភូមិ លើកលែងតែភូមិព្រែកក្មេងដែលការបរិភោគហាក់ដូចកើនឡើងបន្តិចនៅរដូវវស្សា ។ រឿងនេះដោយសារព្រែកក្មេង ជាភូមិលិចទឹកនៅរដូវវស្សា ហើយពឹងផ្អែកលើត្រី និងស្រូវប្រាំង ដូច្នេះខែទាំងនេះមិនមែនជាខែខ្សត់ទេ ។

---

[៤៤] មិនដូចប្រទេសមានចំណូលតិចផ្សេងៗទេ នៅកម្ពុជាប្រជាជនមិនសូវជំនួសអាហារដោយចំណាយមិនមែនអាហារ ឬផ្ទុយមកវិញ ដូចតែងឃើញមានក្នុងទ្រឹស្ដីខាងអភិវឌ្ឍន៍នោះទេ ពីព្រោះចំណាយមិនមែនអាហារមានសម្ពាធខ្លាំង ឧ. ចំណាយលើជំងឺអស់ច្រើន និងធៀសមិនបាន (Biddulph 2000) ។ ដូច្នេះសេចក្ដីសន្និដ្ឋានច្បាស់លាស់ផ្អែកលើតួលេខនេះអាចប្រញ៉ាប់ប្រញ៉ាល់ពេក ។

[៤៥] ការកែតំរូវបែបនេះវាបំបាត់លំអៀងដែលកើតចេញពីលក្ខណៈខុសគ្នាក្នុងរបាយអាយុតាមគ្រួសារក្នុងស្រទាប់ប្រជាជន ។

ទិន្នន័យបង្ហាញថា អ្នកភូមិ ឬមួយស្តុកអង្ករទុកសំរាប់ហូបពេញមួយឆ្នាំ ឬមួយបរិភោគអង្ករជំនួសស្បៀងផ្សេងនៅរដូវខ្សត់ ។ ក្នុងការពិតវាអាចការរួមបញ្ចូលវិធីទាំងពីរនេះ ។

**តារាង៧.២ ការហូបអង្ករ និងហូបស្បៀងសរុប គិតក្នុងមនុស្សពេញវ័យម្នាក់ និងគិតតាមរដូវកាល**

| | ការហូបអង្ករ | | | ការហូបស្បៀងសរុប | | |
|---|---|---|---|---|---|---|
| | គ.ក/ថ្ងៃ | | | គ.ក/ថ្ងៃ | | |
| | លើកទី១ រដូវប្រាំង | លើកទី២ រដូវវស្សា | ភាគរយ ប្រែប្រួល | លើកទី១ រដូវប្រាំង | លើកទី២ រដូវវស្សា | ភាគរយ ប្រែប្រួល |
| **ទំនាបទន្លេសាប** | | | | | | |
| អណ្តូងត្រាច | 0.48 | 0.50 | 4.6 | 944 | 889 | -5.8 |
| ក្រសាំង | 0.49 | 0.49 | 0.2 | 1,156 | 939 | -18.8 |
| ខ្សាច់ជីរស់ | 0.56 | 0.55 | -2.3 | 1,277 | 902 | -29.4 |
| **ទំនាបទន្លេមេគង្គ** | | | | | | |
| ព្រែកក្មេង | 0.46 | 0.49 | 6.2 | 1,526 | 1,581 | 3.6 |
| បាបោង | 0.48 | 0.46 | -3.7 | 1,107 | 831 | -24.9 |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 0.51 | 0.48 | -5.4 | 1,251 | 976 | -22.0 |
| ដងក្តារ | 0.49 | 0.53 | 8.5 | 983 | 912 | -7.3 |
| ត្រពាំងប្រិយ | 0.47 | 0.51 | 6.5 | 784 | 754 | -3.8 |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 0.51 | 0.46 | -9.7 | 1,814 | 1,517 | -16.4 |
| **សរុប** | 0.49 | 0.49 | -0.1 | 1,234 | 1,051 | -14.8 |

## *៧.១.២ ការបរិភោគអង្ករ និងអាហារ គិតតាមទសភាគចំណាយ*

ក្រាហ្វិក៧.១ក ដែលចុះទិន្នន័យការបរិភោគអង្ករតាមទសភាគចំណាយបង្ហាញថា ការហូបអង្ករខុសគ្នាតិចតួចទេរវាងអ្នកធូរធារ និងអ្នកមិនធូរធារ ។ រឿងនេះបញ្ជាក់ថា ទាំងអ្នកមាន និងអ្នកក្រ តែងខំហូបអង្ករឱ្យបានដល់កំរិតកំណត់ណាមួយ (ប្រហាក់ប្រហែលគ្នា) ហើយបន្ទាប់មកទើបអ្នកមានលទ្ធភាព គេប្តូរទៅហូបរបស់ផ្សេងបន្ថែម ។ ប៉ុន្តែមានការខុសគ្នាខ្លាំងនៅក្នុង "ការបរិភោគអាហារសរុប" រវាងអ្នកធូរធារ និងអ្នកមិនធូរធារ (តារាង៧.១ខ) ។ គំលាតការបរិភោគរវាងទសភាគចំណាយខាងលើ និងខាងក្រោមអាចខុសគ្នាជាង ៤ដង ។ ដូចបានបញ្ជាក់ពីខាងដើម អ្នកភូមិកែតំរូវការបរិភោគស្បៀងមិនមែនអង្ករ ជាជាងប៉ះពាល់ការហូបអង្ករ ។

ក្រាហ្វិក៧.១ខ បង្ហាញពីការប្រែប្រួលតាមរដូវលើការបរិភោគសរុប ។ ទិន្នន័យបញ្ជាក់ថា ក្រុមមានចំណាយទាបរក្សាកំរិតបរិភោគ (សំខាន់អង្ករ) សឹងដដែលក្នុងរដូវខ្សត់ ចំណែកក្រុមមានចំណាយខ្ពស់កាត់បន្ថយការបរិភោគ ។ ទិន្នន័យនេះបង្កចំងល់ច្រើន ។ ប្រហែលជាក្រុមចំណាយទាបមិនផ្លាស់ប្តូរបរិមាណហូបតាមរដូវទេ ព្រោះពួកគេហូបតិចមិនអាចបន្ថយទៀតកើតទេ ព្រោះនឹងត្រូវអត់ឃ្លាន ។ ប៉ុន្តែក្រុមអ្នកមានប្រហែលជាកាត់ចេញការបរិភោគលើសរបស់ខ្លួន ។ ដូច្នេះគេអាចអះអាងថា គ្មានអ្នកក្រខ្សត់ខ្លាំងក្នុងភូមិទាំងនេះទេ ព្រោះអ្នកក្រអាចរក្សាបរិមាណបរិភោគនៅដដែលទោះបីនៅរដូវខ្សត់ក្តី ។ គេអាចអះអាងថែមថា គ្មានគ្រួសារ "ធូរធារ" ខ្លាំងទេ ព្រោះគ្រួសារក្នុងទសភាគលើបំផុត ក៏ត្រូវបង្ខំចិត្តបន្ថយការបរិភោគនៅខែខ្សត់ដែរ ។

នៅកំរិតភូមិទាំងអស់ការវិភាគបញ្ជាក់គាំទ្រគំនិតថា អ្នកភូមិរក្សាកំរិតនៃការបរិភោគអង្ករ ហើយធ្វើការកែតំរូវលើស្បៀងមិនមែនអង្ករ និងលើចំណាយមិនមែនស្បៀង ។

**ក្រាហ្វិក៧.១ក ការបរិភោគអង្ករគិតតាមទសភាគ និងតាមខែ (គ.ក/ថ្ងៃ/មនុស្សពេញវ័យ)**




**ក្រាហ្វិក៧.១ខ ការបរិភោគអាហារសរុប គិតតាមទសភាគ និងតាមរដូវ (រៀល/ថ្ងៃ/មនុស្សពេញវ័យ)**




## *៧.១.៣ ការប្រៀបធៀបការបរិភោគអង្ករនៅឆ្នាំ១៩៩៦-៩៧ និង ២០០១*

ការប្រៀបធៀបនេះផ្អែកលើលទ្ធផលអង្កេតឆ្នាំ២០០១ និង ១៩៩៦-៩៧ បង្ហាញថា នៅ៣ភូមិដែលធ្វើអង្កេតឡើងវិញ (ព្រៃកក្អែង បាបោង និងត្រពាំងប្រិយ) មានកាត់បន្ថយការហូបអង្ករខ្លះៗ (តារាង៧.៣) ។ នៅភូមិទី១ និងភូមិទី៣ ការហូបអង្ករថយចុះ ៣-៤%, ចំណែកនៅភូមិទី២ ការហូបអង្ករថយចុះ ១១-១២% ។ ហេតុអ្វីបានជាមានការថយចុះដូច្នេះ ?

១) តើមាន*កំណើន* ភាពក្រីក្រពិតៗមែនទេ?

២) តើមានស្បៀងផ្សេងមកជំនួសអង្ករមែនទេ?

៣) តើមានលំអៀងលើការកែតំរូវទិន្នន័យមែនទេ នៅពេលធ្វើការគណនាតាមឯកតាមនុស្សពេញវ័យ?

តារាង៧.៣ ការបរិភោគអង្ករ/ម្នាក់/ថ្ងៃ: តួលេខកែតំរូវតាមឯកតាមនុស្សពេញវ័យ និងតួលេខគ្មានកែតំរូវ

| ភូមិ | រដូវប្រាំង 1996 | 2001 | ភាគរយប្រែប្រួល | រដូវវស្សា 1997 | 2001 | ភាគរយប្រែប្រួល |
|---|---|---|---|---|---|---|
| | (គ.ក/ថ្ងៃក្នុងមួយឯកតារមនុស្សពេញវ័យ) | | | | | |
| ព្រៃកក្អែង | 0.51 | 0.53 | 4 | 0.53 | 0.49 | -7 |
| បាបោង | 0.59 | 0.56 | -5 | 0.56 | 0.46 | -18 |
| ត្រពាំងប្រិយ | 0.56 | 0.54 | -3 | 0.54 | 0.51 | -6 |
| | (គ.ក/ថ្ងៃក្នុងម្នាក់) | | | | | |
| ព្រៃកក្អែង | 0.37 | 0.38 | 4 | 0.39 | 0.36 | -7 |
| បាបោង | 0.45 | 0.38 | -15 | 0.43 | 0.43 | -6 |
| ត្រពាំងប្រិយ | 0.37 | 0.41 | 11 | 0.40 | 0.40 | -3 |

សំណួរចុងក្រោយត្រូវពិចារណាមុនគេ ។ ដើម្បីគណនាតួលេខក្នុងតារាង៧.៣ ឯកតាមនុស្សពេញវ័យត្រូវកំណត់ឡើង ។ ស្ត្រីពេញវ័យហូបស្មើនឹង ០,៨ បុរសពេញវ័យ ចំនែកកុមារហូបស្មើនឹង ០,៥ បុរសពេញវ័យ ។ ការប្រែប្រួលប្រជាសាស្ត្ររវាងឆ្នាំទាំងពីរអាចធ្វើឱ្យទិន្នន័យលំអៀង ។ ដើម្បីពិនិត្យបញ្ហាតាមមួយបែបផ្សេង របបហូបក្នុងមនុស្សម្នាក់គ្មានដាក់ទំងន់ (unwighted consumption per capita) ត្រូវបានគណនាសំរាប់ទាំងពីររយ:ពេល ។ ទិន្នន័យនេះបង្ហាញថា គំលាតនៃការបរិភោគអង្ករថយចុះតែបន្តិចបន្តួច បើយកមធ្យមភាគការហូបគ្មានដាក់ទំងន់មកប្រៀបធៀប ។ គឺបានន័យថា ការកែតំរូវតាមអាយុមិនធ្វើឱ្យមានលំអៀងច្រើនទេ ។ ចំណុចនេះនាំទៅដល់សំនួរទី២: មានលទ្ធភាពច្រើននៃការជំនួសគ្នារវាងអង្ករ និងស្បៀងផ្សេងទៀត (យ៉ាងហោចណាស់មាន ២ភូមិក្នុងចំណោម ៣ភូមិខាងលើ) ។ បរិមាណដាច់ខាត គិតជាទឹកប្រាក់ចំណាយលើអាហារនៅព្រៃកក្អែងគឺ ៦៦០រៀល/ថ្ងៃនៅឆ្នាំ១៩៩៦-៩៧ ធៀបនឹង ១.៥៩៣រៀលនៅឆ្នាំ២០០១ ។ នៅបាបោង តួលេខគឺ ៧៦៤រៀលនៅឆ្នាំ១៩៩៦-៩៧ ធៀបនឹង ៩៦៩រៀលនៅឆ្នាំ២០០១ ឯនៅត្រពាំងប្រិយគឺ ៨៤០រៀលនៅឆ្នាំ១៩៩៦-៩៧ ធៀបនឹង ៧៦៩រៀលនៅឆ្នាំ២០០១ ។ នៅព្រៃកក្អែង និងបាបោង ការបរិភោគអាហារមធ្យមគិតជាប្រាក់បានកើនឡើង ។ ឯការធ្លាក់ចុះបរិមាណបរិភោគនៅត្រពាំងប្រិយ អាចបង្ហាញពីការធ្លាក់ចុះកំរិតជីវភាព ។ ចំពោះសំនួរទី១ ស្តីពីការប្រែប្រួលភាពក្រីក្រ នឹងមានបញ្ជាក់ជាក្រោយនៅក្នុងជំពូកនេះ ។

## ៧.២ កន្ត្រកអាហារ

អាហារដែលមនុស្សហូបមានច្រើនមុខណាស់ ប៉ុន្តែដើម្បីសំរួលការងារបានចាត់ជាក្រុមអង្ករ ធញ្ញជាតិផ្សេងទៀត សាច់ត្រីនិងស៊ុត បន្លែ ប្រេងនិងខ្លាញ់ ផ្លែឈើ និងអាហារផ្សេងទៀត ។ តំលៃជាភាគរយនៃអាហារទាំងនេះមានចុះក្នុងតារាង៧.៤ ។

គួរកត់សំគាល់ថា ទោះបីស្រូវអង្ករជាសមាសធាតុសំខាន់បំផុតក្នុងអាហារនៅកម្ពុជាក្តី ក៏វាមិនមែនជាចំណែកធំបំផុតនៅក្នុងថវិកាអាហារគ្រួសារទេ ។ គិតជាមធ្យម សមាមាត្រអង្ករនៅក្នុងកន្ត្រកអាហារ គឺតិចជាង ៣០% ប៉ុន្តែនៅភូមិមានឱនភាពស្រូវ សមាមាត្រអង្ករវាខ្ពស់ជាងនេះ ។ អាហារដែលមានចំណាយអតិបរិមាគឺ សាច់ (រួមទាំងត្រី និងស៊ុត) ប៉ុន្តែក្នុងការពិតជាក់ស្តែង មួយចំណែកនៃអាហារនេះរកបានដោយខ្លួនឯង[៨៦] ។

គេបានរកឃើញពីខាងដើមថា មានការប្រែប្រួលខ្លាំងនៃការហូបអាហារមិនមែនបាយ ទៅតាមក្រុមបញ្ចភាគចំណាយ និងតាមរដូវកាល ។ ដើម្បីពិនិត្យលំអិតថែមទៀត គេគណនាសមាមាត្រគិតជាភាគរយនៃចំណាយអាហារមិនមែនអង្ករនៅរដូវ

[៨៦] ការចូលរួមក្នុងទីផ្សារ (ខ្ពស់ច្រើនក្នុងភូមិទាំងនេះ) មានកំរិត ៦៥-៧០% ទៅតាមថ្នាក់សេដ្ឋកិច្ច-សង្គមកិច្ច និងមុខអីវ៉ាន់ ។ គេគិតថាមួយចំណែកធំ គឺជាការដូរទំនិញរវាងប្រជាជនក្នុងភូមិ ។ អង្កេតពីមុនក៏រកឃើញដូច្នេះដែរ (see Murshid 1998) ។

វស្សាធៀបទៅនឹងចំណាយអាហារមិនមែនអង្ករនៅរដូវប្រាំង ។ នៅរដូវខ្វះខាតខែវស្សា (អង្កេតវគ្គ២) ចំណាយសរុបលើអីវ៉ាន់មិនមែនអាហារធ្លាក់ចុះដល់ត្រឹម ៧៨% នៃចំណាយនៅរដូវប្រាំង[៤៧] ។ ការថយចុះជាអតិបរមាកើតមានចំពោះផ្លែឈើ បន្លែ និងអាហារផ្សេងទៀត ដូចជា អាហារសម្រន់ តែ និងកាហ្វេ, ប៉ុន្តែសាច់និងអាហារទាក់ទិននឹងសាច់ និងប្រេង ខ្លាញ់ មិនប្រែប្រួលច្រើនទេ (ឧបសម្ព័ន្ធ៦ តារាង២) ។ នៅក្នុង ៨ភូមិ ឃើញមានការថយចុះ ប៉ុន្តែនៅព្រៃកក្អេង គ្មានការប្រែប្រួលទេ ដូចបានពន្យល់ពីខាងដើមរួចហើយ ។ អង្ករបានពីការផលិតដោយខ្លួនឯងឬទិញគេ អាហារផ្សេងទៀតបានមកពីការទិញ/ដូរ ចាប់ដោយខ្លួនឯង (ត្រី) បេះប្រមូលខ្លួនឯង (បន្លែ ផ្លែឈើ) ឬចិញ្ចឹមនៅផ្ទះ (មាន់ទា) ។ នៅរដូវខ្សត់ការទិញអាហារផ្សេងៗខាងលើត្រូវកាត់បន្ថយដោយខ្វះខាតប្រាក់ ហើយអាហារខ្លះដែលមានតាមរដូវ ដូចជាត្រី អាចរកមិនបាន ។ គេអង្កេតឃើញថា ដើម្បីទិញអង្ករនៅរដូវខ្សត់ អ្នកភូមិខ្លះដែលមិនសូវមានប្រាក់បានលក់ចេញនូវរបស់ហូបផ្សេងៗទៀត (Kim, Chan, and Acharya 2002) ។ មូលហេតុនេះហើយបានជាមានថយចុះការបរិភោគអាហារមិនមែនអង្ករនៅរដូវខ្សត់ ។

**តារាង៧.៤ អាហារ និងការបរិភោគក្នុងមួយឯកតាមនុស្សពេញវ័យម្នាក់ (មធ្យមភាគនៅរដូវប្រាំង និងវស្សា)**

| | អង្ករ | ធញ្ញជាតិ | សាច់ ត្រី | បន្លែ | ប្រេង ខ្លាញ់ | ផ្លែឈើ | ផ្សេងៗ | អាហារសរុប |
|---|---|---|---|---|---|---|---|---|
| **ទំនាបទន្លេសាប** | ភាគរយនៃការបរិភោគស្បៀងសរុប* | | | | | | | |
| អណ្តូងត្រាច | 37.1 | 7.2 | 28.1 | 9.3 | 2.4 | 6.7 | 9.2 | 100.0 |
| ក្រសាំង | 30.6 | 10.7 | 33.3 | 7.8 | 2.1 | 5.0 | 10.4 | 100.0 |
| ខ្សាច់ជីរស់ | 35.4 | 4.3 | 24.1 | 9.2 | 3.7 | 8.3 | 15.0 | 100.0 |
| **ទំនាបទន្លេមេគង្គ** | | | | | | | | |
| ព្រៃកក្អេង | 20.6 | 6.8 | 37.3 | 12.3 | 2.9 | 5.2 | 14.9 | 100.0 |
| បាបោង | 25.1 | 5.3 | 38.6 | 10.7 | 2.8 | 5.6 | 11.9 | 100.0 |
| **តំបន់ខ្ពង់រាប** | | | | | | | | |
| កញ្ជរ | 31.4 | 5.1 | 32.6 | 10.3 | 2.8 | 5.6 | 12.2 | 100.0 |
| ដងក្តារ | 35.8 | 7.1 | 28.8 | 8.0 | 2.5 | 6.9 | 10.8 | 100.0 |
| ត្រពាំងប្រិយ | 41.0 | 4.8 | 31.5 | 7.5 | 2.0 | 4.0 | 9.2 | 100.0 |
| **តំបន់ឆ្នេរ** | | | | | | | | |
| កំពង់ត្នោត | 21.0 | 6.2 | 43.2 | 7.2 | 2.4 | 8.1 | 11.9 | 100.0 |
| សរុប | **28.8** | **6.5** | **34.2** | **9.3** | **2.7** | **6.4** | **12.2** | **100.0** |

* សូមអានឧបសម្ព័ន្ធ ៦ តារាង១ សំរាប់ចំណាយជារៀល ។

## ៧.៣ ការប្រើប្រាស់មិនមែនអាហារ

ការបំបែកតាមមុខចំណាយនូវវិកន្ត្រកប្រើប្រាស់មិនមែនអាហារមានចុះក្នុងតារាង៧.៥ ។ តារាងនេះបង្ហាញថា ជាមធ្យម ១/៣ នៃចំណាយមិនមែនអាហារ គឺសំរាប់ព្យាបាលសុខភាពដែលមានចំណែកធំជាងគេបំផុត ក្នុងចំណាយមិនមែនអាហារ ។ ចំណែកនេះខ្ពស់គួរកត់សំគាល់នៅភូមិខ្សាច់ជីរស់ បាបោង និងដងក្តារ គឺលើសពី ៤០% នៃចំណាយមិនមែនអាហារ ។ នៅភូមិបាបោង ចំណែកអាហារមានតែ ៥៧% ហើយគេសង្ស័យថាមានការកាត់បន្ថយចំណាយអាហារដើម្បីបំពេញចំណាយលើជំងឺ (សូមអានកំណត់សំគាល់លេខ៤៣) ។ គិតជាតំលៃដាច់ខាត ចំណាយលើជំងឺខ្ពស់បំផុតកើត មាននៅភូមិបាបោង គឺ ៧.០៦៤រៀល/ម្នាក់/ខែ ។ ការប្រៀបធៀប ៣ភូមិ ទៅនឹងអង្កេតឆ្នាំ១៩៩៦-៩៧ បង្ហាញថា ចំណាយ លើសុខភាពមានអត្រាកាន់តែខ្ពស់ជាង

[៤៧] រឿងនេះផ្ទុយគ្នានឹងស្ថិរភាពនៃការហូបអង្ករដូចមានចុះក្នុងតារាង៧.២ (គិតជាចំនួនគីឡូ) និង *កំណើន៨%* គិតជាប្រាក់ ។

ទៀតនៅឆ្នាំនោះ (តួលេខក្នុងវង់ក្រចក) ។ នៅភូមិក្រសាំង ចំណែកចំណាយមិនមែនស្បៀង មានកំរិតខ្ពស់ដោយសារចំណាយលើការអប់រំដែលមានកំរិត ៤.២៣៩រៀល/ខែ/ម្នាក់ គឺខ្ពស់ជាងគេនៅក្នុងគំរូតាង ។

**តារាង៧.៥ ចំណែកជាភាគរយនៃមុខចំណាយប្រើប្រាស់មិនមែនអាហារ នៅឆ្នាំ២០០១ និង ១៩៩៦-៩៧** (គណនាចេញពីចំណាយក្នុងមួយឯកតាមនុស្សពេញវ័យ)

| | សំលៀកបំពាក់ | សុខភាព | ការអប់រំ | បុណ្យទាន | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|
| **ទំនាបទន្លេសាប** | | | | | | |
| អណ្តូងត្រាច | 19 | 35 | 15 | 16 | 15 | 100 |
| ក្រសាំង | 12 | 28 | 25 | 16 | 19 | 100 |
| ខ្សាច់ជីរស់ | 16 | 44 | 7 | 18 | 15 | 100 |
| **ទំនាបទន្លេមេគង្គ** | | | | | | |
| ព្រែកក្មេង | 14 (8.8) | 40 (61.4) | 10 (11.2) | 24 (7.4) | 13 (11.1) | 100 (100) |
| បាបោង | 13 (4.7) | 45 (54.1) | 8 (10.5) | 26 (13.5) | 8 (17.1) | 100 (100) |
| តំបន់ខ្ពង់រាប | | | | | | |
| កញ្ជរ | 12 | 36 | 14 | 23 | 15 | 100 |
| ដងក្តារ | 13 | 55 | 7 | 20 | 6 | 100 |
| ត្រពាំងប្រិយ | 12 (NA) | 30 (48.2) | 13 (NA) | 28 (NA) | 18 (NA) | 100 (100) |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 15 | 19 | 24 | 29 | 14 | 100 |
| **សរុប** | **14** | **37** | **14** | **22** | **13** | **100** |

*សំគាល់: តួលេខនៅក្នុងវង់ក្រចង គឺជាទិន្នន័យឆ្នាំ១៩៩៦-៩៧(NA) ជាទិន្នន័យមិនមាននៅក្នុងអង្កេតចុងក្រោយ ។*

សរុបមក ចំណាយលើសុខភាពតំណាងឱ្យ ៩-១០% នៃចំណាយប្រើប្រាស់សរុប ។ អត្រានេះមានកំរិតខ្ពស់ បើពិនិត្យតាមចំណូលគ្រួសារដ៏ទាបនៅក្នុងភូមិទាំងនេះ ។

ក្រាហ្វិក៧.២ បង្ហាញពីការប្រែប្រួលតាមរដូវលើការប្រើប្រាស់មិនមែនអាហារតាមភូមិផ្សេងៗ ។ នៅរដូវខ្សត់មានការកាត់បន្ថយចំណាយមិនមែនអាហារនៅគ្រប់ភូមិ ។ ប៉ុន្តែ មិនអាចរកឃើញលំនាំអ្វីជាក់លាក់ពីការប្រែប្រួលខុសគ្នាតាមភូមិទេ ។ ជាសរុប មានការថយចុះ ៤២% លើចំណាយមិនមែនអាហាររវាងរដូវទាំងពីរ គឺខ្ពស់ជាងអត្រាសំរាប់ចំណាយលើអង្ករ និងអាហារមិនមែនអង្ករ ។ តួលេខនេះបញ្ជាក់ថា អ្នកភូមិតែងកាត់បន្ថយមុខចំណាយមិនមែនអាហារ ជាជាងចំណាយលើអាហារ ។

តារាង៧.២ខ ស្តីពីការកាត់បន្ថយតាមរដូវកាល ចំពោះចំណាយមិនមែនអាហារនៅក្នុងគំរូតាងទាំងមូលគិតតាមទសភាគចំណាយ បានបង្ហាញនូវបទរុំខ្សោយរវាងភាពធូរធារ និងការមិនចាំបាច់កាត់បន្ថយចំណាយ ។ ទិន្នន័យនេះបង្ហាញការពិតជាក់ស្តែងមួយថា គំលាតរវាងអ្នកមាន និងអ្នកក្រមិនធំណាស់ណាទេ ព្រោះម្នាក់ៗត្រូវបង្ខំចិត្តកាត់បន្ថយចំណាយ ។ ចំណុចនេះក៏បានសង្កេតពីខាងដើមដែរ ។

ក្រាហ្វិក៧.២ក ការប្រែប្រួលលើការប្រើប្រាស់មិនមែនអាហារគិតតាមភូមិរវាងអង្កេតវគ្គ១ (រដូវប្រាំង) និងវគ្គ២ (រដូវវស្សា) គិតជារៀល/ថ្ងៃ/ឯកតាមនុស្សពេញវ័យ




ក្រាហ្វិក៧.២ខ ការប្រែប្រួលលើការប្រើប្រាស់មិនមែនអាហារ គិតតាមទសភាគចំណាយ រវាងអង្កេតវគ្គ១ (រដូវប្រាំង) និងវគ្គ២ (រដូវវស្សា) គិតជា រៀល/ថ្ងៃ/ឯកតាមនុស្សពេញវ័យ




## ៧.៤ ភាពយឺត Engel

ភាពយឺត Engel គឺជាភាពយឺត (ការប្រែប្រួលជាភាគរយ) នៃការប្រើប្រាស់អីវ៉ាន់ ប្រើប្រាស់ជាក់លាក់ណាមួយនៅពេលមានការប្រែប្រួលចំណូលសរុប ។ ភាពយឺត Engel ត្រូវគណនាដើម្បីវិនិច្ឆ័យពីចរិតនៃការឆ្លើយតបរបស់អ្នកប្រើប្រាស់នៅចំណូលប្រែប្រួល ។ ភាពយឺតនេះជួយក្នុងការវិភាគគោលនយោបាយជាច្រើន ដូចជា លក្ខណៈសម្បត្តិសំខាន់ៗ ភាពអាច

ជំនួសបាន ឬភាពអន់ជាង/ល្អជាងនៃទំនិញប្រើប្រាស់ ។ នៅប្រទេសខ្លះ ភាពយឺត Engel ជួយណែនាំដល់ការចែកចាយតាមរបប កំណត់ ឬការគ្រប់គ្រងថ្លៃទំនិញមួយចំនួននៅពេលទីផ្សារត្រូវបិទ ឬជួបការខ្វះខាតខ្លាំង ។

វិធីសាស្ត្រសាមញ្ញ និងរឹងប៉ឹងបំផុត ដែលគេប្រើប្រាស់ដើម្បីកំណត់ ភាពយឺត Engel គឺប៉ាន់ស្មានគំរូ double logarithmic regression models with individuall items being the dependent variable, end total income as explanatory variable ។ សមីការនេះមានដូចខាងក្រោម :

$$Ln = (item_i) = A + B\ Ln\ (total\ income)$$ [៤៨]

ក្នុងការវិភាគបច្ចុប្បន្ន ចំណូលសរុបត្រូវជំនួសដោយការប្រើប្រាស់សរុប ។ អថេរទាក់ទង គឺមាន អង្ករ សាច់ ត្រី ... អាហារមិនមែនអង្ករ ចំណាយមិនមែនអាហារ និង ចំណាយសុខភាព, នៅក្នុង ៤សមីការ ដោយប្រើប្រាស់វិធីសាស្ត្រការេតូច បំផុតធម្មតា (Ordinary Least Squares Method) ។ ការប៉ាន់ស្មានបានធ្វើឡើងចំពោះគំរូតាងទាំងមូល ។ សមីការទាំងនេះ មិនបានបង្ហាញតាមភូមិនីមួយៗទេ ពីព្រោះតំលៃមេគុណមិនខុសគ្នាច្រើនទេ ពីភូមិមួយទៅភូមិមួយ ។

**តារាង៧.៦ ភាពយឺត Engel សំរាប់អង្ករ អាហារមិនមែនអង្ករ របស់មិនមែនអាហារ និងសុខភាព**

| ស្រូវ | មិនមែនអង្ករ | សាច់ ត្រី ... | មិនមែនអាហារ | សុខភាព |
|---|---|---|---|---|
| 0.46 | 0.75 | 0.91 | 0.74 | 0.51 |

** All estimates in this table are statistically significant at 0.01 percent confidence.*

ការប៉ាន់ប្រមាណភាពយឺត Engel បង្ហាញក្នុងតារាង៧.៦ ផ្តល់គំនិតថា ការបរិភោគអង្ករមិនកើនច្រើនទេ នៅពេលការ ប្រើប្រាស់សរុបកើនឡើង ។ តួលេខនេះស្របទៅនឹងលទ្ធផលរកឃើញពីមុនដែលថា អ្នកភូមិមានគោលដៅធានាឱ្យខ្លួនឯងមាន អង្ករហូបដល់កំរិតជាក់លាក់ណាមួយ ប៉ុន្តែមិនបង្កើនការហូបអង្ករក្នុងសមាមាត្រប៉ុនគ្នានឹងកំណើនចំណូលនោះទេ ។ អាហារមិន មែនអង្ករមានភាពខ្ពស់យឺតជាង: ជាក់ស្តែង ត្រី និងសាច់ មានតំរូវការខ្ពស់ ហើយនៅពេលចំណូលកើនឡើងការបរិភោគសាច់ ក៏កើនឡើងក្នុងសមាមាត្រសឹងដូចគ្នា ។ អាហារមិនមែនអង្ករ និងអីវ៉ាន់មិនមែនអាហារមានភាពយឺតប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែចំណាយសុខភាពមានភាពយឺតទាបជាង (ប៉ុន្តែមិនទាបដូចអង្ករទេ) ដែលបញ្ជាក់ថា ចំណាយទាក់ទងនឹងសុខភាព ហាក់ដូច ស្ថិតក្នុងប្រភេទមុខចំនាយចាំបាច់ដូចគ្នា គឺអ្នកភូមិត្រូវតែចំណាយអស់ក្នុងចំនួនណាមួយលើសុខភាព ។ ចំណាយនេះមិនមែនកើន លឿនទាន់កំណើនចំណូលរាល់ៗលើកនោះទេ ហើយរឿងនេះបញ្ជាក់ថា អ្នកក្រត្រូវចំណាយច្រើនហួសកំរិតលើសុខភាព ។ ភាព យឺត Engel ដូចប៉ាន់ស្មានខាងលើផ្តល់មូលដ្ឋានស្ថិតិចំពោះគំហើញពីខាងដើមស្តីពីអាកប្បកិរិយារបស់អ្នកប្រើប្រាស់ ។

## ៧.៥ បន្ទាត់ក្រីក្រ និងការប្រៀបធៀបភាពក្រីក្រ

ការវាយតំលៃពីសន្តិសុខស្បៀង ឬការបរិភោគអាហារគ្រប់គ្រាន់មិនអាចចៀសផុតពីការពិភាក្សាលើភាពក្រីក្របានទេ ។ ដូចបានបញ្ជាក់ពីខាងដើមហើយ ក្នុងប្រទេសមានចំណូលទាបមនុស្សម្នាក់ត្រូវចាត់ទុកថាស្ថិតក្រោមបន្ទាត់ក្រីក្រ បើសិនជននោះ ហូបអាហារតិចជាងបរិមាណកំណត់មួយ ។ នៅកម្ពុជាបរិមាណនេះស្មើនឹង ២.១០០កាឡូរី/ថ្ងៃ ។ វិធីសាស្ត្រធម្មតាសំរាប់ប៉ាន់

[៤៨] The value of Engel elasticity is the estimated coefficient B, and A is the intersect. Ln is the natural logarithm of the item or income ។

ស្ថានបន្ទាត់ក្រីក្រនេះ គឺត្រូវស្វែងរកបរិមាណសាច់ប្រាក់ត្រូវចំណាយសំរាប់ទិញអាហារឱ្យបាន ២.១០០កាឡូរី/ថ្ងៃ រួមទាំងប្រាក់បន្ថែមមួយចំនួនតូចទៀតសំរាប់ចំណាយលើអីវ៉ាន់ មិនមែនអាហារ[៤៩] ។

សំរាប់ការវិភាគនៅជំពូកនេះ បន្ទាត់ក្រីក្រសំរាប់ភូមិនីមួយៗត្រូវបានគណនា ។ រឿងនេះដោយសារបន្ទាត់ក្រីក្រសរុបគណនានៅកំរិតជាតិ គឺច្រើនចាប់បង្ខំឱ្យប្រើនូវកំរិតថ្លៃថ្នាក់ជាតិ (ដូចគ្នានឹងកន្ទ្រកនៃការប្រើប្រាស់នៅថ្នាក់ជាតិ) ទៅលើភូមិនីមួយៗ ឬតាមគ្រួសារ ដែលអាចមិនសូវប្រាកដនិយមសំរាប់ការវិភាគកំរិតភូមិ ។ វបសអ បានគណនាបន្ទាត់ក្រីក្រសំរាប់ ៣ភូមិក្នុងអង្កេតពីលើកមុនៗ ដោយប្រើតំលៃជាកាឡូរីនៃអាហារដែលហូបនៅក្នុងស្រុក ។ ចំពោះភូមិទាំងបីនេះ (បាបោង ព្រៃកក្មេង និងត្រពាំងប្រិយ) បន្ទាត់ក្រីក្រ ត្រូវបានកែលំអដោយប្រើទិន្នន័យថ្លៃកត់ត្រាក្នុងអង្កេតចំណាយទ្រទ្រង់ជីវភាពប្រចាំត្រីមាសធ្វើដោយ វបសអ ។ ចំពោះភូមិផ្សេងទៀត ការកែតំរូវបានធ្វើឡើងដោយគិតគូរពីកន្ទ្រកការប្រើប្រាស់ក៏ដូចជាកំរិតថ្លៃដើម្បីរកឃើញបន្ទាត់ក្រីក្រ ។ តារាង៧.៧ បង្ហាញពីបន្ទាត់ក្រីក្រៈ បន្ទាត់ក្រីក្រស្បៀង និងបន្ទាត់ក្រីក្រសរុប ដែលគណនាឡើងដោយបូកបន្ថែម ២០% ជាមួយនឹងបន្ទាត់ក្រីក្រស្បៀង ។ វិធីដូចគ្នាបានយកមកអនុវត្តក្នុងអង្កេតឆ្នាំ១៩៩៦-៩៧ ។ គួរកត់សំគាល់ថា កំពង់ត្នោតមានបន្ទាត់ក្រីក្រខ្ពស់ជាងគេ ពីព្រោះអាហារនៅភូមិនោះភាគច្រើនជាអាហារសមុទ្រដែលថ្លៃខ្ពស់ជាងអាហារ មានបាយជាចំបងនៅតាមកន្លែងផ្សេងៗទៀត ។

**តារាង៧.៧ បន្ទាត់ក្រីក្រ និងអត្រាអ្នករស់នៅក្រោមបន្ទាត់ក្រីក្រ (តាមភូមិ)**

| *ភូមិ/ខ្សែបន្ទាត់ក្រីក្រ* | *ខ្សែបន្ទាត់ក្រីក្រ (រៀល/ថ្ងៃ)* | *ខ្សែបន្ទាត់ក្រីក្រ (រៀល/ថ្ងៃ)* | *ភាគរយក្រោម ខ្សែបន្ទាត់ក្រីក្រ២០០១* | *ភាគរយក្រោម ខ្សែបន្ទាត់ក្រីក្រ១៩៦-៩៧* |
|---|---|---|---|---|
| **ទំនាបទន្លេសាប** | | | | |
| អណ្តូងត្រាច | 855 | 1,069 | 51 | |
| ក្រសាំង | 898 | 1,123 | 33 | |
| ខ្សាច់ជីរស់ | 984 | 1,230 | 45 | |
| **ទំនាបទន្លេមេគង្គ** | | | | |
| ព្រៃកក្មេង | 994 | 1,243 | 15 | 48 |
| បាបោង | 901 | 1,126 | 25 | 43 |
| **តំបន់ខ្ពង់រាប** | | | | |
| កញ្ជរ | 1,046 | 1,308 | 43 | |
| ដងក្តារ | 1,080 | 1,350 | 62 | |
| ត្រពាំងប្រិយ | 888 | 1,110 | 72 | 50 |
| **តំបន់ឆ្នេរ** | | | | |
| កំពង់ត្នោត | 1,194 | 1,492 | 12 | |
| **សរុប** | 982 | 1,228 | 38 | |

តារាង៧.៧ ផ្តល់ផងដែរនូវទិន្នន័យចំនួនមនុស្សធ្លាក់ក្រោមបន្ទាត់ក្រីក្រ តាមការពិនិត្យឃើញក្នុងអង្កេតឆ្នាំ២០០១ និង ១៩៩៦-៩៧ ។ នៅឆ្នាំ២០០១ អត្រាអ្នកភូមិរស់នៅក្រោមបន្ទាត់ក្រីក្រគិតលើ ៩ភូមិមាន ៣៨%[៥០] ។ ភូមិធូរធារគួរសមគឺ ព្រៃកក្មេង បាបោង និងកំពង់ត្នោតៈ សមាមាត្រអ្នកនៅក្រោមបន្ទាត់ក្រីក្រ គឺ ១៥% ២៥% និង ១២% រៀងគ្នា ។ ភូមិក្រសាំង

[៤៩] ក្នុងការអនុវត្តន៍ធម្មតា គេធ្វើការវិនិច្ឆ័យពីតួលេខពិតនៃរបបប្រើប្រាស់អីវ៉ាន់មិនមែនស្បៀង ដោយផ្អែកលើការប្រើប្រាស់ជាក់ស្តែងនៅក្នុងទសភាគទី២ ឬទី៣ នៃរបាយគ្រួសារគិតតាមចំណាយប្រើប្រាស់ជាក់ស្តែង ។ ឯវិធីច្បាស់លាស់លំអិតជាងនេះ ប្រើគំរូ regression សំរាប់ប៉ាន់ស្មានខ្សែកោង Engel ដើម្បីកំណត់ការប្រើប្រាស់មិនមែនស្បៀង ។ សូមអាន RGC (2001), Appendix 3 ។

[៥០] តួលេខប៉ាន់ស្មានភាពក្រីក្រនេះ ប្រហាក់ប្រហែលនឹងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៧ និង ១៩៩៩ ។

មានអ្នករស់នៅក្រោមបន្ទាត់ក្រីក្រតិចជាង ធៀបនឹងមធ្យមភាគលើភូមិទាំង៩ ។ ភូមិក្រីក្រគឺ ត្រពាំងប្រិយ ដែលមានអ្នករស់នៅក្រោមបន្ទាត់ក្រីក្រ ៧២% និងបន្ទាប់មកគឺ ដងក្ដារមាន ៦២% ។ អណ្ដូងត្រាច ខ្សាច់ជីរស់ និង កញ្ជរ ជាភូមិមានប្រជាជនច្រើន និងមានសមាមាត្រមធ្យមអ្នករស់នៅក្រោមបន្ទាត់ក្រីក្រច្រើន (ច្រើនជាងអត្រាមធ្យម) ។ ភូមិនានាដែលមានប្រជាជនស្ថិតនៅក្រោមបន្ទាត់ក្រីក្រតិច គឺជាភូមិមានអតិរេកស្រូវ ឬមានធនធានត្រីច្រើនផងដែរ ។ ដូច្នេះ លទ្ធភាពរកត្រីបាន និងលក្ខខណ្ឌអតិរេកស្រូវ ជាកត្តាកំណត់នូវកំរិតជីវភាព ។

ការប្រៀបធៀបសមាមាត្រអ្នករស់នៅក្រោមបន្ទាត់ក្រីក្រនៅឆ្នាំ២០០១ និង ១៩៩៦-៩៧ (ដែលឆ្លើយនឹងសំនួរលើកឡើងពីខាងដើម) បង្ហាញថា នៅភូមិព្រែកក្មេង មាន ៣៣% បានឆ្លងផុតខ្សែបន្ទាត់ក្រីក្រ ។ នៅបាបោង ១៨% បានឆ្លងផុតខ្សែបន្ទាត់ក្រីក្រ ។ មានតែភូមិត្រពាំងប្រិយមួយប៉ុណ្ណោះ ដែលអត្រាអ្នកក្រីក្រកើនឡើង គឺនៅឆ្នាំ២០០១ បានកើន ២៨% ច្រើនជាងឆ្នាំ១៩៩៦-៩៧ ។ ខណៈដែលអត្រាអ្នកក្រីក្របានប្រែប្រួលគួរកត់សំគាល់ គេអាចរំពឹងថាមានការប្រែប្រួលច្រើនៗនៅក្នុងកំរិតមីក្រូ ។ ឧទាហរណ៍ ការថយអត្រាភាពក្រីក្រអាចសំរេចបានតាមរយៈកំណើនសកម្មភាពនេសាទ ការលូតលាស់កសិកម្ម គំរោងអភិវឌ្ឍន៍ និងជំនួយ (ព្រែកក្មេង) ឬការធ្វើទំនើបកម្មកសិកម្ម (បាបោង) ។ នៅជំពូកទី៤ គេបានកត់សំគាល់ថា ភូមិព្រែកក្មេងបានចំណេញច្រើនណាស់ក្នុងវិស័យនេសាទ ឯនៅបាបោង មានកំណើនកសិកម្មខ្ពស់ ដោយការប្រើពូជស្រូវទំនើប ជីគីមី និងការប្រើប្រាស់ប្រព័ន្ធស្រោចស្រព ។ នៅតំបន់ណាដែលមានការអភិវឌ្ឍន៍ពឹងផ្អែកលើធនធានចំណូលបានកើនឡើង ហើយបើសិនចំណូលទាំងនេះបានបែងចែកស្មើគ្នាល្អ ភាពក្រីក្រនឹងធ្លាក់ចុះ ។ ករណីនេះបានកើតមាននៅព្រែកក្មេង និងបាបោង ។ កំណើនភាពក្រីក្រនៅត្រពាំងប្រិយ អាចផុសចេញពីការរួមផ្សំគ្នារវាងភាពគ្មានដី ភាពគ្មានការងារធ្វើ និងការហិនហោចមូលដ្ឋានធនធានធម្មជាតិ ។ នៅត្រពាំងប្រិយគេទទួលបានកំនើនកសិកម្មតាមការធ្វើចំរុះកម្មមុខដំណាំ ។ ប៉ុន្តែកន្លងមក ការធ្វើចំរុះកម្មមុខដំណាំនៅកម្ពុជា អាចធ្វើបានចំពោះតែដីធំៗ ដែលកសិករជាម្ចាស់ដីអាចកាត់យកដីមួយចំនួនសំរាប់ដាំដំណាំមិនមែនស្រូវ ។ សរុបមក ចំណូលពីកសិកម្មអាចបានទៅដល់តែចំពោះអ្នកមិនក្រ រីឯអ្នកក្រត្រូវរកចំណូលពីការលក់ពលកម្ម ហើយកំរិតប្រាក់ឈ្នួលបច្ចុប្បន្នមិនអាចជួយឱ្យពួកគេឆ្លងផុតបន្ទាត់ក្រីក្របានច្រើននាក់ទេ ។ ផ្ទុយទៅវិញ បើមានការពឹងផ្អែកលើប្រាក់ឈ្នួលកាន់តែខ្លាំង ពួកគេក៏កាន់តែងាយធ្លាក់ទៅក្រោមបន្ទាត់ក្រីក្រ ។ គេក៏បានសង្កេតឃើញបែបនេះ នៅភាគផ្សេងទៀតនៃអាស៊ីផងដែរ (Visaria 1980; Kim, Chan and Acharya 2002:23-31) ។

## ៧.៦ របាយប្រជាជនគិតតាមចំណាយប្រើប្រាស់ និងទំហំភាពក្រីក្រ

### *៧.៦.១ ទំហំនៃវិសមភាព*

ខ្សែកោង Lorenz ដែលជាការតំណាងតាមក្រាហ្វិកនូវវិសមភាព (ក្នុងករណីនេះ គឺការប្រើប្រាស់) គឺជាបន្ទរនូវរបាយគ្រួសារ និងចំណាយសរុបគូសចេញពីអ័ក្សពីរកាត់គ្នា ។ បើខ្សែកោងឃ្លាតកាន់តែឆ្ងាយពីបន្ទាត់ត្រង់ដែលកើតចេញពីបន្ទាត់ឈរពីរ គឺវិសមភាពកាន់តែធំ ហើយបើវាកាន់តែជិតទៅបន្ទាត់ត្រង់ ដែលកើតចេញពីអ័ក្សពីរនោះគឺ វិសមភាពកាន់តែតូច ។ ក្រាហ្វិក ៧.៣ គឺជាខ្សែកោង Lorenz បង្ហាញពីចំណាយប្រើប្រាស់គិតលើទិន្នន័យសរុបគ្រប់ភូមិ ។ វាបង្ហាញស្ទើរតែដូចគ្នានឹងក្រាហ្វិក ៧.២ក និង ៧.២ខ គឺថា ទំហំនៃការពង្រាយចំណាយតាមគ្រួសារក្នុងគំរូតាង គឺមិនសូវខ្ពស់ទេ (spread of expenditures across households in this sample is not very high) ។ វាបង្ហាញដែរថា វិសមភាពនៅក្នុងការប្រើប្រាស់អាហារ គឺតូចជាងការប្រើប្រាស់សរុប ។ តាមនេះវិសមភាពរវាងអ្នកមាន និងអ្នកក្រមិនខ្ពស់ប៉ុន្មានទេ (យ៉ាងហោចណាស់ក៏ចំពោះការប្រើប្រាស់ដែរ) ។

**ក្រាហ្វិក៧.៣ ខ្សែកោង Lorenz នៃចំណាយប្រើប្រាស់សរុប និង ចំណាយអាហារ**




ដើម្បីពិចារណាពីទំហំវិសមភាព, មេគុណ Gini នៃវិសមភាពត្រូវបានគណនាតាមភូមិនីមួយៗ[៥១] ។ មេគុណនេះមានតំលៃស្មើមួយ (=1) សំរាប់វិសមភាពដាច់ខាត និង (=0) សំរាប់សមភាពដាច់ខាត ។ តំលៃនានាដែលគណនាពីទិន្នន័យតាមភូមិមានបង្ហាញក្នុងខ្ទង់មេគុណ Gini នៃតារាង៧.៨ ។ នៅកំរិតសរុប (ដូចក្នុងបរិបទនៃប្រទេសកសិកម្មផ្សេងទៀតដែរ) វិសមភាពនៃការប្រើប្រាស់មានកំរិតទាប[៥២] ។ បន្ទាប់មក មេគុណ Gini មិនបានបង្ហាញទំនាក់ទំនងគួរឱ្យកត់សំគាល់ជាមួយនឹងអត្រានៃភាព ក្រីក្រទេ ។ លទ្ធផលនេះហាក់ដូចសមរម្យពីព្រោះការប្រើប្រាស់សរុបកំរិតទាប (ឧ. នៅត្រពាំងប្រិយ) បញ្ជាក់ពីវិសមភាពតូច ប៉ុន្តែក្នុងពេលជាមួយគ្នាភាពក្រីក្រមានកំរិតខ្ពស់ ។ ម្យ៉ាងទៀត ការប្រើប្រាស់សរុបកំរិតខ្ពស់អាចផ្សារភ្ជាប់នឹងការប្រើប្រាស់មានសមភាពដែលនាំឱ្យមានវិសមភាពទាប និងអត្រាភាពក្រីក្រទាប ។ បន្សំផ្សេងទៀត ក៏អាចកើតមានផងដែរ ។

សេចក្តីសន្និដ្ឋានខ្លះៗដោយផ្អែកលើការវិភាគទាំងនេះ បានផ្តល់មូលដ្ឋានស្ថិតិមួយពីវិសមភាពកំរិតតូចនៃការប្រើប្រាស់រវាងគ្រួសារនានា ។

---

[៥១] A Gini coefficient is a numeric equivalent of what a Lorenz Curve exhibits graphically. It is the ratio of the area between the curved line and the straight line joining the two vertices, and the area under the right-angled triangle formed by joining the two opposite vertices.

[៥២] សូមអានឯកសារ Khan and Lee (1984) and Srinivasan and Bardhan (1988) សំរាប់ការប្រៀបធៀបខ្លះៗនៅអាស៊ី ។ ធនាគារពិភពលោក (see World Bank 2001) ក៏មានផ្តល់តួលេខពីទំហំវិសមភាពក្នុងចំណូល និងការប្រើប្រាស់ ប៉ុន្តែគ្មានការបំបែកតួលេខសំរាប់តំបន់ជនបទទេ ។

តារាង៧.៨ ចំណាត់ថ្នាក់ចំណាយប្រើប្រាស់ (គិតជាភាគរយនៃរបាយប្រជាជន)

| ភូមិ/ចំណាត់ថ្នាក់ចំណាយ | Gini Coefficient | មធ្យមខ្សែបន្ទាត់ក្រីក្រ = 1,228 riels/day; ភាពក្រីក្រ = 982 riels/day | | | | |
|---|---|---|---|---|---|---|
| | | = 75% នៃ ភាពក្រីក្រ | 75% - 100% | 100% - 125% | 125% - 150% | 150% - |
| | | អ្នកក្រណាស់ | អ្នកក្រមធ្យម | អ្នកមិន ក្រមធ្យម | អ្នកមិនក្រ លើមធ្យម | ធូរធារ |
| **ទំនាបទន្លេសាប** | | | | | | |
| អណ្តូងត្រាច | 0.26 | 31 (36) | 33 (32) | 14 (15) | 13 (7) | 9 (9) |
| ក្រសាំង | 0.29 | 11 (23) | 18 (30) | 28 (23) | 17 (14) | 28 (11) |
| ខ្សាច់ជីរស់ | 0.28 | 18 (21) | 28 (28) | 17 (19) | 13 (12) | 25 (21) |
| **ទំនាបទន្លេមេគង្គ** | | | | | | |
| ព្រែកក្មេង | 0.25 | 1 (2) | 10 (8) | 14 (16) | 14 (19) | 61 (55) |
| បាបោង | 0.24 | 14 (26) | 17 (35) | 24 (17) | 20 (13) | 25 (9) |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 0.24 | 8 (6) | 28 (38) | 21 (26) | 21 (16) | 23 (15) |
| ដងក្តារ | 0.23 | 21 (30) | 28 (33) | 27 (20) | 12 (10) | 12 (7) |
| ត្រពាំងប្រិយ | 0.19 | 49 (46) | 40 (43) | 9 (9) | 1 (3) | 1 (0) |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 0.21 | 1 (2) | 11 (9) | 20 (21) | 29 (25) | 39 (43) |
| សរុប | **0.24** | **15 (19)** | **22 (27)** | **20 (19)** | **17 (14)** | **27 (21)** |

*Note: figures in the brackets are poverty proportions calculated for food expenses against the food poverty line.*

## *៧.៦.២ ភាពក្រីក្រ និងវិសមភាព*

តាមការប្រើប្រាស់បន្ទាត់ក្រីក្រដែលបានបកស្រាយនៅផ្នែកខាងដើម គេអាចពិនិត្យពីរបាយនៅជុំវិញបន្ទាត់ក្រីក្រ ដើម្បីអាចដឹងថា តើវាជារបាយស្មើ ឬមិនស្មើល្អ ។ តារាង៧.៨ បង្ហាញផងដែរពីទិន្នន័យនៃរបាយគ្រួសារ ដោយប្រើចំណាត់ថ្នាក់នៃការប្រើប្រាស់ ។ អ្នកក្រណាស់ (very poor) គឺជនណាដែលមានការប្រើប្រាស់ ២៥% ទាបជាងបន្ទាត់ក្រីក្រ ។ អ្នកក្រមធ្យម (moderately poor) គឺជនណាដែលមានការប្រើប្រាស់ស្មើ ឬតិចជាង ២៥% ធៀបនឹងបន្ទាត់ក្រីក្រ ។ ចំណែកឯអ្នកមិនក្រមធ្យម (medium non-poor) គេត្រូវមានអត្រាខ្ពស់ជាបន្ទាត់ក្រីក្រ ហើយអត្រាខ្ពស់ជាងដល់ ២៥% ។ អ្នកមិនក្រលើមធ្យម (medium-high non poor) មានការប្រើប្រាស់ ២៥-៥០% ខ្ពស់ជាងបន្ទាត់ក្រីក្រ ហើយអ្នកមានការប្រើប្រាស់ច្រើនជាង ៥០% ត្រូវបានចាត់ជាអ្នកធូរធារ (better off) ។ បន្ទាត់ក្រីក្រក្នុងតារាងនេះ គឺជាមធ្យមភាគលើគ្រប់ ៩ភូមិ ។ រង្វាស់ពីរត្រូវបានប្រើប្រាស់ គឺ (food poverty line) និងបន្ទាត់ក្រីក្រលើចំណាយសរុប, poverty line based on total expense) ។ ក្នុងករណីបន្ទាត់ក្រីក្រអាហារមានតែចំណាយលើស្បៀងអាហារទេ ដែលត្រូវបានយកមកប្រៀបធៀបជាមួយបន្ទាត់ក្រីក្រអាហារ ។

ជាសរុប តារាងនេះមិនបង្ហាញពីភាពក្រីក្រខ្លាំងពេកនោះទេ គឺមានតែ ១៥% ជាអ្នកក្រីក្របំផុត (១៩% បើវាស់វែងតាមបន្ទាត់ក្រីក្រអាហារ) ។ ទន្ទឹមនេះ អ្នកធូរធារពុំមានច្រើនដែរ ។ ជាសរុប មានតែ ១/៤នៃគ្រួសារ (ឬ ១/៥ បើវាស់វែងតាមបន្ទាត់ក្រីក្រអាហារ) ដែលមានការប្រើប្រាស់លើសពី ៥០% ខ្ពស់ជាងបន្ទាត់ក្រីក្រ ។

នៅភូមិមួយចំនួន ដូចជា ព្រៃកក្អែង និងកំពង់ត្នោត ពុំមានអ្នកក្រីក្រណាស់នោះទេ ។ ប៉ុន្តែនៅភូមិត្រពាំងប្រិយ ប្រជាជនស្ទើរជាងពាក់កណ្តាលជាអ្នកក្រីក្រណាស់ ។ តាមពិតនៅភូមិនេះ មានតែ ១% ប៉ុណ្ណោះជាអ្នកធូរធារ (ពោលគឺការប្រើប្រាស់ ៥០% ខ្ពស់ជាងបន្ទាត់ក្រីក្រ) ។ ភូមិមួយទៀតដែលស្រដៀងគ្នានឹងត្រពាំងប្រិយ គឺភូមិអណ្តូងត្រាច ដែលមានប្រជាជនជិត ១/៣ គឺជាអ្នកក្រីក្រណាស់ ។ នៅភូមិណាដែលមានអ្នកក្រច្រើនភូមិនោះក៏មានអ្នកក្រីក្រណាស់ច្រើនដែរ និងផ្ទុយទៅវិញ ។

គំលាតភាពក្រីក្រ និង សន្ទស្សន៍អាំងតង់ស៊ីតេភាពក្រីក្រ ដែលជាទូទៅគេហៅថា សន្ទស្សន៍ Foster Greer and Thorbecke (FGT) (ដាក់តាមឈ្មោះអ្នករកឃើញ) គឺជារង្វាស់នៃជំរៅភាពក្រីក្រក្រោមបន្ទាត់ក្រីក្រ ។ រូបមន្តជាទូទៅ គឺៈ

$PG^{\alpha} = (1/n)\ \Sigma[(Z - Yi)/Z]^{\alpha}$ (for a k-member group; k <= n)

ក្នុងរូបមននេះ n ជាទំហំប្រជាជន, Yi ជាចំណូល (ចំណាយ) នៃបុគ្គលទី i$^{th}$ ដែលក្រោមបន្ទាត់ក្រីក្រ, Z គឺជាបន្ទាត់ក្រីក្រ, ហើយ PG គឺជាសន្ទស្សន៍ ។ ប្រសិនបើ $\alpha$= 0 សន្ទស្សន៍នេះបន្ថយមកត្រឹមចំនួនមនុស្ស, បើ $\alpha$ = 1 គឺតំណាងឱ្យសន្ទស្សន៍គំលាតភាពក្រីក្រ, ហើយបើតំលៃ $\alpha$ កាន់តែខ្ពស់វាតំណាងឱ្យសន្ទស្សន៍អាំងតង់ស៊ីតេភាពក្រីក្រ ។ គឺបើសិនតំលៃ $\alpha$ កាន់តែខ្ពស់, និងមានទំងន់កាន់តែធំចងភ្ជាប់នឹងវិសមភាពនៅក្នុងសន្ទស្សន៍ស្មុគស្មាញនេះ ដែលគួបផ្សំការរាប់ចំនួនអ្នកមានភាពក្រីក្រជាមួយ និងជំរៅនៃភាពក្រីក្រក្រោមបន្ទាត់ក្រីក្រ ។ តារាង៧.៩ ផ្តល់ការប៉ាន់ស្មាននៃ PG ចំពោះ $\alpha$ = 1 (គំលាតភាពក្រីក្រ) និង $\alpha$ = 2 (អាំងតង់ស៊ីតេភាពក្រីក្រ) ។

**តារាង៧.៩ ការវាស់វែងគំលាតភាពក្រីក្រ និង អាំងតង់ស៊ីតេភាពក្រីក្រ ឆ្នាំ២០០១ និង ១៩៩៦-៩៧**

| | **គំលាតភាពក្រីក្រ 2001 (%)** | **អាំងតង់ស៊ីតេភាពក្រីក្រ 2001 (%)** | **គំលាតភាពក្រីក្រ 1996–97 (%)** |
|---|---|---|---|
| **ទំនាបទន្លេសាប** | | | |
| អណ្តូងត្រាច | 10.7 | 3.1 | |
| ក្រសាំង | 4.4 | 1.4 | |
| ខ្សាច់ជីរស់ | 10.2 | 3.5 | |
| **ទំនាបទន្លេមេគង្គ** | | | |
| ព្រៃកក្អែង | 1.6 | 0.3 | 18.0 |
| បាបោង | 5.1 | 1.5 | 16.0 |
| **តំបន់ខ្ពង់រាប** | | | |
| កញ្ជរ | 7.7 | 2.0 | |
| ដងក្តារ | 15.7 | 5.5 | |
| ត្រពាំងប្រិយ | 18.5 | 6.4 | 16.0 |
| **តំបន់ឆ្នេរ** | | | |
| កំពង់ត្នោត | 1.3 | 0.2 | |
| **សរុប** | **8.2** | **2.7** | |

តារាងនេះបញ្ជាក់គាំទ្រលទ្ធផលរកឃើញពីខាងដើមដែលថា នៅកំរិតសរុបរួម គំលាតភាពក្រីក្រ និងអាំងតង់ស៊ីតេនៃភាពក្រីក្រមិនខ្ពស់ណាស់ណាទេ គឺមានន័យថា អ្នកក្រីក្រភាគច្រើនណាស់មិនឃ្លាតពីបន្ទាត់ក្រីក្រខ្លាំងទេ[៥៣] ។ ដូចបានរកឃើញពីខាងដើម យ៉ាងហោចណាស់ក៏មាន ២ភូមិ គឺដងក្តារ និង ត្រពាំងប្រិយ ដែលមានភាពក្រីក្រកំរិតខ្ពស់ និងគំលាតភាពក្រីក្រធំ ។ ម្យ៉ាងទៀត ការប្រៀបធៀបនឹងអង្កេតឆ្នាំ១៩៩៦-៩៧ បានបង្ហាញពីភាពប្រហាក់ប្រហែលគ្នា តែនៅភូមិត្រពាំងប្រិយមួយ

[៥៣] ការវិភាគផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៩ ក៏បង្ហាញលទ្ធផលប្រហាក់ប្រហែលគ្នាដែរ See RGC (2001) ។

ប៉ុណ្ណោះ ។ នៅព្រៃកក្អែង និងបាបោង, គំលាតភាពក្រីក្រ បានធ្លាក់ចុះយ៉ាងខ្លាំង ដែលស្របគ្នានឹងគំហើញពីខាងដើមដែលថា ភាពក្រីក្របានធ្លាក់ចុះបើគិតជាចំនួនមនុស្សនៅក្នុងតំបន់ទាំងនេះ ។

គេអាចបញ្ជាក់សារឡើងវិញថា ភាពក្រីក្រមានកំរិតទាប (និងបានធ្លាក់ចុះ) នៅក្នុងភូមិមានផលិតភាពស្រូវខ្ពស់ និងមានលទ្ធភាពរកបានធនធានធម្មជាតិ (ជាពិសេសត្រី) ។ ផ្ទុយទៅវិញ សមាមាត្រភាពក្រីក្រមានកំរិតខ្ពស់នៅតាមភូមិដាច់ស្រយាល ឬខ្សត់ធនធាន ឬដែលអ្នកភូមិរកចំណូលពីការលក់ពលកម្ម ។ សរុបមកមូលដ្ឋាន ធនធានធម្មជាតិនៃភូមិមួយ នៅតែជាកត្តាកំណត់នៃកំរិតជីវភាពរបស់ប្រជាជនដដែល ។

## ៧.៧ សេចក្តីសង្ខេប

ជំពូកនេះ រកឃើញថា ចំណាយតាមគ្រួសារសរុបមានការប្រែប្រួលច្រើនតាមរដូវ និងតាមតំបន់ ។ ការប្រើប្រាស់ស្បៀងខ្ពស់រហូតដល់ ៦៨% នៃចំណាយសរុប គឺប្រែប្រួលពី ៥៩-៧៨% ទៅតាមភូមិផ្សេងៗគ្នា ។ ភូមិធូរធារប្រើប្រាស់ក្នុងសមាមាត្រទាបជាងនូវចំណូលគ្រួសារទៅលើអាហារ ។ ការប្រើប្រាស់អង្ករពុំមានភាពយឺតទេ គឺបានន័យថា ប្រជាជនប្រើប្រាស់អង្ករក្នុងសមាមាត្រមួយថេរដោយមិនគិតពីវណ្ណៈសេដ្ឋកិច្ច-សង្គមកិច្ចរបស់ពួកគេទេ ។ ការប្រើប្រាស់អីវ៉ាន់មិនមែនអាហារមានភាពយឺតយ៉ាងខ្លាំង: ប្រជាជនកាត់បន្ថយការប្រើប្រាស់នៅក្នុងរដូវខ្សត់ ហើយអ្នកក្រីក្រកាត់បន្ថយច្រើនជាងគេ ។ ប៉ុន្តែចំណាយលើសុខភាពពុំមានភាពយឺតទេ គឺបានន័យថា ទាំងអ្នកក្រ ទាំងអ្នកមានត្រូវចំណាយសឹងតែដោយខានមិនបានក្នុងសមាមាត្រ ១០% នៃចំណាយសរុបទៅលើសុខភាព ។

គិតជាសរុបលើភូមិទាំង៩ មានអ្នកភូមិរស់នៅក្រោមបន្ទាត់ក្រីក្រ ៣៨% ។ ប៉ុន្តែមានការខុសគ្នាយ៉ាងខ្លាំងពីភូមិមួយទៅភូមិមួយ ។ នៅភូមិមានផលិតភាពទាប និងខ្សត់ធនធានធម្មជាតិ ដូចជា ត្រពាំងប្រិយ និងដងក្តារ អ្នកក្រីក្រ មានច្រើនជាង ៦០% ចំណែកឯភូមិមានផលិតភាពខ្ពស់ និងសំបូរធនធានធម្មជាតិជាង ដូចជា ព្រៃកក្អែង បាបោង និងកំពង់ត្នោត គឺមានប្រជាជនតិចជាង ១/៤ រស់នៅក្រោមបន្ទាត់ក្រីក្រ ។ ទំហំនៃភាពក្រីក្រមានលំនាំប្រហាក់ប្រហែលគ្នា ។ ការវិភាគក្នុងជំពូកនេះបានបញ្ជាក់គាំទ្រដល់គំហើញពីខាងដើមដែលថា ចំណូលពីការងារពឹងផ្អែកលើធនធានធម្មជាតិ វាមានទំនាក់ទំនងបញ្ច្រាសជាមួយនឹងភាពក្រីក្រ ។

ធៀបនឹងអង្កេតឆ្នាំ១៩៩៦-៩៧ ដែល វិបសអ បានធ្វើអង្កេតលើ ៣ភូមិ, គេឃើញមានការរីកចំរើនគួរឱ្យកត់សំគាល់ក្នុង ២ភូមិ ដោយចំនួនអ្នកក្រីក្របានថយចុះយ៉ាងច្រើន ។ នៅភូមិទីបី ដែលជាភូមិក្រធនធានធម្មជាតិ និងមានអត្រាអ្នកក្រីក្រយ៉ាងច្រើនរស់នៅក្រោមបន្ទាត់ក្រីក្រ, ស្ថានភាពបានធ្លាក់ធ្ងន់ធ្ងរថែមទៀត ។ ប៉ុន្តែនៅតាមជនបទមានប្រជាជនតិចតួចទេដែលអាចចាត់ជា "អ្នកក្រីក្រណាស់" ឬ "អ្នកមាន" បាន ។

# ជំពូកទី ៨

# ទីផ្សារពលកម្ម

ការវិភាគបង្ហាញថា ប្រជាជនជនបទធ្វើសកម្មភាពច្រើនមុខនៅក្នុងយុទ្ធសាស្ត្រកចិញ្ចឹមជីវិត ។ ក្នុងករណីខ្លះ គឺជាការងារក្នុងរបរផ្ទាល់ដោយខ្លួនឯង និងករណីខ្លះទៀត គឺជាពលកម្មយកប្រាក់កំរៃ ។ ទីផ្សារពលកម្មក៏មានដំណើរការជាក់ស្តែងសំរាប់បុរស-ស្ត្រី និងជួនកាលសំរាប់កុមារផងដែរ ។ ពួកគេបានចូលរួមក្នុងទីផ្សារពលកម្មដើម្បីរកប្រាក់ ឬការទូទាត់សងតាមបែបបទណាមួយ ។ ការយល់ឃើញជាទូទៅដែលថា ប្រជាជនជនបទកម្ពុជាមានធ្វើអ្វីផ្សេងតិចតួចណាស់ ក្រៅពីរបរធ្វើស្រែសំរាប់មួយរស់ គឺហាក់ដូចជាមិនស៊ីគ្នានឹងការអះអាងនានាខាងលើទេ ។ ក្នុងបរិបទនៃយុទ្ធសាស្ត្រកចិញ្ចឹមជីវិតនៅជនបទ គេគួរលើកឡើងនូវសំនួរជាប់ទាក់ទិនមួយចំនួនដូចខាងក្រោមៈ

១) តើរបរផ្ទាល់ដោយខ្លួនឯង និងការងារមានប្រាក់កំរៃ ដែលពលកររួមទាំងកុមារផងបានចូលរួមមានទំហំប៉ុណ្ណា?

២) តើមានការខុសគ្នាយ៉ាងណាខ្លះខាងយេនឌ័ នៅក្នុងសកម្មភាពផ្សេងៗដែលប្រជាជនអនុវត្ត?

៣) តើប្រាក់កំរៃរកបានដោយកម្មករពលករផ្សេងៗមានលក្ខណៈយ៉ាងណា? តើវាជាប្រាក់កំរៃអាចរស់បានឬទេ?

៤) តើសកម្មភាពមានប្រាក់កំរៃមានច្រើនមុខប៉ុណ្ណា ជាពិសេសតាមរយៈការធ្វើចំណាកស្រុក?

## ៨.១ ការចូលរួមក្នុងកំលាំងពលកម្ម និងពលកម្មកុមារ

តារាង៨.១ រាយការណ៍ពីអត្រាចូលរួមក្នុងកំលាំងពលកម្មរបស់ប្រជាជនទាំង ៩ភូមិ គិតតាមភេទ និងអាយុ ។ ពលកម្មកុមារក្នុងក្រុមអាយុ៧-១២ឆ្នាំ មានច្រើនជាង ៨% បន្តិច ។ ក្នុងចំណោមកុមារក្នុងក្រុមអាយុ ៧-១២ឆ្នាំ មានតែ ៥៥% ប៉ុណ្ណោះបានចូលរៀនដោយគ្មានការខុសគ្នាគួរកត់សំគាល់តាមភេទទេ ។ ក្នុងចំណោមអ្នកចូលរៀនមាន ៥២% នៃភេទប្រុស និង ៤៣% នៃភេទស្រី ក៏បានចូលបំរើការងារផងដែរ ។ ដូច្នេះពលកម្មកុមារ គឺជាកត្តាមួយសំខាន់គួរកត់សំគាល់ ។

កុមារក្នុងក្រុមអាយុ ១៣-១៧ឆ្នាំ បានចូលរួមច្រើនក្នុងពលកម្មកុមារៈ ៤៣,៥% នៃក្មេងប្រុស និង ៥២,៨% នៃក្មេងស្រី បានចេញពីសាលា ហើយចូលទៅក្នុងកំលាំងពលកម្ម ។ គំលាតរវាងភេទផុសចេញពីអត្រាចុះឈ្មោះចូលរៀនទាបត្រឹម ៤១,៦% សំរាប់កុមារី ធៀបនឹងកុមារា ៤៥,៣% ។ សិស្សដែលបន្តការសិក្សាភាគច្រើនក៏បានចូលធ្វើការដែរ ដែលធ្វើឱ្យមានតួលេខ ពលកម្មកុមារ ។

ក្នុងក្រុមអាយុ១៨-២៤ឆ្នាំ មានតែ ៧,៤% នៃយុវជន និង ៣,៥% នៃយុវនារីដែលបន្តការសិក្សា ។ យុវនារី ៣,៥% ទាំងអស់នេះធ្វើការផងនិងរៀនផង ធៀបនឹង ៧៣% ក្នុងចំណោមយុវជន ៧,៤ % ។

ក្នុងក្រុមអាយុច្រើនជាងនេះ ការចូលរួមក្នុងកំលាំងពលកម្មមានកំរិតកាន់តែខ្ពស់ ទាំងសំរាប់ស្ត្រី និងបុរស ។ ទិន្នន័យនេះដែលតែងឃើញមានក្នុងប្រទេសមានចំណូលទាប បង្ហាញថា អត្រាចុះឈ្មោះចូលរៀនមានកំរិតទាប ហើយប្រជាជនឆាប់ចូលរួមក្នុងកំលាំងពលកម្ម ។

**តារាង៨.១ ប្រជាជនសកម្ម និងមិនសកម្មក្នុងសេដ្ឋកិច្ច តាមអាយុ និងភេទ**

| អាយុ | ភេទ | សកម្ម | និស្សិត* | ពិការ | ក្មេងនិងចាស់មិនអាចធ្វើការ | សរុប |
|---|---|---|---|---|---|---|
| 7 – 12 | ប្រុស | 8.4 | 55.3 (52) | 0.2 | 36.1 | 100 |
| | ស្រី | 8.1 | 55.5 (43) | 0.4 | 36.0 | 100 |
| 13 – 17 | ប្រុស | 43.5 | 49.3 (83) | 1.3 | 5.8 | 100 |
| | ស្រី | 52.8 | 41.6 (76) | 1.1 | 4.5 | 100 |
| 18 – 24 | ប្រុស | 91.8 | 7.4 (73) | 0.8 | | 100 |
| | ស្រី | 95.1 | 3.5 (100) | 0.3 | | 100 |
| 25 – 34 | ប្រុស | 98.1 | | 1.6 | | 100 |
| | ស្រី | 98.8 | | 1.2 | | 100 |
| 35 – 44 | ប្រុស | 99.7 | | 0.3 | | 100 |
| | ស្រី | 98.5 | | 1.2 | | 100 |
| 45 – 54 | ប្រុស | 96.9 | | 2.5 | | 100 |
| | ស្រី | 96.0 | | 1.8 | 2.2 | 100 |
| ច្រើនជាង ឬស្មើ 55 | ប្រុស | 66.8 | | 4.1 | 28.5 | 100 |
| | ស្រី | 48.5 | | 3.0 | 47.8 | 100 |

** តួលេខនៅក្នុងវង់ក្រចក បង្ហាញពីភាគរយសិស្សដែលធ្វើការងារ ។*

## ៨.២ របរផ្ទាល់ដោយខ្លួនឯងក្នុងកសិកម្ម

តារាង៨.២ បង្ហាញពីការចំណាយពេលវេលារបស់បុរស និងស្ត្រីនៅក្នុងការងារដាំដុះលើដីរបស់ខ្លួន ។ ចំនួនម៉ោងធ្វើការជាមធ្យមរបស់បុរស (៦,៣ម៉ោង/ថ្ងៃ) ច្រើនលើសស្ត្រីបន្តិច (៦,១ម៉ោង/ថ្ងៃ) ។ នៅភូមិមានផលិតភាពខ្ពស់ ដូចជា ក្រសាំង និងបាបោង អ្នកភូមិចំណាយពេលវេលាច្រើនជាងនៅភូមិផ្សេងទៀតក្នុងការដាំដុះលើដីរបស់ខ្លួន ។ ប៉ុន្តែម៉ោងធ្វើការត្រូវបានរាយការណ៍មិនច្បាស់លាស់ទេ ពីព្រោះភាគច្រើនមិនដែលបានគិតគូរពីរឿងនេះ ។

**តារាង៨.២ ចំនួនម៉ោង និងខែ ធ្វើការងារកសិកម្មផ្ទាល់ខ្លួនក្នុងក្រុមអាយុ១៥-៥៤ឆ្នាំ**

| | ចំនួនម៉ោង/ថ្ងៃ | | | ចំនួនខែ/ឆ្នាំ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| **ទំនាបទន្លេសាប** | | | | | | |
| អណ្តូងត្រាច | 4.7 | 3.3 | 4.1 | 4.4 | 4.6 | 4.5 |
| ក្រសាំង | 8.2 | 7.8 | 8.0 | 3.7 | 4.0 | 3.9 |
| ខ្សាច់ជីរស់ | 6.1 | 6.1 | 6.1 | 5.9 | 5.8 | 5.9 |
| **ទំនាបទន្លេមេគង្គ** | | | | | | |
| ព្រៃកក្មេង | 5.8 | 5.6 | 5.7 | 3.4 | 3.2 | 3.3 |
| បាបោង | 7.6 | 8.1 | 7.9 | 4.7 | 4.2 | 4.5 |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 5.5 | 5.6 | 5.6 | 3.9 | 3.3 | 3.6 |
| ដងក្តារ | 7.0 | 6.8 | 6.9 | 3.9 | 3.9 | 3.9 |
| ត្រពាំងប្រិយ | 5.9 | 6.4 | 6.1 | 6.8 | 6.4 | 6.6 |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 4.9 | 5.2 | 5.0 | 6.3 | 6.2 | 6.2 |
| **សរុប** | **6.3** | **6.1** | **6.2** | **4.7** | **4.6** | **4.7** |

*សំគាល់: កំរិតខ្ពស់បំផុតនៃអាយុគឺត្រឹម ៥៤ឆ្នាំ ។*

កសិកម្មដែលមានការធ្វើស្រែជាសំខាន់មិនធ្វើឱ្យអ្នកភូមិជាប់រវល់ពេញមួយឆ្នាំទេ ។ ជាមធ្យមកសិករធ្វើការដាំដុះលើដីកសិដ្ឋានរបស់ខ្លួនតែ ៤-៥ខែក្នុងមួយឆ្នាំៗ ។ នេះគឺជារយៈពេលធ្វើស្រែជាមធ្យមហើយបុរស និងស្ត្រីចំណាយពេលប្រហែលគ្នា ។ ទិន្នន័យទាំងនេះ បានគាំទ្រចំពោះទិន្នន័យចំណូលដែលរកឃើញពីខាងដើម និងបានបញ្ជាក់ឡើងវិញថា កសិករមិនធ្វើការក្នុងកសិកម្មគ្រប់តែពេលនោះទេ ហើយក៏មិនទទួលចំណូលទាំងអស់តែពីកសិកម្មនោះដែរ ។

## ៨.៣ ការងាររកប្រាក់កំរៃ

ចំណូលប្រចាំថ្ងៃរបស់អ្នកធ្វើការងារស៊ីប្រាក់កំរៃបែងចែកតាមប្រភេទការងារ ទីកន្លែង និង យែនឌ័រ ត្រូវបានអង្កេតក្នុងទាំងពីរវគ្គ គឺនៅរដូវវស្សា និងរដូវប្រាំង (ឧបសម្ព័ន្ធ៧, តារាង១) ។ ក្នុងករណីភាគច្រើន ពលកររកមិនសូវបានច្រើនណាស់ណាជាង ៤.០០០រៀល/ថ្ងៃទេ (ប្រហែល ១ដុល្លារ) ។ ក្នុងគ្រប់ប្រភេទការងារបុរស រកបានច្រើនជាងស្ត្រី ប៉ុន្តែការងារមិនដូចគ្នាទាំងអស់ទេ[៥៤] ។ អត្រាប្រាក់កំរៃសំរាប់ការងារនៅក្នុងភូមិខ្លួនឯងមានកំរិតទាបជាងសំរាប់ការងារនៅក្រៅភូមិ ។ ជាមធ្យមបុរសអាចរកបាន ៣.៥០០រៀល/ថ្ងៃ សំរាប់ការងារក្នុងភូមិខ្លួនឯង និង ៤.៥០០រៀល សំរាប់ការងារនៅក្រៅភូមិ ។ ប្រាក់កំរៃខ្ពស់ សំរាប់ទូទាត់មួយចំណែកនៃចំណាយ និងការលំបាកផ្សេងៗ ដែលបណ្តាលពីរឿងទៅធ្វើការនៅក្រៅភូមិ ។

ការប្រៀបធៀបអត្រាប្រាក់កំរៃរវាងភូមិនីមួយៗ ឬរបរនីមួយៗ មិនសូវមានប្រយោជន៍ទេ ពីព្រោះការចាត់ចែងការងារតាមភូមិនីមួយៗ មិនដូចគ្នាទីផ្សារពលកម្មក៏មិនដូចគ្នា ហើយការងារក៏ខុសគ្នាដែរ ។ ឧទាហរណ៍ អត្រាប្រាក់កំរៃការងារកសិកម្មនៅភូមិអណ្តូងត្រាច គឺ ៦.៤០០ រៀល/ថ្ងៃ ប៉ុន្តែនេះជាអត្រាមធ្យមគិតលើពលករតែពីរនាក់ ។ ភាពខុសគ្នាក្នុងទីផ្សារពលកម្មអាចមើលឃើញនៅភូមិកំពង់ត្នោតដែលគេរាយការណ៍ថាមានអត្រាប្រាក់កំរៃគឺ ៧.០០០រៀល/ថ្ងៃ សំរាប់ការងារកសិកម្មនៅពេលធ្វើអង្កេតក្នុងរដូវវស្សា ប៉ុន្តែមានមនុស្សតែម្នាក់គត់ដែលរាយការណ៍ថា បានធ្វើការងារយកប្រាក់កំរៃ ។ ចំពោះប្រភេទខុសៗគ្នានៃការងារវិញ កម្មករនៅភូមិកញ្ជរ ទទួលប្រាក់កំរៃប្រចាំថ្ងៃខ្ពស់បំផុត (៨.៣៨៩រៀល នៅក្នុងអង្កេតរដូវវស្សា-វគ្គ២) ប៉ុន្តែវាជាការងារក្រៅភូមិដែលមានជាសំខាន់ការសាបព្រោះ និងការឈើពីព្រៃ ។

ក្នុងភូមិនេសាទ ពលករស៊ីប្រាក់កំរៃនៅខ្សាច់ជីរស់ រកចំណូលបានតិចបំផុត ។ នៅរដូវប្រាំងឆ្នាំ២០០១ បុរសរកបាន ២.៥០០រៀល/ថ្ងៃនៅភូមិខ្សាច់ជីរស់ធៀបនឹង ៤.៤០០រៀលនៅព្រែកក្មេង និង ៤.០០០រៀលនៅកំពង់ត្នោត ។ រឿងនេះបង្ហាញថា ខ្សាច់ជីរស់ ស្ថិតក្នុងចំណោមភូមិក្រីក្របំផុត ។ នៅរដូវវស្សា ចំណូលពីការរកត្រីធ្លាក់ចុះនៅ២ភូមិនេសាទទឹកសាប ប៉ុន្តែកើនឡើងនៅភូមិនេសាទតំបន់ឆ្នេរសមុទ្រ ។ គេរាយការណ៍ថា ស្ត្រីអ្នកនេសាទរកប្រាក់ចំណូលបានតិចជាងបុរសអ្នកនេសាទ ។

ការរកធនធានជលផលក្រៅពីត្រី មិនផ្តល់ចំណូលជាប្រាក់បានច្រើនដូចសកម្មភាពខាងលើទេ ។ នៅភូមិក្រសាំង និង ព្រែកក្មេង (ដែលមានអ្នកភូមិច្រើនជាងគេធ្វើសកម្មភាពនេះ) បុរសរកចំណូលបាន ៣.៥០០រៀល/ថ្ងៃ ឬតិចជាង ឯស្ត្រីរកបានកាន់តែតិចជាងទៀត ។ ការប្រមែប្រមូលធនធានព្រៃឈើ ក៏មិនផ្តល់ចំណូលប្រាក់ច្រើនដែរ លើកលែងតែនៅភូមិកញ្ជរ ដែលអ្នកភូមិធ្វើការងារធ្ងន់ខាងកែច្នៃឈើ ។

ជាសង្ខេប ទិន្នន័យបង្ហាញថា ប្រាក់កំរៃមិនបានច្រើនទេ ចំពោះការងារគ្រប់ប្រភេទដែលគេឃើញមាននៅជនបទ ពីព្រោះមានតិចនាក់ណាស់ដែលរកបានច្រើនជាង ១ដុល្លារ/ថ្ងៃ ។

---

[៥៤] ឧទាហរណ៍ ក្នុងការងារកសិកម្មបុរសដែលជាអ្នករៀបចំដីដោយប្រើសត្វអូសទាញមួយនឹម បានទទួលកំរៃពីរដងច្រើនជាងពលករស្ត្រីដែលស៊ីឈ្នួលដកស្ទូង ។

តារាង៨.៣ ចំណូល/ប្រាក់កំរៃ បែងចែកតាមកំរិតអប់រំ ប្រភេទការងារ និងយែនឌ័រ (ពាន់រៀល/ថ្ងៃ)

| | មិនចេះអក្សរ | | | ទទួលការអប់រំខ្លះ | | | អនុវិទ្យាល័យ និងខ្ពស់ជាង | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| | | | | | លើក ទី ១-រដូវប្រាំង | | | | |
| ការងារកសិកម្មក្នុងភូមិ | 2.1 | 2.5 | 2.4 | 2.7 | 2.9 | 2.8 | 2.5 | 2.5 | 2.5 |
| ការងារក្រៅភូមិ | 4.4 | 3.1 | 3.7 | 5.5 | 3.0 | 4.7 | 6.4 | 3.9 | 5.7 |
| ធ្វើការនៅថៃ | 7.1 | 6.7 | 6.9 | 6.4 | 9.0 | 7.1 | 6.7 | - | 6.7 |
| របរ និងជំនួញតូចតាច | 3.9 | 3.2 | 3.2 | 3.3 | 3.5 | 3.5 | 5.2 | 2.7 | 3.7 |
| ធ្វើស្ករត្នោត | 5.3 | 0.5 | 4.3 | 6.7 | - | 6.7 | 4.6 | 7.0 | 4.9 |
| នេសាទ | 4.1 | 2.0 | 3.5 | 4.0 | 2.4 | 3.7 | 3.9 | 3.0 | 3.8 |
| ប្រមូលធនធានតាមបឹងបួរ | 2.6 | 2.4 | 2.4 | 3.6 | 2.3 | 2.7 | 2.8 | 1.7 | 2.3 |
| ប្រមូលធនធានព្រៃឈើ | 2.8 | 1.4 | 2.2 | 3.3 | 1.4 | 2.6 | 3.1 | 1.1 | 2.5 |
| ការងារផ្សេងទៀត | 7.7 | 4.5 | 5.4 | 3.3 | 4.8 | 4.0 | 7.4 | 3.1 | 6.3 |
| សរុប | **4.4** | **2.9** | **3.8** | **4.3** | **3.3** | **4.2** | **4.7** | **2.7** | **4.2** |
| | | | | | លើកទី ២-រដូវវស្សា | | | | |
| ការងារកសិកម្មក្នុងភូមិ | 3.1 | 3.0 | 3.0 | 3.2 | 2.9 | 3.0 | 3.4 | 2.4 | 3.0 |
| ការងារក្រៅភូមិ | 3.5 | 4.1 | 3.8 | 6.1 | 3.2 | 5.2 | 7.6 | 4.3 | 6.7 |
| ធ្វើការនៅថៃ | 5.5 | 6.2 | 5.9 | 6.5 | 4.9 | 6.0 | 7.1 | 7.0 | 7.1 |
| របរ និងជំនួញតូចតាច | 3.0 | 2.4 | 2.4 | 4.7 | 2.4 | 2.7 | 4.1 | 2.4 | 3.0 |
| ធ្វើស្ករត្នោត | 5.9 | - | 5.9 | 4.6 | - | 4.6 | 3.9 | - | 3.9 |
| នេសាទ | 3.1 | 2.0 | 2.7 | 3.4 | 2.2 | 3.1 | 3.5 | 3.2 | 3.5 |
| ប្រមូលធនធានតាមបឹងបួរ | 3.9 | 2.5 | 2.6 | 3.0 | 2.2 | 2.4 | 2.5 | 1.8 | 2.2 |
| ប្រមូលធនធានព្រៃឈើ | 4.3 | 1.8 | 3.2 | 5.6 | 1.5 | 5.0 | 6.2 | 2.3 | 5.4 |
| ការងារផ្សេងទៀត | 3.6 | 3.5 | 3.5 | 4.2 | 3.1 | 3.9 | 4.3 | 2.1 | 3.7 |
| សរុប | **4.0** | **2.8** | **3.7** | **4.6** | **2.5** | **4.0** | **4.8** | **2.8** | **4.3** |

តារាង៨.៣ បង្ហាញពីចំណូលប្រចាំថ្ងៃនៅក្នុងការងារផ្សេងៗ ធ្វើដោយពលករមានកំរិតអប់រំ ។ សំរាប់ការងារភាគច្រើន អ្នកមិនចេះអក្សររកចំណូលបានតិចជាងអ្នកចេះអក្សរ ។ ចំពោះការងារកសិកម្មនៅក្នុងភូមិ អ្នកចេះអក្សររកចំណូលបានច្រើនជាងអ្នកមិនចេះអក្សរប្រហែលពីរបីរយរៀល ។ សំរាប់ពលករទាំងពីរភេទ បើមានការអប់រំកាន់តែខ្ពស់ប្រាក់ចំណូលក៏បានកាន់តែខ្ពស់ដែរ ប៉ុន្តែប្រាក់កំរៃរបស់ស្ត្រីតែងតែបានតិចជាងបុរសសំរាប់គ្រប់កំរិតអប់រំ ។ ការអប់រំហាក់ដូចមិនធ្វើឱ្យមានអ្វីខុសគ្នាច្រើនទេ លើប្រាក់ចំណូលរកបានពីការនេសាទ ។ ចំពោះរបរផ្សេងទៀត ប្រាក់ចំនួលមានការខុសប្លែកគ្នាខ្លះ ទៅតាមកំរិតអប់រំ ។ ទិន្នន័យក្នុងតារាងនេះបង្ហាញថា ទោះបីការងារនៅជនបទមានចរិតភាគច្រើនជាការងារកំលាំងបាយក្តី ក៏ការអប់រំនៅតែមានសារៈសំខាន់ជាបញ្ហាក្នុងការកំណត់ប្រាក់កំរៃដដែល ។

## ៨.៤ ចំណាកស្រុកលក់ពលកម្មទៅប្រទេសថៃ

ការចំណាកស្រុកលក់ពលកម្មឆ្លងដែន បានកើនឡើងជាមួយនឹងការធ្វើសមាហរណកម្មក្នុងតំបន់ ។ ការរីកចំរើនសេដ្ឋកិច្ចថៃមុនពេលមានវិបត្តិហិរញ្ញវត្ថុឆ្នាំ១៩៩៧ បានទាក់ទាញពលករកម្ពុជាជាច្រើនឱ្យធ្វើដំណើរទៅរកការងារធ្វើនៅថៃ ទាំងនៅទីក្រុងបាងកក និងតាមបណ្តាខេត្តជាប់ព្រំប្រទល់កម្ពុជា (Chan and So 1999) ។ ទោះបីសេដ្ឋកិច្ចថៃបានធ្លាក់ចុះក្តី ប៉ុន្តែនៅ

កម្ពុជាខ្វះចំរុះកម្មមុខរបរសំរាប់ស្រូបយកកំណើនកំលាំងពលកម្ម ។ ជាលទ្ធផល ពលករកម្ពុជាជាច្រើនបានធ្វើចំណាកស្រុកទៅប្រទេសថៃ ។

អង្កេតនេះបានរកឃើញថាមាន ១១០គ្រួសារនៅភូមិក្រសាំង ឬ ៤៨%នៃគ្រួសារសរុប, បានបញ្ជូនសមាជិកគ្រួសារយ៉ាងហោចណាស់ម្នាក់ទៅធ្វើការនៅថៃ (តារាង៨.៤) ។ នៅឆ្នាំ២០០១ មានពលករបុរស ៩៥នាក់ បានធ្វើដំណើរទៅធ្វើការនៅថៃ ។ ពួកគេតំណាងឱ្យ ៣០%នៃបុរសមានអាយុ១៥-៥៤ឆ្នាំ នៅក្នុងភូមិ ។ ពួកគេរកកំរៃបានជាមធ្យម ៦.៦៥០រៀល/ថ្ងៃ។ ស្ត្រី ៥៣នាក់ (១៧%នៃស្ត្រីមានអាយុ១៥-៥៤ឆ្នាំ) ក៏ធ្វើចំណាកស្រុកទៅថៃដែរ ។ ពួកគេរកប្រាក់កំរៃបានតិចជាងត្រឹម ៥.៨០០រៀល/ថ្ងៃ ។ ទោះបីជាស្ថិតនៅជិតភូមិក្រសាំងក្តី ភូមិអណ្តូងត្រាចមានតែបុរស ១២នាក់ និងស្ត្រី ៥នាក់ ទៅលក់ ពលកម្មនៅថៃ ។ ទំនាក់ទំនង និងការស្គាល់ទីផ្សារពលកម្មអាចជួយសំរួលច្រើនដល់ចំណាកស្រុកអន្តរជាតិ ។ ក្នុងមួយរយៈពេល កន្លងមក ភូមិក្រសាំងបានកសាងទំនាក់ទំនងដូចខាងលើ ចំណែកឯភូមិអណ្តូងត្រាច ដែលជាភូមិតាំងទីលំនៅថ្មីរបស់ជនមាតុភូមិ និវត្តន៍ពុំទាន់បានធ្វើដូច្នេះទេ ។

ឱកាសការងារនៅថៃ គឺមានពេញ១មួយឆ្នាំ ប៉ុន្តែតំរូវការនៅរដូវភ្លៀងមានច្រើនជាងរដូវប្រាំងបន្តិច ។ ការងារភាគច្រើនដែលជនចំណាកស្រុកកម្ពុជាធ្វើ គឺការដាំដុះ ដកស្ទូង បោចស្មៅ និងប្រមូលផល ។ ជនចំណាកស្រុកភាគច្រើន ជាជនខុសច្បាប់ ហើយស្នាក់នៅថៃតែ ៣-៤សប្តាហ៍ជាមធ្យមក្នុងដំណើរមួយលើក១ ។

**តារាង៨.៤ ចំនួនជនចំណាកស្រុកទៅថៃ និងអត្រាប្រាក់កំរៃ**

| | ចំនួនគ្រួសារ (% នៃគ្រួសារសរុប) | ចំនួនជណចំណាកស្រុក (% នៃក្រុម (15–54) | | | ប្រាក់កំរៃ រៀល/ថ្ងៃ | | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ក្រសាំង | 110 (48%) | 95 (30%) | 53 (17%) | 148 (23%) | 6,650 | 5,800 | 6,300 |
| អណ្តូងត្រាច | 14 (7%) | 12 (4%) | 5 (2%) | 17 (3%) | 7,330 | 9,000 | 7,750 |

## ៨.៥ សេចក្តីសង្ខេប

ពលកម្មកុមារមានទំហំគួរកត់សំគាល់ ។ កុមារជាច្រើនដែលនៅសិក្សា ក៏បានចូលរួមធ្វើការងារដែរ ។ ជាមធ្យមកសិករមិនជាប់រវល់លើសពី ៥ខែទេ សំរាប់ការងារនៅតាមកសិដ្ឋានគ្រួសារ ។ បុរស និងស្ត្រី ចំណាយពេលប្រហែលគ្នាទៅលើការងារកសិដ្ឋានរបស់ខ្លួន (ប្រហែល ៦ម៉ោង/ថ្ងៃ) ។ ដូច្នេះមានពេលសល់ទំនេរសំរាប់កសិករជាច្រើន ពីព្រោះការងារនៅកសិដ្ឋានរបស់ខ្លួនឯងមិនអាចស្រូបអស់ទេនូវពេលវេលាដែលកសិករមាន ។ ជាមធ្យម ពលករបុរសរកប្រាក់កំរៃបាន ១៥% ច្រើនជាងពលករស្ត្រី ប៉ុន្តែការងាររបស់បុរស និងស្ត្រីមិនដូចគ្នាទេ ។ ប្រាក់កំរៃប្រចាំថ្ងៃជាមធ្យមតាមភូមិនានាគឺ ៣០០០-៥០០០រៀល ។ ពលករចំណាកស្រុកទៅប្រទេសថៃរកប្រាក់កំរៃបានពី ៦០០០-៧០០០រៀល/ថ្ងៃ ។ នៅក្នុងវិស័យជ្រើសរើសមួយចំនួន ពលករមានកំរិតអប់រំដល់មធ្យមសិក្សា ឬខ្ពស់ជាងរកចំណូលបាន ៥ដងច្រើនជាងពលករមានការអប់រំត្រឹមកំរិតមូលដ្ឋាន ហើយពលករមានការអប់រំត្រឹមកំរិតមូលដ្ឋាននេះរកចំណូលបាន ១៥% ច្រើនជាងពលករមិនចេះអក្សរ ។

នៅក្នុងបរិបទសន្តិសុខស្បៀង ការងារយកប្រាក់កំរៃកាន់តែមានសារៈសំខាន់ ។ ប៉ុន្តែការងារភាគច្រើន ដែលពលករធ្វើ គឺការងារប្រើកំលាំងបាយ និងគ្មានជំនាញ ហើយផ្តល់ប្រាក់កំរៃមានកំរិតទាបស្ទើរតែមិនគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតឱ្យរស់ផង ។ និន្នាការបច្ចុប្បន្ន បង្ហាញថា ដោយសារមានពលករកាន់តែច្រើនចូលធ្វើការងារយកប្រាក់កំរៃ ដូច្នេះចំណូលគ្រួសារជាមធ្យមនឹងត្រូវធ្លាក់ចុះ ។ នេះជាចំណុចមួយគួរព្រួយបារម្ភ ។

## ជំពូកទី ៩

# វិបត្តិ ដំណោះស្រាយ និងជំនួយពីក្រៅ

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ កសិករកម្ពុជាបានជួបគ្រោះធម្មជាតិយ៉ាងធ្ងន់ធ្ងរ ជាពិសេសទឹកជំនន់ និងការរាំងស្ងួត ។ នៅឆ្នាំ ២000 ប្រទេសកម្ពុជាបានជួបគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងរយៈ ៤0ឆ្នាំកន្លងមក ។ ការខូចខាតមានប្រមាណ ១៥៧ លានដុល្លារ និងមានបាត់បង់ជីវិតមនុស្ស ៣៤៧នាក់ ។ នៅឆ្នាំ២00១ មានគ្រោះទឹកជំនន់មួយទៀតបណ្តាលឱ្យខូចខាតអស់ ៣៦លានដុល្លារតាមការប៉ាន់ស្មាន ។ ស្ថានភាពមានគ្រោះមហន្តរាយបន្តដល់ឆ្នាំ២00២ ដោយនៅឆ្នាំនោះប្រទេសកម្ពុជាត្រូវជួប វិបត្តិទ្វេ គឺគ្រោះរាំងស្ងួតជាប្រវត្តិសាស្ត្រ និងទឹកជំនន់តាមទន្លេមេគង្គ[៥៥] ។ យោលតាមវដ្តនៃគ្រោះមហន្តរាយ ប្រទេសកម្ពុជា ប្រហែលត្រូវប្រឈមមុខនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតយ៉ាងទៀងទាត់ក្នុងពេលអនាគត ។

គ្រោះមហន្តរាយទាំងនេះប៉ះពាល់ខ្លាំងជាងគេដល់កសិករ ដោយបានកាត់បន្ថយសន្តិសុខស្បៀង និងបង្កើនភាពក្រីក្រ ។ ហើយក្នុងមួយឆ្នាំៗ ប្រជាជនត្រូវប្រឈមនឹងឧបសគ្គផ្សេងៗទៀត ដែលជាចំណែកមួយក្នុងជីវិតរស់នៅរបស់ពួកគេ និងដែលមាន ជាអាទិ៍ ជំងឺ ការស្លាប់មុនអាយុនូវសមាជិកគ្រួសារ និង/ឬសត្វចិញ្ចឹម ការខូចខាតដំណាំដោយសត្វចង្រៃបំផ្លាញ ចោរកម្ម និង ការបាត់បង់ភ្លាមៗនូវការងារ ឬរបរចិញ្ចឹមជីវិត ។ ដោយគ្មានប្រព័ន្ធធានារ៉ាប់រងសង្គមកិច្ច ឬប្រព័ន្ធគាំទ្រផ្សេងទៀត គ្រោះ មហន្តរាយអាចធ្វើឱ្យខូចខាតដល់របរចិញ្ចឹមជីវិត ។ គ្រោះមហន្តរាយម្តងហើយម្តងទៀត អាចធ្វើឱ្យគ្រួសារមួយចំនួន ដែលតាម ធម្មតាជាប្រភេទគ្រួសារមិនក្រឱ្យទៅជាគ្រួសារងាយរងគ្រោះដោយភាពក្រីក្រ និងធ្វើឱ្យទៅជាគ្រួសារក្រីក្រ កាន់តែក្រីក្រថែម ទៀត ។ ជំពូកនេះពិនិត្យពីភាពងាយរងគ្រោះទាំងនេះ ពោលគឺ ចរិត ទំហំ និងផលប៉ះពាល់នៃវិបត្តិចំពោះសហគមន៍នៅជនបទ និងការឆ្លើយតបចំពោះវិបត្តិទាំងនេះ ។ ជំពូកនេះនឹងខិតខំដោះស្រាយនូវសំនួរដូចខាងក្រោម:

១) តើនៅកំរិតគ្រួសារមានការប៉ះពាល់ប៉ុណ្ណាដោយសារ វត្តមាន និងទំហំនៃវិបត្តិទាំងនេះ?

២) តើប្រភេទនៃវិបត្តិនីមួយៗ ធ្វើឱ្យខូចខាតប៉ុណ្ណាគិតជាទឹកប្រាក់ចំពោះគ្រួសារប្រជាជន?

៣) តើគ្រួសាររងគ្រោះដោយវិបត្តិ មានវិធានការឆ្លើយតបយ៉ាងណាខ្លះ?

៤) តើមានជំនួយខាងក្រៅអ្វីខ្លះ ដែលបានផ្តល់ទៅឱ្យគ្រួសារតាមភូមិផ្សេងៗ និងតាមក្រុមចំណូលផ្សេងៗ ដើម្បី សំរាលបញ្ហាចោទ?

### ៩.១ វត្តមានវិបត្តិ និងការបាត់បង់ជាទឹកប្រាក់

វិបត្តិផ្សេងៗ បានប៉ះពាល់ស្ទើរគ្រប់គ្រួសារក្នុងគំរូតាង លើកលែងតែនៅភូមិត្រពាំងប្រិយ ក្នុងកំឡុងពេលធ្វើអង្កេត (តារាង៩.១) ។ ជាមធ្យម ៩0% នៃគ្រួសារ (ជិតដល់ ១00% នៅខ្សាច់ជីរស់ ព្រៃកក្មេង និងដងក្តារ) ដែលជួបវិបត្តិមួយ ឬច្រើន ។ ត្រពាំងប្រិយជាភូមិតូចជាងគេក្នុងគំរូតាង និងមានការប៉ះពាល់តិចជាងគេ គឺមានតែ ២២គ្រួសារនៅក្នុងចំណោម

[៥៥] សេចក្តីប្រកាសពីស្ថានភាពមានគ្រោះមហន្តរាយ នៅឆ្នាំ២00២ ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន។

៦៨គ្រួសារក្នុងភូមិប៉ុណ្ណោះ ដែលរាយការណ៍ថា ត្រូវបានប៉ះពាល់ដោយឧបសគ្គខ្លះ ។ ទឹកជំនន់មិនប៉ះពាល់ដល់ត្រពាំងប្រិយទេ ពីព្រោះភូមិនេះស្ថិតនៅតំបន់ខ្ពង់រាប ។

នៅភូមិក្រសាំង ខ្សាច់ជីរស់ និងដងក្តារ ការខាតបង់គិតជាទឹកប្រាក់សំរាប់គ្រួសាររងគ្រោះ គឺជាង ១លានរៀលក្នុងមួយឆ្នាំ ។ ការខាតបង់នេះស្មើនឹង ៤០-៦០% នៃចំណូលគ្រួសារប្រចាំឆ្នាំ ។ ការខាតបង់ជាមធ្យមក្នុងមួយគ្រួសារគិតលើភូមិទាំង៩ គឺ ៩១៣.០០០រៀល ត្រូវជា ១/៣ នៃចំណូលប្រចាំឆ្នាំសរុប ។ គ្រួសារនៅតំបន់ឆ្នេរ និងតំបន់ទន្លេមេគង្គ មិនរងគ្រោះធ្ងន់ដូចគ្រួសារនៅតំបន់ផ្សេងទៀតទេ ។

**តារាង៩.១ វត្តមាន និងទំហំវិបត្តិនៅឆ្នាំ២០០០-០១**

| | ភាគរយនៃគ្រួសាររងគ្រោះដោយវិបត្តិ | ការបាត់បង់ជាប្រាក់ / គ្រួសារ (ពាន់រៀល/ឆ្នាំ) | ចំណូលសរុប/គ្រួសារ (ពាន់រៀល/ឆ្នាំ) | ការបាត់បង់ជាភាគរយនៃចំណូលគ្រួសារ (%) |
|---|---|---|---|---|
| **ទំនាបទន្លេសាប** | | | | |
| អណ្តូងត្រាច | 92 | 770 | 2,662 | 29 |
| ក្រសាំង | 96 | 1,481 | 3,582 | 41 |
| ខ្សាច់ជីរស់ | 99 | 1,295 | 2,023 | 64 |
| **ទំនាបទន្លេមេគង្គ** | | | | |
| ព្រែកក្មេង | 99 | 870 | 3,633 | 24 |
| បាបោង | 95 | 719 | 3,311 | 22 |
| **តំបន់ខ្ពង់រាប** | | | | |
| កញ្ជរ | 93 | 701 | 1,831 | 38 |
| ដងក្តារ | 99 | 1,016 | 1,383 | 73 |
| ត្រពាំងប្រិយ | 32 | 313 | 1,652 | 19 |
| **តំបន់ឆ្នេរ** | | | | |
| កំពង់ត្នោត | 83 | 438 | 3,387 | 13 |
| សរុប | **90** | **913** | **2,750** | **33** |

វិបត្តិបង្កដោយជំងឺឃើញមាននៅគ្រប់ទីកន្លែង ។ គិតក្នុងភូមិទាំង៩ ៦៤%នៃគ្រួសារទាំងអស់រាយការណ៍ថា មានបញ្ហាសុខភាពធ្ងន់ធ្ងរ ។ ប្រជាជនភូមិក្រសាំងបានរាយការណ៍ពីវត្តមានជំងឺដ៏កាត់ច្រើនបំផុត (៨៨%), បន្ទាប់មកគឺភូមិបាបោង កញ្ជរ និងដងក្តារ (ឧបសម្ព័ន្ធ៨, តារាង១) ។ ទាំងអ្នកមាន និងអ្នកក្រ មានបញ្ហាខាងសុខភាព ដូច្នេះការឈឺថ្កាត់កើតមានជាទូទៅនៅជនបទកម្ពុជា ។ ចំណាយលើជំងឺមិនខុសគ្នាច្រើនទេ ទៅតាមភូមិ និងតាមគ្រួសារៈ ចំណាយជាមធ្យមគឺ ៣៧.៦០០០រៀល/ឆ្នាំ សំរាប់គ្រួសាររងគ្រោះនីមួយៗ ។

ភូមិរងគ្រោះធ្ងន់បំផុតដោយការបាត់បង់ផលដំណាំ ដោយសារសត្វចង្រៃបំផ្លាញនៅឆ្នាំ២០០០-០១ គឺភូមិខ្សាច់ជីរស់ ដែលមានគ្រួសារ ៧៧% បានទទួលរងគ្រោះ ហើយគ្រួសារនីមួយៗបាត់បង់ប្រហែល ២៩៧.០០០រៀល នៅក្នុងឆ្នាំនោះ ។ ដងក្តារ ជាភូមិបន្ទាប់ដែលមានគ្រួសារ ៥៥% បាត់បង់ផលដំណាំដោយសារសត្វចង្រៃ ហើយការខាតបង់មានប្រហែល ៣៩.០០០រៀល ក្នុងមួយគ្រួសាររងគ្រោះ ។ ភូមិដែលសត្វចង្រៃបានប៉ះពាល់តិចបំផុតគឺ ក្រសាំង បាបោង ត្រពាំងប្រិយ និងកំពង់ត្នោត ។

គ្រួសារ ៤៣% បានរាយការណ៍ថា ត្រូវប៉ះពាល់ទឹកជំនន់នៅឆ្នាំ២០០០ និង ២០០១ ។ ទឹកជំនន់បានប៉ះពាល់គ្រប់ភូមិនៅតំបន់ទន្លេសាប និងតំបន់ទន្លេមេគង្គ ។ បើគិតជាសមាមាត្រនៃគ្រួសារទទួលរងគ្រោះដោយទឹកជំនន់ ភូមិអណ្តូងត្រាច និង

ខ្សាច់ជីរស់ បាត់បង់ផលដំណាំច្រើនជាងភូមិផ្សេងៗទៀត ។ ប៉ុន្តែការខាតបង់ (គិតជាប្រាក់) នៅភូមិក្រសាំង ខ្ពស់ជាងគេខ្លាំងណាស់: គិតជាមធ្យម រួមទាំងការខាតបង់ស្រូវវស្សាឆ្នាំ២០០០ និងការខាតបង់ស្រូវនៅចុងរដូវប្រាំងឆ្នាំ២០០១ ផង, គ្រួសាររងគ្រោះនីមួយៗត្រូវខាតអស់ ១.៧៨៣.០០០រៀល ។ គ្រួសារមានដីធំត្រូវរងគ្រោះខ្លាំងជាងគេ ដោយសារគ្រោះមហន្តរាយពីរឆ្នាំជាប់គ្នានេះ ។

ក្រៅពីខូចខាតដំណាំ ទឹកជំនន់បានបំផ្លាញទ្រព្យសម្បត្តិផ្សេងទៀតជាច្រើន រួមទាំងផ្ទះសំបែងផងដែរ ។ នៅព្រែកក្មេង គ្រួសារ ៨៥% បានទទួលរងគ្រោះបែបនេះ ហើយជាមធ្យមគ្រួសាររងគ្រោះត្រូវខាតបង់ប្រហែល ៤៣៨.០០០រៀល ។ ភូមិមានទឹកជំនន់ជាទៀងទាត់មួយទៀតគឺ ខ្សាច់ជីរស់ ដែលរងគ្រោះធ្ងន់ធ្ងរដែរ ប៉ុន្តែចំនួនគ្រួសារត្រូវប៉ះពាល់មានតិចជាង ហើយការខូចខាតគិតជាទឹកប្រាក់ក៏ទាបជាងដែរ បើធៀបនឹងភូមិព្រែកក្មេង ។ នៅភូមិក្រសាំង មានគ្រួសារតែ ៥% ប៉ុណ្ណោះដែលបានរងគ្រោះដល់ខូចខាតទ្រព្យសម្បត្តិ ប៉ុន្តែការខាតបង់មានកំរិតធ្ងន់ធ្ងរគិតជាមធ្យម ២លានរៀលក្នុងមួយគ្រួសារដែលត្រូវប៉ះពាល់ ។

គោ ក្របី និងជ្រូក ជាទ្រព្យយ៉ាងសំខាន់នៅជនបទ ។ នៅពេលគោក្របីត្រូវស្លាប់ដោយជំងឺ ឬមានគេលួចសេដ្ឋកិច្ចគ្រួសារត្រូវរអាក់រអួល ។ ករណីមានការលួច ឬបាត់បង់សត្វបែបនេះ បានប៉ះពាល់ដល់គ្រួសារស្ទើរពាក់កណ្តាលនៅអណ្តូងត្រាច ខ្សាច់ជីរស់ បាបោង និងដងក្តារ ។ ការខាតបង់ចំពោះគ្រួសាររងគ្រោះមានប្រហែល ២០០.០០០-៣០០.០០០រៀលក្នុងរយៈពេលមួយឆ្នាំ ។ ប្រហែល ១/៤ នៃគ្រួសារអ្នកភូមិនៅ ព្រែកក្មេង កញ្ជរ និង ដងក្តារ រាយការណ៍ពីករណីមានលួច ឬប្លន់ ។ ផ្ទុយទៅវិញ នៅក្រសាំង បាបោង និងត្រពាំងប្រិយ សឹងតែគ្មានជួបបញ្ហាបែបនេះទេ ។

គ្រួសារមួយចំនួនប្រឈមមុខនឹងការបាត់បង់ការងារ ឬការបញ្ឈប់មុខរបរភ្លាមៗ ។ ៧០% នៃគ្រួសារនៅដងក្តារ បានរាយការណ៍ពីរឿងនេះ ដូចជាការបាត់បង់ការងារក្នុងព្រៃសម្បទានជាដើម (ជាមធ្យមគ្រួសារនៅដងក្តារអាចរកចំណូលបាន ៨០០.០០០រៀល/ឆ្នាំ ពីការប្រមូលផលព្រៃឈើ) ។

**តារាង៩.២ វត្តមាន និងការខាតបង់ដោយវិបត្តិ នៅក្នុងមួយឆ្នាំ (បែងចែកតាមបញ្ចភាគចំណូល)**

| បញ្ចភាគចំណូល/ ឯកតាពេញវ័យតាមក្បាល | វិបត្តិផ្សេងៗ/ សរុប | សមាជិកគ្រួសារ ស្លាប់ | វិបត្តិសុខភាព | ដំណាំខូចដោយ សត្វចង្រៃ | ដំណាំខូចដោយ ទឹកជំនន់ | ផលផ្សេងៗខូច ដោយទឹកជំនន់ | សត្វស្លាប់ ឬលួច | ចោរលួច ឬប្លន់ ឬ ឆបោក | វិបត្តិផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | ភាគរយនៃគ្រួសារប្រឈមនឹងវិបត្តិ | | | | | | | | |
| 1st 20% (ក្របំផុត) | 88 | 7 | 63 | 21 | 39 | 24 | 24 | 9 | 14 |
| 2nd 20% | 92 | 9 | 68 | 20 | 42 | 22 | 37 | 11 | 17 |
| 3rd 20% | 91 | 5 | 61 | 24 | 43 | 24 | 31 | 9 | 16 |
| 4th 20% | 93 | 5 | 60 | 28 | 49 | 24 | 33 | 13 | 17 |
| 5th 20% (មានបំផុត) | 89 | 10 | 66 | 25 | 42 | 21 | 36 | 15 | 18 |
| | ការបាត់បង់ជាប្រាក់មធ្យម (ពាន់រៀល/គ្រួសាររងគ្រោះ) | | | | | | | | |
| 1st 20% (ក្របំផុត) | 591 | 233 | 271 | 153 | 323 | 171 | 230 | 142 | 433 |
| 2nd 20% | 781 | 531 | 339 | 125 | 365 | 308 | 134 | 570 | 465 |
| 3rd 20% | 766 | 292 | 363 | 141 | 471 | 273 | 224 | 129 | 482 |
| 4th 20% | 973 | 764 | 386 | 200 | 623 | 209 | 258 | 290 | 602 |
| 5th 20% (មានបំផុត) | 1,464 | 1,218 | 518 | 253 | 761 | 716 | 296 | 342 | 877 |

តារាង៩.២ បង្ហាញពីរបាយណ៏គ្រួសារ តាមក្រុមប្រាក់ចំណូល និងប្រភេទវិបត្តិត្រូវប្រឈម ។ វិបត្តិបានប៉ះពាល់ស្ទើរគ្រប់គ្នា ។ គ្រួសារធូរធារបាត់បង់ទ្រព្យសម្បត្តិគិតជាទឹកប្រាក់ច្រើនជាងគ្រួសារមិនសូវធូរធារ ដែលជារឿងធម្មតាទេ ពីព្រោះគ្រួសារធូរធារមានទ្រព្យច្រើនជាង ។ ប៉ុន្តែអ្នកក្រីក្រត្រូវបាត់បង់ច្រើនជាង បើធៀបនឹងសមាមាត្រចំណូលរបស់ពួកគេ ។ ក្នុងបញ្ចភាគចំណូលក្រីក្របំផុត វិបត្តិនាំឱ្យបាត់បង់រហូតដល់ ៥០% នៃចំណូលគ្រួសារសរុប ។ ក្នុងបញ្ចភាគក្រីក្របំផុតលំដាប់ទី២ ការបាត់បង់មានកំរិត ៤០% នៃចំនូល ហើយក្នុងបញ្ចភាគចំនូលធូរធារ បរិមាណបាត់បង់មានប្រហែល ៣០% នៃចំនូលពួកគេ ។

## ៩.២ ការឆ្លើយតបចំពោះវិបត្តិ

តើគ្រួសារនានាឆ្លើយតបយ៉ាងណាចំពោះវិបត្តិ? គ្រួសារផ្សេងគ្នាជ្រើសយកយុទ្ធសាស្ត្រខុសៗគ្នាតាមលទ្ធភាពរបស់ខ្លួនក្នុងការប្រើប្រាស់ធនធានដែលខ្លួនបានសន្សំទុក ។ ការឆ្លើយតបជាទូទៅមួយ គឺការប្រើប្រាក់សន្សំ និង/ឬការកាត់បន្ថយការប្រើប្រាស់ក្នុងនេះមាន ៦៨% នៃគ្រួសាររងគ្រោះរាយការណ៍ថា បានប្រើប្រាក់សន្សំ (ឧបសម្ព័ន្ធ៨ តារាង២) ។ សមាមាត្រគ្រួសារមានលទ្ធភាពប្រើប្រាស់ប្រាក់សន្សំ គឺមានកំរិតខ្ពស់នៅភូមិធូរធារ ដូចជា ព្រៃកគ្មេង បាបោង និងព្រែកត្នោត ។ ផ្ទុយទៅវិញ ចំនួនគ្រួសារដែលកាត់បន្ថយការប្រើប្រាស់មានច្រើននៅភូមិក្រសាំង ខ្សាច់ជីរស់ កញ្ជរ និងដងក្តារ ដែលនៅទីនោះ អ្នកភូមិអាចសន្សំបានតិចជាង ។

ដើម្បីដោះស្រាយវិបត្តិ ប្រជាជនក៏ចូលចិត្តខ្ចីប្រាក់គេដែរ (ដោយមាន ឬគ្មានការប្រាក់) ។ ប្រហែល ៥០% នៃគ្រួសារជួបវិបត្តិបានខ្ចីប្រាក់គេ ដើម្បីសំរាលទំងន់វិបត្តិ ។ គ្រួសារមានសត្វចិញ្ចឹម គេមានជំរើសដោះស្រាយដោយលក់សត្វទាំងនេះ ។ គ្រួសារនៅអណ្តូងត្រាច ដងក្តារ និងត្រពាំងប្រិយ លក់សត្វចិញ្ចឹមច្រើនជាងគ្រួសារនៅភូមិដទៃ ។ ការលក់ដីកសិកម្ម ឬដីលំនៅដ្ឋាន គឺជាជំរើសចុងក្រោយ ដោយសារដីធ្លីគឺជាទ្រព្យដ៏មានតំលៃបំផុត ។ ទោះយ៉ាងនេះក្តី មានគ្រួសាររងគ្រោះមួយចំនួនតូចបានលក់ដីកសិកម្ម ។ ធនធានចំបងមួយទៀតគឺ កំលាំងពលកម្មរបស់មនុស្សពេញវ័យ និងកុមារ ។ នៅភូមិនានាដែលការធ្វើចំណាកស្រុកទៅរកការងារ គឺជាចំណែកមួយយ៉ាងសំខាន់នៃការរកចិញ្ចឹមជីវិត (ក្រសាំង និង ត្រពាំងប្រិយ) គ្រួសារមួយចំនួនតូចបានធ្វើដំណើរទៅក្រៅភូមិដើម្បីរកការងារធ្វើ ។ គ្រួសារជាច្រើនបានបញ្ជូនកូនចៅទៅធ្វើការឱ្យគេ ដើម្បីសំរាលផលប៉ះពាល់អាក្រក់នៃវិបត្តិ ។

គ្រួសារអ្នកក្រ និងគ្រួសារអ្នកមិនក្រ បានប្រើប្រាស់យុទ្ធសាស្ត្រខុសគ្នាដើម្បីទប់ទល់នឹងវិបត្តិ ។ ដូចមានបង្ហាញក្នុងតារាង៩.៣ គ្រួសារធូរធារច្រើនយកប្រាក់សន្សំមកប្រើប្រាស់ ដោយសារពួកគេមានទុនបំរុងនេះខ្លះដែរ ។ ផ្ទុយទៅវិញ អ្នកក្រច្រើនកាត់បន្ថយការប្រើប្រាស់ ព្រោះវាជាជំរើសមួយក្នុងចំណោមជំរើសដ៏តិចតួចរបស់ពួកគេ ។ ប្រហែល ៦០% នៃគ្រួសារក្នុងក្រុមចំណូលខ្ពស់បំផុត ក៏បានកាត់បន្ថយការប្រើប្រាស់ដែរ ប៉ុន្តែមុខចំណាយដែលអ្នកមានកាត់បន្ថយ វាមិនដូចគ្នានឹងអ្វីដែលអ្នកក្រីក្រកាត់បន្ថយនោះទេ ។ ទោះយ៉ាងនេះក្តី ទិន្នន័យស្ថិតិទាំងនេះ បង្ហាញថា អ្នកមាននៅជនបទមិនមែនជាអ្នកមានពិតៗនោះទេ ហើយពួកគេក៏ងាយរងគ្រោះ ដូចបានបញ្ជាក់ក្នុងជំពូក៧ នេះដែរ ។

**តារាង៩.៣ ការដោះស្រាយចំពោះវិបត្តិ តាមបញ្ចភាគចំណូល (របាយតាមគ្រួសារ)**

| បញ្ចភាគចំណូល/ឯកតាពេញវ័យ តាមភូមិ | ប្រើប្រាក់សន្សំ | បន្ថយការប្រើប្រាស់ | ខ្ចីបុល | លក់សត្វចិញ្ចឹម | លក់ដីស្រែ | សមាជិកគ្រួសារធ្វើចំណាកស្រុក | លក់ពលកម្មកុមារ |
|---|---|---|---|---|---|---|---|
| | ភាគរយនៃគ្រួសារប្រឈមវិបត្តិ | | | | | | |
| 1st 20% (ក្របំផុត) | 56 | 75 | 54 | 2 | 3 | 12 | 6 |
| 2nd 20% | 61 | 66 | 58 | 6 | 2 | 11 | 6 |
| 3rd 20% | 70 | 70 | 52 | 5 | 3 | 9 | 4 |
| 4th 20% | 78 | 68 | 52 | 8 | 1 | 8 | 3 |
| 5th 20% (មានបំផុត) | 75 | 60 | 33 | 18 | 2 | 7 | 3 |

គ្រួសារមួយចំនួនតូចក្នុងចំណោមអ្នកធូរធារ (ធៀបនឹងអ្នកក្រីក្រ) ឆ្លើយតបនឹងវិបត្តិដោយការខ្ចីបុលគេ ។ ពួកអ្នកធូរធារ គេចូលចិត្តលក់សត្វចិញ្ចឹមជាង ។ ចំពោះអ្នកក្រដែលមានសត្វចិញ្ចឹមតិចតួច គេច្រើនពឹងផ្អែកលើការលក់ពលកម្ម រួមទាំងពលកម្មរបស់កូនខ្លួនផង ។

## ៩.៣ ជំនួយពីខាងក្រៅ សំរាប់សំរាលវិបត្តិ

ក្រៅពីមធ្យោបាយផ្ទាល់ខ្លួន គ្រួសារអាចពឹងផ្អែកផងដែរលើជំនួយពីខាងក្រៅដើម្បីទប់ទល់វិបត្តិ ជាពិសេសនៅពេលធនធានរបស់ពួកគេបានរីងហួតអស់ ។ ក្នុងពេលសព្វថ្ងៃនៅកម្ពុជាការពឹងពាក់ទៅវិញទៅមករវាងគ្រួសារនានានៅតែខ្លាំងដដែល ហើយគេពឹងផ្អែកលើទំនាក់ទំនង គ្រួសារ/សាច់ញាតិ នៅពេលមានវិបត្តិ (McAndrew, 1998) ។ នៅពេលមានវិបត្តិធ្ងន់ធ្ងរ ដូចជាទឹកជំនន់ និងការរាំងស្ងួតរដ្ឋាភិបាល និង NGOs បំពេញតួនាទីយ៉ាងសំខាន់ក្នុងការសំរាលបញ្ហាប្រឈម ។ មានទិន្នន័យជាក់លាក់បង្ហាញថា ការឆ្លើយតបរបស់រដ្ឋាភិបាលមានកំលាំងខ្លាំងជាងគេបន្ទាប់មកគឺ NGOs និងសាច់ញាតិ (ឧបសម្ព័ន្ធ៨ តារាង៣) ។

តារាង៩.៤ បង្ហាញពីរបាយគ្រួសារតាមក្រុមចំណូល និងជំនួយបានទទួលសំរាប់សំរាលវិបត្តិ ។ ជំនួយរបស់រដ្ឋាភិបាល និង NGOs ច្រើនផ្តោតលើតំបន់ជាក់លាក់នានា មិនមែនផ្តោតលើក្រុមចំណូលទេ ។ ទាំងអ្នកក្រ និងអ្នកមិនក្រ ទទួលបានជំនួយសឹងស្មើគ្នា ដែលជាការបញ្ជាក់ថា គ្មានការកំណត់មុខសញ្ញាជំនួយតាមប្រភេទគ្រួសារទេ ។

**តារាង៩.៤ វត្តមាននៃជំនួយពីខាងក្រៅ**

| បញ្ចភាគចំណូល/ឯកតាពេញវ័យ តាមភូមិ | ជំនួយពីញាតិ /មិត្ត | ជំនួយពី NGOs | ជំនួយពីរដ្ឋាភិបាល |
|---|---|---|---|
| | *ភាគរយនៃគ្រួសារប្រឈមវិបត្តិ* | | |
| 1st 20% (ក្របំផុត) | 18 | 18 | 38 |
| 2nd 20% | 14 | 17 | 41 |
| 3rd 20% | 8 | 14 | 41 |
| 4th 20% | 9 | 16 | 37 |
| 5th 20% (មានបំផុត) | 12 | 17 | 32 |

## ៩.៤ សេចក្តីសង្ខេប

ការប្រឈមនឹងវិបត្តិ ទោះបណ្តាលពីធម្មជាតិ ឬមនុស្សបង្កើតក្តី សឹងតែក្លាយជាចំណែកមួយនៃជីវិតនៅតាមភូមិទៅហើយ ។ បន្ថែមលើបញ្ហាសុខភាពការខូចខាតដំណាំបញ្ហាសន្តិសុខផ្សេងទៀត និងទឹកជំនន់ដ៏ធំឡើកនៅឆ្នាំ២០០០ និង ២០០១ បានបង្កើនបញ្ហាហិរញ្ញវត្ថុដល់ភូមិនានាស្ថិតនៅតាមតំបន់ទន្លេសាប និងទន្លេមេគង្គ ។ អ្នកមិនក្រទទួលខាតបង់គិតជាប្រាក់ច្រើនជាងអ្នកក្រី ប៉ុន្តែអ្នកក្រត្រូវខាតបង់ច្រើនជាង បើធៀបតាមសមាមាត្រចំណូលពួកគេ ។ ការឆ្លើយតបនឹងវិបត្តិខុសគ្នាខ្លាំងណាស់រវាងភូមិ ឬគ្រួសារនានា ។ គ្រួសាររងគ្រោះភាគច្រើនដោះស្រាយវិបត្តិដោយយកប្រាក់សន្សំមកប្រើប្រាស់ និង/ឬកាត់បន្ថយការប្រើប្រាស់ ។ បន្ទាប់មក គឺមានជំរើសការខ្ចីបុល ការលក់សត្វចិញ្ចឹម និងការធ្វើចំណាកស្រុក ។ រដ្ឋាភិបាល និង NGOs ក៏បានផ្តល់ជំនួយសង្គ្រោះដល់គ្រួសារមួយចំនួននៅក្នុងភូមិរងគ្រោះដោយទឹកជំនន់ដែរ ។ ជំនួយត្រូវបានផ្តល់ឱ្យដោយគ្មានគិតពីក្រុមប្រាក់ចំណូលទេ គឺបានន័យថា ជំនួយគ្មានការកំណត់មុខសញ្ញាសំរាប់តែអ្នកក្រីក្រនោះទេ ។

ក្នុងបរិបទនៃសន្តិសុខស្បៀង អ្នកក្រងាយរងគ្រោះខ្លាំងក្នុងការប្រឈមនឹងគ្រោះធម្មជាតិ និងបញ្ហាផ្ទាល់ខ្លួន ។ ដោយគ្មានការធានារ៉ាប់រងខាងសង្គមកិច្ចអ្វីសោះ គ្រួសារជាច្រើនអាចនឹងត្រូវបាត់បង់មធ្យោបាយរកចិញ្ចឹមជីវិត ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះជាងមុនទៀត ។

# ជំពូកទី ១០

# សេចក្តីសន្និដ្ឋាន

ឯកសារនេះបង្ហាញពីគំហើញនៃអង្កេតលើ ៩ភូមិ ស្ថិតនៅក្នុងតំបន់អាកាសធាតុកសិកម្មទាំងបួននៅកម្ពុជា ដើម្បីវាយតំលៃពីចិរិត និងទំហំនៃសន្តិសុខស្បៀងនៅតាមភូមិកម្ពុជា ។ គំហើញនានានៃការសិក្សានេះ ផ្អែកលើអង្កេតតាមបញ្ជីសំនួរលើ ១០០៥គ្រួសារ ក្នុង ៩ភូមិ និងមានបញ្ជីសំនួរមួយទៀតសំរាប់ភូមិ ។ អង្កេតបានធ្វើឡើងជាពីរវគ្គគឺ រដូវវស្សា និងរដូវប្រាំង› ដើម្បីក្តាប់ពីការប្រែប្រួលសន្តិសុខស្បៀងតាមរដូវកាល ។

អង្កេតលើ ៩ ភូមិនេះ គឺបន្តពីអង្កេតលើកមុនធ្វើដោយ វបសអ លើ ៣ភូមិ ដែលឥឡូវនេះក៏ត្រូវបានធ្វើអង្កេតឡើងវិញដែរ ។វិធីនេះបានផ្តល់លទ្ធភាពឱ្យធ្វើការប្រៀបធៀបខ្លះៗបានជាមួយនឹងអង្កេតលើកមុន ។

អង្កេតនេះគឺជាការសិក្សាពីរោគសញ្ញា ប៉ុន្តែវាមិនមែនជាខ្នាតពុម្ពសំរាប់ការកំណត់គោលនយោបាយអភិវឌ្ឍន៍ជនបទនោះទេ ។ ដូច្នេះបន្ទាប់ពីបានបង្ហាញសេចក្តីសង្ខេបនៃគំហើញមក ជំពូកនេះនឹងបង្ហាញខ្លីៗពីការយល់ដឹងពីនិន្នាការបច្ចុប្បន្ននៃការអភិវឌ្ឍន៍-សេដ្ឋកិច្ចសង្គមកិច្ចនៅជនបទកម្ពុជា ។ នៅខាងចុងជំពូកនេះមានការពិពណ៌នាដោយសង្ខេបមួយពីការសង្កេតឃើញជាទូទៅ ដែលមិនមែនជាការប្រកាសយ៉ាងរឹងប៉ឹងអំពីទិសដៅនៃគោលនយោបាយនោះទេ ។

## ១០.១ គំហើញទូទៅ

គំហើញធំៗបានពីការចុះអង្កេតដល់កន្លែង នឹងលើកមកបង្ហាញជាមុន ដើម្បីផ្តល់ជាទស្សនៈជាក់លាក់មួយពីការវិភាគដែលបានបង្ហាញនៅក្នុងជំពូកទី៣-៩ :

១) ដីធ្លី និងធនធានធម្មជាតិផ្សេងទៀត គឺជាប្រភពចំបងសំរាប់ការចិញ្ចឹមជីវិតនៅតាមភូមិក្នុងជនបទកម្ពុជា ។ កសិករដែលពុំមានដីកសិកម្មផ្ទាល់ខ្លួន ឬមានលទ្ធភាពតិចតួចក្នុងការប្រើប្រាស់ធនធានធម្មជាតិផ្សេងទៀត ត្រូវប្រឈមមុខនឹងភាព ក្រីក្រតាមរដូវកាលឬជាប្រចាំ ព្រមទាំងអសន្តិសុខស្បៀងផងដែរ ។ អត្រាគ្មានដីកសិកម្មមានកំរិតខ្ពស់ គឺប្រហែល ២០% នៃគ្រួសារនៅជនបទគ្មានដីសោះទេ ប៉ុន្តែពួកគេក៏មិនមែនជាកសិករទាំងអស់គ្នាដែរ ។ គ្រួសារ ២៥% ទៀត មានដីតិចជាង ០,៥ហ.ត ដែលមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពទេ ។ សរុបមកជាង ៤០% នៃគ្រួសារនៅជនបទ ស្ថិតក្នុងប្រភេទ "អ្នកគ្មានដី ឬ ជិតគ្មានដី" ។

២) ព្រំដែនដី មិនបានពង្រីកលឿនទាន់កំណើនប្រជាជនទេ ហើយជាវិបាក បរិមាណដីធ្លីសំរាប់មនុស្សម្នាក់កាន់តែថយចុះតិចទៅៗ ។ នេះជាមូលហេតុសំខាន់ដែលប្រជាជនក្លាយជាអ្នកគ្មានដី ឬអ្នកជិតគ្មានដី ។ម្យ៉ាងទៀតទីផ្សារដីធ្លីមានសកម្មភាពខ្លាំង និងមានការផ្ទេរដីយ៉ាងលឿន ជាពិសេសដីមានផលិតភាពល្អ ហើយនេះជាមូលហេតុមួយទៀតដែលធ្វើឱ្យ ប្រជាជនក្លាយជាអ្នកគ្មានដី ។ តាមការប៉ាន់ស្មានសព្វថ្ងៃ អ្នកគ្មានដីកំពុងកើនឡើងក្នុងអត្រាប្រចាំឆ្នាំ ២% ។

៣) នៅកម្ពុជាទិន្នផលកសិកម្មនៅទាបនៅឡើយ ។ កសិដ្ឋានតូចៗមានផលិតភាពខ្ពស់ជាងចំពោះដំណាំរដូវវស្សាប្រើធាតុចូលតិច ។ ប៉ុន្តែកសិដ្ឋានតូចមិនសុទ្ធតែមានផលិតភាពខ្ពស់ជាង ចំពោះដំណាំប្រើធាតុចូលច្រើននៅរដូវប្រាំងនោះទេ ។ ក្នុងរដូវណាក៏ដោយ កសិដ្ឋានតូចផ្តល់ចំណូលទាបជាង ហើយជាលទ្ធផលគ្រួសារនីមួយៗមានស្តុកស្បៀងតិច ។ ដោយទំហំកសិដ្ឋានរួមកាន់តែតូច ហើយផលិតភាពមិនបានកើនលឿនគ្រប់គ្រាន់ ចំណូលរបស់កសិករគឺនៅតែទាប ។ តាមពិត ចំណូលនេះទាបខ្លាំងណាស់ រហូតដល់កសិករមួយចំនួនមិនអាចដោះស្រាយចំណាយចាំបាច់បានទេ ជាពិសេសលើជំងឺ ហើយក្នុងករណីខ្លះពួកគេត្រូវបង្ខំចិត្តលក់ដីធ្លីរបស់ខ្លួន ។ ម្យ៉ាងទៀត ដីធ្លីកាន់តែតូចទៅៗ ដោយសារប្រជាជនមានកំណើនលឿន ឯមុខរបរ ជាពិសេសក្នុងតំបន់ជនបទមិនបានរីកចំរើនលឿនគ្រប់គ្រាន់ទេ ។

៤) គ្រួសារគ្មានដីរកចំណូលបានជាចំបងពីពលកម្មយកប្រាក់កំរៃ ។ ប៉ុន្តែដោយប្រាក់កំរៃនៅទាប ក៏រិតជីវភាព(ព្រឹត្តិ) ចំណូលនេះ មិនគ្រប់គ្រាន់ទេ សំរាប់ធានាសន្តិសុខស្បៀងឱ្យគ្រួសារទាំងនេះ ។

៥) ដូចក្នុងសង្គមពឹងផ្អែកលើកសិកម្មដទៃទៀតដែរ អ្នកភូមិនៅកម្ពុជាត្រូវការឥណទានឱ្យបានទៀងទាត់សំរាប់បំរើផលិតកម្ម និងការប្រើប្រាស់ ។ កង្វះទុន និងរបៀបរបបរឹងកំព្រឹសរបស់ឥណទានស្ថាប័ន បានជំរុញប្រជាជនឱ្យទៅរកអ្នកចងការប្រាក់ឯកជនដែលផ្តល់ឥណទានមានតំលៃថ្លៃ ។ ចំណាយលើឥណទានខ្ពស់ បានកាត់បន្ថយចំណូលអាចប្រើបានរបស់គ្រួសារ និងបានប៉ះពាល់ដល់សន្តិសុខស្បៀង ។

៦) ប្រជាជនជនបទភាគច្រើនរកចិញ្ចឹមជីវិតតាមប្រភពជាច្រើនៈ ប្រភពសំខាន់ៗមានជាអាទិ៍ កសិកម្ម ធនធានរួម (ព្រៃឈើ និងត្រី) និងពលកម្មយកប្រាក់កំរៃ ។ ជាមធ្យមកសិកម្មផ្តល់តែ ១/៣ នៃចំណូល ប៉ុន្តែវាប្រែប្រួលខុសគ្នាច្រើនតាមតំបន់ ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗ ចំណែកនៃចំណូលពីកសិកម្មបានកើនឡើង ជាពិសេសក្នុងតំបន់បានធ្វើអង្កេតឡើងវិញ (ដែលអាចប្រៀបធៀបតាមឆ្នាំខុសគ្នាបាន), ចំណែកឯចំណូលពីធនធានទ្រព្យរួមមិនបានកើនឡើងទាន់គ្នារាល់ៗលើកនោះទេ ។ អ្នកក្រីក្រត្រូវប្រឈមមុខនឹងអសន្តិសុខស្បៀង ពីព្រោះពួកគេទទួលចំនូលច្រើនពីធនធានទ្រព្យរួម និង ចំណូលតិចពីកសិកម្ម, ហើយចំណូលបានពីការលក់ពលកម្មក៏មិនបានច្រើនដែរ ។

៧) ដោយប្រើនិយមន័យដ៏រឹងកំព្រឹស ជំរឿនឆ្នាំ១៩៩៨ បានសន្និដ្ឋានថា ការងារយកប្រាក់កំរៃនៅជនបទសឹងតែគ្មានសោះ ។ ផ្ទុយទៅវិញ អង្កេតនេះ (និងអង្កេតលើកមុនធ្វើដោយ វិបសអ នៅឆ្នាំ១៩៩៦-៩៧) បង្ហាញថា មានប្រជាជនជាច្រើនរកចំណូលពីពលកម្មយកប្រាក់កំរៃ ហើយសមាមាត្ររបស់វានៅក្នុងចំណូលសរុបអាចខ្ពស់ដល់ ១៧% ។ ប៉ុន្តែអត្រាប្រាក់ កំរៃមានក៏រិតទាប អត្រាមធ្យមមិនលើស ៤.០០០រៀល/ថ្ងៃទេ និងមានចាប់ពី ៣.០០០-៥.០០០រៀល/ថ្ងៃ នៅតាម ទីកន្លែង និងតាមពលករជាបុរស ឬស្ត្រី ។

៨) អ្នកមាន និងអ្នកក្រ បរិភោគអង្ករចំនួនសឹងស្មើគ្នានៅគ្រប់រដូវ ។ ប៉ុន្តែមានការខុសគ្នាច្រើនលើការប្រើប្រាស់អាហារមិនមែនអង្ករ និងអីវ៉ាន់មិនមែនអាហារ ។ ដូច្នេះ សន្តិសុខស្បៀងត្រូវបានកំនត់និយមន័យថា ជាការប្រើប្រាស់ស្រូវអង្ករក្នុងចំនួនកំណត់មួយ ។ យោងតាមអង្កេតលើភូមិទាំង៩ អ្នករស់នៅក្រោមបន្ទាត់ក្រីក្រ មាន ៣៨% ។ តួលេខនេះ ប្រហាក់ប្រហែលគ្នានឹងតួលេខរកឃើញដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៧ និង ១៩៩៩ ។ នៅជនបទ អ្នកមានណាស់ ឬក្រណាស់ពុំមានច្រើនទេ ។ ទោះអ្នកមានក្តីក៏បានកាត់បន្ថយការប្រើប្រាស់នៅរដូវខ្សត់ដែរ ចំណែកឯអ្នកក្រីក៏អាចរក្សាការប្រើប្រាស់ស្រូវអង្ករក្នុងចំនួនកំណត់មួយដែរ ។

៩) ប្រជាជនត្រូវប្រឈមនឹងភាពមិនទៀងទាត់បណ្តាលពីគ្រោះធម្មជាតិ ។ ការខាតបង់ជាមធ្យមអាចខ្ពស់ដល់ ១/៣ នៃចំណូលសរុបប្រចាំឆ្នាំ ។ បើគិតតាមសមាមាត្រចំណូល អ្នកក្រីក្រត្រូវខាតបង់ច្រើនជាងអ្នកមាន ។ វិធីសាស្ត្រជួយសំរាលវិបត្តិ គឺយោលតាមតំបន់នីមួយៗ និងមិនផ្សារភ្ជាប់នឹងស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនៃគ្រួសារទេ ។

ការអង្កេតនេះផ្តល់ទិន្នន័យដូចខាងក្រោម ដែលអាចជួយកែតំរូវដល់ទស្សនៈជាទូទៅមួយចំនួនស្តីពីស្ថានភាពកសិកម្មកម្ពុជា ។ ពលកម្មយកប្រាក់កំរៃមានច្រើនពាសពេញ មិនដូចចុះក្នុងរបាយការណ៍ជំរឿនទេ ។ សព្វថ្ងៃមានប្រជាជនកាន់តែច្រើនពឹងផ្អែកលើពលកម្ម ហើយទោះបីពលករភាគច្រើនមិនធ្វើការយកប្រាក់កំរៃអស់មួយភាគធំនៃឆ្នាំនីមួយៗ ក៏ដោយរឿងនេះប្រហែលជាមូលហេតុដែលអង្កេតមិនបានរកឃើញពួកគេ) ក៏មានច្រើននាក់ណាស់ បានបំរើការជាពលករយកប្រាក់កំរៃអស់មួយរយៈពេលដែរក្នុងមួយឆ្នាំៗ ។

ជាការមិនត្រឹមត្រូវទេដែលនិយាយខុសថា ជនបទកម្ពុជាមានធ្វើអ្វីផ្សេងតិចតួចណាស់ក្រៅការធ្វើស្រែ ។ ការពិតការដាំដុះស្រូវ និងដំណាំទូទៅផ្សេងទៀត ផ្តល់ការងារឱ្យកសិករតែ ៤-៥ខែប៉ុណ្ណោះជាមធ្យម ។ ពេលនៅសល់ពីនេះ ពួកគេចំណាយលើការបេះបន្លែ ការនេសាទ និងសកម្មភាពបេះប្រមូលរបស់ហូប និងមិនសំរាប់ហូបផ្សេងៗ ដែលច្រើនតែមិនបានរាប់ចូលនៅក្នុងអង្កេតធំៗ) ។ បន្ថែមលើនេះ ប្រជាជនប្រកបរបរអាជីវកម្មតូចៗ និងលក់ពលកម្ម ។ ដូច្នេះហើយចំណូលមធ្យមពីកសិកម្មបានមិនលើសពី ៣០% នៃចំណូលសរុបទេ ឯចំណូលក្រៅពីនេះបានពីប្រភពមិនមែនកសិកម្ម ។ គោលនយោបាយនានាដែលសំដៅធ្វើឯកជនីយកម្មធនធានទ្រព្យរួម ឬកាត់បន្ថយលទ្ធភាពប្រើប្រាស់ធនធានមួយចំនួនសំរាប់គោលដៅអភិរក្ស) អាចប៉ះពាល់ដល់ការរកចិញ្ចឹមជីវិតនៅជនបទ ។

ដីតូចៗគឺ ជារបត់ពីសម័យកាលមុន ។ វាពុំមានប្រសិទ្ធិភាពល្អទេ សំរាប់របៀបរបបទំនើបធ្វើកសិកម្ម ឬក៏សំរាប់ផ្តល់ជីវភាពសមរម្យ និងសន្តិសុខស្បៀងដល់កសិករ ។ កសិករតូចៗបាត់បង់ដីដោយពួកគេមិនអាចរក្សាទុកកើតនូវដីតូចៗ ដែលគ្មានប្រសិទ្ធភាពខាងសេដ្ឋកិច្ច ។

ទិន្នន័យអង្កេតបង្ហាញថា អ្នករកស៊ីចងការប្រាក់នៅតែប្រភពចំបងគេនៃឥណទាន ។ រឿងនេះមិនមែនគ្រាន់តែដោយសារការផ្គត់ផ្គង់ឥណទានប្រភពស្ថាប័នឥណទានមានតិចនោះទេ ប៉ុន្តែចរិតនៃតំរូវការឥណទានក្នុងមជ្ឈដ្ឋានកសិកម្ម ក៏ខុសប្លែកច្រើនពីអ្វីដែលប្រព័ន្ធធនាគារផ្លូវការតែងធ្លាប់ជឿជាក់នោះដែរ ។ អ្នកភូមិមានការបែងចែកតិចតួចណាស់រវាងឥណទានទទួលបានសំរាប់បំរើផលិតម្ម វិនិយោគ ការប្រើប្រាស់ ឬពិធីបុណ្យផ្សេងៗ ចំនែកឯអ្នកផ្គត់ផ្គង់គេចង់ផ្តល់ឥណទានតែសំរាប់គោលបំនងវិនិយោគ និងផលិតកម្មប៉ុណ្ណោះ ។

វិសមភាពជាក់ស្តែងក្នុងបញ្ហាដីធ្លី និងការប្រើប្រាស់ បង្ហាញថា វាជាការប្រញ៉ាប់ប្រញ៉ាល់ពេកបើសិនសន្និដ្ឋានថា អ្នកភូមិក្រ ពីព្រោះមានអ្នកមាន ។ គំលាតរវាង "អ្នកក្រ" និង "អ្នកមិនក្រ" មិនធំណាស់ណាទេ មិនដូចសេដ្ឋកិច្ចប្រទេសអាស៊ីមួយចំនួនទៀតឡើយ) ។

សហគមន៍កសិករទទួលរងគ្រោះយ៉ាងញឹកញាប់ដោយវិបត្តិ ហើយការខូចខាតសំរាប់គ្រួសាររងគ្រោះនីមួយៗ មានសមាមាត្រធំ បើធៀបនឹងចំណូលគ្រួសារសរុបប្រចាំឆ្នាំ ។ វិបត្តិម្តងហើយម្តងទៀត បានបង្កើនភាពងាយរងគ្រោះដល់ប្រជាជនជនបទមួយភាគធំ ។

លក្ខខណ្ឌសុខភាពមិនល្អ ជាលទ្ធផលនៃភាពក្រីក្រ អាហារូបត្ថម្ភកំរិតទាប និងបរិស្ថានមិនល្អសំរាប់សុខភាព (ឧទាហរណ៍ទឹកបរិភោគ) ។ លទ្ធភាពតិចតួចនៃសេវាការពារ និងព្យាបាលជំងឺ គឺជាមូលហេតុដែលធ្វើឱ្យអ្នកភូមិស្វែងរកសេវាព្យាបាលសុខភាពឯកជនដ៏ថ្លៃ ដែលធ្វើឱ្យពួកគេជំពាក់បំណុល ។

## ១០.២ ការស្វែងយល់ពីសេដ្ឋកិច្ចជនបទកម្ពុជា

តើសេដ្ឋកិច្ចជនបទកម្ពុជាកំពុងវិវត្តទៅទិសណា? តើទិន្នន័យ និងការវិភាគក្នុងឯកសារនេះ ផ្ដល់ចម្លើយចំពោះសំនួរនេះឬទេ? គេដឹងជាទូទៅថា កសិកម្មកម្ពុជាមានឫសគល់ចេញពីកសិកម្មយថាផល (extensive origins) ដែលក្នុងនេះមានប្រជាជនតិចទេដែលពឹងផ្អែកលើដីធ្លី និងធនធានធម្មជាតិផ្សេងទៀត ។ ដូច្នេះហើយ ទោះបីផលិតភាពមានកំរិតទាប ក៏តែងមានស្បៀងគ្រប់គ្រាន់ដែរ (Acharya and Chan 2001) ។ មកដល់ពាក់កណ្ដាលសតវត្សរ៍ទី20 ហើយក្ដី ក៏ប្រជាជនកម្ពុជានៅមានតិចជាង ៤លាននាក់ ធៀបនឹងប្រហែល ១១លាននាក់ នៅឆ្នាំ១៩៩៨) ។

ដោយសេដ្ឋកិច្ចជនបទមានការធ្វើពាណិជ្ជកម្ម និងការពាក់ព័ន្ធកាន់តែច្រើននឹងទីផ្សារធំៗ ក្នុងមួយភាគធំនៃសតវត្សរ៍ទី២០នេះ ដោយគ្មានការប្រឹងប្រែងអ្វីគួរឱ្យកត់សំគាល់ ដើម្បីកែតំរូវរចនាសម្ព័ន្ធនៃការផ្គត់ផ្គង់ ឬការរៀបចំផលិតកម្មនៅក្នុងសេដ្ឋកិច្ចជនបទទេ) ប្រព័ន្ធនេះកំពុងជួបការតឹងតែងកាន់តែខ្លាំង ។ សព្វថ្ងៃមានការទាមទារជាច្រើនលើធនធានព្រៃឈើ ទឹក ត្រី និង ដីធ្លី ពីមជ្ឈដ្ឋានខាងក្រៅវិស័យកសិកម្ម ។ បញ្ហាកាន់តែស្មុគស្មាញថែមទៀត ដោយសារប្រជាជនកើនយ៉ាងលឿន ហើយសេដ្ឋកិច្ចជនបទក៏មានតំរូវការកាន់តែច្រើនឡើងលើធនធាន ។ ដោយតំរូវការកាន់តែធំលើសការផ្គត់ផ្គង់ច្រើនឡើង ធនធានជាប្រពៃណី ដូចជា ដី ព្រៃឈើ ត្រី ជាដើម កាន់តែមានតិចទៅៗសំរាប់ប្រជាជនជនបទម្នាក់ៗ ។ ដូច្នេះហើយប្រភេទថ្មីមួយនៃពលករកសិកម្មអ្នកគ្មានដីធ្លី ក៏បានផុសឡើងយ៉ាងលឿនក្នុងពេលសព្វថ្ងៃនេះ ។

ក្នុងតំបន់ជនបទ គុណភាពជីវិតមិនមែនធ្លាក់ចុះចំពោះប្រជាជនគ្រប់គ្នាទាំងអស់ទេ ។ ក្នុងតំបន់ជាច្រើនគេបានធ្វើទំនើបកម្មកសិកម្ម ហើយពូជដំណាំមានទិន្នផលខ្ពស់ ជី និងប្រព័ន្ធស្រោចស្រព ក៏មានប្រើប្រាស់កាន់តែច្រើន ។ "បដិវត្តន៍បៃតង" មានជោគជ័យជាពិសេសក្នុងតំបន់ទាំងឡាយដែលមានដីគុណភាពល្អ និងមានប្រភពទឹកស្រួលយកមកប្រើប្រាស់ ។ ក្នុងតំបន់ទាំងនេះ កសិករបានកើនប្រាក់ចំណូល ហើយកសិកម្មកាន់តែក្លាយជាប្រភពចំបងនៃការចិញ្ចឹមជីវិត ។ ក្នុងតំបន់ខ្លះទៀត ធនធានដូចជាត្រីជាដើម នៅសំបូរនៅឡើយ ឬលទ្ធភាពមានត្រី បានកើនឡើងដោយសារផ្ដើមសកម្មភាពចិញ្ចឹមត្រី) ហើយចំណូលបានពីវិស័យនេះក៏កើនឡើងដែរ ។ ដូច្នេះ ចំណូលកើនឡើងតាមកន្លែងនានាដែលធនធានមានកំណើន ឬមានការអភិវឌ្ឍន៍) ហើយអ្នកមានកម្មសិទ្ធិលើធនធានពិតជាបានចំនេញ ថ្វីបើក្នុងដំណាក់កាលនេះគេមិនទាន់ច្បាស់ទេថា ឥទ្ធិពលមេគុណនៃកំណើនចំណូលនេះវាខ្លាំងប៉ុណ្ណា ។ គេក៏មិនច្បាស់ដែរថា តើក្នុងរឿងនេះនឹងមានការចែកចាយផលចំណេញទៅដល់អ្នកដែលគ្មានធនធានតាមរយៈការងារធ្វើដែរឬទេ ។

ក្នុងតំបន់មួយចំនួនផ្សេងទៀត ធនធានបានថយចុះ ឬក៏គ្មានការរីកចំរើន ។ តំបន់ទាំងនេះមានកំហិតខាងធម្មជាតិជាច្រើនស្រាប់ទៅហើយ ដូចជា ភ្លៀងមិនគ្រប់គ្រាន់ ប្រភពទឹកមិនសំបូរ ហើយទំងន់នៃកំណើនតំរូវការក៏បានបង្កការលំបាក ។ ដោយសារអ្នកភូមិថយចុះចំណូលទទួលបានពីប្រភពជាប្រពៃណីពួកគេកាន់តែចូលធ្វើការងារស៊ីប្រាក់កំរៃច្រើនឡើង ។ ប៉ុន្តែចំណូលបានពីពលកម្ម វាមានកំរិតទាបជាងចំណូលបានពីធនធានរូបវន្តផលិតកម្ម (ឧ. កសិកម្ម, ត្រី) ហើយអត្រាប្រាក់កំរៃអាចទាបជាង ១ដល្លារ/ថ្ងៃទៅទៀត ។ម្យ៉ាងទៀត កំណើនចំនួនការងារមិនមែនកសិកម្ម វាមានល្បឿនយឺត និងមិនស្មើគ្នាទេ ក្នុងទូទាំងប្រទេស ។ ក្នុងការផ្ទេរមុខរបរដែលកើតមាននៅគ្រប់កន្លែងនេះមានឱនភាព ឬរឿងផ្សេងទៀតប្រាក់ចំណូលរបស់អ្នកខ្លះក៏បានថយចុះ ដោយសារប្រាក់កំរៃទាប និងមិនសូវមានការងារ ។ ដូច្នេះហើយ អត្រាភាពក្រីក្រសរុប មិនបានថយចុះលឿនទាន់អថេរម៉ាក្រូសេដ្ឋកិច្ចផ្សេងៗទៀតដូចជា កំណើនផសសជាដើមនោះទេ ។ ដើម្បីប៉ះប៉ូវលើចំណូលដ៏ទាបប្រជាជនកាន់តែច្រើនពិសេសតាមតំបន់ជិតព្រំដែន ឬមួយធ្វើដំណើរទៅថៃដែលអាចមានប្រាក់កំរៃខ្ពស់ជាង ឬមួយធ្វើចំណាកស្រុកចូលទីក្រុង ដោយសង្ឃឹមថា អាចរកចិញ្ចឹមជីវិតបានប្រសើរជាង ។ ប៉ុន្តែច្រកទាំងពីរនេះមិនមែនងាយស្រួលសំរេចបាននោះទេ ជាពិសេសចំណាកស្រុកឆ្លងដែនដែលមិនមែនជាដំណោះស្រាយមានចីរភាពឡើយ ។

កសិកម្មមិនបានរីកធំលឿនគ្រប់គ្រាន់ទេ ហើយទិន្នផលបច្ចុប្បន្ននៅកម្ពុជាស្ថិតក្នុងកំរិតទាបបំផុតនៅអាស៊ីអគ្នេយ៍ ។ ក្នុងចំណោមមូលហេតុផ្សេងៗ គឺមានកង្វះគណទានប្រព័ន្ធស្រោចស្រពមិនគ្រប់គ្រាន់ ចំណងទាក់ទងទីផ្សារមិនគ្រប់គ្រាន់ និងហេដ្ឋារចនាសម្ព័ន្ធ (ទាំងរូបវន្ត និងសង្គមកិច្ច) គុណភាពអន់ ។ ម្យ៉ាងទៀត សកម្មភាពមិនមែនកសិកម្មនៅជនបទ ក៏គ្មានការរីកលូតលាស់ដោយសារហេតុផលដូចគ្នា ។ ជាការធម្មតាទេសេដ្ឋកិច្ចជនបទដែលលូតលាស់យឺតៗ មិនអាចជួយទ្រទ្រង់បានយ៉ាងសក្តិសិទ្ធិដល់ពលករកាន់តែច្រើនដែលចូលមកក្នុងកំលាំងពលកម្មក្នុងមួយឆ្នាំៗ ហើយនេះជាមូលហេតុមួយនៃកំណើនអសន្តិសុខស្បៀង ។

ចំនួលពីពលកម្មមានកំរិតទាបដោយសារមូលហេតុបីយ៉ាងតិច ។ ទី១ វិស័យមិនមែនកសិកម្មរីកលូតលាស់មិនបានលឿនគ្រប់គ្រាន់ទេ ទាំងនៅតំបន់ជនបទ និងទីក្រុង ។ ហើយកាលណាវាមានការរីកលូតលាស់ ដូចជា ក្នុងវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ជាដើម ការងារក៏មិនបានកើនឡើងលឿនគ្រប់គ្រាន់ដែរ ។ ទី២ ចរិត និងធាតុផ្សំនៃកំណើនសេដ្ឋកិច្ច វាមានចំណងទាក់ទងតិចតួចជាមួយតំបន់ជនបទ ។ ក្នុងផ្នែកផលិត គឺសឹងតែគ្មានសោះតំលៃបន្ថែមដោយផលិតកម្ម គឺវាក់ក្រៅតែពីការផ្ញើប្រាក់ទៅផ្ទះដោយពលករធម្មតា និងពលករចំណាកស្រុក ។ ប៉ុន្តែទឹកប្រាក់ទាំងនេះតូចៗ ហើយកាន់តែថយចុះ ជាពិសេសដោយសារឧស្សាហកម្មកាត់ដេរមិនបានរីកលូតលាស់លឿនដូចកាលពីមុន ។ ឧទាហរណ៍ បើធៀបនឹងថៃក្នុងទសវត្សរ៍១៩៧០-១៩៨០ និងចិនក្នុងទសវត្សរ៍១៩៩០, ចំណងទាក់ទងនឹងជនបទនៃការរីកលូតលាស់វាតូចទេនៅកម្ពុជា ។ ទី៣ វិនិយោគលើទុនមនុស្សមានកំរិតទាបនៅកម្ពុជា ពិសេសក្នុងតំបន់ជនបទ ។ ដូច្នេះសំរាប់ការងារមានជំនាញភាគច្រើន គេបានប្រើប្រាស់ពលកម្មបរទេស ហើយការផ្ទេរជំនាញមានកំរិតទាប ។ ការងារជាច្រើនមិនប្រើពលកម្មគ្មានជំនាញសុទ្ធសាធនោះទេ ដូច្នេះ ចំណែកជាច្រើននៃទីផ្សារពលកម្មបានបិទទ្វារចំពោះយុវជនជនបទ ។

ដូចបានលើករួចហើយ កសិករនៅតែទាញយកចំណូលពីប្រភពជាច្រើន ។ ដោយសារប្រភពចំណូលខ្លះបានថយចុះ ឧ. ព្រៃឈើ, ត្រី) ប្រាក់ចំណូលរបស់អ្នកភូមិមួយចំនួនអាចធ្លាក់ចុះ។ ម្យ៉ាងទៀតបើសិនមានការអនុញ្ញាតឱ្យប្រើប្រាស់យ៉ាងពេញលេញនូវធនធានទ្រព្យរួម ធនធានទាំងនេះនឹងថយចុះយ៉ាងលឿននៅក្រោមប្រព័ន្ធធ្វើសមាហរណកម្មទីផ្សារថ្មី ដូចបានពិនិត្យឃើញមួយរយៈក្នុងទសវត្សរ៍១៩៩០ ។ គេមិនច្បាស់ទេថា តើការគ្រប់គ្រងធនធាន "ផ្អែកលើសហគមន៍" បែបថ្មីដែលស្នើឡើងដោយរដ្ឋាភិបាល និងពួកអ្នកផ្តល់ជំនួយនឹងអាចដោះស្រាយបញ្ហានេះបានឬទេ ។ ពិតហើយ គ្មានច្រកចេញណាងាយនោះទេ លើកលែងតែមានការកែតំរូវច្រើនគួរសមចំពោះប្រព័ន្ធមួយ ដែលដើមឡើយសំដៅជួយទ្រទ្រង់ដល់ប្រជាជនចំនួនតិចជាងនេះឆ្ងាយណាស់ និងដោះស្រាយតំរូវការតូចជាងនេះ ។ ការកែតំរូវទាំងនេះគួរស្ថិតក្នុងទិសដៅពង្រឹងកសិកម្ម និងបណ្តាធនធានអាចកើតឡើងវិញផ្សេងៗ ជាបន្ថែមទៅលើការបង្កើតជំរើសច្រើនទៀតនៃការរកចិញ្ចឹមជីវិត ។

ចំពោះស្ថានភាពសន្តិសុខស្បៀងជាទូទៅវិញ តើវាយ៉ាងដូចម្តេច? ពិតហើយ ផលិតកម្មស្បៀងបានកើនឡើងជាបណ្តើរៗ តែជាទៀងទាត់ ហើយនឹងបន្តកើនឡើងតទៅទៀតក្នុងអនាគតដ៏ខ្លីខាងមុខ ជាពិសេសដោយសារមានកសិករច្រើនៗបានទទួលស្គាល់ និងប្រើប្រាស់ពូជដំណាំមានទិន្នផលខ្ពស់ ជី ព្រមទាំងអាចគ្រប់គ្រងទឹកបានមួយកំរិតសំរាប់ការស្រោចស្រព ។ ម្យ៉ាងទៀតមានការធ្វើចំរុះកម្មមុខដំណាំមួយចំនួនហើយ ។ ផលិតផលស្បៀងក៏មាននាំចេញមួយចំនួន ដោយគេរំពឹងថា វានឹងរីកលូតលាស់ទៅមុខទៀត ។ ប៉ុន្តែសមិទ្ធិផលទាំងនេះអាចជួយកែលំអសន្តិសុខស្បៀងរបស់កសិករ និងអ្នកភូមិដែលមានឱនភាពស្បៀងបានតែមួយកំរិតតូចប៉ុណ្ណោះ ។ ការបែងចែកផលចំណេញនឹងត្រូវរំពឹងផ្អែកមួយចំនួនធំទៅលើកំណើនឱកាសល្អខាងប្រាក់កំរៃ និងពលកម្ម ទាំងនៅក្នុងកសិកម្ម និងសកម្មភាពផ្សេងៗទៀត ។

## ១០.៣ ជំរើសគោលនយោបាយ

ឯកសារនេះពិភាក្សាពីលទ្ធផលនៃការសិក្សាពីបញ្ហាចោទនានា ដោយគ្មានគោលបំណងទាញសេចក្តីសន្និដ្ឋានយ៉ាងដាច់ណាត់ផ្សេងៗឡើយ ។ ប៉ុន្តែគួរបញ្ជាក់ឡើងដែរនូវការសង្កេត និងការអះអាងមួយចំនួនដូចតទៅ :

### ១០.៣.១ ការធ្វើសនិទានកម្ម

ជំហានទី១ គឺត្រូវធ្វើសនិទានកម្មការកាន់កាប់ដីកសិកម្ម ដែលជាប្រភពចំបងនៃការរកចិញ្ចឹមជីវិតនៅជនបទកម្ពុជា ។ រឿងនេះអាចធ្វើទៅបាននៅក្នុងកម្មវិធីអភិវឌ្ឍន៍កសិកម្មនានាដែលរដ្ឋាភិបាលកំពុងអនុវត្តសព្វថ្ងៃ ។ ការដាក់តួលេខទាបមួយចំពោះទំហំអតិបរមានៃដីកាន់កាប់ និងការបញ្ឈប់ការពុះបំបែកប្លង់ដីតូចៗហួសហេតុ អាចជាចំណែកដ៏ចាំបាច់នៃកម្មវិធីនេះ ។ តាមពិត គេអាចធ្វើការត្រិះរិះពិចារណាលើបទពិសោធន៍នៃប្រទេសមួយចំនួននៅអាស៊ី ក្នុងការអនុវត្តកំណែទំរង់ដីធ្លី ដូចជាទំហំសមរម្យនៃដីកាន់កាប់ជាដើម ហើយដាក់បញ្ចូលវាទៅក្នុងកម្មវិធីកំណែទំរង់ដីធ្លី ។

បន្ទាប់មក ត្រូវដោះស្រាយពីភាពគ្មានដីធ្លី ។ កម្ពុជាមានដីនៅសល់មួយចំនួន ដូចមានប៉ាន់ស្មាននៅក្នុងឯកសារ Chan, Tep and Acharya (2002) ។ គេឃើញថា ដីទាំងនេះអាចបែងចែកបានមួយចំនួនដើម្បីកាត់បន្ថយ ឬក៏បំបាត់ចេញនូវភាពគ្មានដីធ្លី ដោយឈរលើមូលដ្ឋានមួយនាក់ទទួលបានមួយលើក ។ ប៉ុន្តែភាពគ្មានដីធ្លីមិនអាចដោះស្រាយបានតែតាមការបែងចែកដីមួយមុខនោះទេ ។ ពីព្រោះគ្រួសារគ្មានដីក៏ជាចំណែកមួយនៃសហគមន៍ធំដូចគេឯងដែរ ហើយការបញ្ជូនប្រជាជនទៅតាំងលំនៅនៅកន្លែងមានដីសល់មិនអាចធ្វើទៅកើតទេ ។

### ១០.៣.២ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ

ចំណុចព្រួយបារម្ភមួយទៀតគឺ កង្វះហេដ្ឋារចនាសម្ព័ន្ធនៅតាមកន្លែងមានដីនៅសល់ ។ គ្រប់កន្លែងមិនមែនសុទ្ធតែរស់នៅបានទាំងអស់ទេ គឺត្រូវមានហេដ្ឋារចនាសម្ព័ន្ធក្នុងកំរិតអប្បបរមាណាមួយ ។ ក្នុងបរិបទនេះ មុខរបរមិនពឹងផ្អែកលើដីត្រូវតែបំផុសជំរុញឡើងនៅតាមកន្លែងនានាដែលអ្នកគ្មានដីកំពុងរស់នៅសព្វថ្ងៃ ។ ឧស្សាហកម្មជនបទផ្សេងៗ សកម្មភាពកែច្នៃផលិតផលកសិកម្ម និងរបរក្រៅកសិដ្ឋានផ្សេងទៀត ដូចជា នេសាទ និងការកែច្នៃ ត្រី គឺជាជំរើសដែលគួរយកចិត្តទុកដាក់ ។ គួរបញ្ជាក់ផងដែរថា ក្រៅពីលទ្ធភាពប្រើប្រាស់ធនធានចំពោះកសិករធម្មតា និងការគ្រប់គ្រងបែបវិទ្យាសាស្ត្រនូវស្តុកធនធាន, ការបង្កើនផលិតភាព និងការបង្កើតតំលៃបន្ថែម ក៏មានសារៈសំខាន់ប៉ុនគ្នាដែរ ។

### ១០.៣.៣ ទំនើបកម្មកសិកម្ម

ការកែលំអផលិតភាពដី និងអត្រាចំណេញនៃប្រតិបត្តិការកសិកម្ម គឺមានសារៈសំខាន់បំផុត ។ ដូច្នេះគួរប្រឹងប្រែងធ្វើទំនើបកម្មកសិកម្ម និងប្រើប្រាស់ដីធ្លីឱ្យបានកាន់តែសកម្មថែមទៀត ។ ដើម្បីសំរេចរឿងនេះ ការប្រើពូជដំណាំមានទិន្នផលខ្ពស់ ជីថ្នាំសំលាប់សត្វចង្រៃ និងវត្តមានប្រព័ន្ធស្រោចស្រព គឺជាលក្ខខណ្ឌខ្លះៗដែលត្រូវមានជាមុន ។ ដំណើរការធ្វើទំនើបកម្មកសិកម្មទាំងមូលត្រូវស្ថិតលើមាគ៌ាមួយដែលឃ្លាតចេញពីរបបជីវព្រឹត្តិ និងតំរង់ទិសទៅទីផ្សារតាមរយៈការផ្គត់ផ្គង់ដ៏រឹងប៉ឹង ។

### ១០.៣.៤ ការកសាងសង្គមផ្តល់ឥណទាន

តំរូវការឥណទានរបស់អ្នកភូមិវាផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងជីវភាពរបស់កសិករ ។ ប៉ុន្តែស្ថាប័នមីក្រូឥណទាននានានៅកម្ពុជា ជាទូទៅធ្វើប្រតិបត្តិការធនាគារដូចក្នុងសៀវភៅសិក្សាធម្មតាដូច្នោះឯង ។ អ្វីដែលនៅខ្វះ គឺប្រហែលជាដំណាក់កាលកណ្តាលនៃការកសាងបណ្តាសង្គមឥណទានផ្អែកលើសហគមន៍ ដែលទទួលប្រាក់បញ្ញើពីសមាជិក និងពីធនាគារ និងឱ្យប្រាក់ខ្ចីដល់សមាជិកសង្គមទៅតាមសំណើរបស់គេ ។ សង្គមទាំងនេះឱ្យខ្ចីប្រាក់ជាបន្ត ដល់អតិថិជនដោយគិតកំរៃ និងប្រមូលប្រាក់ជំពាក់មកវិញ ។ ដោយសារវដ្តឥណទានមានរយៈពេលខ្លី ដូច្នេះ ទោះទឹកប្រាក់តូចៗក៏អាចផ្តល់ផលយ៉ាងច្រើនណាស់ដែរ ។ នេះជាគំរូមួយមានជោគជ័យក្នុងប្រទេសជាច្រើន ។ នៅកម្ពុជាក្រុមប្រឹក្សាឃុំអាចជួយដល់ការបង្កើត និងការពង្រឹងសកម្មភាពនៃសង្គមឥណទានទាំងនេះបាន ។

### ១០.៣.៥ ការគ្រប់គ្រងធនធានធម្មជាតិ

ធនធានទ្រព្យរួម គឺជាប្រភពជួយទ្រទ្រង់ជីវភាពមួយដ៏សំខាន់ ។ ការគ្រប់គ្រងធនធានទ្រព្យរួម គឺជាអាទិភាពមួយ ស្រាប់ហើយរបស់រដ្ឋាភិបាល ។ ការសិក្សានេះបានគូសរំលេចពីទំហំ និងការពឹងផ្អែកលើធនធានទ្រព្យរួម ហើយនឹងចំនួន ផលិតផលដ៏ច្រើនមុខដែលធនធានទ្រព្យរួមបានផ្តល់ឱ្យ ។ ទិដ្ឋភាពទាំងនេះអាចយកទៅដាក់បញ្ចូលក្នុងគោលនយោបាយបាន ។

### ១០.៣.៦ ការកាត់បន្ថយភាពក្រីក្រ

ភាពក្រីក្រជារឿងមួយគួរព្រួយបារម្ភ ។ គេអាចប្រមើលឃើញយ៉ាងងាយថា ប្រជាជនជាច្រើនក្នុងតំបន់ជនបទ នឹងនៅ តែក្រីក្រនៅពេលបានធ្វើកំណែទំរង់ដីធ្លី និងទំនើបកម្មកសិកម្មដ៏សមស្របរួចហើយ ។ បទពិសោធន៍ក្នុងសាកលលោកបង្ហាញថា ជាបន្ថែមលើវិធីសាស្ត្រដោះស្រាយតាមវិស័យដើម្បីកាត់បន្ថយភាពក្រីក្រ, វិធីសាស្ត្រដោះស្រាយលើក្រុមមុខសញ្ញាជាក់លាក់ក៏ សំខាន់ដូចគ្នាដែរ ។ បច្ចុប្បន្នរដ្ឋាភិបាលកំពុងស្ថិតក្នុងដំណើរការកសាងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលជាកម្មវិធីមួយមាន អាទិភាពខ្ពស់ ។ ឆ្លងតាមការសិក្សានេះ គេអាចជូនមតិពីដំណើរការមួយចំនួនដែលមានចំណងទាក់ទងផ្ទាល់នឹងភាពក្រីក្រនៅ តំបន់ជនបទ ។ លទ្ធផលនៃការសិក្សានេះ អាចតាមដានស្រាវជ្រាវជាបន្ថែមទៀត ជាពិសេសទាក់ទិននឹង:

ក) ភាពគ្មាន ឬ ជិតគ្មានដីធ្លី

ខ) ការពឹងផ្អែករបស់កសិករទៅលើចំណូលមិនមែនកសិកម្ម

គ) ការថយចុះក្នុងចំណូលមិនមែនកសិកម្ម

ឃ) ដំណើរការនៃទីផ្សារ ដីធ្លី ពលកម្ម និង ទុន

### ១០.៣.៧ ការគ្រប់គ្រងគ្រោះមហន្តរាយ

ដោយសារមានគ្រោះធម្មជាតិជាញឹកញាប់ ត្រូវមានគោលនយោបាយរយៈពេលវែងនៃការគ្រប់គ្រងទឹកជំនន់ ការគ្រប់ គ្រងទឹក ការស្រោចស្រព និងផលិតកម្មថាមពល ប៉ុន្តែត្រូវថ្លឹងថ្លែងរឿងនេះជាមួយនឹងលទ្ធភាពមានផលប៉ះពាល់ទៅលើធនធាន ជលផលដ៏សំបូររបស់កម្ពុជា ។ លើសពីនេះទៀត ដោយសារគ្មានការធានារ៉ាប់រងខាងសង្គមកិច្ចអ្វីសោះ ក្រៅពីជំនួយចំពោះកិច្ច (adhoc aid) របស់ NGOs និងរដ្ឋាភិបាល, ដូច្នេះចាំបាច់ត្រូវមានដាក់ប្រើប្រព័ន្ធខ្លះ ដែលអាចរ៉ាប់រងវិបត្តិបង្កដោយគ្រោះ ធម្មជាតិ ។ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនគេមានការធានារ៉ាប់រងលើផលដំណាំ ការដាក់អនុវត្តប្រព័ន្ធទ្រទ្រង់អប្បបរមា ហើយក្នុងប្រទេសខ្លះទៀត ប្រព័ន្ធធានាការងារធ្វើ គឺជាចំណែកមួយនៃការធានារ៉ាប់រងសង្គមកិច្ច ។ ប្រទេសកម្ពុជា ត្រូវតែបង្កើត ប្រព័ន្ធរបស់ខ្លួនផ្ទាល់នៃការធានារ៉ាប់រងសង្គមកិច្ច និងជំនួយសង្គមកិច្ច ។

# ឧបសម្ព័ន្ធទី ១

# ទិន្នន័យគំរូតាង

តារាង១. ទំហំគំរូតាង និងប្រជាជន

| ភូមិ | ប្រជាជនតាមភូមិ | ចំនួនគ្រួសារ | គ្រួសារគំរូតាំង | សមាមាត្រប្រជាជនសុទ្ធ |
|---|---|---|---|---|
| ទំនាបទន្លេសាប | | | | |
| អណ្តូងត្រាច | 1,119 | 196 | 85 | 43.4 |
| ក្រសាំង | 1,263 | 228 | 120 | 52.6 |
| ខ្សាច់ជីរស់ | 1,842 | 305 | 120 | 39.4 |
| ទំនាបទន្លេមេគង្គ | | | | |
| ព្រៃកក្អែង | 1,592 | 339 | 120 | 35.4 |
| បាបោង | 2,571 | 536 | 127 | 23.7 |
| តំបន់ខ្ពង់រាប | | | | |
| កញ្ជរ | 1,153 | 278 | 120 | 43.1 |
| ដងក្តារ | 1,422 | 306 | 125 | 40.8 |
| ត្រពាំងប្រិយ | 347 | 68 | 68 | 100.0 |
| តំបន់ឆ្នេរ | | | | |
| កំពង់ត្នោត | 2,048 | 348 | 120 | 34.5 |
| សរុប | **13,357** | **2,602** | **1,005** | **38.6** |

តារាង២. ប្រភពទឹកផឹកសំខាន់ៗ គិតជាភាគរយនៃគ្រួសារ

| ភូមិ | អណ្តូងស្នប់ | អណ្តូងជីក | ស្រះ | ព្រែក | ទន្លេ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|
| ទំនាបទន្លេសាប | | | | | | | |
| អណ្តូងត្រាច | 59 | 2 | 38 | 0 | 0 | 1 | 100 |
| ក្រសាំង | 5 | 0 | 92 | 0 | 0 | 3 | 100 |
| ខ្សាច់ជីរស់ | 4 | 0 | 9 | 87 | 0 | 0 | 100 |
| ទំនាបទន្លេមេគង្គ | | | | | | | |
| ព្រៃកក្អែង | 14 | 18 | 0 | 66 | 1 | 1 | 100 |
| បាបោង | 98 | 2 | 0 | 0 | 0 | 0 | 100 |
| តំបន់ខ្ពង់រាប | | | | | | | |
| កញ្ជរ | 0 | 1 | 0 | 0 | 98 | 1 | 100 |
| ដងក្តារ | 2 | 98 | 0 | 0 | 0 | 0 | 100 |
| ត្រពាំងប្រិយ | 0 | 78 | 22 | 0 | 0 | 0 | 100 |
| តំបន់ឆ្នេរ | | | | | | | |
| កំពង់ត្នោត | 2 | 0 | 98 | 0 | 0 | 0 | 100 |

## តារាង៣. ភាគរយនៃប្រជាជនតាមក្រុមអាយុ

| ភូមិ | ក្រុមអាយុ | | | | | |
|---|---|---|---|---|---|---|
| | ក្រោម ១០ | 10 – 19 | 20 – 39 | 40 – 54 | 55+ | សរុប |
| **ទំនាបទន្លេសាប** | | | | | | |
| អណ្ដូងត្រាច | 28 | 28 | 27 | 11 | 7 | 100 |
| ក្រសាំង | 27 | 30 | 23 | 13 | 7 | 100 |
| ខ្សាច់ជីរស់ | 31 | 28 | 23 | 12 | 5 | 100 |
| **ទំនាបទន្លេមេគង្គ** | | | | | | |
| ព្រៃកក្អេង | 30 | 28 | 23 | 11 | 8 | 100 |
| បាបោង | 23 | 26 | 26 | 14 | 10 | 100 |
| **តំបន់ខ្ពង់រាប** | | | | | | |
| កញ្ជរ | 28 | 25 | 26 | 11 | 10 | 100 |
| ដងក្ដារ | 28 | 23 | 29 | 11 | 8 | 100 |
| ត្រពាំងប្រិយ | 28 | 27 | 28 | 10 | 7 | 100 |
| **តំបន់ឆ្នេរ** | | | | | | |
| កំពង់ត្នោត | 26 | 30 | 24 | 11 | 9 | 100 |

## តារាង៤. ភាគរយប្រជាជនតាមភេទ អាយុពី ៧ឆ្នាំឡើងទៅ

| ភូមិ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| **ទំនាបទន្លេសាប** | | | |
| អណ្ដូងត្រាច | 46.4 | 53.6 | 100.0 |
| ក្រសាំង | 49.0 | 51.0 | 100.0 |
| ខ្សាច់ជីរស់ | 50.8 | 49.2 | 100.0 |
| **ទំនាបទន្លេមេគង្គ** | | | |
